Unofficial translation





# សៀវភៅមគ្គុទេសក៍ អាស៊ាន ស្តីពីការអនុវត្តន៍គោលការណ៍ មិនដាក់ទណ្ឌកម្ម ក្នុងកិច្ចការពារ ជនរងគ្រោះដោយការ ជួញដូរមនុស្ស

ឆ្នាំ ២០២៤

Unofficial translation

បោះពុម្ពផ្សាយដោយលេខាធិការដ្ឋានអាស៊ាន គាំទ្រដោយកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលអូស្ត្រាលី

© ២០២៥, លេខាធិការដ្ឋានអាស៊ាន និងកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស

**លេខាធិការដ្ឋានអាស៊ាន**

ផ្នែកទំនាក់ទំនងសហគមន៍ (CRD)

70A Jalan Sisingamangaraja Jakarta 12110, ប្រទេសឥណ្ឌូនេស៊ី លេខទូរស័ព្ទ: (62 21) 724-3372, 726-2991

ទូរសារ៖ (62 21) 739-8234, 724-3504

អ៊ីមែល៖ public@asean.org

ចំណងជើង៖ **សៀវភៅមគ្គុទេសក៍អាស៊ាន ស្តីពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មក្នុងកិច្ចការពារជនរងគ្រោះដោយការជួញដូរមនុស្ស**, អាស៊ាន, ឆ្នាំ២០២៥

រក្សាសិទ្ធិគ្រប់យ៉ាង: ខ្លឹមសារនៃឯកសារបោះពុម្ពផ្សាយនេះអាចដកស្រង់ និងអាចបោះពុម្ពឡើងវិញបានដោយសេរី សម្រាប់គោលបំណងការសិក្សា និងមិនមែនពាណិជ្ជកម្មផ្សេងទៀត ដរាបណាការផលិតឡើងវិញណាមួយត្រូវបានអនុញ្ញាត និងទទួលស្គាល់ពីលេខាធិការដ្ឋានអាស៊ាន។

**សេចក្តីបដិសេធ៖** គោលការណ៍ណែនាំនេះត្រូវបានបង្កើតឡើងដោយកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) និងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) និងផ្តល់មូលនិធិដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស។ ទស្សនៈដែលបានបង្ហាញនៅក្នុងសៀវភៅមគ្គុទេសក៍នេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលីឡើយ។

# សៀវភៅមគ្គុទេសក៍ អាស៊ាន ស្តីពីការអនុវត្តន៍ គោលការណ៍មិនដាក់ទណ្ឌកម្ម ក្នុងកិច្ចការពារ ជនរងគ្រោះដោយការជួញដូរមនុស្ស

# មាតិកា


**ទិដ្ឋភាពរួមនៃគោលការណ៍ណែនាំ** ........ ៧

**អក្សរកាត់** ........ ១២

**វាក្យសព្ទ** ........ ១៣

**អារម្ភកថា របស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស**
( AICHR ) ........ **១៦**

**អារម្ភកថា របស់កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន** ( SOMTC )
**ប្រធានស្ម័គ្រចិត្តអាស៊ានលើវិស័យអាទិភាពប្រឆាំងការជួញដូរមនុស្ស** ........ **១៨**

**អារម្ភកថា របស់ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំអាស៊ាន និងឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រឆាំងទាសភាពសម័យទំនើប ការរត់ពន្ធមនុស្ស និងការជួញដូរមនុស្ស** ........ **២០**

**សេចក្តីថ្លែងអំណរគុណ** ........ **២១**

**សេចក្តីផ្តើម** ........ **២២**

**ផ្នែកទី ១. ការយល់ដឹងអំពីគោលការណ៍មិនដាក់ទណ្ឌកម្ម** ........ **២៣៣**

*តើអ្វីជាគោលការណ៍មិនដាក់ទណ្ឌកម្ម ?* ........ *២៤*

*ហេតុអ្វីបានជាគោលការណ៍មិនដាក់ទណ្ឌកម្ម មានសារៈសំខាន់ ?* ........ *២៨*

*តើគោលការណ៍មិនដាក់ទណ្ឌកម្ម មានប្រភពមកពីណា ?* ........ *៣២*

*តើគួរអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មនៅពេលណា ?* ........ *៣៦*

*តើនរណាទទួលខុសត្រូវលើការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ?* ........ *៤០*

**ផ្នែកទី ២. ការពង្រឹងច្បាប់ ដើម្បីគាំទ្រគោលការណ៍មិនដាក់ទណ្ឌកម្ម** ........ **៤៧**

*[១] ពង្រឹងច្បាប់ប្រឆាំងការជួញដូរមនុស្ស ដើម្បីការពារជនរងគ្រោះពីការដាក់ទោសទណ្ឌ* ........ *៤៨*

*[២] ពង្រឹងបទបញ្ញត្តិផ្សេងទៀត (ដែលមិនពាក់ព័ន្ធនឹងការជួញដូរមនុស្ស) ដើម្បីការពារជនរងគ្រោះពីការដាក់ទោសទណ្ឌ* ........ *៦១*

**ផ្នែកទី ៣. ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មក្នុងការពិនិត្យបឋម និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស** ........ **៦៤**

*[៣] ពង្រឹងសមត្ថភាពមន្ត្រីជួរមុខ ក្នុងការកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស ក្នុងចំណោមជនល្មើសដែលពួកគេជួបប្រទះ* ........ *៦៧*

*[៤] កសាងការយល់ដឹងរបស់មន្ត្រីជួរមុខស្តីពីសូចនាករនានាដើម្បីត្រួតពិនិត្យ និងកំណត់អត្តសញ្ញាណជនរងគ្រោះ* ........ *៧៤*

*[៥] បង្កើនភាពអង់អាចដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម* ........ *៧៧*

*[៦] ធានាថា មន្ត្រីនគរបាលយុត្តិធម៌បំពេញកាតព្វកិច្ចរបស់ពួកគេចំពោះជនដែលត្រូវបានចាប់ខ្លួន* ........ *៨៤*

[៧] ទទួលស្គាល់ស្ថានភាពជាជនរងគ្រោះរបស់បុគ្គល ដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងរដ្ឋសមាជិកអាស៊ានផ្សេងទៀត ........ ៨៥

**ផ្នែកទី ៤. ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម នៅពេលជនរងគ្រោះកំពុងប្រឈមនឹងការជំនុំជម្រះទោស ........ ៨៧**

[៨] ពង្រឹងសមត្ថភាពរបស់ព្រះរាជអាជ្ញា ក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ........ ៨៩

[៩] ពង្រឹងសមត្ថភាពរបស់មេធាវីការពារក្តី ក្នុងការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ........ ៩៤

[១០] ពង្រឹងសមត្ថភាពរបស់មន្ត្រីតុលាការ ដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ........ ១០០

[១១] អនុវត្តយុត្តិធម៌ស្តារឡើងវិញ ជាជាងយុត្តិធម៌សងសឹកសម្រាប់ ជនល្មើស-ជាជនរងគ្រោះ ........ ១០៣

**ផ្នែកទី ៥. ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មនៅពេលជនរងគ្រោះត្រូវបានផ្តន្ទាទោស ..... ១០៧**

[១២] បញ្ចៀស ឬសម្រាលទោសសម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្សដែលត្រូវបានផ្តន្ទាទោស ........ ១០៨

[១៣] ផ្តល់ឱ្យជនរងគ្រោះនូវដំណោះស្រាយសម្រាប់ការដាក់ទោសទណ្ឌខុស ........ ១១០

**ផ្នែកទី ៦. ការតាមដាន និងរាយការណ៍ស្តីពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ........ ១១៥**

[១៤] បញ្ចូលការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មទៅក្នុងយន្តការតាមដានថ្នាក់ជាតិ ........ ១១៧

[១៥] រាយការណ៍អំពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ........ ១១៩

ឧបសម្ព័ន្ធ ១ ៖ បទបញ្ញត្តិច្បាប់ក្នុងរដ្ឋសមាជិកអាស៊ានស្តីពីការមិនដាក់ទណ្ឌកម្ម ........ ១២១

ឧបសម្ព័ន្ធ ២ ៖ បទបញ្ញត្តិគោលនយោបាយក្នុងរដ្ឋសមាជិកអាស៊ានស្តីពីការមិនដាក់ទណ្ឌកម្ម ........ ១២៤

ឧបសម្ព័ន្ធ ៣ ៖ ឧទាហរណ៍នៃកិច្ចព្រមព្រៀងទ្វេភាគី និងកិច្ចព្រមព្រៀងអនុតំបន់ដែលពាក់ព័ន្ធនឹងការមិនដាក់ទោសទណ្ឌ ........ ១២៧

ឧបសម្ព័ន្ធ ៤ ៖ គោលការណ៍ណែនាំស្តីពីការអនុវត្តល្អបំផុតជាអន្តរជាតិ ........ ១៣១

ឧបសម្ព័ន្ធ ៥ ៖ ឧទាហរណ៍នៃបទល្មើសដែលស្ថិតក្រោមវិសាលភាពនៃគោលការណ៍មិនដាក់ទណ្ឌកម្ម ........ ១៤១

បទល្មើសស្ថានភាព (រដ្ឋបាល និងព្រហ្មទណ្ឌ) ........ ១៤១

បទល្មើសព្រហ្មទណ្ឌផ្សេងទៀត ........ ១៤១

# ទិដ្ឋភាពរួមនៃគោលការណ៍ណែនាំ

| គោលការណ៍ណែនាំ | របៀបសម្រេចបានការអនុវត្តន៍គោលការណ៍ណែនាំ |
|---|---|
| **ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម** | |
| **...នៅក្នុងច្បាប់** | |
| **គោលការណ៍ណែនាំទី ១**<br>**ពង្រឹងច្បាប់ប្រឆាំងការជួញដូរមនុស្ស ដើម្បីការពារជនរងគ្រោះពីការដាក់ទោសទណ្ឌ** | • ពិនិត្យលទ្ធភាពកែសម្រួលនិយមន័យនៃការជួញដូរមនុស្ស ដើម្បីរួមបញ្ចូលការកេងប្រវ័ញ្ចក្នុងសកម្មភាពបទល្មើស<br>• ព្រាង ឬវិសោធនកម្មបទបញ្ញត្តិដាក់លាក់ក្នុងការការពារផ្នែកផ្លូវច្បាប់<br>• បញ្ជាក់ច្បាស់ពីទំនាក់ទំនងចាំបាច់រវាងការជួញដូរ និងសកម្មភាព ល្មើសច្បាប់របស់ជនរងគ្រោះ<br>• បញ្ជាក់ច្បាស់ពីស្ថានទម្ងន់ និងស្តង់ដារនៃការបង្ហាញភស្តុតាងចាំបាច់។ |
| **គោលការណ៍ណែនាំទី ២**<br>**ពង្រឹងបទបញ្ញត្តិផ្សេងទៀត (ដែលមិនពាក់ព័ន្ធនឹងការជួញដូរមនុស្ស) ដើម្បីការពារជនរងគ្រោះពីការដាក់ទោសទណ្ឌ** | • ពិនិត្យលទ្ធភាពកែសម្រួលបទបញ្ញត្តិព្រហ្មទណ្ឌ និងបទបញ្ញត្តិរដ្ឋបាល ដើម្បីកាត់បន្ថយហានិភ័យនៃការកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្ស<br>• កំណត់អាយុអប្បបរមាសមស្របដែលត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ<br>• ពិនិត្យលទ្ធភាពកែសម្រួល ឬអនុម័តច្បាប់ដើម្បីអនុញ្ញាតឱ្យមានការធ្វើមោឃភាព ការលុបចោល ឬការបិទកំណត់ត្រាបទល្មើសរបស់ជនរងគ្រោះ |
| **...នៅក្នុងការពិនិត្យបឋម និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស** | |
| **គោលការណ៍ណែនាំទី ៣**<br>**ពង្រឹងសមត្ថភាពរបស់មន្ត្រីជួរមុខ ក្នុងការកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនរងគ្រោះ ក្នុងចំណោមជនល្មើសដែលពួកគេជួបប្រទះ** | • ពង្រឹងការយល់ដឹងអំពីធាតុផ្សំនៃបទល្មើសជួញដូរមនុស្ស<br>• ពង្រឹងការយល់ដឹងអំពីទិដ្ឋភាពប្រទាក់ក្រឡាគ្នានៃការជួញដូរមនុស្ស<br>• បំពាក់បំប៉នមន្ត្រីក្នុងការអនុវត្តន៍ន៍សច្ចធារណ៍ចំពោះភាពជាជនរងគ្រោះនិងភាពជាអនីតិជន<br>• ដេញដោលការយល់ខុស និងភាពលំអៀងដោយអចេតនាលើការជួញដូរមនុស្ស និងការបង្កភាពរងគ្រោះ<br>• លើកកម្ពស់ការមិនរើសអើង ក្នុងដំណើរការពិនិត្យ និងកំណត់អត្តសញ្ញាណ<br>• លើកកម្ពស់ការពិនិត្យ និងការកំណត់អត្តសញ្ញាណដែលយកចិត្តទុកដាក់ចំពោះកុមារ គិតគូរពីយេនឌ័រ ផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត និងមានជំនាញ<br>• ដេញដោលគោលនយោបាយរដ្ឋ ដែលបង្កើនហានិភ័យនៃការដាក់ទោសទណ្ឌជនរងគ្រោះដោយការជួញដូរមនុស្ស។ |

| | |
|---|---|
| **គោលការណ៍ណែនាំទី ៤**<br><br>**កសាងការយល់ដឹងរបស់មន្ត្រីជួរមុខ ស្តីពីសូចនាករនានាដើម្បីត្រួតពិនិត្យ និងកំណត់អត្តសញ្ញាណជនរងគ្រោះ** | • ប្រមូល ពិនិត្យ និងកែសម្រួលសូចនាករដែលមានស្រាប់ឱ្យស្របតាមបរិបទ<br>• ធានាថា សូចនាករមិនផាត់ចេញអ្នកដែលអាចជាជនរងគ្រោះ<br>• ធ្វើបច្ចុប្បន្នភាពសូចនាករជាទៀងទាត់<br>• ផ្សព្វផ្សាយសូចនាករដល់អ្នកពាក់ព័ន្ធដែលអាចជួបប្រទះជនរងគ្រោះ<br>• បង្កើនការយល់ដឹងរបស់អ្នកអនុវត្តស្តីពីរបៀបអនុវត្តសូចនាករក្នុងស្ថានភាពជាក់ស្តែង<br>• គាំទ្រឱ្យមានសូចនាករស៊ីសង្វាក់គ្នានៅទូទាំងតំបន់អាស៊ាន។ |
| **គោលការណ៍ណែនាំទី ៥**<br><br>**បង្កើនភាពអង់អាចដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម** | • ធានាថា មន្ត្រីជួរមុខយល់ និងដឹងពីរបៀបអនុវត្តធន្ទានុសិទ្ធិរបស់ពួកគេ<br>• ជំរុញឱ្យមានកាតព្វកិច្ចផ្តួចផ្តើមស៊ើបអង្កេតលើករណីជួញដូរមនុស្ស<br>• កសាងបណ្តាញអ្នកអនុវត្ត ដើម្បីគាំទ្រការពិនិត្យ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ<br>• លុបបំបាត់កត្តារាំងស្ទះ និងបង្កើតកត្តាលើកទឹកចិត្ត ដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម<br>• ធានាថា មន្ត្រីដឹងពីរបៀបបញ្ជូនជនរងគ្រោះទៅកាន់បណ្តាញការពារ។ |
| **គោលការណ៍ណែនាំទី ៦**<br><br>**ធានាថា មន្ត្រីនគរបាលយុត្តិធម៌បំពេញកាតព្វកិច្ចរបស់ពួកគេចំពោះជនដែលត្រូវបានចាប់ខ្លួន** | • បង្កើនការយល់ដឹងរបស់មន្ត្រីជួរមុខ អំពីផលប៉ះពាល់នៃការចាប់ខ្លួនជនរងគ្រោះដោយការជួញដូរមនុស្ស<br>• ធានាថា មន្ត្រីដែលបំពេញភារកិច្ចចាប់ខ្លួន គោរពសិទ្ធិទទួលបានព័ត៌មានរបស់ជនដែលត្រូវបានចាប់ខ្លួន។ |
| **គោលការណ៍ណែនាំទី ៧**<br><br>**ទទួលស្គាល់ស្ថានភាពជាជនរងគ្រោះ របស់បុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងរដ្ឋសមាជិកអាស៊ានផ្សេងទៀត** | • ពិនិត្យលទ្ធភាពកែសម្រួលកិច្ចព្រមព្រៀងទ្វេភាគី ដែលមានស្រាប់ ដើម្បីពង្រឹងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម<br>• អនុវត្តកិច្ចព្រមព្រៀងដែលមានស្រាប់ ដែលពាក់ព័ន្ធនឹងគោលការណ៍មិនដាក់ទណ្ឌកម្ម។ |

**...នៅពេលដែលជនរងគ្រោះដោយការជួញដូរមនុស្ស កំពុងប្រឈមនឹងការជំនុំជម្រះ**

| | |
|---|---|
| គោលការណ៍ណែនាំទី ៨<br><br>**ពង្រឹងសមត្ថភាពរបស់ព្រះរាជអាជ្ញា ក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម** | • បញ្ជាក់ច្បាស់ពីទំនាក់ទំនង រវាងស្ថានភាពជាជនរងគ្រោះ និងការមិនផ្តន្ទាទោស<br>• ធានាថា ព្រះរាជអាជ្ញាយល់ពីធន្ទានុសិទ្ធិរបស់ខ្លួន និងដឹងពីរបៀបអនុវត្ត<br>• តម្រូវឱ្យព្រះរាជអាជ្ញា ពិនិត្យមើលធាតុផ្សំអត្តនោម័ត (mens rea) នៃបទល្មើសដែលបានចោទប្រកាន់លើជនរងគ្រោះ<br>• គាំទ្រព្រះរាជអាជ្ញា ក្នុងការពិចារណាលើសេចក្តីសម្រេចរបស់ខ្លួនថា តើត្រូវកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្ស ឬទេ<br>• ធានាផ្តល់ព័ត៌មានដល់ជនរងគ្រោះ ស្តីពីសេចក្តីសម្រេចកាត់ទោសពួកគេ។ |
| គោលការណ៍ណែនាំទី ៩<br><br>**ពង្រឹងសមត្ថភាពរបស់មេធាវីការពារក្តី ក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម** | • ធានាការផ្តល់ជំនួយផ្នែកច្បាប់ ដល់ជនរងគ្រោះដោយការជួញដូរមនុស្សដែលប្រឈមនឹងការដាក់ទោសទណ្ឌ<br>• ធានាថា មេធាវីការពារក្តីដឹងពីរបៀបអនុវត្តការការពារដែលបានកំណត់ក្នុងច្បាប់ជាតិ សម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស<br>• ជំរុញការបកស្រាយ និងការអនុវត្តន៍ការការពារ ក្នុងបរិបទនៃការជួញដូរមនុស្សឱ្យបានទូលំទូលាយ<br>• ធានាថា មេធាវីការចុងចោទយល់ពីភាពមិនពាក់ព័ន្ធនៃការយល់ព្រម នៅពេលការពារក្តីករណីជួញដូរមនុស្ស។ |
| គោលការណ៍ណែនាំទី ១០<br><br>**ពង្រឹងសមត្ថភាពរបស់មន្ត្រីតុលាការ ក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម** | • បង្កើនការយល់ដឹងរបស់ចៅក្រម អំពីធាតុផ្សំនៃបទល្មើសជួញដូរមនុស្ស និងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម<br>• ធានាថា ចៅក្រមយល់ពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេចំពោះជនរងគ្រោះដែលត្រូវបានឃុំខ្លួន<br>• បង្កើនការយល់ដឹងរបស់ចៅក្រមស្តីពីរបៀបដែលសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គាំទ្រការអនុវត្តន៍គោលការណ៍មិនដាក់ទោសទណ្ឌ។ |
| គោលការណ៍ណែនាំទី ១១<br><br>**អនុវត្តយុត្តិធម៌ស្តារឡើងវិញ ជាជាងយុត្តិធម៌សងសឹក សម្រាប់ជនប្រព្រឹត្តបទល្មើស-ជាជនរងគ្រោះ** | • ស្វែងរកឱកាស ដើម្បីអនុវត្តគំរូយុត្តិធម៌ស្តារឡើងវិញចំពោះជនរងគ្រោះដោយការជួញដូរមនុស្សដែលកំពុងស្ថិតក្រោមការជំនុំជម្រះទោស<br>• ធានា វិធីសាស្ត្រយុត្តិធម៌ស្តារឡើងវិញសម្រាប់កុមារដែលប្រព្រឹត្តបទល្មើស។ |
| គោលការណ៍ណែនាំទី ១២<br><br>**បញ្ឈៀស ឬសម្រាលទោសសម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស ដែលត្រូវបានផ្តន្ទាទោស** | • ពិចារណាថា តើវិធានដែលទាក់ទងនឹងការសម្រាលទោស អាចផ្តល់ការសង្គ្រោះពីការដាក់ទណ្ឌកម្មដោយរបៀបណា<br>• ធានាថា ការដាក់ទោសឆ្លុះបញ្ចាំងពីការខុសត្រូវរបស់ជនប្រព្រឹត្តបទល្មើស-ជាជនរងគ្រោះ។ |

| | |
|---|---|
| គោលការណ៍ណែនាំទី ១៣<br><br>**ផ្តល់ឱ្យជនរងគ្រោះនូវដំណោះស្រាយសម្រាប់ការដាក់ទោសទណ្ឌមិនត្រឹមត្រូវ** | • រិះរកឱកាសដែលមានស្រាប់ សម្រាប់ជនរងគ្រោះក្នុងការស្វែងរកដំណោះស្រាយ សម្រាប់ការដាក់ទោសទណ្ឌមិនត្រឹមត្រូវ<br>• រិះរកឱកាស ដើម្បីធ្វើមោឃភាព លុបចោល ឬបិទការផ្តន្ទាទោសជនរងគ្រោះ ដោយការជួញដូរមនុស្ស<br>• កំណត់រក និងដោះស្រាយឧបសគ្គរបស់ជនរងគ្រោះ ក្នុងការជំរុញឱ្យមានការលុបចោលការផ្តន្ទាទោស។ |
| គោលការណ៍ណែនាំទី ១៤<br><br>**បញ្ចូលការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មទៅក្នុងយន្តការតាមដានថ្នាក់ជាតិ** | • រៀបចំសូចនាករ ដើម្បីវាស់ស្ទង់ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម<br>• ប្រមូល ការពារ បូកសរុប និងវិភាគទិន្នន័យស្តីពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម<br>• អនុវត្តវិធីសាស្រ្តភាគីពាក់ព័ន្ធចម្រុះ ក្នុងការតាមដានការអនុវត្តន៍។ |
| គោលការណ៍ណែនាំទី ១៥<br><br>**រាយការណ៍ អំពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម** | • រាយការណ៍ អំពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មទៅ SOMTC<br>• រៀបចំ និងអនុវត្តវិធីសាស្រ្តស្តង់ដារក្នុងការរាយការណ៍អំពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម<br>• របាយការណ៍សាធារណៈ ស្តីពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម។ |

# អក្សរកាត់

| | | |
|---|---|---|
| ACTIP | ASEAN Convention Against Trafficking in Persons, Especially Women and Children | អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ |
| AICHR | ASEAN Intergovernmental Commission on Human Rights, | គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្ដីពី សិទ្ធិមនុស្ស |
| AMMTC | ASEAN Ministerial Meeting on Transnational Crime | កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានស្ដីពីឧក្រិដ្ឋកម្ម ឆ្លងដែន |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ASEAN-ACT | ASEAN-Australia Counter-Trafficking | កម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរ មនុស្ស |
| CSO | Civil Society Organisation | អង្គការសង្គមស៊ីវិល |
| EU | European Union | សហភាពអឺរ៉ុប |
| IO | International Organisation | អង្គការអន្តរជាតិ |
| NGO | Non-Governmental Organisation | អង្គការមិនមែនរដ្ឋាភិបាល |
| OHCHR | Office of the United Nations High Commissioner for Human Rights | ការិយាល័យឧត្ដមស្នងការអង្គការសហប្រជា ជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| SOMTC | ASEAN Senior Officials Meeting on Transnational Crime | កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្ដីពីឧក្រិដ្ឋកម្ម ឆ្លងដែន |
| TIP | Trafficking in Persons | ការជួញដូរមនុស្ស |
| UN | United Nations | អង្គការសហប្រជាជាតិ |
| UNTOC | United Nations Convention againt Transnational Organized Crime | អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីការ ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការ ចាត់តាំង |

# វាក្យសព្ទ

| | |
|---|---|
| កុមារ | សម្រាប់គោលបំណងនៃគោលការណ៍ណែនាំនេះ **កុមារ** មានន័យថា បុគ្គលណាម្នាក់ដែលមានអាយុតិចជាងដប់ប្រាំបីឆ្នាំ។[1] |
| អ្នកអនុវត្តការងារប្រឆាំងការជួញដូរមនុស្ស | សម្រាប់គោលបំណងនៃគោលការណ៍ណែនាំនេះ **អ្នកអនុវត្តការងារប្រឆាំងការជួញដូរមនុស្ស** គឺជាតួអង្គរដ្ឋដែលមានកាតព្វកិច្ចដោះស្រាយការជួញដូរមនុស្ស។ តួអង្គរដ្ឋដែលអនុវត្តការប្រឆាំងការជួញដូរមនុស្ស ក៏អាចរួមបញ្ចូលតួអង្គមិនមែនរដ្ឋដែលអាចពាក់ព័ន្ធក្នុងការគាំទ្រដល់រដ្ឋ ដើម្បីឆ្លើយតបនឹងការជួញដូរមនុស្សផងដែរ ដោយអនុលោមតាមច្បាប់អន្តរជាតិ និងច្បាប់ក្នុងតំបន់។ |
| គោលការណ៍មិនដាក់ទណ្ឌកម្ម | សម្រាប់គោលបំណងនៃគោលការណ៍ណែនាំនេះ គោលការណ៍មិនដាក់ទណ្ឌកម្ម សំដៅលើគោលការណ៍ទទួលស្គាល់ដោយអាស៊ានដែលរដ្ឋសមាជិកអាស៊ាននីមួយៗត្រូវគោរពតាមច្បាប់ បទបញ្ញា និងគោលនយោបាយក្នុងស្រុករបស់ខ្លួន ហើយក្នុងករណីសមស្រប ពិចារណាមិនឃុំខ្លួនជនរងគ្រោះនៃការជួញដូរមនុស្សក្នុងបទឧក្រិដ្ឋ ឬផ្នែករដ្ឋបាលចំពោះសកម្មភាពខុសច្បាប់ដែលបានប្រព្រឹត្តដោយពួកគេ ប្រសិនបើសកម្មភាពទាំងនោះពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអំពើជួញដូរមនុស្ស។[2] |
| អ្នកដែលត្រូវបានសន្មតជាមុនថា ជាជនរងគ្រោះដោយការជួញដូរមនុស្ស / អ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស | សម្រាប់គោលបំណងនៃគោលការណ៍ណែនាំនេះ **អ្នកដែលត្រូវបានសន្មតជាមុនថា ជាជនរងគ្រោះដោយការជួញដូរមនុស្ស/អ្នកដែលអាចជាជនរងគ្រោះ ដោយការជួញដូរមនុស្ស** គឺជាបុគ្គលដែលស្ថិតក្រោមការសង្ស័យរបស់មន្ត្រីជួរមុខ ដោយមានមូលដ្ឋានអាចជឿជាក់បានថា បានក្លាយជាកម្មវត្ថុនៃការជួញដូរមនុស្ស ដែលមិនទាន់ត្រូវបានកំណត់អត្តសញ្ញាណជាផ្លូវការថាជាបុគ្គលបែបនោះ។ |

[1] មាត្រា ៣(យ) *ពិធីសារស្តីពីការទប់ស្កាត់ បង្រ្កាប និងផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង (ពិធីសារស្តីពីការជួញដូរមនុស្ស)* និងមាត្រា ២(យ) នៃអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ACTIP)

[2] មាត្រា ១៤*(៧)* អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ *(ACTIP)*

| | |
|---|---|
| ការជួញដូរ សម្រាប់ការបង្ខំឱ្យប្រព្រឹត្តបទឧក្រិដ្ឋ (ឬសម្រាប់ការកេងប្រវ័ញ្ចក្នុងសកម្មភាពឧក្រិដ្ឋ / ខុសច្បាប់ /ល្មើសច្បាប់) | សម្រាប់គោលបំណងនៃគោលការណ៍ណែនាំនេះ ការជួញដូរមនុស្សបង្ខំឱ្យប្រព្រឹត្តបទល្មើស (ឬសម្រាប់ការកេងប្រវ័ញ្ចក្នុងសកម្មភាពឧក្រិដ្ឋកម្ម /ខុសច្បាប់ / ល្មើសច្បាប់) គឺជាពាក្យដែលអាចប្រើជំនួសគ្នាបាន ដែលគេអាចយល់បានថាជាការជួញដូរមនុស្ស ក្នុងគោលបំណងកេងប្រវ័ញ្ចជនរងគ្រោះតាមរយៈការបង្ខំ ឬបញ្ឆោតពួកគេឱ្យប្រព្រឹត្តអំពើល្មើសច្បាប់ ដើម្បីផលប្រយោជន៍សេដ្ឋកិច្ច ឬផលប្រយោជន៍ផ្សេងទៀតរបស់អ្នកជួញដូរ ឬអ្នកកេងប្រវ័ញ្ច។[3] |
| ការជួញដូរមនុស្ស | **ការជួញដូរមនុស្ស** ត្រូវបានកំណត់និយមន័យក្នុងពិធីសារអង្គការសហប្រជាជាតិស្តីពីការជួញដូរមនុស្ស ដែលបំពេញបន្ថែមលើ UNTOC និងអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ<br>ដូចខាងក្រោម៖<br>(ក) "ការជួញដូរមនុស្ស" សំដៅលើការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងសំចត ឬទទួលជននានាតាមមធ្យោបាយនៃការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង ឬទម្រង់ដទៃទៀតនៃការបង្ខិតបង្ខំ ការចាប់ជំរិត ការបន្លំ ការឆបោក ការប្រើអំណាចរំលោភបំពាន ឬការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ ឬការផ្តល់ ឬការទទួលកម្រៃ ឬផលប្រយោជន៍នានា ដើម្បីសម្រេចបានការយល់ព្រមនៃមនុស្សម្នាក់ដែលមានអំណាចត្រួតត្រាលើមនុស្សណាម្នាក់ទៀត ក្នុងបំណងកេងប្រវ័ញ្ច។ ការកេងប្រវ័ញ្ចត្រូវរាប់បញ្ចូល យ៉ាងហោចណាស់ ការកេងប្រវ័ញ្ចលើពេស្យាកម្មអ្នកដទៃ ឬទម្រង់ដទៃទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទ ការធ្វើពលកម្ម ឬសេវាដោយបង្ខំ ទាសភាព ឬការប្រព្រឹត្តប្រហាក់ប្រហែលនឹងទាសភាព សេវាគតិភាព ឬការដកហូតសរីរាង្គ។<br>(ខ) ការយល់ព្រមរបស់ជនរងគ្រោះដោយការជួញដូរមនុស្សចំពោះការកេងប្រវ័ញ្ចដែលជាការគ្រោងទុក ដូចមានចែងក្នុងវាក្យខណ្ឌ (ក) នៃមាត្រានេះ នឹងមិនចាត់ទុកថាបានការឡើយ ក្នុងករណីប្រើប្រាស់ មធ្យោបាយណាមួយ ដូចមានចែងក្នុងវាក្យខណ្ឌ (ក)។<br>(គ) ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងសំចត ឬការទទួលកុមារសម្រាប់គោលដៅនៃការកេងប្រវ័ញ្ច ត្រូវ |

[3] ប្រភព៖ ដកស្រង់ពី *Casinos, cyber fraud, and trafficking in persons for forced criminality in Southeast Asia: Policy Report* (UNODC, September 2023) p.1

| | |
|---|---|
| | បានចាត់ទុកថាជា "ការជួញដូរមនុស្ស" ទោះបីករណីនេះមិនពាក់ព័ន្ធនឹងមធ្យោបាយណាមួយ ដូចដែលមានចែងក្នុងវាក្យខណ្ឌ (ក) នៃមាត្រានេះក៏ដោយ។<br>(ឃ) "កុមារ" មានន័យថា បុគ្គលណាម្នាក់ដែលមានអាយុតិចជាងដប់ប្រាំបីឆ្នាំ។ |
| ជនរងគ្រោះដោយការជួញដូរមនុស្ស | សម្រាប់គោលបំណងនៃគោលការណ៍ណែនាំនេះ ជនរងគ្រោះ មានន័យថា រូបវន្តបុគ្គលណាម្នាក់ដែលជាកម្មវត្ថុនៃសកម្មភាពជួញដូរមនុស្ស ដូចមានចែងក្នុងអនុសញ្ញា ACTIP។[4] |
| ជនប្រព្រឹត្តបទល្មើស-ជាជនរងគ្រោះ | សម្រាប់គោលបំណងនៃគោលការណ៍ណែនាំនេះ ជនប្រព្រឹត្តបទល្មើស-ជាជនរងគ្រោះ គឺជាបុគ្គលដែលត្រូវបានសន្មតជាមុនថាជាជនរងគ្រោះ ឬជាជនរងគ្រោះដោយការជួញដូរមនុស្ស ដែលក៏ពាក់ព័ន្ធផងដែរក្នុងការប្រព្រឹត្តសកម្មភាពល្មើសច្បាប់ ដែលប្រព្រឹត្តដោយពួកគេ ប្រសិនបើសកម្មភាពទាំងនោះពាក់ព័ន្ធដោយផ្ទាល់នឹងសកម្មភាពជួញដូរមនុស្ស។ |

[4] មាត្រា ២(ង) អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ACTIP)

# អារម្ភកថា របស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស ( AICHR )

ការជួញដូរមនុស្សនៅតែជាបញ្ហាមួយដ៏ស្រួចស្រាវ និងបង្កវិនាសកម្មបំផុតចំពោះមនុស្សជាតិ ដោយដកហូតសេចក្ដីថ្លៃថ្នូរ និងសេរីភាពរបស់បុគ្គល ហើយក្នុងពេលជាមួយគ្នានោះ បំផ្លាញមូលដ្ឋានគ្រឹះរបស់សង្គមជាតិយើង។ ជាញឹកញាប់ជនរងគ្រោះដោយការជួញដូរមនុស្ស មិនត្រឹមតែប្រឈមនឹងការកេងប្រវ័ញ្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងភាពអយុត្តិធម៌បន្ថែមទៀត ដូចជា ការមាក់ងាយ ការដាក់ទោសព្រហ្មទណ្ឌ និងកង្វះលទ្ធភាពទទួលបានយុត្តិធម៌ ជាដើម។

ក្នុងនាមជាតំណាងប្រទេសឥណ្ឌូនេស៊ីប្រចាំគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាន ស្តីពីសិទ្ធិមនុស្ស (AICHR) ពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៤ ខ្ញុំមានកិត្តិយសដោយបានមើលឃើញការប្តេជ្ញាចិត្តកាន់តែច្រើនឡើងរបស់អាស៊ាន ក្នុងការឆ្លើយតបចំពោះភាពស្មុគស្មាញនៃការជួញដូរមនុស្ស។

គោលការណ៍ណែនាំរបស់អាស៊ានស្តីពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ដើម្បីការពារជនរងគ្រោះដោយការជួញដូរមនុស្ស គឺជាជំហានសំខាន់មួយក្នុងការប្រយុទ្ធប្រឆាំងរួមគ្នារបស់យើងដើម្បីដោះស្រាយភាពអយុត្តិធម៌ទាំងនេះ ដោយបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការការពារជនរងគ្រោះ និងធានាការគោរពសិទ្ធិរបស់ពួកគេ។ គោលការណ៍ណែនាំនេះពង្រឹងគោលការណ៍ដែលថាការការពារជនរងគ្រោះ មិនត្រឹមតែជាកាតព្វកិច្ចផ្លូវច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកាតព្វកិច្ចសីលធម៌និងមនុស្សធម៌ផងដែរ។

គោលការណ៍ណែនាំនេះកើតចេញពីកិច្ចសហការឥតឈប់ឈរ ដែលឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់តួអង្គពោរពេញដោយការប្តេជ្ញាចិត្តជាច្រើននៅទូទាំងអាស៊ាន។ ខ្ញុំសូមសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះតំណាង AICHR កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) និងស្ថាប័នតាមវិស័យរបស់អាស៊ាន។ ខ្ញុំក៏សូមអរគុណដល់អ្នកជំនាញ និងអង្គការសង្គមស៊ីវិលដែលបានផ្តល់ពេលវេលា ជំនាញ និងការប្តេជ្ញាចិត្តរបស់ពួកគេ ដើម្បីបង្កើតឯកសារសំខាន់នេះ។

គោលការណ៍ណែនាំនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រដ្ឋសមាជិកអាស៊ាន ចំពោះគោលការណ៍ដែលមានចែងក្នុងអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ACTIP) និងស្ថាបនាពីលើផែនការការងារពហុវិស័យអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស (ផែនការការងារ Bohol TIP ២.០)។

នេះជាសក្ខីភាពនៃការទទួលស្គាល់របស់អាស៊ានថា គោលការណ៍មិនដាក់ទណ្ឌកម្មមិនមែនគ្រាន់តែជាកាតព្វកិច្ចផ្លូវច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការទាមទារខាងសីលធម៌ផងដែរ។ តាមរយៈការទប់ស្កាត់ការដាក់ទោសព្រហ្មទណ្ឌចំពោះជនរងគ្រោះ យើងបញ្ជាក់ពីសេចក្តីថ្លៃថ្នូររបស់ពួកគេ និងបង្កើនប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងរបស់យើង ក្នុងការផ្តន្ទាទោសអ្នកជួញដូរ និងកម្ចាត់បណ្តាញឧក្រិដ្ឋជន។

ខ្ញុំក៏សូមសម្តែងការដឹងគុណយ៉ាងស្មោះចំពោះក្រុមការងារនៃកម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស និងបណ្ឌិត Marika McAdam ដែលប្រសិនបើគ្មានពួកគាត់ទេ គោលការណ៍ណែនាំនេះនឹងមិនអាចសម្រេចបានឡើយ។ ពួកគាត់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាថា ការអភិវឌ្ឍគោលការណ៍ណែនាំនេះ គ្រប់ជ្រុងជ្រោយ មានបរិយាបន្ន និងផ្អែកលើការអនុវត្តន៍ល្អបំផុតជាអន្តរជាតិ។

គោលការណ៍ណែនាំនេះតំណាងឱ្យការសម្រេចចិត្តរួមរបស់អាស៊ានដើម្បីធានាថា ជនរងគ្រោះដោយការជួញដូរមនុស្ស មិនត្រូវបានដាក់ទោសទណ្ឌចំពោះបទល្មើសដែលពួកគេត្រូវបានបង្ខំឱ្យប្រព្រឹត្ត ដែលបណ្តាលមកពីការកេង

ប្រព័ន្ធលើពួកគេ។ គោលការណ៍ណែនាំនេះផ្តល់ជំហានជាក់ស្តែង និងអាចអនុវត្តបានសម្រាប់អ្នកតាក់តែងច្បាប់ ទីភ្នាក់ងារអនុវត្តន៍ច្បាប់ ស្ថាប័នតុលាការ និងភាគីពាក់ព័ន្ធផ្សេងទៀតនៅទូទាំងរដ្ឋសមាជិកអាស៊ាន ដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម។

លើសពីក្របខណ្ឌផ្លូវច្បាប់ គោលការណ៍ណែនាំនេះទាមទារឱ្យមានការផ្លាស់ប្តូរផ្នត់គំនិត ដោយផ្តល់អាទិភាពលើវិធីសាស្រ្តដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរទីភ្នាក់ងារឱ្យកាន់តែរឹងមាំ និងការតម្រឹមកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិឱ្យស្របនឹងអនុសញ្ញា ACTIP។

វាក៏ជាការអំពាវនាវឱ្យធ្វើសកម្មភាពផងដែរ ព្រោះគោលការណ៍ណែនាំនេះជំរុញឱ្យយើងជម្នះឧបសគ្គជាប្រព័ន្ធ ដើម្បីបង្កើតបរិយាកាសដែលជនរងគ្រោះអាចស្វែងរកការការពារដោយមិនភ័យខ្លាចការសងសឹក និងលើកកម្ពស់សាមគ្គីភាពក្នុងតំបន់ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ទោះជាយ៉ាងណា ជោគជ័យនៃលិខិតុបករណ៍នេះ អាស្រ័យលើយើងទាំងអស់គ្នា ពោលគឺការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការអនុម័ត និងប្រតិបត្តិការអនុវត្តន៍ទាំងនេះ ភាពក្លាហានរបស់សង្គមស៊ីវិលក្នុងការតស៊ូមតិឱ្យមានការផ្លាស់ប្តូរ និងភាពមុតមាំរបស់បុគ្គលម្នាក់ៗដែលឧទ្ទិសដល់បុព្វហេតុនៃយុត្តិធម៌។

គោលការណ៍ណែនាំនេះក៏ជាការរំលឹកអំពីអ្វីដែលអាចធ្វើទៅបាន នៅពេលដែលយើងធ្វើការជាមួយគ្នា។ វាគូសបញ្ជាក់ពីអំណាចនៃភាពជាដៃគូទូទាំងរដ្ឋាភិបាល សង្គមស៊ីវិល និងយន្តការថ្នាក់តំបន់ ដោយបង្ហាញថា នៅពេលយើងប្រមាច់បញ្ចូលគ្នានូវចំណុចខ្លាំងរបស់យើង យើងនឹងអាចបំបែកប្រព័ន្ធនៃការកេងប្រវ័ញ្ច និងកសាងផ្លូវឆ្ពោះទៅរកយុត្តិធម៌ និងការបង្កើនភាពអង់អាច។ ខ្ញុំមានកិត្តិយសដែលបានចូលរួមក្នុងដំណើរការរបស់អាស៊ានឆ្ពោះទៅរកគោលដៅនេះ។

សូមឱ្យយើងទទួលយកគោលការណ៍ណែនាំនេះ មិនមែនគ្រាន់តែជាឧបករណ៍ប៉ុណ្ណោះទេ ប៉ុន្តែជាឱកាសដើម្បីបញ្ជាក់ឡើងវិញនូវគុណតម្លៃរួមរបស់យើង គឺសិទ្ធិមនុស្ស យុត្តិធម៌ និងសមភាព។ ក្រោមការសហការគ្នា យើងពិតជាអាចប្រែក្លាយចក្ខុវិស័យនេះទៅជាការពិត ដោយធានាថា ជនរងគ្រោះទទួលបានការគាំទ្រ ការបង្កើនភាពអង់អាច និងការការពារ។

ក្នុងការធ្វើដូច្នេះ យើងមិនត្រឹមតែអាចពង្រឹងប្រព័ន្ធរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងមូលដ្ឋានគ្រឹះនៃសហគមន៍អាស៊ានរបស់យើងទៀតផងនោះគឺក្តីមេត្តា ភាពធន់ និងជំនឿដ៏មុតមាំចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្សគ្រប់រូប។

**លោកស្រី Yuyun Wahyuningrum**
**តំណាងឥណ្ឌូនេស៊ីប្រចាំ AICHR (២០១៩-២០២៤)**

# អនុស្សរណៈ របស់កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) ប្រធានស្ម័គ្រចិត្តអាស៊ានលើវិស័យអាទិភាពប្រឆាំងការជួញដូរមនុស្ស

កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC)-ហ្វីលីពីន នៅតែប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស តាមរយៈអភិក្រមដ៏ទូលំទូលាយ និងផ្តោតលើជនរងគ្រោះ។ គំនិតផ្តួចផ្តើមដ៏សំខាន់មួយនៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះគឺគោលការណ៍ណែនាំអាស៊ានស្តីពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មសម្រាប់ជនរងគ្រោះនៃការជួញដូរមនុស្ស ដែលតំណាងឱ្យការប្តេជ្ញាចិត្តរួមគ្នារបស់យើងក្នុងការធានាទាំងការទប់ស្កាត់ និងការការពារសម្រាប់ជនរងគ្រោះទាំងអស់។ គំនិតផ្តួចផ្តើមនេះ ជាសមិទ្ធផលនៃកិច្ចសហការយ៉ាងជិតស្និទ្ធរវាង SOMTC និងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) ឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការឆ្លើយតបជាអន្តរវិស័យរួមគ្នាចំពោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ដូចដែលខ្ញុំឆ្លុះបញ្ចាំងលើកិច្ចខិតខំប្រឹងប្រែងរួមរបស់យើង វាជាសក្ខីភាពដែលថា ផែនការការងារ ពហុវិស័យអាស៊ានស្តីពីការជួញដូរមនុស្ស (២០២៣-២០២៨) តំណាងឱ្យព្រឹត្តិការណ៍ដ៏សំខាន់មួយនៅក្នុងដំណើររបស់យើង ដែលជំរុញកិច្ចសហប្រតិបត្តិការលើវិស័យចម្រុះ ដោយការបង្រួបបង្រួមតំបន់របស់យើងក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មដ៏សាហាវនេះ។

ក្នុងនាមជាអ្នកដឹកនាំស្ម័គ្រចិត្តអាស៊ានផ្តោតលើការជួញដូរមនុស្សជាអាទិភាពហ្វីលីពីនទទួលស្គាល់សារៈសំខាន់នៃការលើកកម្ពស់ការរួមផ្សំគ្នាក្នុងចំណោមស្ថាប័នតាមវិស័យអាស៊ាន។ ការអភិវឌ្ឍន៍នៃគោលការណ៍ណែនាំនេះ អាចធ្វើទៅបានតាមរយៈការសន្ទនាក្នុងន័យស្ថាបនា និងចែករំលែកជំនាញរវាងភាគីពាក់ព័ន្ធ។ ភាពជាដៃគូដ៏រឹងមាំនេះបង្ហាញពីធន្ទះរួមក្នុងតំបន់របស់យើងក្នុងការពង្រឹងការការពារជនរងគ្រោះពីការជួញដូរ និងទប់ស្កាត់ការក្លាយជាជនរងគ្រោះជាថ្មីទៀតរបស់ពួកគេ។

គោលការណ៍មិនដាក់ទោសទណ្ឌ គឺរួមបញ្ចូលកិច្ចខិតខំប្រឹងប្រែងដ៏ទូលំទូលាយរបស់អាស៊ានក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ជាមួយនឹងកិច្ចការពារសិទ្ធិមនុស្ស។ ជនរងគ្រោះនៃការជួញដូរច្រើនតែស៊ូទ្រាំនឹងការកេងប្រវ័ញ្ចធ្ងន់ធ្ងរ ហើយវាជាកាតព្វកិច្ចរបស់យើងក្នុងការធានាថាពួកគេទទួលបានការការពារ ជាជាងការកាត់ទោស។ គោលការណ៍ណែនាំអាស៊ានផ្តល់នូវវិធីសាស្ត្រ រចនាសម្ព័ន្ធសម្រាប់រដ្ឋសមាជិកអាស៊ានក្នុងការដាក់បញ្ចូលគោលការណ៍នេះក្នុងក្របខ័ណ្ឌជាតិរបស់ពួកគេ ស្របតាមប្រព័ន្ធច្បាប់រៀងៗខ្លួន។ អភិក្រមនេះ ស្របតាមការអនុវត្តន៍ល្អបំផុតរបស់អន្តរជាតិ និងពង្រឹងចក្ខុវិស័យរបស់អាស៊ានអំពីយុត្តិធម៌ និងបរិយាបន្នសហគមន៍។

SOMTC-ហ្វីលីពីន ទទួលស្គាល់ថាការដោះស្រាយការជួញដូរមនុស្សតម្រូវឱ្យមានយុទ្ធសាស្ត្រពហុភាគី ដែលរួមមានការការពារ ការការពារ ការកាត់ទោស គោលនយោបាយ និងច្បាប់ ការកសាងសមត្ថភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ គោលការណ៍ណែនាំនេះត្រូវបានប្រើប្រាស់ជាធនធានជាក់ស្តែងសម្រាប់មន្ត្រីអនុវត្តច្បាប់ អាជ្ញាធរតុលាការ និងសម្រាប់អ្នកបង្កើតគោលនយោបាយក្នុងការស្វែងរកភាពស្មុគស្មាញនៃការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម។ ជាងនេះទៅទៀត កិច្ចសហការរវាង SOMTC និង AICHR ក្នុងការបង្កើតគោលការណ៍ណែនាំនេះ បានគូសបញ្ជាក់ពីសារៈសំខាន់សម្រាប់អភិក្រមផ្អែកលើសិទ្ធិមនុស្សក្នុងការដោះស្រាយបញ្ហាជួញដូរមនុស្ស។ ចំនុចប្រសព្វនៃការពិចារណាអំពីសន្តិសុខ និងសិទ្ធិមនុស្ស មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការដោះស្រាយបញ្ហាជាឫសគល់ និងផលវិបាកនៃការជួញដូរ

មនុស្ស។ ជនរងគ្រោះទាំងឡាយត្រូវតែទទួលបាននូវការយកចិត្តទុកដាក់ដោយសេចក្តីថ្លៃថ្នូរ និងផ្តល់ការគាំទ្រនូវអ្វីដែលជាតម្រូវការចាំបាច់ ដើម្បីអាចកសាងជីវិតរបស់ពួកគេឡើងវិញ។

គោលការណ៍ណែនាំដែលមិនមែនជាឧបករណ៍មានកាតព្វកិច្ចផ្នែកផ្លូវច្បាប់នេះ ត្រូវបានបង្កើតឡើងដើម្បីជួយបំពេញបន្ថែមនូវគំនិតផ្តួចផ្តើមថ្នាក់ជាតិ និងថ្នាក់តំបន់ដែលមានស្រាប់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ រដ្ឋសមាជិកអាស៊ានរក្សាភាពបត់បែនក្នុងការអនុវត្តន៍គោលការណ៍ណែនាំដោយអនុលោមតាមក្របខ័ណ្ឌច្បាប់ក្នុងស្រុក និងកាតព្វកិច្ចអន្តរជាតិរបស់ពួកគេ។

ក្នុងបរិបទនេះ ការអនុម័តគោលការណ៍មិនដាក់ទណ្ឌកម្ម គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយ ដើម្បីផ្តល់អំណាចដល់រដ្ឋសមាជិកអាស៊ាន ក្នុងការធ្វើសមាហរណកម្មទៅក្នុងគោលនយោបាយ និងក្របខ័ណ្ឌជាតិរបស់ពួកគេ។ SOMTC ទទួលស្គាល់ថា ការអនុវត្តន៍ដោយជោគជ័យនៃគោលការណ៍មិនដាក់ទណ្ឌកម្ម តម្រូវឱ្យមានការកសាងសមត្ថភាព និងការចែករំលែកចំណេះដឹងជាបន្តបន្ទាប់ក្នុងចំណោមរដ្ឋសមាជិកអាស៊ាន។ ការផ្លាស់ប្តូរការអនុវត្តន៍ និងបទពិសោធន៍ល្អៗនឹងរួមចំណែកលើកកម្ពស់ការអនុវត្តន៍គោលការណ៍ណែនាំនេះឱ្យកាន់តែមានសង្គតិភាពនៅទូទាំងតំបន់។

ក្នុងដំណើរឆ្ពោះទៅមុខរបស់យើង អាស៊ានត្រូវតែមានភាពហ័សរហួន និងឆ្លើយតបទៅនឹងការវិវត្តនៃបញ្ហាប្រឈមនៃឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសការជួញដូរមនុស្ស។ លក្ខណៈថាមវន្តនៃបញ្ហានេះតម្រូវឱ្យមានវិធានការសម្របខ្លួន និងការគិតគូរទៅមុខ ដើម្បីធានាថាជនរងគ្រោះទទួលបានការគាំពារ ដែលពួកគេសមនឹងទទួលបាន។

SOMTC-ហ្វីលីពីន សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះ AICHR-ឥណ្ឌូនេស៊ី និងដៃគូទាំងអស់សម្រាប់ការរួមចំណែកដ៏មានតម្លៃរបស់ពួកគេក្នុងការអភិវឌ្ឍគោលការណ៍ណែនាំអាស៊ាននេះ។ កិច្ចខិត ខំប្រឹងប្រែងរួមគ្នានេះធានាថាគោលការណ៍ណែនាំ នឹងក្លាយជាធនធានដ៏រឹងមាំសម្រាប់ការអនុវត្តន៍ជាក់ស្តែងរបស់រដ្ឋសមាជិកអាស៊ានក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដោយបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរួមរបស់យើងចំពោះយុត្តិធម៌ សិទ្ធិមនុស្ស និងសន្តិសុខក្នុងតំបន់។

NESTOR B SANARES

**កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន - អ្នកដឹកនាំហ្វីលីពីន**

**ប្រធានស្ម័គ្រចិត្តអាស៊ានលើវិស័យអាទិភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស**

# អារម្ភកថា របស់ឯកអគ្គរដ្ឋទូតអូស្រ្តាលីប្រចាំអាស៊ាន និង ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រឆាំងទាសភាពសម័យទំនើប ការរត់ពន្ធមនុស្ស និងការជួញដូរមនុស្ស

ការជួញដូរមនុស្សនៅតែជាបញ្ហាប្រឈមមួយ ក្នុងចំណោមបញ្ហាប្រឈមដ៏ស្មុគស្មាញ នៃពេលវេលារបស់យើង។ ជនរងគ្រោះនៃការជួញដូរ ច្រើនតែស៊ូទ្រាំនឹងការឈឺចាប់ និងការកេងប្រវ័ញ្ចដែលមិនអាចនឹកស្មានដល់។ លក្ខណៈវិវឌ្ឍន៍នៃឧក្រិដ្ឋកម្ម រួមទាំងការកើនឡើងនៃការជួញដូរសម្រាប់ឧក្រិដ្ឋកម្មដោយបង្ខំ បញ្ជាក់ពីតម្រូវការចាំបាច់សម្រាប់ការខិតខំប្រឹងប្រែងជាបន្តបន្ទាប់ ដើម្បីការពារសិទ្ធិជនរងគ្រោះពីការជួញដូរ។

អស់រយៈពេលជាង២០ឆ្នាំមកហើយ ដែលអូស្ត្រាលីបានសហការជាមួយអាស៊ាន និងរដ្ឋសមាជិកអាស៊ាន ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ កិច្ចសហការនេះកំពុងបន្តតាមរយៈកម្មវិធីអាស៊ានអូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) របស់យើង ដែលគាំទ្រអាស៊ាន និងរដ្ឋជាសមាជិករបស់ខ្លួន ក្នុងការអនុវត្តន៍អនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ACTIP)។ ACTIP ផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ស្របតាមច្បាប់ក្នុងស្រុករបស់ប្រទេសសមាជិកអាស៊ាន។

ការប្រកាន់ខ្ជាប់នូវ "គោលការណ៍មិនដាក់ទណ្ឌកម្ម" ជួយការពារសិទ្ធិជនរងគ្រោះនៃការជួញដូរ និងធានាថាពួកគេមិនត្រូវបានផ្តន្ទាទោស ឬពិន័យជាប្រាក់ សម្រាប់អំពើខុសច្បាប់ដែលបានប្រព្រឹត្តជាលទ្ធផលផ្ទាល់នៃការជួញដូររបស់ពួកគេ។

រដ្ឋាភិបាលអូស្ត្រាលីមានមោទនភាពក្នុងការគាំទ្រដល់ការបង្កើតសៀវភៅមគ្គុទេសក៍ស្តីពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម តាមរយៈការសហការយ៉ាងរឹងមាំក្នុងចំណោមរដ្ឋសមាជិកអាស៊ាន កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស និងអង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិលផ្សេងៗ។

យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍គោលការណ៍ណែនាំនេះ។ ចូរយើងបន្តធ្វើការជាមួយគ្នា ដើម្បីធានាថាជនរងគ្រោះនៃការជួញដូរទទួលបានយុត្តិធម៌ និងការការពារដែលពួកគេសមនឹងទទួលបានស្របតាមអនុសញ្ញា ACTIP និងច្បាប់អន្តរជាតិ។

**H.E. Tiffany McDonald**
ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំអាស៊ាន

**H.E. Lynn Bell**
ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រឆាំងទាសភាពសម័យទំនើប
ការរត់ពន្ធមនុស្ស និងការជួញដូរមនុស្ស

# សេចក្ដីថ្លែងអំណរគុណ

គោលការណ៍ណែនាំអាស៊ាន ស្ដីពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មសម្រាប់ការពារជនរងគ្រោះដោយការជួញដូរមនុស្ស ត្រូវបានរៀបចំឡើងដោយមានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT)។

គោលការណ៍ណែនាំនេះគឺជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នា និងការពិគ្រោះយោបល់ពីកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានទទួលស្ដីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) និងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្ដីពីសិទ្ធិមនុស្ស (AICHR)។ សមិទ្ធផលនេះ បានបង្ហាញពីការប្ដេជ្ញាចិត្តរបស់អាស៊ានក្នុងការលើកស្ទួយសិទ្ធិមនុស្សរបស់ជនរងគ្រោះដោយការជួញដូរមនុស្ស និងការឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលប៉ះពាល់ដល់តំបន់។ គោលការណ៍នេះ ផ្ដល់ការណែនាំដល់រដ្ឋសមាជិកអាស៊ាន ក្នុងការអនុវត្តន៍កាតព្វកិច្ចរបស់ខ្លួននៅក្រោមអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ និងផែនការការងារពហុវិស័យអាស៊ានប្រឆាំងការជួញដូរមនុស្សឆ្នាំ ២០២៣-២០២៨ ("ផែនការការងារ Bohol TIP 2.0") ដើម្បីធានាថា ជនរងគ្រោះនៃការជួញដូរមនុស្សមិនត្រូវបានដាក់ទណ្ឌកម្ម ឬទទួលខុសត្រូវផ្នែករដ្ឋបាល ចំពោះអំពើខុសច្បាប់ណាមួយដែលពួកគេបានប្រព្រឹត្ត ប្រសិនបើអំពើនោះជាផលវិបាកដោយផ្ទាល់នៃការជួញដូរមនុស្ស។

ក្នុងដំណើរការរៀបចំគោលការណ៍ណែនាំនេះ SOMTC និង AICHR បានអនុវត្តដំណើរការចូលរួមយ៉ាងទូលំទូលាយ ដោយបានធ្វើការពិគ្រោះយោបល់ជាមួយរដ្ឋាភិបាលរដ្ឋសមាជិកអាស៊ានទាំងអស់ ស្ថាប័នអាស៊ានផ្សេងៗ សង្គមស៊ីវិល និងអង្គការអន្តរជាតិ។ សិក្ខាសាលាពិគ្រោះយោបល់ត្រូវបានរៀបចំឡើងនៅថ្ងៃទី១០-១២ ខែមិថុនា ឆ្នាំ២០២៤ និងថ្ងៃទី២-៣ ខែកញ្ញា ឆ្នាំ២០២៤ ដើម្បីប្រមូលយោបល់ ចំណេះដឹង និងបទពិសោធន៍ពីអ្នកអនុវត្តការងារប្រឆាំងការជួញដូរមនុស្សជាច្រើន ទាំងពីក្នុង និងក្រៅតំបន់អាស៊ាន។ សេចក្ដីព្រាងគោលការណ៍ណែនាំនេះត្រូវបានផ្សព្វផ្សាយដល់តំណាងរដ្ឋសមាជិកអាស៊ានទាំងអស់នៃ SOMTC និង AICHR ដើម្បីពិភាក្សាបន្ថែម។

SOMTC និង AICHR សូមធ្វើការកោតសរសើរ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកស្រីបណ្ឌិត Marika McAdam ទីប្រឹក្សា ដែលបានផ្ដល់ការគាំទ្រយ៉ាងសំខាន់ក្នុងការរៀបចំគោលការណ៍ណែនាំនេះ ព្រមទាំងលោកស្រី Nurul Qoiriah នាយិកាទទួលបន្ទុកសមភាពយេនឌ័រ ពិការភាព បរិយាបន្នសង្គម និងសិទ្ធិជនរងគ្រោះនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស ដែលបានគាំទ្រផ្នែកបច្ចេកទេស និងសម្របសម្រួលដំណើរការទាំងមូលនៃការរៀបចំគោលការណ៍នេះ។

# សេចក្ដីផ្ដើម

រដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ទាំងអស់គឺជាភាគីហត្ថលេខីនៃអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ACTIP)។ មាត្រា ១៤(៧) នៃអនុសញ្ញានេះបានកំណត់គោលការណ៍មិនដាក់ទណ្ឌកម្មដូចខាងក្រោម៖

"ភាគីនីមួយៗត្រូវអនុវត្តតាមច្បាប់ បទបញ្ញា និងគោលនយោបាយជាតិរបស់ខ្លួន ហើយនៅក្នុងករណីសមស្រប ត្រូវពិចារណាមិនដាក់ទណ្ឌកម្មព្រហ្មទណ្ឌដល់ជនរងគ្រោះនៃការជួញដូរមនុស្ស ឬដាក់ពួកគេឲ្យទទួលខុសត្រូវផ្នែករដ្ឋបាល ចំពោះអំពើខុសច្បាប់ណាមួយដែលពួកគេបានប្រព្រឹត្ត ប្រសិនបើអំពើនោះកើតឡើងដោយសារផលវិបាកដោយផ្ទាល់នៃការជួញដូរមនុស្ស។"

ផែនការការងារពហុវិស័យអាស៊ានប្រឆាំងការជួញដូរមនុស្សឆ្នាំ២០២៣-២០២៨("ផែនការការងារ Bohol TIP 2.0") ដែលត្រូវបានអនុម័តដោយកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (AMMTC) លើកទី១៧ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ ២០២៣ បានពង្រឹងមាត្រា ១៤(៧) នៃអនុសញ្ញា ACTIP នៅក្នុងគោលការណ៍ទី៣ ដែលបញ្ជាក់ថា៖ "ជនរងគ្រោះនៃការជួញដូរមនុស្សមិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌ ឬទទួលខុសត្រូវផ្នែករដ្ឋបាលចំពោះអំពើខុសច្បាប់ណាមួយដែលពួកគេបានប្រព្រឹត្ត ប្រសិនបើអំពើនោះជាផលវិបាកដោយផ្ទាល់នៃការជួញដូរមនុស្ស"។[5]

ក្រោមផែនការការងារ Bohol TIP ២.០ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) គឺជាស្ថាប័នសម្របសម្រួលវិស័យអាស៊ានលើសកម្មភាព/កម្មវិធីនានា ដើម្បីផ្តល់ប្រសិទ្ធភាពដល់គោលការណ៍មិនដាក់ទណ្ឌ កម្មនៅក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្ស គោលនយោបាយ និងការអនុវត្តន៍របស់រដ្ឋសមាជិកអាស៊ាន។ សកម្មភាពនៅក្នុងអាណត្តិនេះរួមមានការលើកទឹកចិត្តដល់រដ្ឋសមាជិកអាស៊ានឱ្យ ពិនិត្យឡើងវិញ ហើយក្នុងករណីដែលសមស្រប ធ្វើកំណែទម្រង់ច្បាប់ ឬក្រមព្រហ្មទណ្ឌ ឬគោលការណ៍ណែនាំ។ កសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងព្រះរាជអាជ្ញាលើគោលការណ៍មិនដាក់ទណ្ឌកម្ម និងធ្វើការត្រួតពិនិត្យជាទៀងទាត់សម្រាប់ជនអន្តោប្រវេសន៍ និងកន្លែងឃុំឃាំង ដើម្បីស្វែងរកជនដែលត្រូវបានជួញដូរក្នុងចំណោមពួកគេ។

គោលការណ៍ណែនាំអាស៊ានដែលមិនមានកាតព្វកិច្ចផ្លូវច្បាប់នេះ បានកើតចេញពីការចូលរួមចំណែករបស់ SOMTC និងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) បានធ្វើការកត់សម្គាល់ថា គោលការណ៍មិនដាក់ទណ្ឌកម្មមានសារៈសំខាន់យ៉ាងខ្លាំង ទាំងក្នុងការលើកកម្ពស់សិទ្ធិមនុស្សរបស់ជនរងគ្រោះដោយការជួញដូរមនុស្ស និងក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន។ គោលការណ៍នេះត្រូវបានរៀបចំទ ដើម្បីគាំទ្រដល់ស្ថាប័នអាស៊ានតាមវិស័យ និងរដ្ឋសមាជិកអាស៊ាន ដើម្បីពង្រឹងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មក្នុងសកម្មភាពរបស់ពួកគេ ស្របតាមច្បាប់ជាតិរបស់ប្រទេសសមាជិកអាស៊ាននីមួយៗ និងក្នុងការបំពេញកាតព្វកិច្ចអន្តរជាតិ និងតំបន់។

សៀវភៅមគ្គុទេសក៍អាស៊ាននេះ ផ្តោតលើការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មចំពោះជនរងគ្រោះដោយការជួញដូរមនុស្សក្នុងរដ្ឋសមាជិកអាស៊ាន (ASEAN-ACT, ២០២២) ដែលត្រូវបានណែនាំជាធនធានសម្រាប់គាំទ្រដល់រដ្ឋសមាជិកអាស៊ានក្នុងការងាររបស់ពួកគេ6 និងដោយសិក្ខាសាលាពិគ្រោះយោបល់ចំនួនពីរលើក ដែលបានធ្វើឡើងនៅក្នុងខែមិថុនា និងខែកញ្ញា ឆ្នាំ២០២៤ ដោយមានការចូលរួមពីតំណាងរបស់ SOMTC, AICHR, យន្តការជាតិប្រឆាំងការជួញដូរមនុស្ស ផ្នែកសិទ្ធិមនុស្ស អង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធ៕

[5] គោលការណ៍មិនដាក់ទណ្ឌកម្ម មាននៅក្នុងគោលការណ៍ណែនាំរបស់ OHCHR និងគោលការណ៍ណែនាំស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស (២០០២)។ គោលការណ៍នេះត្រូវបានចេញជាសេចក្ដីថ្លែងការណ៍តំបន់ដោយគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ គោលការណ៍ណែនាំស្តីពីការយកចិត្តទុកដាក់ចំពោះយេនឌ័រសម្រាប់ដោះស្រាយបញ្ហាស្ត្រីរងគ្រោះដោយការជួញដូរមនុស្ស។ គោលការណ៍ណែនាំអាស៊ានសម្រាប់អ្នកអនុវត្តស្តីពីការឆ្លើយតបក្នុងការងារយុត្តិធម៌ព្រហ្មទណ្ឌចំពោះការជួញដូរមនុស្ស (២០០៧); និងផែនការសកម្មភាពអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។

[6] មានជាភាសាអង់គ្លេស បាហាសា ឥណ្ឌូនេស៊ី ភូមា ខ្មែរ ឡាវ ថៃ និងវៀតណាម។

[7]សូមមើលអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង (UNTOC) និងពិធីសារបំពេញបន្ថែមដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ព្រមទាំងអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ACTIP)។

## ផ្នែកទី ១

# ការយល់ដឹងអំពី
# គោលការណ៍
# មិនដាក់ទណ្ឌកម្ម

## ផ្នែកទី ១. ការយល់ដឹងអំពីគោលការណ៍មិនដាក់ទណ្ឌកម្ម

រដ្ឋសមាជិកអាស៊ានមានកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ និងច្បាប់តំបន់ ដោយអាស្រ័យលើច្បាប់ វិធាន បទបញ្ញត្តិ និងគោលនយោបាយក្នុងស្រុករបស់ខ្លួន ក្នុងការស៊ើបអង្កេត និងផ្តន្ទាទោសអ្នកជួញដូរមនុស្ស ការពារ និងជួយជនរងគ្រោះដោយការជួញដូរមនុស្ស និងសហប្រតិបត្តិការ ដើម្បីគោលបំណងទាំងនេះ។ រដ្ឋសមាជិកគួរពិចារណាអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ដើម្បីបំពេញកាតព្វកិច្ចទាំងនេះ។

ACTIP គឺជាឧបករណ៍ចងកាតព្វកិច្ចផ្លូវច្បាប់។ យោងតាមមាត្រា ១៤(៧) នៃអនុសញ្ញា ACTIP រដ្ឋភាគីនៃអនុសញ្ញាACTIP បានប្តេជ្ញាពិចារណាចាត់ទុកជនរងគ្រោះដោយការជួញដូរមនុស្សថាមិនជាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ឬខាងរដ្ឋបាលឡើយ ចំពោះសកម្មភាពល្មើសច្បាប់ដែលពួកគេបានប្រព្រឹត្ត ប្រសិនបើសកម្មភាពបែបនោះជាប់ទាក់ទងដោយផ្ទាល់ទៅនឹងសកម្មភាពនៃការជួញដូរមនុស្ស។

ទោះបីជាគោលការណ៍មិនដាក់ទណ្ឌកម្មត្រូវបានអនុវត្តទូទាំងតំបន់អាស៊ានក៏ដោយ ក៏ជនរងគ្រោះដោយការជួញដូរមនុស្ស ត្រូវបានឃុំខ្លួន និងនិរទេសចេញពីប្រទេសអាស៊ានដោយសារបទល្មើសដែលជាប់ពាក់ព័ន្ធនឹងស្ថានភាព និងត្រូវបានផ្តន្ទាទោសសម្រាប់បទល្មើសតូចតាច និងបទល្មើសធ្ងន់ធ្ងរដែលពួកគេបានប្រព្រឹត្ត ដែលជាប់ទាក់ទងនឹងសកម្មភាពនៃការជួញដូរពួកគេ ឬក្នុងកិច្ចខិតខំប្រឹងប្រែងគេចចេញពីសកម្មភាពនេះ។[7] ខណៈដែលមានការចងកាតព្វកិច្ចច្បាស់លាស់ រដ្ឋសមាជិកអាស៊ានត្រូវពង្រឹងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ឱ្យបានជាក់ស្តែង។

### តើអ្វីជាគោលការណ៍មិនដាក់ទណ្ឌកម្ម?

គោលការណ៍មិនដាក់ទណ្ឌកម្ម គឺជាគោលការណ៍ត្រូវបានទទួលស្គាល់ដែលចែងថា រដ្ឋគួរពិចារណាមិនដាក់ទណ្ឌកម្មជនរងគ្រោះដោយការជួញដូរមនុស្ស ចំពោះសកម្មភាពល្មើសច្បាប់ដែលពួកគេបានប្រព្រឹត្ត ប្រសិនបើសកម្មភាពបែបទនោះជាប់ទាក់ទងដោយផ្ទាល់ទៅនឹងសកម្មភាពនៃការជួញដូរមនុស្ស។ គោលបំណងនៃគោលការណ៍មិនដាក់ទណ្ឌ កម្ម គឺដើម្បីការពារជនរងគ្រោះពីការចាប់ខ្លួន ការឃុំខ្លួន ការនិរទេស ការស៊ើបអង្កេត ការផ្តន្ទាទោស ការដាក់ទោស និងការកាត់ទោសសម្រាប់សកម្មភាពល្មើសច្បាប់ដែលពួកគេបានចូលរួម ដែលបណ្តាលមកពីសកម្មភាពជួញដូរមនុស្ស។ គោលការណ៍នេះក៏មានសកម្មភាពការពារប្រឆាំងនឹងទម្រង់ផ្សេងទៀតនៃការដាក់ទោសទណ្ឌផងដែរជាអាទិ៍ការដកហូតសញ្ជាតិជាដើម។

គោលការណ៍មិនដាក់ទណ្ឌកម្ម ឆ្លុះបញ្ចាំងពីលក្ខណៈនៃការជួញដូរមនុស្សដែលជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។ ក្នុងករណីខ្លះ ការដាក់ទោសទណ្ឌជនរងគ្រោះអាចផ្ទុយនឹងការប្តេជ្ញារបស់រដ្ឋ ដែលត្រូវ ពិចារណាផ្តល់ការការពារដល់ជនរងគ្រោះ និងអាចនាំឱ្យមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបន្ថែមទៀត។[8]

---

[8] សូមមើលឧបសម្ព័ន្ធ ៤។

[9] *ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ Siobhán Mullally,* ឯកសារ អ.ស.ប *A/HRC/47/34,* ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០២១ [១៨]-[១៩]។

គោលការណ៍មិនដាក់ទណ្ឌកម្មក៏ត្រូវបានគាំទ្រដោយច្បាប់ព្រហ្មទណ្ឌផងដែរ។ ច្បាប់ព្រហ្មទណ្ឌតម្រូវឱ្យបុគ្គលម្នាក់ទទួលខុសត្រូវចំពោះបទល្មើសដែលពួកគេបានប្រព្រឹត្តដោយចេតនា។ ការវាយតម្លៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ តម្រូវឱ្យមានចេតនាប្រព្រឹត្តបទល្មើស។ គោលការណ៍មិនដាក់ទណ្ឌកម្ម មិនរារាំងការផ្តន្ទាទោសអ្នកដែលពាក់ព័ន្ធក្នុងសកម្មភាពល្មើសច្បាប់ ដែលពួកគេបានប្រព្រឹត្តតាមទំនើងចិត្តនោះឡើយ។ ផ្ទុយទៅវិញ គោលការណ៍មិនដាក់ទណ្ឌកម្ម ទទួលស្គាល់ថា នៅពេលដែលបុគ្គលម្នាក់មិនមានចេតនាប្រព្រឹត្តបទល្មើស ព្រោះមានការប្រើប្រាស់មធ្យោបាយដើម្បីជួញដូរពួកគេ ពួកគេមិនអាចត្រូវបានចាត់ទុកថាទទួលខុសត្រូវចំពោះសកម្មភាពល្មើសច្បាប់របស់ពួកគេនោះឡើយ។ អ្នកជួញដូរប្រើប្រាស់មធ្យោបាយប្រឆាំងនឹងជនរងគ្រោះ ដូចជា ការគាបសង្កត់ ការក្លែងបន្លំ ការបង្ខិតបង្ខំ និងការបំពានលើភាពងាយរងគ្រោះរបស់ពួកគេជាដើម ដើម្បីគាបសង្កត់ជនរងគ្រោះឱ្យធ្វើទៅតាមអ្វីដែលពួកគេចង់បាន។ ជនរងគ្រោះដោយការជួញដូរមនុស្សមិនអាចត្រូវបានចាត់ទុកថាទទួលខុសត្រូវចំពោះការចូលរួមរបស់ពួកគេក្នុងសកម្មភាពល្មើសច្បាប់ ដែលអ្នកជួញដូរបានប្រើមធ្យោបាយ ដើម្បីបំផ្លាញ ឬកាត់បន្ថយចេតនាដែលជនរងគ្រោះអាចនឹងមាននោះឡើយ។ មានន័យថា ជនរងគ្រោះមិនអាចត្រូវបានចាត់ទុកថាទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេបានឡើយ។ ក្នុងករណីជនរងគ្រោះជាកុមារ អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ បានណែនាំថា នៅពេលដែលមានការកំណត់ទំនាក់ទំនងរវាងបទល្មើសដែលបានប្រព្រឹត្ត និងស្ថានភាពរបស់កុមារក្នុងនាមជាជនរងគ្រោះដែលបានសន្មត ឬកំណត់អត្តសញ្ញាណ ដោយការជួញដូរមនុស្ស រដ្ឋគួរពិចារណាបញ្ឈប់នីតិវិធី លុបចោលការដាក់ទោសដែលចេញរួចហើយ និង/ឬដោះលែងកុមារភ្លាមៗពីមន្ទីរឃុំឃាំង។[៩]

"ជនរងគ្រោះ" និង "ជនល្មើស" មិនមែនជាទស្សនទានទ្វេភាគនោះទេ (បុគ្គលម្នាក់អាចជាជនរងគ្រោះផង និងជាជនល្មើសផង)។ វាអាចជារឿងសមស្របដែលជនរងគ្រោះដោយការជួញដូរមនុស្សត្រូវបានការពារពីការដាក់ទោសទណ្ឌសម្រាប់សកម្មភាពល្មើសច្បាប់មួយចំនួន ប៉ុន្តែត្រូវបានផ្តន្ទាទោសសម្រាប់សកម្មភាពផ្សេងទៀតដែលមិនទាក់ទងនឹងការណ៍ដែលពួកគេត្រូវបានជួញដូរ។ ឧទាហរណ៍ ជនរងគ្រោះអាចត្រូវបានជួញដូរឱ្យប្រព្រឹត្តបទល្មើស ឧទាហរណ៍ នៅពេលដែលពួកគេត្រូវបានកេងប្រវ័ញ្ចឱ្យលក់គ្រឿងញៀនខុស ច្បាប់ជាដើម។ ក្នុងករណីនេះ ពួកគេមិនគួរត្រូវបានដាក់ទោសចំពោះបទល្មើសដែលពាក់ព័ន្ធនឹងគ្រឿងញៀននោះទេ ប៉ុន្តែគេនៅតែអាចដាក់ទោសពួកគេសម្រាប់សកម្មភាពល្មើសច្បាប់ផ្សេងទៀតដែលពួកគេបានចូលរួមដែលមិនទាក់ទងនឹងសកម្មភាពនៃការជួញដូរពួកគេ។

## វិសាលភាព

គោលការណ៍មិនដាក់ទណ្ឌកម្ម អនុវត្តចំពោះគ្រប់ដំណាក់កាលនៃការជួញដូរមនុស្ស និងគ្រប់ដំណាក់កាលនៃយុត្តិធម៌ព្រហ្មទណ្ឌ។ គោលការណ៍នេះគួរអនុវត្តភ្លាមៗ នៅពេលដែលមន្ត្រីជួរមុខមានការសង្ស័យដែលគួរឱ្យជឿជាក់ថាបុគ្គលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស ដោយមិនគិតពីស្ថានទម្ងន់ ឬភាពធ្ងន់ធ្ងរនៃបទល្មើសដែលគាត់បានប្រព្រឹត្ត ឬចូលរួមប្រព្រឹត្ត។ រដ្ឋសមាជិកអាស៊ានមួយចំនួនមានគោលនយោបាយអនុញ្ញាតឱ្យអាជ្ញាធរដែលសង្ស័យថា បុគ្គលម្នាក់ជាជនរងគ្រោះដោយការជួញដូរមនុស្ស ប្រព្រឹត្តចំពោះបុគ្គលនោះប្រៀបដូចជាគាត់គឺជាជនរងគ្រោះ ដើម្បីផ្តល់ជំនួយ

10 *ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ Siobhán Mullally,* ឯកសារ អ.ស.ប *A/HRC/47/34,* ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០២១ [៤៧]។ សូមមើលផងដែរគោលការណ៍ណែនាំ ៨(៣) នៃ គោលការណ៍ និងគោលការណ៍ណែនាំរបស់ OHCHR ស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស (២០០២)

និងការការពារបឋម។ នេះហៅថា ការសន្មតជាមុនអំពីភាពជាជនរងគ្រោះ។[10] ក្នុងករណីដែលរដ្ឋសមាជិកអាស៊ានអនុវត្តការសន្មតជាមុនចំពោះភាពជាជនរងគ្រោះនេះ គួរអនុវត្តគោលការណ៍នេះ (សូមមើលផ្នែកទី ៣ គោលការណ៍ណែនាំទី ៤) ដើម្បីការពារអ្នកដែលត្រូវបានសន្មតថាជាជនរងគ្រោះ/អ្នកដែលអាចជាជនរងគ្រោះ ពីការដាក់ទោសទណ្ឌ។

គោលការណ៍មិនដាក់ទណ្ឌកម្ម អនុវត្តចំពោះគ្រប់ដំណាក់កាលនៃដំណើរការជួញដូរមនុស្ស និងក្នុងគ្រប់ដំណាក់កាលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ ជនរងគ្រោះគួរត្រូវបានការពារពីការដាក់ទោសទណ្ឌសម្រាប់បទល្មើសរដ្ឋប្បវេណី បទល្មើសរដ្ឋបាល បទល្មើសអន្តោប្រវេសន៍ និងបទល្មើសព្រហ្មទណ្ឌ។

*ដ្យាក្រាម៖ វិសាលភាពនៃការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម*

**ជនរងគ្រោះទាំងអស់**

- មនុស្សពេញវ័យ
- កុមារ
- ប្រជាពលរដ្ឋ
- ជនចំណាកស្រុក
- ផ្សេងទៀត

**ដោយការជួញដូរមនុស្សគ្រប់ប្រភេទ**

- ការកេងប្រវ័ញ្ចផ្លូវភេទ
- ការងារដោយបង្ខំ
- ការបង្ខំឱ្យប្រព្រឹត្តបទល្មើស
- ការដកហូតសរីរាង្គ
- ការជួញដូរទៅក្នុងអំពើភេរវកម្ម
- ផ្សេងទៀត

**សម្រាប់សកម្មភាពល្មើសច្បាប់**

- បទល្មើសស្ថានភាព
- បទល្មើសតូចតាច
- បទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ

**ក្នុងករណីជនរងគ្រោះប្រព្រឹត្តបទល្មើស ដែលជាផលវិបាកដោយផ្ទាល់នៃការជួញដូរពួកគេ**

ប្រភេទ ឬភាពធ្ងន់ធ្ងរនៃសកម្មភាពល្មើសច្បាប់ មិនមែនជាកត្តាដើម្បីកំណត់ថាតើ ត្រូវអនុវត្តគោលការណ៍មិនដាក់ទណ្ឌ កម្ម ឬអត់នោះទេ។ ផ្ទុយទៅវិញ គោលការណ៍មិនដាក់ទណ្ឌកម្មអនុវត្ត នៅពេលដែលសកម្មភាពល្មើសច្បាប់ជាប់ទាក់ទងដោយផ្ទាល់ទៅនឹងបុគ្គលដែលត្រូវបានជួញដូរ។ ពោលគឺនៅពេលដែលជាតុផ្សំនៃបទល្មើសជួញដូរមនុស្ស ដែលជាលក្ខខណ្ឌតម្រូវក្នុងច្បាប់ជាតិរបស់រដ្ឋមួយ ត្រូវបានភ្ជាប់ទៅនឹងការប្រព្រឹត្តល្មើសរបស់ជនរងគ្រោះ រដ្ឋអាចកំណត់ថាគួរអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម។ ឧទាហរណ៍ ក្នុងករណីដែលជនរងគ្រោះចូលរួមក្នុងសកម្មភាពល្មើសច្បាប់ដោយផ្ទាល់ ដោយសារពួកគេត្រូវបានជួញដូរ ការប្រើប្រាស់មធ្យោបាយរបស់អ្នកជួញដូរ (រួមទាំងការគាបសង្កត់ ការក្លែងបន្លំ ការបង្ខិតបង្ខំ ការឆបោក ការរំលោភលើស្ថានភាពងាយរងគ្រោះ) ដើម្បីជំរុញឱ្យជនរងគ្រោះចូលរួមប្រព្រឹត្តបទល្មើសបែបនោះ គឺដូចគ្នានឹងការណ៍ដែលជនរងគ្រោះខ្វះចេតនាគ្រប់គ្រាន់ ដើម្បីត្រូវបានចាត់ទុកថាទទួលខុសត្រូវខាងព្រហ្មទណ្ឌ។

[11] *គោលការណ៍ណែនាំគោលនយោបាយស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស៖ មគ្គុទេសក៍ណែនាំសម្រាប់អ្នកបង្កើតគោលនយោបាយ និងអ្នកអនុវត្ត* (ដំណើរការ Bali ខែ ឧសភា ឆ្នាំ ២០១៥) ទំព័រ ៣

និយាយឱ្យខ្លី គ្មានការកំណត់ប្រភេទនៃសកម្មភាពល្មើសច្បាប់ដែលគួរមានការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម នោះទេ។ គោលការណ៍នេះគួរអនុវត្ត សូម្បីតែនៅពេលដែលជនរងគ្រោះបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងការជួញដូរពួកគេ ដូចជា ការផលិត ឬដាំដុះគ្រឿងញៀន ឬការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ឬអំពើភេរវកម្ម។ ឧទាហរណ៍ទាំងនេះ និងឧទាហរណ៍ផ្សេងទៀតនៃសកម្មភាពល្មើសច្បាប់ដែលគួរមានការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម អាចរកបានក្នុងឧបសម្ព័ន្ធ ៥។ ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម មិនមានន័យថាជាការផ្តល់អភ័យឯកសិទ្ធិដល់ជនរងគ្រោះឱ្យរួចផុតពីការដាក់ទោសទណ្ឌសម្រាប់បទល្មើសទាំងអស់ដែលពួកគេបានប្រព្រឹត្តនោះទេ ប៉ុន្តែផ្ទុយទៅវិញ គួរអនុវត្តគោលការណ៍នេះ ដើម្បីធ្វើការកំណត់អំពីការទទួលខុសត្រូវរបស់ពួកគេ។

### *ប្រអប់៖ ការការពារប្រឆាំងនឹងការប្រើប្រាស់ខុសនូវគោលការណ៍មិនដាក់ទណ្ឌកម្ម*

អ្នកជំនាញវិស័យយុត្តិធម៌ព្រហ្មទណ្ឌ និងអ្នកតាក់តែងគោលនយោបាយមួយចំនួន អាចបង្ហាញក្តីបារម្ភថា គោលការណ៍មិនដាក់ទណ្ឌកម្មអាចត្រូវបានប្រើប្រាស់ខុស ដើម្បីការពារជនរងគ្រោះពីការផ្តន្ទាទោសសម្រាប់បទល្មើសដែលមិនពាក់ព័ន្ធទាំងស្រុងនឹងការជួញដូរពួកគេ ឬត្រូវបានអនុវត្តខុស ដើម្បីការពារមនុស្សដែលមិនមែនជាជនរងគ្រោះដោយការជួញដូរមនុស្ស។

ច្បាប់ទាំងអស់អាចត្រូវបានប្រើប្រាស់ខុសដោយអ្នកប្រព្រឹត្តអំពើទុច្ចរិត និងអនុវត្តខុសដោយអ្នកអនុវត្តដែលខ្វះជំនាញ និងសមត្ថភាពក្នុងការអនុវត្តន៍ច្បាប់ឱ្យបានត្រឹមត្រូវ។ នៅក្នុងការអនុវត្តន៍ជាក់ស្តែង ការខកខានក្នុងការអនុវត្តន៍ "គោលការណ៍មិនដាក់ទណ្ឌកម្ម" (ដែលការពារជនរងគ្រោះដោយការជួញដូរពីការផ្តន្ទាទោសសម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តជាលទ្ធផលនៃការជួញដូរ) បង្កឲ្យមានហានិភ័យខ្ពស់ដល់ជនរងគ្រោះ ជាងការអនុវត្តន៍វាខុសដើម្បីការពារជនល្មើស។

គេអាចកាត់បន្ថយហានិភ័យដែលគោលការណ៍មិនដាក់ទណ្ឌកម្ម អាចត្រូវបានប្រើប្រាស់ខុសដោយឧក្រិដ្ឋជនដែលមានទោសធ្ងន់ ដើម្បីបញ្ចៀសការទទួលខុសត្រូវខាងព្រហ្មទណ្ឌ តាមរយៈការអនុវត្តន៍ច្បាប់ប្រកបដោយជំនាញ និងភាពស្មោះត្រង់តែប៉ុណ្ណោះ។ ដូច្នេះ រដ្ឋគួរបន្តកសាងសមត្ថភាពផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីអនុវត្តការសាកល្បងធាតុផ្សំទាំងបី (សកម្មភាព មធ្យោបាយ និងគោលបំណង) ឬការធ្វើតេស្តធាតុផ្សំពីរ (សកម្មភាព និងគោលបំណង) ក្នុងករណីដែលជនរងគ្រោះគឺជាកុមារ ដើម្បីកំណត់អត្តសញ្ញាណបុគ្គលម្នាក់ជាជនរងគ្រោះដោយការជួញដូរមនុស្ស និងដើម្បីបញ្ជាក់ ឬបដិសេធភាពទាក់ទងគ្នារវាងការប្រព្រឹត្តរបស់ជនរងគ្រោះ និងភាពជាជនរងគ្រោះរបស់គាត់។ វិធីសាស្ត្រនេះត្រូវផ្អែកតាមនិយមន័យនៃការជួញដូរមនុស្សដែលបានកំណត់ក្នុងពិធីសារស្តីពីការជួញដូរមនុស្ស និងអនុសញ្ញា ACTIP ដោយអនុលោមតាមប្រព័ន្ធផ្លូវច្បាប់ក្នុងដែនយុត្តាធិការពាក់ព័ន្ធ ព្រមទាំងកាតព្វកិច្ចសិទ្ធិមនុស្សថ្នាក់ជាតិ និងអន្តរជាតិ។

## ហេតុអ្វីបានជាគោលការណ៍មិនដាក់ទណ្ឌកម្ម មានសារៈសំខាន់?

ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម គឺជាផ្នែកដ៏សំខាន់នៃកាតព្វកិច្ចរបស់រដ្ឋ ក្នុងការកំណត់អត្តសញ្ញាណ ការពារ និងជួយដល់ជនរងគ្រោះដោយការជួញដូរមនុស្ស និងផ្តន្ទាទោសអ្នកជួញដូរមនុស្ស។ ការប្រកាន់ខ្ជាប់គោលការណ៍នីតិរដ្ឋក៏មានសារៈសំខាន់ផងដែរ ដើម្បីធានាថា ជនរងគ្រោះមិនត្រូវបានដាក់ទោសសម្រាប់អំពើដែលពួកគេនឹងមិនបានប្រព្រឹត្ត ប្រសិនបើពួកគេមិនក្លាយជាជនរងគ្រោះនោះទេ។ គោលការណ៍នេះជួយគាំទ្រដល់រដ្ឋក្នុងការការពារអ្នកដែលត្រូវការការការពារ និងផ្តន្ទាទោសអ្នកដែលគួរទទួលការផ្តន្ទាទោស។ ការអនុវត្តគោលការណ៍នេះ នាំឱ្យមានលទ្ធផលល្អបំផុតផ្នែកសិទ្ធិមនុស្ស និងយុត្តិធម៌ព្រហ្មទណ្ឌប្រសើរជាងមុន។

### ការការពារជនរងគ្រោះដោយការជួញដូរមនុស្ស

ក្រោមច្បាប់ស្តីពីការជួញដូរមនុស្ស និងច្បាប់សិទ្ធិមនុស្ស រដ្ឋមានកាតព្វកិច្ចការពារមនុស្សពីការជួញដូរ និងកំណត់អត្តសញ្ញាណ ការពារ និងជួយជនរងគ្រោះដោយការជួញដូរមនុស្ស។ ដូច្នេះ គោលការណ៍មិនដាក់ទណ្ឌកម្ម គឺជាផ្នែកចាំបាច់នៃកាតព្វកិច្ចការពាររបស់រដ្ឋ។

រដ្ឋត្រូវតែការពារជនរងគ្រោះពីការដាក់ទោសទណ្ឌ តាមរយៈប្រព័ន្ធរដ្ឋបាល ប្រព័ន្ធគ្រប់គ្រងអន្តោប្រវេសន៍ និងការងារ និងដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ គោលការណ៍មិនដាក់ទណ្ឌកម្ម មានគោលបំណងការពារជនរងគ្រោះពីការដាក់ទោសទណ្ឌ រួមទាំងតាមរយៈការដកហូតសេរីភាពក្នុងមន្ទីរអន្តោប្រវេសន៍ ឬទីតាំងផ្សេងទៀត ប្រាក់ពិន័យចំពោះការស្នាក់នៅលើសកាលកំណត់ ការហាមឃាត់មិនឱ្យចូលមកវិញ ការនិរទេស ឬការ បណ្តេញចេញ។ គោលការណ៍នេះក៏មានគោលបំណងការពារជនរងគ្រោះពីការប្រព្រឹត្តដាក់ ដែលមានន័យស្មើនឹងការដាក់ទោសទណ្ឌផងដែរ រួមទាំងការដាក់ក្នុងជម្រកសុវត្ថិភាពដែលផ្ទុយនឹងឆន្ទៈរបស់ពួកគេ ឬការផ្តល់សេវាដែលពួកគេមិនត្រូវការ ឬមិនចង់បាន។

គោលការណ៍មិនដាក់ទណ្ឌកម្ម ក៏ខិតខំការពារប្រឆាំងនឹងការដកហូតសញ្ជាតិ ឬភាពជាពលរដ្ឋ និងការដកចេញពីការការពារជនភៀសខ្លួនអន្តរជាតិផងដែរ រួមទាំងតាមរយៈការគោរពតាមគោលការណ៍ *មិនបញ្ជូនត្រឡប់ទៅវិញ*។ ក្នុងករណីដែលគោលការណ៍មិនដាក់ទណ្ឌកម្ម មិនត្រូវបានគោរពតាមប្រកបដោយប្រសិទ្ធភាពនៅក្នុងប្រទេសដើមរបស់ជនរងគ្រោះ ហានិភ័យដែលពួកគេនឹងប្រឈមនឹងគ្រោះថ្នាក់ដែលមិនអាចស្រោចស្រង់បាន ឬការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរផ្សេងទៀតនៅពេលត្រូវបានបញ្ជូនត្រឡប់ទៅវិញ រដ្ឋម្ចាស់ស្រុកមានកាតព្វកិច្ច *មិនបញ្ជូនត្រឡប់ទៅវិញ*។ ក្នុងករណីដែលការវិលត្រឡប់ដោយឈរលើគោលការណ៍ សិទ្ធិ មិនមែនជាជម្រើស ជនរងគ្រោះដោយការជួញដូរមនុស្ស គួរមានលទ្ធភាពទទួលបានស្ថានភាពផ្លូវច្បាប់ដែលមានសុវត្ថិភាព និងវិធានការបរិយាបន្នសង្គមរយៈពេលវែងសម្រាប់ជាជម្រើសឈរលើគោលការណ៍សិទ្ធិ ជំនួសឱ្យការវិលត្រឡប់មកវិញ។[11]

[12] កតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់, សេចក្តីសម្រេចដែលត្រូវបានអនុម័តដោយមហាសន្និបាតនៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៨, ឯកសារអង្គការសហប្រជាជាតិ A/RES/73/195, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៩, កថាខណ្ឌ ២៦(h) អំពាវនាវឱ្យរដ្ឋ "ផ្តល់ដល់ជនទេសន្តរប្រវេសក៍ដែលបានក្លាយជាជនរងគ្រោះដោយការជួញដូរមនុស្សនូវការការពារ និងជំនួយ ដូចជា វិធានការសម្រាប់ការស្តារឡើងវិញផ្នែកកាយសម្បទា ផ្លូវចិត្ត និងសង្គម ព្រមទាំងវិធានការដែល

គោលការណ៍នេះក៏ត្រូវអនុវត្ត ដើម្បីធានាថា ជនរងគ្រោះមិនត្រូវបានចាប់ខ្លួន និងកាត់ទោសខុសក្នុងនាមជាជនល្មើស និងតម្រូវឱ្យមានដំណោះស្រាយសម្រាប់ការរំលោភសិទ្ធិរបស់ពួកគេ រួមទាំងការឃុំខ្លួន ការបណ្ដេញចេញ ឬការផ្ដន្ទាទោសដោយមិនត្រឹមត្រូវ។

ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មចំពោះជនរងគ្រោះដោយការជួញដូរមនុស្ស ផ្ដល់ប្រយោជន៍ដល់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ប្រសិនបើពួកគេមិនត្រូវបានការពារពីការដាក់ទោសទណ្ឌទេនោះ ជនរងគ្រោះប្រហែលជាមិនគាំទ្រអាជ្ញាធរក្នុងការកំណត់អត្តសញ្ញាណពួកគេប្រកបដោយប្រសិទ្ធភាពឡើយ។ លើសពីនេះ ជនរងគ្រោះដែលត្រូវបានការពារពីការដាក់ទោសទណ្ឌ ច្រើនតែសហការជាមួយអាជ្ញាធរក្នុងការនាំខ្លួនអ្នកជួញដូរមនុស្ស និងឧក្រិដ្ឋជនដែលមានទោសធ្ងន់ផ្សេងទៀតមកកាត់ទោស។ មានហេតុផលជាច្រើនដែលជនរងគ្រោះអាចស្ទាក់ស្ទើរក្នុងការសហការជាមួយអ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌ ជាអាទិ៍៖

- ពួកគេប្រហែលជាមិនទុកចិត្តអាជ្ញាធរ ព្រោះពួកគេគិត (ខុស ឬត្រូវ) ថា អាជ្ញាធរសមគំនិតក្នុងសកម្មភាពរបស់អ្នកជួញដូរមនុស្ស។
- ពួកគេប្រហែលជាស្ទាក់ស្ទើរក្នុងការជួយអាជ្ញាធរស៊ើបអង្កេត និងកាត់ទោសអ្នកជួញដូរមនុស្ស ព្រោះការធ្វើដូច្នេះនឹងមានន័យថាជាការស្នាក់នៅយូរក្នុងជម្រកសុវត្ថិភាព និងការខកឱកាសធ្វើការ និងផ្គត់ផ្គង់គ្រួសាររបស់ពួកគេ។
- ពួកគេប្រហែលជាខ្លាចថា ការជួយអាជ្ញាធរនឹងបណ្ដាលឱ្យមានការសងសឹកពីអ្នកជួញដូរមនុស្ស។
- ពួកគេប្រហែលជាខ្លាចថាការសហការជាមួយអាជ្ញាធរនឹងនាំឱ្យមានការទោសទណ្ឌដល់ខ្លួនឯង ក្នុងករណីដែលព័ត៌មានដែលពួកគេចែករំលែក ធ្វើឱ្យពួកគេជាប់ពាក់ព័ន្ធក្នុងសកម្មភាពល្មើសច្បាប់។

ការជម្នះនូវឧបសគ្គទាំងនេះ និងឧបសគ្គផ្សេងទៀត បង្ហាញពីភាពចាំបាច់នៃការអនុវត្តន៍ការការពារអ្នកផ្ដល់ព័ត៌មាន ព្រមទាំងការការពារសាក្សី ស្របតាមកាតព្វកិច្ចក្នុងច្បាប់អន្តរជាតិ ច្បាប់តំបន់ និងច្បាប់ជាតិ សម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្សដែលអាចជាប់ពាក់ព័ន្ធក្នុងសកម្មភាពល្មើសច្បាប់។12 វាក៏បង្ហាញពីភាពចាំបាច់ក្នុងការអនុវត្តន៍អភិក្រមដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ដើម្បីការពារ និងជួយជនរងគ្រោះ ស្របតាមតម្រូវការ និងចំណង់ចំណូលចិត្តផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។ កង្វល់ទាំងនេះគូសបញ្ជាក់ពីសារៈសំខាន់នៃការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មដើម្បីការពារជនរងគ្រោះ ជំរុញកិច្ចសហការរបស់ពួកគេ និងនាំខ្លួនអ្នកជួញដូរមនុស្ស និងឧក្រិដ្ឋជនដែលមានទោសធ្ងន់ផ្សេងទៀតមកកាត់ទោស។

---

អនុញ្ញាតឱ្យពួកគេបន្តស្នាក់នៅក្នុងប្រទេសគោលដៅ ជាបណ្ដោះអាសន្ន ឬជាអចិន្ត្រៃយ៍ ក្នុងករណីសមស្រប ដើម្បីសម្រួលឱ្យជនរងគ្រោះទទួលបានយុត្តិធម៌ រួមទាំងការដោះស្រាយ និងសំណងជំងឺចិត្ត ដោយអនុលោមតាមច្បាប់អន្តរជាតិ"។

[13] សូមមើល *ដូចជា* មាត្រា ២៤ នៃ UNTOC ដែលទាក់ទងនឹងការការពារសាក្សី។

## ប្រអប់៖ ឧទាហរណ៍ (ការសុំទាន)

"ក" ដែលមានពិការភាពក្នុងការរៀនសូត្រ ត្រូវបានបញ្ជូនទៅទីក្រុងដោយញាតិសាច់ឆ្ងាយម្នាក់។ គេប្រាប់គ្រួសារ "ក" ថា "ក" នឹងទទួលបានការងារល្អនៅទីក្រុង និងមានពេលទៅរៀននៅសាលាអប់រំពិសេសដែលមានគ្រូដែលអាចជួយគាត់។ ផ្ទុយទៅវិញ"ក" ត្រូវបានបង្ខំឱ្យអង្គុយតាមផ្លូវសុំទានគេ។ ជាច្រើនខែកន្លងមកនេះគាត់មិនត្រូវបានអនុញ្ញាតឱ្យទាក់ទងទៅក្រុមគ្រួសាររបស់គាត់ទេចាប់តាំងពីគាត់មកនៅទីក្រុង។ ថ្ងៃមួយប៉ូលីសបានមកនាំគាត់ចេញហើយដាក់គាត់នៅកន្លែងមួយដែលគាត់មិនអាចចាកចេញបាន។ ពួកគេប្រាប់គាត់ថា នេះគឺដើម្បីការពារគាត់ ប៉ុន្តែគាត់គ្រាន់តែចង់ទៅផ្ទះជួបជុំគ្រួសារវិញប៉ុណ្ណោះ។

*<u>ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖</u>* បុគ្គលិកនៅជម្រកសុវត្ថិភាពសម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស ដែល "ក" ត្រូវបានដាក់នៅទីនោះ បានទទួលស្គាល់ថា គាត់មិនចង់ស្នាក់នៅក្នុងជម្រកសុវត្ថិភាពនេះទេ និងមិនយល់ថាហេតុអ្វីបានជាគាត់ស្នាក់នៅក្នុងជម្រកសុវត្ថិភាពនេះ។ ពួកគេបានពន្យល់គាត់ថា គាត់ត្រូវតែស្នាក់នៅក្នុងប្រទេសនេះសិន ព្រោះប៉ូលីសកំពុងស៊ើបអង្កេតមនុស្សដែលបាននាំគាត់មកប្រទេសនេះ និងបង្ខំគាត់ឱ្យសុំទានតាមផ្លូវ ហើយគាត់នឹងត្រូវប្រាប់តុលាការអំពីអ្វីដែលបានកើតឡើងចំពោះគាត់។ "ក" មានការព្រួយបារម្ភ និងនិយាយដដែលៗថា គាត់ចង់ត្រឡប់ទៅផ្ទះជួបជុំគ្រួសារវិញ។ បុគ្គលិកសង្គមកិច្ចដែលតំណាងឱ្យផលប្រយោជន៍របស់ "ក" បានទាក់ទងជាមួយអ្នកស៊ើបអង្កេត ដើម្បីរៀបចំឱ្យ "ក" ធ្វើសេចក្តីថ្លែងការណ៍មុនការជំនុំជម្រះ ដូច្នេះ គាត់មិនចាំបាច់ផ្តល់សក្ខីកម្មនៅក្នុងតុលាការទេ និងអាចវិលត្រឡប់ទៅផ្ទះរបស់គាត់ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## ការកាត់ទោសអ្នកជួញដូរមនុស្ស

ក្រោមច្បាប់អន្តរជាតិ រដ្ឋទាំងឡាយមានកាតព្វកិច្ចទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងកាត់ទោសជនបង្ក។ ប្រទេសដែលមានសមត្ថភាពទន់ខ្សោយក្នុងការប្រឆាំងការជួញដូរមនុស្ស ជាទីទាក់ទាញសម្រាប់ឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ព្រោះប្រទេសទាំងនោះផ្តល់លក្ខខណ្ឌអំណោយផលដល់ពួកគេក្នុងការធ្វើប្រតិបត្តិការដោយមិនភ័យខ្លាចការកាត់ទោស។ ជាញឹកញាប់ អ្នកជួញដូរមនុស្សធ្វើឱ្យជនរងគ្រោះរបស់ពួកគេងាយប្រឈមនឹងហានិភ័យនៃការដាក់ទោសទណ្ឌ តាមរយៈការបង្វែរការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ពួកគេទៅលើជនរងគ្រោះ សម្រាប់ជាយុទ្ធសាស្ត្រដោយចេតនាដើម្បីរំខានដល់កិច្ចខិតខំប្រឹងប្រែងរបស់អ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌ។ ដូច្នេះ ក្នុងករណីដែលរដ្ឋមិនអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ចំពោះជនរងគ្រោះដោយការជួញដូរមនុស្ស នេះជាសញ្ញាគ្រោះថ្នាក់ដែលមានន័យថា រដ្ឋកំពុងជួយអ្នកជួញដូរមនុស្សក្នុងការអនុវត្តសកម្មភាពឧក្រិដ្ឋរបស់ពួកគេ។ យុទ្ធសាស្ត្រសំខាន់មួយរបស់អ្នកជួញដូរមនុស្ស គឺការគំរាមកំហែងជនរងគ្រោះដោយប្រាប់ពួកគេថា អាជ្ញាធរនឹងចាប់ខ្លួន ឃុំខ្លួន និងបណ្តេញពួកគេចេញ ឬអាចនឹងកាត់ទោសពួកគេសម្រាប់សកម្មភាពដែលពួកគេបានជាប់ពាក់ព័ន្ធ។ នៅពេលដែលមន្ត្រីរដ្ឋធ្វើសកម្មភាពទាំងនេះ និងផ្តល់ប្រយោជន៍ដល់អ្នកជួញដូរមនុស្សដោយមិនដឹងខ្លួន អ្នកជួញដូរមនុស្សនឹងត្រូវបានបញ្ជាក់ថាត្រឹមត្រូវ និងមានការបង្វែរការយកចិត្តទុកដាក់របស់អាជ្ញាធរ ពីកិច្ចខិតខំប្រឹងប្រែងដើម្បីនាំខ្លួនអ្នកជួញដូរមនុស្សមកកាត់ទោស ទៅជាការដាក់ទោសជនរងគ្រោះវិញ។ មានន័យថា រដ្ឋដែលកាត់ទោស ឬដាក់ទោសជនរងគ្រោះដោយការជួញដូរមនុស្សតាមមធ្យោបាយផ្សេងទៀត មិនបានស៊ើបអង្កេត កាត់ទោស និងបង្អាក់សកម្មភាពជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាពឡើយ ផ្ទុយទៅវិញ ពួកគេកំពុងគាំទ្រអ្នកជួញដូរមនុស្ស និងឧក្រិដ្ឋជនផ្សេងទៀតឱ្យប្រព្រឹត្តបទឧក្រិដ្ឋរបស់ពួកគេ ដោយមិនជាប់ទោស។

រដ្ឋទាំងឡាយមានភារកិច្ចស៊ើបអង្កេតអំពីទំនាក់ទំនងរវាងជនរងគ្រោះដោយការជួញដូរមនុស្ស ដែលពួកគេជួបប្រទះ (ទោះនៅក្នុងឧស្សាហកម្មផ្លូវភេទ នៅលើទូកនេសាទដែលខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ (IUU) ឬនៅក្នុងបរិវេណទីតាំងឆបោក ឬរោងចក្រផលិតកញ្ឆាក៏ដោយ) និងអ្នកដែលកំពុងកេងប្រវ័ញ្ចពួកគេ។ ក្នុងករណីគ្មានការកំណត់ទំនាក់ទំនងទាំងនេះ មានន័យថា រដ្ឋទាំងឡាយមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការស៊ើបអង្កេត និងកាត់ទោសជនប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរឡើយ។

ជាញឹកញាប់ សក្ខីកម្មរបស់ជនរងគ្រោះគឺជាភស្តុតាងសំខាន់ក្នុងករណីប្រឆាំងនឹងអ្នកជួញដូរមនុស្ស ជាពិសេសនៅពេលដែលអាជ្ញាធរមិនបានស៊ើបអង្កេតករណីជួញដូរមនុស្សយ៉ាងសកម្ម។ នៅពេលដែលជនរងគ្រោះមិនត្រូវបានការពារពីការដាក់ទោសទណ្ឌ ពួកគេមិនអាចសហការជាមួយអាជ្ញាធរក្នុងកិច្ចខិតខំប្រឹងប្រែងស៊ើបអង្កេត និងកាត់ទោសអ្នកជួញដូរមនុស្សបានឡើយ។ ដូច្នេះ ការមិនអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មអាចនាំឱ្យខកឱកាសក្នុងការប្រែក្លាយជនរងគ្រោះទៅជាសាក្សីប្រឆាំងនឹងជនប្រព្រឹត្តអំពើជួញដូរមនុស្ស និងបទល្មើសធ្ងន់ធ្ងរផ្សេងទៀត។

## តើគោលការណ៍មិនដាក់ទណ្ឌកម្ម មានប្រភពមកពីណា?

### ច្បាប់អន្តរជាតិ

គោលការណ៍មិនដាក់ទណ្ឌកម្ម មិនមានចែងច្បាស់ក្នុងពិធីសារដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទោសករណីជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ពិធីសារស្តីពីការជួញដូរមនុស្ស) ឡើយ។ ទោះយ៉ាងណាក៏ដោយ ប្រការលើកលែងក្រោមមាត្រា ១៤ នៃពិធីសារដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទោសករណីជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ពិធីសារស្តីពីការជួញដូរមនុស្ស) លើកទឹកចិត្តឱ្យរដ្ឋអនុវត្តពិធីសារនេះដោយអនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ពួកគេ ខណៈដែលមាត្រា ២៥ នៃ UNTOC តម្រូវឱ្យរដ្ឋភាគីការពារសិទ្ធិរបស់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម ដែលមានអង្គការចាត់តាំង។ មានការទទួលស្គាល់កាន់តែច្រើនឡើងក្នុងយុត្តិសាស្ត្រអន្តរជាតិ និងលិខិតុបករណ៍ច្បាប់ដែលមិនចងកាតព្វកិច្ចថា គោលការណ៍មិនដាក់ទណ្ឌកម្ម គឺជាវិធីសាស្ត្រអនុវត្តន៍ល្អបំផុតសម្រាប់ការអនុវត្តន៍លិខិតុបករណ៍ទាំងនោះប្រកបដោយប្រសិទ្ធភាព ដោយឈរលើគោលការណ៍សិទ្ធិមនុស្ស និងយកចិត្តទុកដាក់ចំពោះជនរងគ្រោះ។

គោលការណ៍មិនដាក់ទណ្ឌកម្ម ត្រូវបានបង្ហាញយ៉ាងច្បាស់ក្នុងមាត្រា ៤(២) ក្រោមពិធីសារ ឆ្នាំ ២០១៤ នៃអនុសញ្ញាលេខ ២៩ ស្តីពីការងារដោយបង្ខំ។

> យោងតាមគោលការណ៍មូលដ្ឋាននៃប្រព័ន្ធច្បាប់របស់ខ្លួន សមាជិកនីមួយៗត្រូវ ចាត់វិធានការចាំបាច់ដើម្បីធានាថា អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិមិនកាត់ទោស ឬដាក់ទណ្ឌកម្មលើជនរងគ្រោះនៃការងារដោយបង្ខំ សម្រាប់ការចូលរួមរបស់ពួកគេក្នុងសកម្មភាពល្មើសច្បាប់ ដែលពួកគេត្រូវបានបង្ខំឱ្យប្រព្រឹត្តដោយសារការជាប់ទាក់ទងដោយផ្ទាល់ទៅនឹងការងារដោយបង្ខំ។

ការងារ ឬសេវាដោយបង្ខំ ដូចមានចែងក្នុងអនុសញ្ញា ILO លេខ ២៩ អាចរួមបញ្ចូលការធ្វើការងារ ឬការផ្តល់សេវាក្នុងវិស័យដែលមិនមានការគ្រប់គ្រង ឬខុសច្បាប់ផងដែរ។ ដូច្នេះការអនុវត្តន៍ការមិនដាក់ទណ្ឌ កម្មលើការងារដោយបង្ខំ នឹងការងារដែលមានភាពពាក់ព័ន្ធ ជាពិសេសចំពោះការអនុវត្តន៍ចំណាត់ការរបស់រដ្ឋលើករណីជួញដូរមនុស្សដោយបង្ខំឱ្យប្រព្រឹត្តបទល្មើស ដូចគ្នានឹងករណីជួញដូរមនុស្សដោយបង្ខំឱ្យធ្វើការនៅក្នុងច្បាប់ជាតិរបស់ខ្លួន។

លិខិតុបករណ៍អន្តរជាតិជាច្រើនផ្សេងទៀត បានពង្រឹងគោលការណ៍មិនដាក់ទណ្ឌកម្ម រួមទាំង *គោលការណ៍ និងគោលការណ៍ណែនាំជាអនុសាសន៍ស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។*

> ជនរងគ្រោះដោយការជួញដូរមនុស្ស មិនត្រូវបានឃុំខ្លួន ចោទប្រកាន់ ឬកាត់ទោសសម្រាប់ភាពល្មើសច្បាប់នៃការចូល ឬស្នាក់នៅរបស់ពួកគេក្នុងប្រទេសឆ្លងកាត់ និងប្រទេសគោលដៅ ឬសម្រាប់ការចូលរួមរបស់ពួកគេក្នុងសកម្មភាពល្មើសច្បាប់ ក្នុងកម្រិតដែលការចូលរួមបែបនេះ ជាប់ទាក់ទងដោយផ្ទាល់ទៅនឹង ស្ថានភាពរបស់ពួកគេក្នុងនាមជាជនរងគ្រោះដោយការជួញដូរមនុស្ស។

គោលការណ៍ណែនាំ ៤(៥) បញ្ជាក់ថា រដ្ឋគួរពិចារណា៖

ជានាថា ច្បាប់ការពារជនរងគ្រោះដោយការជួញដូរមនុស្សពីការកាត់ទោស ការឃុំខ្លួន ឬការដាក់ទោសទណ្ឌ សម្រាប់ភាពល្មើសច្បាប់នៃការចូល ឬស្នាក់នៅរបស់ពួកគេ ឬសម្រាប់សកម្មភាពពាក់ព័ន្ធរបស់ពួកគេ ដែលបណ្តាលមកពីស្ថានភាពរបស់ពួកគេក្នុងនាមជាជនរងគ្រោះដោយការជួញដូរមនុស្ស។

ទាក់ទងនឹងកុមារ គោលការណ៍ណែនាំ ៨(៣) បញ្ជាក់ថា រដ្ឋ និងក្នុងករណីអាចអនុវត្តទៅបាន អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល គួរពិចារណា៖

ជានាថា កុមារដែលជាជនរងគ្រោះដោយការជួញដូរមនុស្ស មិនត្រូវបានដាក់ឱ្យស្ថិតក្រោមនីតិវិធី ឬទណ្ឌកម្មព្រហ្មទណ្ឌ សម្រាប់បទល្មើសដែលទាក់ទងនឹងស្ថានភាពរបស់ពួកគេក្នុងនាមជាជនរងគ្រោះដោយការជួញដូរមនុស្ស។

គោលការណ៍មិនដាក់ទណ្ឌកម្មត្រូវបានពង្រឹងបន្ថែមទៀត ក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស[14] និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ដែលអំពាវនាវឱ្យរដ្ឋទាំងឡាយមិនដាក់ទោសទណ្ឌជនរងគ្រោះដោយការជួញដូរមនុស្ស។[15] លិខិតុបករណ៍ទាំងនេះ និងលិខិតុបករណ៍ពាក់ព័ន្ធផ្សេងទៀតសុទ្ធតែមានលើកឡើងក្នុងគោលការណ៍ណែនាំនេះ និងអាចរកបានក្នុងឧបសម្ព័ន្ធ ៤។

## ច្បាប់ក្នុងតំបន់

ACTIP គឺជាលិខិតុបករណ៍ជឿនលឿនដែលបង្ហាញយ៉ាងច្បាស់អំពីគោលការណ៍មិនដាក់ទណ្ឌកម្មនៅមាត្រា ១៤(៧)។

អនុលោមតាមច្បាប់ គោលការណ៍ និងគោលនយោបាយជាតិ និងក្នុងករណីសមស្រប ភាគីនីមួយៗត្រូវពិចារណាចាត់ទុកជនរងគ្រោះដោយការជួញដូរមនុស្សថា មិនពាក់ព័ន្ធនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ឬខាងរដ្ឋបាលឡើយ ចំពោះសកម្មភាពល្មើសច្បាប់ដែលពួកគេបានប្រព្រឹត្ត ប្រសិនបើសកម្មភាពបែបនោះជាប់ទាក់ទងដោយផ្ទាល់ទៅនឹងសកម្មភាពនៃការជួញដូរមនុស្ស។

បទបញ្ញត្តិនេះបញ្ជាក់យ៉ាងច្បាស់ថា តាមរយៈភាពបត់បែនខ្លះៗក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន រដ្ឋសមាជិកអាស៊ានគួរពិចារណាអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម។ រដ្ឋសមាជិកអាស៊ានទាំងអស់ សុទ្ធសឹងជាភាគីនៃអនុសញ្ញា ACTIP មានន័យថា រដ្ឋសមាជិកទាំងអស់ត្រូវបានចងកាតព្វកិច្ចផ្លូវច្បាប់ដោយមាត្រា ១៤(៧)។

---

[14] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ, Maria Grazia Giammarinaro, ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០២០, ឯកសារអង្គការសហប្រជាជាតិ A/HRC/44/45, កថាខណ្ឌ ៣៦។ ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ, Siobhán Mullaly, ឯកសារអង្គការសហប្រជាជាតិ. A/HRC/47/34 (ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០២១)។

[15] សេចក្តីសម្រេចលេខ ២៣៣១ (២០១៦) របស់ក្រុមប្រឹក្សាសន្តិសុខ។ សេចក្តីសម្រេចលេខ ២៣៨៨ (២០១៧) របស់ក្រុមប្រឹក្សាសន្តិសុខ។

ដប់ឆ្នាំមុនការអនុម័តអនុសញ្ញាអាស៊ាននេះ មាត្រា ២៦ នៃអនុសញ្ញាក្រុមប្រឹក្សាអឺរ៉ុបស្តីពីសកម្មភាពប្រឆាំងនឹងការជួញដូរមនុស្ស ឆ្នាំ ២០០៥ (កម្រងសន្ធិសញ្ញាក្រុមប្រឹក្សាអឺរ៉ុបលេខ ១៩៧) បានបង្ហាញគោលការណ៍មិនដាក់ទណ្ឌកម្មដូចខាងក្រោម៖

> យោងតាមគោលការណ៍មូលដ្ឋាននៃប្រព័ន្ធច្បាប់របស់ខ្លួន ភាគីនីមួយៗត្រូវផ្តល់លទ្ធភាពនៃការមិនដាក់ទណ្ឌកម្មលើជនរងគ្រោះ សម្រាប់ការចូលរួមរបស់ពួកគេក្នុងសកម្មភាពល្មើសច្បាប់ ក្នុងកម្រិតដែលពួកគេត្រូវបានបង្ខំឱ្យធ្វើដូច្នោះ។

ខណៈដែលរដ្ឋសមាជិកអាស៊ានមិនត្រូវបានចងកាតព្វកិច្ចដោយអនុសញ្ញារបស់ក្រុមប្រឹក្សាអឺរ៉ុប ពួកគេអាចរៀនសូត្រពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋផ្សេងទៀត ដើម្បីប្រតិបត្តិគោលការណ៍មិនដាក់ទណ្ឌកម្មក្នុងការអនុវត្តន៍ជាក់ស្តែង និងក្នុងការណែនាំដែលមាន ដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ។

## ច្បាប់ជាតិ

ប្រទេសភាគច្រើននៅអាស៊ាន មានបទបញ្ញត្តិជាក់លាក់ស្តីពីការមិនដាក់ទណ្ឌកម្មនៅក្នុងច្បាប់ជាតិរបស់ខ្លួន (សូមមើលឧបសម្ព័ន្ធ ១) លើកលែងតែកម្ពុជា និងសិង្ហបុរី។ វៀតណាមបានធ្វើវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្សរបស់ខ្លួន នៅខែវិច្ឆិកា ឆ្នាំ ២០២៤ ដើម្បីបញ្ចូលបទបញ្ញត្តិស្តីពីការមិនដាក់ទណ្ឌកម្ម។ ច្បាប់នោះនឹងចូលជាធរមាននៅថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០២៥។

បទបញ្ញត្តិក្នុងច្បាប់ជាតិស្តីពីការមិនដាក់ទណ្ឌកម្ម ប្រើប្រាស់វិធីសាស្ត្រខុសៗគ្នាដើម្បីកំណត់ទំនាក់ទំនងរវាងការប្រព្រឹត្តល្មើសច្បាប់របស់ជនរងគ្រោះ និងការណ៍ដែលគាត់ត្រូវបានគេជួញដូរ។

- ប្រទេសមួយ (ឥណ្ឌូនេស៊ី) មានលក្ខខណ្ឌថា ជនរងគ្រោះត្រូវបានបង្ខំឱ្យចូលរួមក្នុងសកម្មភាពល្មើសច្បាប់ ដើម្បីអាចអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មបាន។
- ប្រទេសផ្សេងទៀត (ប្រ៊ុយណេដារូសាឡឹម ឡាវ ម៉ាឡេស៊ី និងវៀតណាម) មានលក្ខខណ្ឌថា អំពើល្មើសច្បាប់ដែលជនរងគ្រោះបានប្រព្រឹត្ត ដែលទាក់ទងដោយផ្ទាល់ទៅនឹងសកម្មភាពនៃការជួញដូរមនុស្ស។ ច្បាប់ឆ្នាំ ២០០៥ នៅមីយ៉ាន់ម៉ា មានលក្ខខណ្ឌថា សកម្មភាពល្មើសច្បាប់ត្រូវតែជា 'ផលវិបាកដោយផ្ទាល់' នៃការជួញដូរមនុស្ស ប៉ុន្តែច្បាប់ឆ្នាំ ២០២២ ដែលលុបចោលច្បាប់មុននោះមិនបានបញ្ជាក់ច្បាស់អំពីទំនាក់ទំនងដែលត្រូវការចាំបាច់នោះទេ។
- ច្បាប់ប្រទេសហ្វីលីពីន ចែងថាអំពើល្មើសច្បាប់គឺជាអំពើទាំងឡាយណាដែលប្រព្រឹត្តឡើងជាលទ្ធផលដោយផ្ទាល់ ឬជាឧប្បត្តិហេតុ ឬទាក់ទងនឹងការជួញដូរមនុស្ស ឬក្រោមការស្តាប់បង្គាប់បញ្ជារបស់អ្នកជួញដូរមនុស្ស ទាក់ទងនឹងបញ្ជានោះ។
- បទបញ្ញត្តិមួយចំនួនកំណត់វិសាលភាពនៃការការពារសម្រាប់បទល្មើសជាក់លាក់ គឺបទល្មើសពាក់ព័ន្ធនឹងអន្តោប្រវេសន៍ និងឯកសារ (ប្រ៊ុយណេដារូសាឡឹម ម៉ាឡេស៊ី) អន្តោប្រវេសន៍ខុសច្បាប់ និងពេស្យាចារ (ឡាវ) និងការជួញដូរមនុស្ស ការចូល ការចេញ ការស្នាក់នៅ និងការងារខុសច្បាប់ ក៏ដូចជាបទល្មើសទាក់ទងនឹងឯកសារ (មីយ៉ាន់ម៉ា)។ ក្នុងប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន ការការពារពីការដាក់ទោសទណ្ឌ មិនត្រូវបានកំណត់ត្រឹមបទល្មើសជាក់លាក់នោះទេ។
- ប្រទេសថៃតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្ស សម្រាប់បទល្មើសដែលពាក់ព័ន្ធនឹងអន្តោប្រវេសន៍ ពេស្យាចារ ឯកសារ ឬការងារ។[16] ស្រដៀងគ្នានេះដែរច្បាប់ឆ្នាំ២០២២ របស់មីយ៉ាន់ម៉ា តម្រូវឱ្យមានការអនុញ្ញាតពីស្ថាប័នសួល ដើម្បីចាត់វិធានការប្រឆាំងនឹងជនរងគ្រោះដោយការជួញដូរមនុស្ស។

បទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌ ដែលមានចែងក្នុងច្បាប់ជាតិរបស់រដ្ឋសមាជិកអាស៊ាន មានបង្ហាញក្នុងឧបសម្ព័ន្ធ ១។

[16] ផ្នែកទី ៤១ នៃ *ច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្ស* B.E. ២៥៥១ (២០០៨), វិសោធនកម្មក្នុងឆ្នាំ ២០១៥ (BE ២៥៥៨) និង ២០១៧ (BE ២៥៦០)។ ការសិក្សារបស់កម្មវិធី ASEAN-ACT ក្នុងឆ្នាំ ២០២២ បានរកឃើញថា មិនមានការស្នើសុំជាលាយលក្ខណ៍អក្សរនោះទេ។

វាគឺជាការអនុវត្តន៍ល្អក្នុងការអនុម័តបទបញ្ញត្តិច្បាប់ច្បាស់លាស់ ដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មក្នុងច្បាប់ជាតិ។[17] ទោះយ៉ាងណា នៅពេលដែលរដ្ឋខ្លះច្បាប់ជាតិដែលបង្ហាញច្បាស់ពីគោលការណ៍មិនដាក់ទណ្ឌកម្ម ឬនៅពេលដែលច្បាប់ជាតិរបស់រដ្ឋមិនអនុវត្តចំពោះស្ថានភាពជាក់លាក់របស់ជនរងគ្រោះ នៅតែអាចមានឱកាសផ្សេងទៀតនៅក្នុងច្បាប់ដើម្បីការពារជនរងគ្រោះពីការដាក់ទោសទណ្ឌ រួមទាំងដោយការផ្តល់ការការពារទូទៅ ដូចជា ការបង្ខិតបង្ខំ ដែលអាចត្រូវបានកំណត់ក្នុងច្បាប់ជាតិ។ អ្នកអនុវត្តការងារក៏អាចអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ដោយយោងទៅតាមកាតព្វកិច្ចថ្នាក់តំបន់ និងអន្តរជាតិរបស់ខ្លួនក្រោម UNTOC និងពិធីសារស្តីពីការជួញដូរមនុស្ស និងអនុសញ្ញា ACTIP បានផងដែរ។

## តើគួរអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មនៅពេលណា?

ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម មិនគួរអាស្រ័យលើការកំណត់ជាផ្លូវការថា បុគ្គលម្នាក់គឺជាជនរងគ្រោះដោយការជួញដូរមនុស្សនោះទេ។ ឱកាសក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម គឺចាប់ពីពេលដែលអាជ្ញាធរជួបជាមួយអ្នកដែលត្រូវបានសន្មតជាជនរងគ្រោះដោយការជួញដូរមនុស្សជាលើកដំបូង និងក្នុងការចូលរួមរបស់ពួកគេជាមួយដំណើរការយុត្តិធម៌ព្រហ្មទណ្ឌទាំងមូល ទាំងក្នុងនាមជាជនរងគ្រោះ ឬក្នុងករណីខ្លះ ក្នុងនាមជាជនល្មើស។

### ការពិនិត្យបឋម និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស (ផ្នែកទី ២)

ល្អបំផុត ជនរងគ្រោះគួរត្រូវបានកំណត់អត្តសញ្ញាណ នៅពេលដែលអាជ្ញាធរមានការសង្ស័យដែលអាចជឿបានថាបុគ្គលម្នាក់អាចជាជនរងគ្រោះដោយការជួញដូរមនុស្ស មុនការដាក់ទោសទណ្ឌណាមួយ។ ប្រសិនបើជនរងគ្រោះដោយការជួញដូរមនុស្ស មិនត្រូវបានកំណត់អត្តសញ្ញាណភ្លាមៗទេ គេនឹងមានការពិបាកក្នុងការបង្វែរពួកគេទៅក្នុងបណ្តាញការពារវិញ។ ទោះយ៉ាងណា នៅគ្រប់ចំណុចដែលអាជ្ញាធរជួបជនរងគ្រោះដោយការជួញដូរមនុស្ស សុទ្ធតែជាឱកាសដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម។

ដូចដែលបានលើកឡើងខាងលើ ជនរងគ្រោះ និងជនល្មើស មិនមែនជាទស្សនៈទានទ្វេភាគនោះទេ។ បុគ្គលម្នាក់ប្រហែលជាត្រូវការការការពារពីការដាក់ទោសទណ្ឌសម្រាប់សកម្មភាពល្មើសច្បាប់មួយចំនួន ប៉ុន្តែមិនមែនសម្រាប់សកម្មភាពល្មើសច្បាប់ផ្សេងទៀតឡើយ។ អ្នកអនុវត្តអាចមានការលំបាកក្នុងការកំណត់ថាតើសកម្មភាពល្មើសច្បាប់ណាមួយរបស់ជនរងគ្រោះ ទាក់ទងនឹងសកម្មភាពនៃការជួញដូរពួកគេ និងថាតើសកម្មភាពល្មើសច្បាប់ណាមួយ មិនទាក់ទងនឹងសកម្មភាពនៃការជួញដូរពួកគេ ដែលអាចមានភាពសមស្របក្នុងការចាត់ទុកជនរងគ្រោះជាជនល្មើស។ ការកំណត់អត្តសញ្ញាណរបស់ពួកគេប្រកបដោយប្រសិទ្ធភាពពីដំបូង ថាជាជនរងគ្រោះដោយការជួញដូរមនុស្ស គឺជាកត្តាសំខាន់ក្នុងការកំណត់បែបនេះ។

មន្ត្រីការងារ មន្ត្រីអន្តោប្រវេសន៍ និងមន្ត្រីផ្សេងទៀតដែលជួបជាមួយអ្នកដែលអាចជាជនរងគ្រោះដោយសារការជួញដូរមនុស្សជាលើកដំបូង ដែលពាក់ព័ន្ធក្នុងសកម្មភាពល្មើសច្បាប់ អាចធ្វើការពិនិត្យបឋម និងកំណត់អត្តសញ្ញាណពួកគេថា

---

17 *ការណែនាំស្តីពីការឆ្លើយតបសមស្របផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ទៅនឹងជនរងគ្រោះដែលត្រូវបានបង្ខំឱ្យប្រព្រឹត្តបទល្មើសដោយសារគាត់ត្រូវបានគេជួញដូរ៖ ឯកសារសោតែរដែលរៀបចំឡើងដោយលេខាធិការដ្ឋានក្រុមការងារស្តីពីការជួញដូរមនុស្ស,* វីយែន ថ្ងៃទី ១០ និង ១១ ខែ កញ្ញា ឆ្នាំ ២០២០, ឯកសារអង្គការសហប្រជាជាតិ. *CTOC/COP/WG.4/2020/2* (ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ ), កថាខណ្ឌ ៤១។

ជាអ្នកដែលអាចជាជនរងគ្រោះ ប្រកបដោយប្រសិទ្ធភាព និងបង្វែរពួកគេចេញពីដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ទៅកាន់បណ្ដាញការពារ។

ឧទាហរណ៍ អធិការការងារប្រហែលជាកំពុងស៊ើបអង្កេតលើការប្រើប្រាស់កម្លាំងពលកម្ម ហើយបានជួបមនុស្សដែលពួកគេសង្ស័យថាអាចត្រូវបានគេជួញដូរឱ្យបំពេញប្រភេទការងារជាក់លាក់។ មន្ត្រីអន្តោប្រវេសន៍ដែលកំពុងស៊ើបអង្កេតការធ្វើចំណាកស្រុកខុសច្បាប់ អាចជួបមនុស្សដែលត្រូវបានគេជួញដូរ។ មន្ត្រីនគរបាលអាចកំពុងស៊ើបអង្កេតបទល្មើសធ្ងន់ធ្ងរដូចជា ការផលិត ឬជាំជុះគ្រឿងញៀន ការរត់ពន្ធទំនិញ ឬបទល្មើសតាមអ៊ីនធឺណិត ដូចជា ការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ហើយប្រទះស្ថានភាពមនុស្សដែលត្រូវបានគេជួញដូរឱ្យធ្លាក់ចូលទៅក្នុងស្ថានភាពទាំងនេះ។ ក្នុងស្ថានភាពទាំងអស់នេះ ពេលដែលអាជ្ញាធរកំណត់អត្តសញ្ញាណត្រឹមត្រូវលើជនរងគ្រោះដែលពួកគេជួប ពួកគេអាចដោះលែងជនរងគ្រោះភ្លាមៗពីការឃុំខ្លួនមុនពេលជំនុំជម្រះ ឬការឃុំខ្លួនពីបទអន្តោប្រវេសន៍ខុសច្បាប់ រួចបង្វែរពួកគេទៅបណ្ដាញការពារ។

អ្នកជំនាញសុខាភិបាល និងអ្នកផ្ដល់សេវាផ្សេងទៀត ក៏មានតួនាទីជានាការប្រកាន់ខ្ជាប់គោលការណ៍មិនដាក់ទណ្ឌកម្មផងដែរ។ ប្រសិនបើពួកគេអាចកត់សម្គាល់ជនរងគ្រោះដោយការជួញដូរមនុស្សក្នុងចំណោមមនុស្សដែលពួកគេប្រាស្រ័យទាក់ទង ពួកគេអាចជួយដល់មន្ត្រីការងារ មន្ត្រីអន្តោប្រវេសន៍ និងមន្ត្រីផ្សេងទៀតឱ្យទទួលស្គាល់ស្ថានភាពជាជនរងគ្រោះរបស់បុគ្គល និងអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មប្រកបដោយប្រសិទ្ធភាព។

មន្ត្រីជួរមុខនិងអ្នកផ្សេងទៀតដែលប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះដោយសារការជួញដូរមនុស្ស ត្រូវតែអាចកត់សម្គាល់មនុស្សគ្រប់ប្រភេទដែលអាចជាជនរងគ្រោះ។ នេះរួមបញ្ចូលជនរងគ្រោះដែលអាចងាយរងគ្រោះខ្លាំង ដោយសារពួកគេជាជនភៀសខ្លួន ជនគេចចេញពីជម្លោះ ក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា (LGBTQI+) ជនមានពិការភាព ជនចំណាកស្រុកដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ និងអ្នកផ្សេងទៀតដែលអាចមានតម្រូវការការពារពិសេស។[18] មនុស្សដែលចម្រូងចម្រាស់ជាមួយច្បាប់ រួមទាំងយុវជន ងាយមិនទទួលបានការបំពេញតម្រូវការការពារ និងតម្រូវការជំនួយដែលពួកគេត្រូវការ។ ដូច្នេះ មន្ត្រីត្រូវជម្នះឧបសគ្គមួយចំនួន រួមទាំងភាពលំអៀងដោយអចេតនារបស់ពួកគេ ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព និងការពារពួកគេពីការដាក់ទោសទណ្ឌ។

បញ្ហាកំណត់អត្តសញ្ញាណទាំងនេះ និងបញ្ហាផ្សេងទៀត ត្រូវបានលើកមកពិភាក្សាក្នុងផ្នែកទី ២ ខាងក្រោម។

**នៅពេលជនរងគ្រោះកំពុងប្រឈមនឹងការជំនុំជម្រះ (ផ្នែកទី ៤)**

នៅពេលមន្ត្រីជួរមុខបរាជ័យក្នុងការបំពេញកាតព្វកិច្ចអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ដើម្បីបង្វែរជនរងគ្រោះទៅកាន់បណ្ដាញការពារ ជនរងគ្រោះអាចត្រូវបាននិរទេស ដែលផ្ទុយនឹងគោលការណ៍មិនដាក់ទណ្ឌកម្ម។ នៅពេលជនរងគ្រោះត្រូវបានចាប់ខ្លួន និងរងការចោទប្រកាន់ អ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌគឺជាខ្សែការពារបន្ទាប់ប្រឆាំងនឹងការដាក់ទោសទណ្ឌខុសឆ្គងបន្ថែមទៀតលើជនរងគ្រោះ។

---

[18] សូមមើល *ដូចជា* កតិកាសញ្ញាពិភពលោកស្ដីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់, UN Doc A/RES/73/195, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៩, គោលដៅទី ៧ ៖ ដោះស្រាយ និងកាត់បន្ថយភាពងាយរងគ្រោះក្នុងការធ្វើទេសន្តរប្រវេសន៍។

នៅពេលព្រះរាជអាជ្ញាមានមូលដ្ឋានសមហេតុផលក្នុងការសង្ស័យថា បុគ្គលដែលពួកគេកំពុងចោទប្រកាន់ គឺជាជនរងគ្រោះដោយការជួញដូរមនុស្ស ពួកគេគួរអនុវត្តធន្ទានុសិទ្ធិមិនធ្វើការចោទប្រកាន់ ឬស្នើឱ្យបញ្ឈប់នីតិវិធី។

នៅពេលដែលនៅតែមាននីតិវិធីប្រឆាំងនឹងជនរងគ្រោះដោយការជួញដូរមនុស្ស មេធាវីការពារក្តីដែលតំណាងជនរងគ្រោះដោយការជួញដូរមនុស្ស ត្រូវអនុវត្តវិធានការការពារ ដើម្បីការពារជនរងគ្រោះពីការផ្តន្ទាទោស។ អ្នកអនុវត្តក៏អាចពិចារណាឱកាសផ្សេងទៀតដែលអាចស្តែងចេញពីស្ថានភាពជាជនរងគ្រោះដោយការជួញដូរមនុស្សរបស់បុគ្គល ដើម្បីការពារពួកគេពីការដាក់ទោសទណ្ឌ។

មន្ត្រីតុលាការមានឱកាសបន្ថែមទៀត ដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មនៅក្នុងតុលាការ។ អាស្រ័យលើកាលៈទេសៈនៃករណី តុលាការអាចបញ្ឈប់នីតិវិធីប្រឆាំងនឹងជនរងគ្រោះ ឬប្រសិនបើពួកគេជ្រើសរើសបន្តនីតិវិធី ពួកគេអាចសម្រេចមិនផ្តន្ទាទោសជនរងគ្រោះ ឬសម្រាលទោសដែលបានដាក់ ប្រសិនបើជនរងគ្រោះត្រូវបានផ្តន្ទាទោស។

**នៅពេលជនរងគ្រោះត្រូវបានផ្តន្ទាទោស (ផ្នែកទី ៥)**

សម្រាប់ជាជម្រើសចុងក្រោយ នៅពេលជនរងគ្រោះត្រូវបានផ្តន្ទាទោសដោយមិនត្រឹមត្រូវ ផ្ទុយនឹងគោលការណ៍មិនដាក់ទណ្ឌកម្ម រដ្ឋអាចរិះរកឱកាសដើម្បីធ្វើមោឃភាព ឬលុបការផ្តន្ទាទោស និងផ្តល់ឱ្យជនរងគ្រោះនូវដំណោះស្រាយសម្រាប់ការដាក់ទោសទណ្ឌខុស។

| ឱកាសអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម | |
|---|---|
| នៅពេលមន្ត្រីជួរមុខបានជួបជនរងគ្រោះដោយការជួញដូរមនុស្ស | • មន្ត្រីជួរមុខ ប្រើប្រាស់ការសន្និដ្ឋានជាមុន ចំពោះស្ថានភាពជាជនរងគ្រោះ ស្របតាមគោលនយោបាយកំណត់អត្តសញ្ញាណរបស់ខ្លួន ក្នុងការកំណត់អត្តសញ្ញាណបឋមរកភាពរងគ្រោះដោយអំពើជួញដូរមនុស្ស<br>• មន្ត្រីជួរមុខ បង្វែរអ្នកដែលត្រូវបានសន្និដ្ឋានថាជាជនរងគ្រោះដោយការជួញដូរមនុស្ស ចេញពីដំណើរការអន្តោប្រវេសន៍ និង/ឬដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ទៅកាន់បណ្តាញការពារ<br>• អ្នកអនុវត្តច្បាប់ប្រើធន្ទានុសិទ្ធិ មិនចាប់ខ្លួន ឬចោទប្រកាន់ជនរងគ្រោះដោយការជួញដូរមនុស្សសម្រាប់ការពាក់ព័ន្ធរបស់ពួកគេ ក្នុងសកម្មភាពល្មើសច្បាប់។ |
| នៅពេលជនរងគ្រោះដោយការជួញដូរមនុស្សប្រឈមនឹងការឃុំខ្លួន ការបញ្ជូនត្រឡប់ ឬទណ្ឌកម្មអន្តោប្រវេសន៍ផ្សេងទៀត ដែលផ្ទុយនឹងគោលការណ៍មិនដាក់ទណ្ឌកម្ម | • មន្ត្រីអន្តោប្រវេសន៍ដែលទទួលស្គាល់ថា បុគ្គលដែលកំពុងជាប់ឃុំ គឺជាអ្នកដែលត្រូវបានសន្និដ្ឋានថាជាជនរងគ្រោះដោយការជួញដូរមនុស្ស ដោះលែងពួកគេពីមន្ទីរអន្តោប្រវេសន៍ និងបញ្ជូនពួកគេទៅបណ្តាញការពារ<br>• ការផ្តល់ទិដ្ឋាការការពារ ដល់ជនរងគ្រោះជាជនបរទេសដែលមានវត្តមានខុសច្បាប់ក្នុងប្រទេស ដើម្បីអនុញ្ញាតឱ្យពួកគេបន្តស្នាក់នៅជាបណ្តោះអាសន្ន។ |

| | |
|---|---|
| នៅពេលជនរងគ្រោះដោយការជួញដូរមនុស្សត្រូវបានដាក់ក្នុងការជំនុំជម្រះសម្រាប់សកម្មភាពល្មើសច្បាប់ដែលកើតចេញពីការណ៍ដែលពួកគេត្រូវបានជួញដូរ | • ព្រះរាជអាជ្ញា ប្រើធន្ទានុសិទ្ធិមិនធ្វើការចោទប្រកាន់ជនរងគ្រោះ ឬស្នើឱ្យបញ្ឈប់នីតិវិធី<br>• មេធាវីការពារក្ដីអនុវត្តវិធានការការពារ ដែលមានចែងក្នុងច្បាប់ជាតិ ដើម្បីការពារជនរងគ្រោះដែលកំពុងស្ថិតក្រោមការជំនុំជម្រះទោសសម្រាប់អំពើល្មើសច្បាប់ដែលពួកគេបានប្រព្រឹត្ត ក្នុងបរិបទនៃសកម្មភាពជួញដូរពួកគេ<br>• តុលាការមិនផ្ដន្ទាទោសជនរងគ្រោះដោយការជួញដូរមនុស្ស<br>• ការសម្រាលទោសដែលដាក់លើជនរងគ្រោះដោយការជួញដូរមនុស្ស។ |
| នៅពេលជនរងគ្រោះដោយការជួញដូរមនុស្សត្រូវបានផ្ដន្ទាទោសខុស | • កំណត់ត្រាព្រហ្មទណ្ឌត្រូវបានធ្វើមោឃភាព លុបចោល ឬបិទ ជនរងគ្រោះដោយការជួញដូរមនុស្ស មានលទ្ធភាពទទួលបានដំណោះស្រាយសម្រាប់ការផ្ដន្ទាទោសខុស។ |

រដ្ឋក៏គួរធានាផងដែរថាមានយន្តការជាស្រេច ដើម្បីត្រួតពិនិត្យការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មក្នុងអន្តរកម្មទាំងអស់នេះ និងដើម្បីរក្សាការទទួលខុសត្រូវរបស់អ្នកដែលអនុវត្តខុស ឬខកខានមិនបានអនុវត្តគោលការណ៍នេះឱ្យបានជាក់ស្ដែង (ផ្នែកទី ៦)។

### អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្ដីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ

រដ្ឋត្រូវធានាថា គោលការណ៍មិនដាក់ទណ្ឌកម្ម ត្រូវបានអនុវត្តចំពោះ៖

(ក) គ្រប់ទម្រង់នៃការជួញដូរមនុស្ស រួមទាំងក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ កេងប្រវ័ញ្ចការងារ និងបង្ខំ
ឱ្យប្រព្រឹត្តបទល្មើស ក៏ដូចជាអនុវត្តទាំងចំពោះករណីនៃការជួញដូរជាអន្តរជាតិ និងករណីនៃការជួញដូរក្នុងស្រុក។

(ខ) សកម្មភាពល្មើសច្បាប់ណាមួយដែលធ្វើឡើងដោយជនដែលត្រូវបានជួញដូរ ដែលជាផលវិបាកដោយផ្ទាល់នៃស្ថានភាពដែលពួកគេត្រូវបានជួញដូរ ដោយមិនគិតពីស្ថានទម្ងន់ ឬភាពធ្ងន់ធ្ងរនៃបទល្មើសដែលបានប្រព្រឹត្ត។

(គ) បទល្មើសព្រហ្មទណ្ឌ បទល្មើសរដ្ឋប្បវេណី បទល្មើសរដ្ឋបាល និងបទល្មើសអន្តោប្រវេសន៍ ក៏ដូចជាទម្រង់ផ្សេងទៀតនៃការដាក់ទោសទណ្ឌ ដូចជា ការដកហូតសញ្ជាតិតាមទំនើងចិត្ត ការបដិសេធជំនួយកុងស៊ុល ឬការធ្វើមាតុភូមិនិវត្តន៍ ការដកចេញពីស្ថានភាពជាជនភៀសខ្លួន ឬទម្រង់ផ្សេងទៀតនៃការការពារពីអន្តរជាតិ និងការបំបែកចេញពីគ្រួសារ។

(ឃ) ស្ថានភាពណាមួយនៃការដកហូតសេរីភាព រួមទាំងការឃុំខ្លួនក្រោមបទល្មើសអន្តោប្រវេសន៍ និងការឃុំខ្លួនរង់ចាំនីតិវិធី និរទេសចេញ ផ្ទេរ ឬបញ្ជូនគេត្រឡប់ទៅវិញ។[1]

## តើនរណាទទួលខុសត្រូវលើការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម?

រដ្ឋគឺជាភាគីនៃច្បាប់អន្តរជាតិ និងច្បាប់តំបន់ ដូច្នេះ រដ្ឋជាអ្នកមានកាតព្វកិច្ចការពារជនរងគ្រោះដោយការជួញដូរមនុស្ស កាត់ទោសអ្នកជួញដូរមនុស្ស និងសហប្រតិបត្តិការក្រោមគោលបំណងទាំងនេះ។ ហេតុនេះ មន្រ្តីរដ្ឋទទួលខុសត្រូវលើការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ស្របតាមកាតព្វកិច្ចជាអន្តរជាតិ និងកាតព្វកិច្ចថ្នាក់តំបន់ ដោយអនុលោមតាមច្បាប់ វិធាន បទបញ្ញត្តិ និងការអនុវត្តន៍ក្នុងស្រុករបស់រដ្ឋសមាជិកអាស៊ាននីមួយៗ។

អ្នកពាក់ព័ន្ធផ្សេងទៀត រួមទាំងស្ថាប័នតាមវិស័យរបស់អាស៊ាន អង្គការសង្គមស៊ីវិល (CSOs) អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងអង្គការអន្តរជាតិ អាចគាំទ្ររដ្ឋក្នុងការបំពេញកាតព្វកិច្ចទាំងនេះ ប៉ុន្តែចុងក្រោយ រដ្ឋនៅតែជាអ្នកទទួលខុសត្រូវ។[19]

### មន្ត្រីរដ្ឋ

ភាពខុសគ្នានៃច្បាប់ តួនាទី និងសិទ្ធិអំណាចរបស់នគរបាល ព្រះរាជអាជ្ញា និងតុលាការ និងគុណតម្លៃ និងប្រពៃណីនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ សុទ្ធតែជះឥទ្ធិពលលើរបៀបបកស្រាយ និងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម នៅក្នុងរដ្ឋផ្សេងៗ។ ដោយមិនគិតពីភាពខុសគ្នានេះ មន្ត្រីអន្តោប្រវេសន៍ និងមន្ត្រីកុងស៊ុល អធិការការងារ និងមន្ត្រីនគរបាលដែលប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះដោយការជួញដូរមនុស្ស មានកាតព្វកិច្ចចំពោះពួកគេ។ អ្នកស៊ើបអង្កេត ព្រះរាជអាជ្ញា មេធាវីការពារក្តី និងមន្ត្រីតុលាការ សុទ្ធតែមានតួនាទីការពារជនរងគ្រោះពីការដាក់ទោសទណ្ឌ ដូច្នេះ ពួកគេគួរមានជំនាញ ធនធាន និងសមត្ថភាពចាំបាច់ ដើម្បីបំពេញតួនាទីរៀងៗខ្លួន។

### ស្ថាប័នប្រឆាំងការជួញដូរមនុស្ស

ស្ថាប័នអន្តរទីភ្នាក់ងាររដ្ឋដែលមានទំនួលខុសត្រូវលើការប្រឆាំងការជួញដូរមនុស្ស មានតួនាទីសំខាន់ក្នុងការមិនដាក់ទណ្ឌកម្ម។ ពួកគេអាចមានភារកិច្ចដែលកំណត់ដោយច្បាប់ ដើម្បីធានាថា អ្នកពាក់ព័ន្ធដែលជួបជាមួយអ្នកដែលអាចជាជនរងគ្រោះ ក្នុងពេលបំពេញការងាររបស់ខ្លួន ដឹងថាអ្វីជាការជួញដូរមនុស្ស និងដឹងពីរបៀបបញ្ជូនអ្នកដែលអាចជាជនរងគ្រោះតាមរយៈយន្តការបញ្ជូនថ្នាក់ជាតិ។ ក្នុងករណីគ្មានយន្តការបញ្ជូនថ្នាក់ជាតិដែលមានប្រសិទ្ធភាព គួរបញ្ជាក់ច្បាស់ថាតើគេអាចទាក់ទងនៅនរណាដើម្បីទទួលបានការគាំទ្រក្នុងការការពារជនរងគ្រោះដោយការជួញដូរមនុស្សដែលបានកំណត់អត្តសញ្ញាណ។

ស្ថាប័នប្រឆាំងការជួញដូរមនុស្ស មានតួនាទីសំខាន់ក្នុងការកសាងសមត្ថភាពប្រទេសរបស់ខ្លួន ដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម។ នេះអាចរួមបញ្ចូលការចេញសេចក្តីណែនាំ ការផ្តល់ការបណ្តុះបណ្តាល និងការណែនាំដើម្បីកសាងសមត្ថភាពរបស់អ្នកអនុវត្តដែលមានឯកទេស និងអ្នកអនុវត្តដែលគ្មានឯកទេសនៅក្នុងប្រទេសរបស់ខ្លួន ដើម្បីឱ្យពួកគេយល់កាន់តែច្បាស់អំពីការជួញដូរមនុស្ស កំណត់អត្តសញ្ញាណជនរងគ្រោះ និងអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម។

---

[19] ប្រភព៖ *ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ Siobhán Mullally*, ឯកសារ អ.ស.ប A/HRC/47/34, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០២១, [៥៧]

## ប្រអប់: ស្ថាប័នជាតិប្រឆាំងការជួញដូរមនុស្ស

| | |
|---|---|
| ប្រ៊ុយណេដារូសាឡឹម: | គណៈកម្មាធិការការងារជាតិស្តីពីការជួញដូរមនុស្ស |
| កម្ពុជា: | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) |
| ឥណ្ឌូនេស៊ី: | ក្រុមការងារទប់ស្កាត់ និងដោះស្រាយបទល្មើសព្រហ្មទណ្ឌនៃការជួញដូរមនុស្ស(Gugus Tugas TPPO) |
| ឡាវ: | គណៈកម្មាធិការដឹកនាំថ្នាក់ជាតិស្តីពីការជួញដូរមនុស្ស (NSC) |
| ម៉ាឡេស៊ី: | ក្រុមប្រឹក្សាប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការរត់ពន្ធជនចំណាកស្រុក (NSO MAPO) |
| មីយ៉ាន់ម៉ា: | ស្ថាប័នស្នូលដើម្បីបង្ក្រាបការជួញដូរមនុស្ស (CBTIP) |
| ហ្វីលីពីន: | ក្រុមប្រឹក្សាអន្តរទីភ្នាក់ងារប្រឆាំងការជួញដូរមនុស្សមនុស្ស (IACAT) |
| សិង្ហបុរី: | ក្រុមការងារអន្តរទីភ្នាក់ងារស្តីពីការជួញដូរមនុស្ស (TIP-TF) |
| ថៃ: | គណៈកម្មាធិការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គណៈកម្មាធិការ ATP) |
| វៀតណាម: | គណៈកម្មាធិការដឹកនាំថ្នាក់ជាតិស្តីពីការទប់ស្កាត់ និងបង្ក្រាបបទល្មើស (NSC) |

### ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ

ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ មានតួនាទីសំខាន់ក្នុងការធានាថា រដ្ឋបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួនចំពោះជនរងគ្រោះដោយការជួញដូរមនុស្ស។ នេះរួមបញ្ចូលការត្រួតពិនិត្យ និងរាយការណ៍អំពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មចំពោះជនរងគ្រោះដោយការជួញដូរមនុស្ស ក៏ដូចជាការផ្តល់ដំបូន្មានដល់តួអង្គរដ្ឋស្តីពីរបៀបអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ដើម្បីឱ្យស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិមានការទទួលស្គាល់ពីសហគមន៍អន្តរជាតិ ពួកគេត្រូវគោរពតាមស្តង់ដារដែលបានកំណត់ក្នុងគោលការណ៍ទីក្រុងប៉ារីស ដែលពាក់ព័ន្ធនឹងស្ថានភាពរបស់ស្ថាប័នជាតិ (គោលការណ៍ទីក្រុងប៉ារីស) ដែលត្រូវបានអនុម័តដោយមហាសន្និបាតក្នុងឆ្នាំ ១៩៩៣។[20] ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក មានស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិជាច្រើនដែលត្រូវបានទទួលស្គាល់ដោយសម្ព័ន្ធពិភពលោកនៃស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ។ គិតត្រឹមខែធ្នូ ឆ្នាំ ២០២៤ ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិនៅអាស៊ាន រួមមានគណៈកម្មការសិទ្ធិមនុស្សថ្នាក់ជាតិឥណ្ឌូនេស៊ី គណៈកម្មការសិទ្ធិមនុស្សម៉ាឡេស៊ី គណៈកម្មការសិទ្ធិមនុស្សហ្វីលីពីន និងគណៈកម្មការសិទ្ធិមនុស្សថ្នាក់ជាតិថៃ។[21] ស្ថាប័នទាំងនេះ រួមជាមួយនឹង Provedor de Direitos Humanos e Justiça នៃទីម័រខាងកើត ត្រូវបានទទួលស្គាល់ថាជាដៃគូរបស់ AICHR ហើយបាននិងកំពុងពិភាក្សានៅក្នុងការងារជាច្រើនរបស់ AICHR ក្នុងការជំរុញសិទ្ធិមនុស្សនៅក្នុងតំបន់។

[20] គោលការណ៍ទីក្រុងប៉ារីស អាចរកបានតាម៖ https://www.ohchr.org/en/instruments-mechanisms/instruments/principles-relating-status-national-institutions-paris

[21] តារាងស្ថានភាពនៃស្ថាប័នថ្នាក់ជាតិដែលទទួលស្គាល់ដោយសម្ព័ន្ធពិភពលោកនៃស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ, ស្ថានភាពនៃការទទួលស្គាល់ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៤, អាចរកបាននៅ៖ https://www.ohchr.org/en/documents/tools-and-resources/current-chart-accreditation-nhris

## តួនាទីរបស់តួអង្គមិនមែនរដ្ឋ

អង្គការសង្គមស៊ីវិល (CSOs) អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងអង្គការអន្តរជាតិ (IOs) អាចជួយដល់រដ្ឋក្នុងការបំពេញកាតព្វកិច្ចកំណត់អត្តសញ្ញាណបឋម រកភាពរងគ្រោះដោយអំពើជួញដូរមនុស្ស និងអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម។ ពួកគេអាចចែករំលែកលទ្ធផលស្រាវជ្រាវ ក៏ដូចជាបទពិសោធន៍ និងជំនាញរបស់ពួកគេក្នុងការធ្វើការជាមួយជនរងគ្រោះដោយការជួញដូរមនុស្ស ដែលត្រូវបានដាក់ទោសព្រហ្មទណ្ឌ។ ពួកគេអាចចែករំលែកការយល់ដឹងអំពីនិន្នាថ្មីៗនៃការញដូរមនុស្ស ពាក់ព័ន្ធនឹងការកាត់បន្ថយហានិភ័យនៃការដាក់ទោសទណ្ឌ ដែលអាចជួយដល់អ្នកអនុវត្តច្បាប់ក្នុងការកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស នៅក្នុងវិស័យដែលពួកគេធ្វើប្រតិបត្តិការ។

តួអង្គមិនមែនរដ្ឋក៏អាចគាំទ្រដល់ការកសាងសមត្ថភាពរបស់អ្នកអនុវត្ត ក្នុងការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មឱ្យបានជាក់ស្តែងផងដែរ។ ក្រៅពីនេះ ពួកគេមានតួនាទីក្នុងការត្រួតពិនិត្យការប្រព្រឹត្តចំពោះជនរងគ្រោះដោយការជួញដូរមនុស្ស នៅជនរងគ្រោះប្រឡូកក្នុងប្រព័ន្ធអន្តោប្រវេសន៍ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងការធានាការប្រកាន់ខ្ជាប់គោលការណ៍មិនដាក់ទណ្ឌកម្ម។

# ផ្នែកទី ២

# ការពង្រឹងច្បាប់ ដើម្បីគាំទ្រគោលការណ៍ មិនដាក់ទណ្ឌកម្ម

## ផ្នែកទី ២. ការពង្រឹងច្បាប់ ដើម្បីគាំទ្រគោលការណ៍មិនដាក់ទណ្ឌកម្ម

រដ្ឋមានឱកាសជាច្រើនក្នុងការពង្រឹងច្បាប់ប្រឆាំងការជួញដូរមនុស្ស និងច្បាប់ផ្សេងទៀត ដើម្បីគាំទ្រគោលការណ៍មិនដាក់ទណ្ឌកម្ម។

រដ្ឋគួរពិចារណាកែប្រែនិយមន័យនៃការជួញដូរមនុស្ស ដើម្បីបញ្ចូលការកេងប្រវ័ញ្ចក្នុងសកម្មភាពបទល្មើស ជាទម្រង់ជាក់លាក់នៃការជួញដូរមនុស្ស។ និយមន័យនៃការជួញដូរមនុស្សដែលរួមបញ្ចូលគោលបំណងកេងប្រវ័ញ្ចនេះ អាចលុបបំបាត់ភាពស្រពិចស្រពិលសម្រាប់មន្ត្រីជួរមុខដែលត្រូវត្រួតពិនិត្យជនរងគ្រោះដោយការជួញដូរមនុស្ស និងធ្វើឱ្យពួកគេដឹងថា មនុស្សដែលពួកគេជួបប្រទះក្នុងនាមជាឧក្រិដ្ឋជនអាចជាជនដែលត្រូវបានគេជួញដូរ។ និយមន័យដែលបញ្ចូលការបង្ខំឱ្យប្រព្រឹត្តបទល្មើសជាទម្រង់មួយនៃការកេងប្រវ័ញ្ច ក៏បញ្ចៀសការតម្រូវឱ្យព្រះរាជអាជ្ញាកំណត់ប្រភេទនៃការកេងប្រវ័ញ្ចមួយផ្សេងទៀត (ឧទាហរណ៍ ការងារ ឬសេវាដោយបង្ខំ ទាសភាព ការអនុវត្តន៍ដែលស្រដៀងនឹងទាសភាព ឬ 'ផ្សេងទៀត') សម្រាប់ស្ថានភាពដែលជនរងគ្រោះដោយការជួញដូរមនុស្ស ត្រូវបានកេងប្រវ័ញ្ចក្នុងសកម្មភាពបទឧក្រិដ្ឋ។

រដ្ឋគួរពិចារណាអនុម័តបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌ ក្នុងច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស។ បទបញ្ញត្តិទាំងនេះ គួរការពារមិនឱ្យមានការដាក់ទោសជនរងគ្រោះដោយការជួញដូរមនុស្សទាំងអស់សម្រាប់សកម្មភាពល្មើសច្បាប់ទាំងអស់ដែលទាក់ទងនឹងសកម្មភាពនៃការជួញដូរពួកគេ។ បទបញ្ញត្តិបែបនេះអាចបង្កើនភាពអង់អាចរបស់អ្នកអនុវត្តច្បាប់ក្នុងការចេញសេចក្តីសម្រេចមិនឱ្យធ្វើការចាប់ខ្លួន បង្កើនសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញាក្នុងការប្រើឆន្ទានុសិទ្ធិមិនបន្តការចោទប្រកាន់ និងផ្តល់អំណាចដល់មេធាវីការពារក្តី ក្នុងការការពារជនប្រព្រឹត្តបទល្មើស-ជាជនរងគ្រោះ ដែលពួកគេធ្វើជាតំណាង។

ក្រៅពីនេះ មានឱកាសក្នុងការពង្រឹងច្បាប់ផ្សេងទៀត ក្រៅពីច្បាប់ស្តីពីការជួញដូរមនុស្ស ដើម្បីការពារជនរងគ្រោះពីគ្រប់ទម្រង់នៃការដាក់ទោសទណ្ឌ។ ឱកាសទាំងនេះទាក់ទងនឹងបទល្មើសដែលជនរងគ្រោះដោយការជួញដូរមនុស្សតែងប្រឈមនឹងហានិភ័យនៃការដាក់ទោសទណ្ឌ អាយុអប្បបរមាសម្រាប់ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ និងច្បាប់ដើម្បីធ្វើមោឃភាព លុបចោល ឬបិទកំណត់ត្រាព្រហ្មទណ្ឌរបស់ជនរងគ្រោះ។

### *[១] ពង្រឹងច្បាប់ប្រឆាំងការជួញដូរមនុស្ស ដើម្បីការពារជនរងគ្រោះពីការដាក់ទោសទណ្ឌ*

រដ្ឋត្រូវបានលើកទឹកចិត្តឱ្យចែងបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌ នៅក្នុងច្បាប់ជាតិរបស់ខ្លួន ដើម្បីបំពេញបន្ថែមលើវិធានការការពារដែលមានចែងក្នុងច្បាប់។ វិសាលភាពសម្រាប់ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម មិនគួរមានដែនកំណត់ទេ។ គោលការណ៍នេះគួរអនុវត្តចំពោះជនរងគ្រោះដោយការជួញដូរមនុស្សទាំងអស់ ដោយផ្អែកលើការមិនរើសអើង ពោលគឺមិនគិតពីប្រភេទនៃការជួញដូរពួកគេ និងប្រភេទនៃសកម្មភាពល្មើសច្បាប់ដែលពួកគេបាន

## ពិនិត្យលទ្ធភាពកែសម្រួលនិយមន័យនៃការជួញដូរមនុស្ស ដើម្បីបញ្ចូលការកេងប្រវ័ញ្ច ទៅក្នុងសកម្មភាពល្មើសច្បាប់

និយមន័យនៃការជួញដូរមនុស្សក្នុងច្បាប់អន្តរជាតិ និងច្បាប់តំបន់អាស៊ាន បញ្ចូលសកម្មភាពដូច តទៅថាជាទម្រង់នៃការកេងប្រវ័ញ្ច ៖ ការកេងប្រវ័ញ្ចលើពេស្យាកម្មអ្នកដទៃ ឬទម្រង់ដទៃទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទ ការធ្វើពលកម្ម ឬសេវាដោយបង្ខំ ទាសភាព ឬការប្រព្រឹត្តប្រហាក់ប្រហែលនឹងទាសភាព អ្នកបម្រើដាច់ថ្លៃ ឬការដកហូតសរីរាង្គ។ ការបញ្ចូលសកម្មភាពទាំងនេះ មានន័យថា យ៉ាងហោចណាស់ រដ្ឋអាចបញ្ចូលទម្រង់បន្ថែម និងថែមទាំងកែប្រែច្បាប់របស់ខ្លួន ដើម្បីបញ្ជាក់ពីទម្រង់បន្ថែមទៀត។ ឧទាហរណ៍ ម៉ាឡេស៊ីបានបញ្ចូល 'សកម្មភាពល្មើសច្បាប់ណាមួយ' ជាទម្រង់នៃការកេងប្រវ័ញ្ច ដើម្បីបញ្ចូលស្ថានភាពនៃជនរងគ្រោះដែលត្រូវបានកេងប្រវ័ញ្ច ទៅក្នុងសកម្មភាពល្មើសច្បាប់។ ច្បាប់ប្រឆាំងនឹងការជួញដូរមនុស្សនៅវៀតណាម (ប្រកាសឱ្យប្រើនៅខែ វិច្ឆិកា ឆ្នាំ ២០២៤ ដើម្បីចូលជាធរមាននៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២៥) រួមបញ្ចូល 'ការបង្ខំជនរងគ្រោះឱ្យប្រព្រឹត្តបទល្មើស' ជាគោលបំណងអមនុស្សធម៌នៃការជួញដូរមនុស្ស។

រដ្ឋសមាជិកអាស៊ានផ្សេងទៀតអាចកែប្រែច្បាប់ជួញដូរមនុស្សរបស់ខ្លួន ដើម្បីបញ្ចូលសកម្មភាពល្មើសច្បាប់ជាទម្រង់ជាក់លាក់នៃការកេងប្រវ័ញ្ច ក្នុងនិយមន័យនៃការជួញដូរមនុស្ស។ ការបញ្ចូលសកម្មភាពល្មើសច្បាប់ ជាទម្រង់ជាក់លាក់នៃការកេងប្រវ័ញ្ច នឹងជួយដល់មន្ត្រីជួរមុខ និងមន្ត្រីអនុវត្តន៍ច្បាប់ក្នុងការកំណត់អត្តសញ្ញាណករណីជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព។ ការណ៍នេះក៏នឹងជួយដល់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ជនល្មើសដែលបានជួញដូរមនុស្សបង្ខំឱ្យប្រព្រឹត្តបទល្មើសផងដែរ។

ក្នុងករណីគ្មានការកេងប្រវ័ញ្ចក្នុងសកម្មភាពល្មើសច្បាប់ ឬការបង្ខំឱ្យប្រព្រឹត្តបទល្មើស ជាទម្រង់ជាក់លាក់នៃការកេងប្រវ័ញ្ច ដែលបានបញ្ជាក់ក្នុងនិយមន័យនៃការជួញដូរមនុស្ស អ្នកជំនាញខាងយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវយល់ពីរបៀបបញ្ចូលស្ថានភាពបែបនេះ នៅក្នុងទម្រង់នៃការកេងប្រវ័ញ្ចដែលមានស្រាប់ អាចជាការងារ ឬសេវាដោយបង្ខំ ទាសភាព ឬការប្រព្រឹត្តប្រហាក់ប្រហែលនឹងទាសភាព ឬសាមញ្ញដូចជា 'ផ្សេងទៀត' ជាដើម។ នៅពេលច្បាប់ចែងពីបញ្ជីបទល្មើសដែលត្រូវយកបទបញ្ញត្តិនេះមកអនុវត្ត ច្បាប់នេះគួរចែងថាបញ្ជីបទល្មើសនេះនៅមិនទាន់អស់សេចក្តីនៅឡើយ។[22]

---

22 ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ, Siobhán Mullaly, ឯកសារ ឯកសារ អ.ស.ប A/HRC/47/34 (ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០២១) កថាខណ្ឌ ៣៧ និង ៣៨។

**ប្រអប់: ឧទាហរណ៍ (ប្រទេសអូស្ត្រាលី)**

អូស្ត្រាលីមិនបានបញ្ចូលការកេងប្រវ័ញ្ចក្នុងសកម្មភាពល្មើសច្បាប់ ជាទម្រង់នៃការកេងប្រវ័ញ្ចក្នុងនិយមន័យនៃការជួញដូរមនុស្សរបស់ខ្លួនឡើយ។ ការពិនិត្យឡើងវិញលើច្បាប់របស់អូស្ត្រាលីបានរកឃើញថា "និយមន័យនៃការកេងប្រវ័ញ្ចរបស់អូស្ត្រាលី ទំនងជាបានបញ្ចូលការកេងប្រវ័ញ្ចក្នុងសកម្មភាពបទល្មើសរួចទៅហើយ ព្រោះថាទម្រង់នៃការកេងប្រវ័ញ្ចការងារដែលពាក់ព័ន្ធនឹងនិយមន័យនេះ អាចរួមបញ្ចូលទាំងទម្រង់ការងារ និងសេវាដែលស្របច្បាប់ និងខុសច្បាប់ ឬមិនជាប់លាប់។ ទោះយ៉ាងណាក៏ដោយ ការបញ្ចូលយ៉ាងជាក់ច្បាស់នូវឃ្លាដែលបញ្ជាក់ថា ការកេងប្រវ័ញ្ចអាចរួមបញ្ចូលសកម្មភាពកេងប្រវ័ញ្ច អាចផ្តល់ប្រសិទ្ធភាពកាន់តែខ្លាំងដល់គោលការណ៍មិនដាក់ទណ្ឌកម្ម។"[23]

គេអាចរៀនសូត្រពីវិធីសាស្ត្រនីតិកម្មដែលបានអនុវត្តនៅក្នុងតំបន់ផ្សេងទៀត។ ប្រទេសនានាក្នុងសហភាពអឺរ៉ុបរកឃើញថា ការបញ្ចូលសកម្មភាពល្មើសច្បាប់ជាទម្រង់នៃការកេងប្រវ័ញ្ច នឹងជួយដល់អ្នក អនុវត្តក្នុងកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព។[24] នៅសហភាពអឺរ៉ុប បទបញ្ញាលេខ EU ២០១១/៣៦/EU៩ ទទួលស្គាល់ជាពិសេសនូវបាតុភូតនៃអ្នកជួញដូរមនុស្សដែលបង្ខំជនរងគ្រោះឱ្យប្រព្រឹត្តបទល្មើស ជាទម្រង់មួយនៃការកេងប្រវ័ញ្ចដែលបានបញ្ចូលក្នុងនិយមន័យនៃការជួញដូរមនុស្ស។[25] បទបញ្ញានោះរួមបញ្ចូល 'ការកេងប្រវ័ញ្ចក្នុងសកម្មភាពល្មើសច្បាប់' ជាទម្រង់នៃការកេងប្រវ័ញ្ច ដែលត្រូវបានយល់ថាជា "ការកេងប្រវ័ញ្ចលើមនុស្សម្នាក់ឱ្យប្រព្រឹត្ត ជាអាទិ៍ ការលួចហោប៉ៅ ការលួចទំនិញពីហាង ការជួញដូរគ្រឿងញៀន និងសកម្មភាពប្រហាក់ប្រហែលដទៃទៀតដែលស្ថិតក្រោមការដាក់ទោសទណ្ឌ និងពាក់ព័ន្ធនឹងការទទួលបានផលចំណេញហិរញ្ញវត្ថុ។"[26] បទបញ្ញានេះពន្យល់បន្ថែមថា ប្រទេសជាសមាជិកគួរការពារជនរងគ្រោះពីការកាត់ទោស ឬការដាក់ទោសទណ្ឌសម្រាប់សកម្មភាពបទឧក្រិដ្ឋ ដូចជា ការប្រើឯកសារក្លែងក្លាយ ឬបទល្មើសក្រោមច្បាប់ស្តីពីពេស្យាចារ ឬអន្តោប្រវេសន៍ ដែលពួកគេត្រូវបានបង្ខំឱ្យប្រព្រឹត្ត ក្រោមផលវិបាកដោយផ្ទាល់នៃការជួញដូរមនុស្ស។[27]

បទបញ្ញាឆ្នាំ ២០១១ នេះត្រូវបានធ្វើវិសោធនកម្មដោយបទបញ្ញាលេខ EU ២០២៤/១៧១២ ដែលចូលជាធរមាននៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៤។ បទបញ្ញាថ្មីនេះពង្រីកវិសាលភាពនៃការកេងប្រវ័ញ្ចបន្ថែមទៀត (ដើម្បីបញ្ចូលការកេងប្រវ័ញ្ចផ្សេងៗ ដូចជា ការពរពោះជំនួស អាពាហ៍ពិពាហ៍ដោយបង្ខំ និងការសុំកូនដោយខុសច្បាប់ជាដើម) ហើយក្នុងពេលជាមួយគ្នានោះ រក្សាទុកនូវទម្រង់ពីមុន រួមទាំង 'ការកេងប្រវ័ញ្ចក្នុងសកម្មភាពបទឧក្រិដ្ឋ'។ បទបញ្ញាឆ្នាំ ២០២៤ បង្ហាញពី

---

[23] ការពិនិត្យឡើងវិញដោយមានគោលដៅនៃបទល្មើសទាសភាពសម័យទំនើប ក្នុងផ្នែក ២៧០ និង ២៧១ នៃ *ច្បាប់ក្រមព្រហ្មទណ្ឌ ១៩៩៥* (Cth): របាយការណ៍លទ្ធផលរកឃើញ (Commonwealth of Australia ២០២៣) ទំព័រ ៦៨

[24] សូមមើលឧបសម្ព័ន្ធ ២។

[25] សូមមើល សារៈសំខាន់នៃការអនុវត្តន៍បទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌ៖ កាតព្វកិច្ចក្នុងការការពារជនរងគ្រោះ Maria Grazia Giammarinaro អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ អង្គការសហប្រជាជាតិ ហ្សឺណែវ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ ទំព័រ២ កថាខណ្ឌ [៣]

[26] បទបញ្ញាលេខ ២០១១/៣៦/EU របស់សភាអឺរ៉ុប និងក្រុមប្រឹក្សា ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ ស្តីពីការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការការពារជនរងគ្រោះ (ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១) (ចូលជាធរមានថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១១) កថាខណ្ឌ (១១) និងមាត្រា ២(៣)។

[27] បទបញ្ញាលេខ ២០១១/៣៦/EU របស់សភាអឺរ៉ុប និងក្រុមប្រឹក្សា ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ ស្តីពីការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការការពារជនរងគ្រោះ (ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១) (ចូលជាធរមានថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១១) កថាខណ្ឌ ១៤។

កង្វល់ជាពិសេសចំពោះការកំណត់គោលដៅលើកុមារដោយក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ដើម្បីប្រើប្រាស់កុមារក្នុងការប្រព្រឹត្តសកម្មភាពបទឧក្រិដ្ឋ។[28]

ការយល់ដឹងរបស់សហភាពអឺរ៉ុបនេះ បង្កើនការយល់ដឹងក្នុងស្រុកស្ដីពីការជួញដូរមនុស្ស និងកិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់ក្នុងតំបន់ផងដែរ។ Europol កត់សម្គាល់ថា ការជួញដូរមនុស្សអាច "មានទម្រង់ជាការកេងប្រវ័ញ្ចក្នុងគោលបំណងបង្ខំឱ្យប្រព្រឹត្តបទល្មើស ដូចជា ការលូកហោប៉ៅ ការលួចទំនិញពីហាង និងការជួញដូរគ្រឿងញៀន។"[29] ផ្អែកលើការយល់ដឹងបែបនោះ ក្នុងទិវាសកម្មភាពរួមស្ដីពីការអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស មានការលើកឡើងពីការជួញដូរមនុស្សក្នុងគោលបំណងបង្ខំឱ្យប្រព្រឹត្តបទល្មើស ក្នុងចំណោមទម្រង់កេងប្រវ័ញ្ចផ្សេងទៀត។[30]

## ព្រាង ឬកែប្រែបទបញ្ញត្តិច្បាប់ជាក់លាក់ស្ដីពីការមិនដាក់ទោសទណ្ឌ

វិធានការការពារដែលអាចត្រូវបានបញ្ចូលក្នុងច្បាប់ជាតិ ដូចជា ការបង្ខិតបង្ខំ និងភាពចាំបាច់ ជួយការការពារជនរងគ្រោះដោយការជួញដូរមនុស្សពីការដាក់ទោសទណ្ឌ ប៉ុន្តែមិនការពារជនរងគ្រោះពីការចោទប្រកាន់ និងការជំនុំជម្រះទោសនៅដំណាក់ដំបូងឡើយ។ ការអនុម័តបទបញ្ញត្តិច្បាប់ច្បាស់លាស់ និងជាក់លាក់ស្ដីពីការមិនដាក់ទោសទណ្ឌ គឺជាឧត្តមានុវត្តន៍ក្នុងការអនុវត្តគោលការណ៍មិនដាក់ទោសទណ្ឌ មុនពេលជនរងគ្រោះត្រូវបានជំនុំជម្រះទោស។[31] លើសពីនេះទៀត វិធានការការពារទូទៅអាចត្រឹមតែសម្រាលទោស ជាជាងនាំឱ្យមានការរួចខ្លួនជនជាប់ចោទដែលត្រូវបានចាប់ខ្លួន ចោទប្រកាន់ និងកាត់ក្ដីដោយអយុត្តិធម៌។ នេះជាបទពិសោធន៍ដែលមានន័យស្មើនឹងការដាក់ទោស ដែលផ្ទុយនឹងគោលការណ៍មិនដាក់ទណ្ឌកម្ម។

អ្នកតាក់តែងច្បាប់គួរពិចារណាធ្វើសេចក្ដីព្រាង ឬកែប្រែបទបញ្ញត្តិច្បាប់ជាក់លាក់ ដើម្បីបញ្ចូលគោលការណ៍មិនដាក់ទណ្ឌកម្មក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្ស។ នៅក្នុងយុត្តាធិការដែលមានការកាត់ទោសដោយបង្ខំ ច្បាប់គួរតម្រូវឱ្យមានការមិនកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្ស ឬការបញ្ឈប់ការកាត់ទោសនៅដំណាក់កាលដំបូង។ នៅក្នុងយុត្តាធិការដែលមានការកាត់ទោសតាមឆន្ទានុសិទ្ធិ ច្បាប់គួរជានាថា ព្រះរាជអាជ្ញាមិនបន្តការកាត់ទោស ឬបញ្ឈប់ភ្លាមៗនូវការកាត់ទោសដែលបានចាប់ផ្ដើមឡើង នៅពេលមានការបង្ហាញច្បាស់ថា ការប្រព្រឹត្តបទល្មើសរបស់បុគ្គលគឺបណ្ដាលមកពីគាត់ត្រូវបានគេជួញដូរ។

28 បទបញ្ជាលេខ (EU) ២០២៤/១៧១២ របស់សភាអឺរ៉ុប និងក្រុមប្រឹក្សា ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ ធ្វើវិសោធនកម្មបទបញ្ជាលេខ ២០១១/៣៦/EU ស្ដីពីការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការការពារជនរងគ្រោះ កថាខណ្ឌ ២៣

29 https://www.europol.europa.eu/crime-areas/trafficking-in-human-beings

30 https://www.europol.europa.eu/media-press/newsroom/news/human-trafficking-action-week-219-criminals-arrested-and-1-374-victims-identified

31 ការណែនាំស្ដីពីបញ្ហានៃការឆ្លើយតបសមស្របផ្នែកយុត្តិធម៌ព្រហ្មទណ្ឌចំពោះជនរងគ្រោះដែលត្រូវបានបង្ខំឱ្យប្រព្រឹត្តបទល្មើស ដោយសារពួកគេត្រូវបានជួញដូរ ៖ ឯកសារសាវតារដែលរៀបចំឡើងដោយលេខាធិការដ្ឋានក្រុមការងារស្ដីពីការជួញដូរមនុស្ស វីយែន ថ្ងៃទី១០ និងទី១១ ខែកញ្ញា ឆ្នាំ២០២០ ឯកសារ អ.ស.ប CTOC/COP/WG.4/2020/2 (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០) កថាខណ្ឌ ៤៦

គួរព្រាងបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌដើម្បីអនុវត្តចំពោះជនរងគ្រោះទាំងអស់ដោយផ្អែកលើការមិនរើសអើង ពោលគឺមិនគិតពីប្រភេទនៃការជួញដូរពួកគេ ឬប្រភេទបទល្មើសដែលពួកគេបានប្រព្រឹត្ត ដោយសារការជួញដូរនោះ។ ដូច្នេះ ប្រទេសជាសមាជិកអាស៊ានអាចពិចារណាអនុម័ត ឬកែប្រែបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌ ដើម្បីធានាការបញ្ចូលរាល់សកម្មភាពល្មើសច្បាប់របស់ជនរងគ្រោះដោយការជួញដូរមនុស្ស ដែលបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃការជួញដូរនោះ។[32]បទបញ្ញត្តិច្បាប់គួរតែអនុវត្តចំពោះបទល្មើសរដ្ឋប្បវេណី បទល្មើសរដ្ឋបាល បទល្មើសអន្តោប្រវេសន៍ និងបទល្មើសព្រហ្មទណ្ឌផ្សេងៗ និងត្រូវអនុវត្តចំពោះជនរងគ្រោះទាំងអស់ដោយផ្អែកលើការមិនរើសអើង ពោលគឺមិនគិតពីប្រភេទនៃការកេងប្រវ័ញ្ចដែលពួកគេត្រូវបានជួញដូរ និងមិនគិតពីស្ថានទម្ងន់ ឬភាពធ្ងន់ធ្ងរនៃបទល្មើសដែលពួកគេបានប្រព្រឹត្ត។[33]

*ដ្យាក្រាម៖ វិសាលភាពនៃការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម*

| ជនរងគ្រោះទាំងអស់ | | ដោយការជួញដូរមនុស្សគ្រប់ប្រភេទ | | សម្រាប់សកម្មភាពល្មើសច្បាប់ទាំងអស់ |
|---|---|---|---|---|
| មនុស្សពេញវ័យ<br>កុមារ<br>ប្រជាពលរដ្ឋ<br>ជនចំណាកស្រុក<br>ផ្សេងទៀត | ▷ | ការកេងប្រវ័ញ្ចផ្លូវភេទ<br>ការងារដោយបង្ខំ<br>ការបង្ខំឱ្យប្រព្រឹត្តបទល្មើស<br>ការដកហូតសរីរាង្គ<br>ការជួញដូរទៅក្នុងអំពើភេរវកម្ម<br>ផ្សេងទៀត | ▷ | បទល្មើសស្ថានភាព<br>បទល្មើសតូចតាច<br>បទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ |

ក្នុងករណីជនរងគ្រោះប្រព្រឹត្តបទល្មើស ដែលជាផលវិបាកដោយផ្ទាល់នៃការជួញដូរពួកគេ

ប្រភេទ ឬភាពធ្ងន់ធ្ងរនៃសកម្មភាពល្មើសច្បាប់ មិនមែនជាកត្តាដើម្បីកំណត់ថាតើត្រូវអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ឬអត់នោះទេ។ ការអនុញ្ញាតឱ្យមានការអនុវត្តន៍គោលការណ៍នេះយ៉ាងទូលំទូលាយ មិននាំឱ្យមានការហាមឃាត់ទូទៅលើការកាត់ទោសជនរងគ្រោះឡើយ ប៉ុន្តែផ្តល់ព័ត៌មានស្តីពីស្តង់ដារនៃការស៊ើបសួរ។[34] គោលការណ៍នេះតម្រូវឱ្យ

32 *ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ Siobhán Mullally* ឯកសារ អ.ស.ប *A/HRC/47/34* ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ *[៥៧]*

33 ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ Siobhán Mullaly ឯកសារ អ.ស.ប A/HRC/47/34 (ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១) កថាខណ្ឌ ៣៧។

34 សូមមើលប្រអប់៖ *ការការពារប្រឆាំងនឹងការប្រើប្រាស់ខុសនូវគោលការណ៍មិនដាក់ទណ្ឌកម្ម* ខាងលើ។

អាជ្ញាធរពិចារណាពីការមិនដាក់ទោសទណ្ឌជនរងគ្រោះ នៅពេលមានការកំណត់ទំនាក់ទំនងរវាងសកម្មភាពល្មើសច្បាប់របស់ជនរងគ្រោះ និងការជួញដូរពួកគេ។[35]

ដូចដែលបានពន្យល់ដោយអតីតអ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារថា៖

កាលណាបទល្មើសកាន់តែធ្ងន់ធ្ងរ ការស៊ើបសួរនឹងកាន់តែស៊ីជម្រៅ ដើម្បីកំណត់កាលៈទេសៈដែលមានការប្រព្រឹត្តបទល្មើស និងថាតើអាចអនុវត្តសិទ្ធិមិនត្រូវបានគេដាក់ទោស បានត្រឹមត្រូវ ឬទេ។ ឆ្ងាយពីការពាក់ព័ន្ធនឹង 'ភាពមិនអាចប៉ះពាល់បាន' ការការពារបែបនេះឆ្លើយតបទៅនឹង (១) ភាពចាំបាច់ក្នុងការកំណត់កាលៈទេសៈពិតប្រាកដដែលមានការប្រព្រឹត្តបទល្មើស (២) អនុញ្ញាតឱ្យមានការបង្វែរជនរងគ្រោះទៅរកលក្ខណៈពិសេសនៃការការពារ និងជំនួយ ដែលពួកគេមានសិទ្ធិទទួលបាន និង (៣) លើកទឹកចិត្តឱ្យមានការស៊ើបអង្កេតលើបទល្មើសនៃការជួញដូរមនុស្ស ដែលនាំឱ្យមានការកើនឡើងនៃការកាត់ទោសអ្នកជួញដូរមនុស្ស និងការថយចុះនៃការកាត់ទោសជនរងគ្រោះសម្រាប់បទល្មើសដែលពួកគេបានប្រព្រឹត្ត នៅពេលពួកគេស្ថិតក្រោមឥទ្ធិពលគ្របដណ្តប់ ឬការកេងប្រវ័ញ្ចពីអ្នកដទៃ។ បន្ថែមលើនេះ គោលការណ៍មិនដាក់ទណ្ឌកម្មនឹងដំណើរការដោយមិនប៉ះពាល់ដល់វិធានការការពារណាមួយ ក្នុងច្បាប់ជាតិ។[36]

ការសំខាន់គឺ ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម មិនត្រូវបានផ្អែកលើលក្ខខណ្ឌនៃការកាត់ទោសអ្នកជួញដូរមនុស្សដែលរងការចោទប្រកាន់ ឬកិច្ចសហប្រតិបត្តិការរបស់ជនរងគ្រោះ ក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ។[37]

[35] *ករណីរបស់ V.C.L និង A.N. ទល់នឹង ចក្រភពអង់គ្លេស (*ពាក្យបណ្តឹងលេខ ៧៧៥៨៧/១២ និង ៧៤៦០៣/១២*)* សាលក្រម Strasbourg ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ កថាខណ្ឌ ១៥៨

[36] សារៈសំខាន់នៃការអនុវត្តន៍បទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌ៖ កាតព្វកិច្ចក្នុងការការពារជនរងគ្រោះ Maria Grazia Giammarinaro អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ អង្គការសហប្រជាជាតិ ហ្សឺណែវ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ ទំព័រ១១ កថាខណ្ឌ [៤១]

[37] ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ Siobhán Mullaly ឯកសារ អ.ស.ប A/HRC/47/34 (ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១) កថាខណ្ឌ ៥៨

### អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ

រដ្ឋគួរផ្តល់សច្ចាប័ន និងអនុវត្តរាល់លិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធដែលហាមឃាត់ការជួញដូរមនុស្ស និងចែងពីសិទ្ធិមិនត្រូវបានគេដាក់ទោស រួមទាំងពិធីសារ ILO សម្រាប់អនុសញ្ញាស្តីពីការងារដោយបង្ខំ ឆ្នាំ១៩៣០ (អនុសញ្ញាលេខ ២៩)។ រដ្ឋគួរអនុវត្តរាល់វិធានការសមស្របផ្នែកច្បាប់ គោលនយោបាយ រដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព នូវគោលការណ៍មិនដាក់ទណ្ឌកម្មជនរងគ្រោះដោយការជួញដូរមនុស្ស និងគួរៈ

(ក) បញ្ចូលបទបញ្ញត្តិជាក់លាក់មួយទៅក្នុងច្បាប់ជាតិ ដើម្បីផ្តល់ការមិនដាក់ទោសទណ្ឌជនរងគ្រោះដោយការជួញដូរមនុស្ស។

(ខ) អនុម័តគោលការណ៍ណែនាំស្តីពីការកាត់ទោស ដើម្បីសម្រួលដល់ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មដែលមានសង្គតិភាព និងជាប្រព័ន្ធ ក្នុងគ្រប់ករណីជួញដូរមនុស្សទាំងអស់។

(គ) អនុម័តបញ្ជីបើក និងមិនរៀបរាប់ពេញលេញនូវបទល្មើសដែលពាក់ព័ន្ធជាញឹកញាប់ទៅនឹងការជួញដូរមនុស្ស ដែលគួរត្រូវបានផ្សព្វផ្សាយ និងបញ្ចូលក្នុងការបណ្តុះបណ្តាល និងក្នុងគោលការណ៍ណែនាំដែលបានបោះពុម្ពផ្សាយសម្រាប់អាជាធរអនវតន៍ចកប់ទាំងអស់ និងមនសទោំងអស់ដែលទំនងជាមានទំនាក់ទំនងជាមយជនដែលតេវបានជពាជរ។ [38]

**ធានាថា ច្បាប់បញ្ជាក់ច្បាស់អំពីទំនាក់ទំនងចាំបាច់រវាងអំពើជួញដូរមនុស្ស និងសកម្មភាពល្មើសច្បាប់របស់ជនរងគ្រោះ**

រដ្ឋអនុវត្តវិធីសាស្រ្តផ្សេងៗគ្នា ដើម្បីកំណត់ថាតើត្រូវអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ឬអត់ ក្នុងស្ថានភាពដែលជនរងគ្រោះដោយការជួញដូរមនុស្ស ចូលរួមក្នុងសកម្មភាពល្មើសច្បាប់។ វិធីសាស្រ្ត ២ ដែលគេប្រើទូទៅបំផុត គឺការបង្ខាប់បញ្ហា (ឬការបង្ខិតបង្ខំ) និងការជំរុញឱ្យប្រព្រឹត្ត។

**ការបង្ខាប់បញ្ហា (ឬការបង្ខិតបង្ខំ)** ៖ អនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម នៅពេលដែលអាចបង្ហាញថា ជនរងគ្រោះដោយការជួញដូរមនុស្ស ត្រូវបានអ្នកជួញដូរមនុស្សបង្ខំឱ្យចូលរួមក្នុងសកម្មភាពល្មើសច្បាប់ដែលពាក់ព័ន្ធ។

**ការជំរុញឱ្យប្រព្រឹត្ត** ៖ អនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម នៅពេលដែលអាចបង្ហាញថា សកម្មភាពល្មើសច្បាប់របស់ជនរងគ្រោះ គឺជាផលវិបាកដោយផ្ទាល់នៃការជួញដូរមនុស្ស។

គំរូទាំងនេះត្រូវបានបង្ហាញក្នុងបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌ ក្នុងច្បាប់ជាតិស្តីពីការប្រឆាំងការជួញដូរ។ បទបញ្ញត្តិបែបនេះមានសារៈសំខាន់ សម្រាប់អ្នកអនុវត្តច្បាប់ក្នុងការសម្រេចថា តើត្រូវចាប់ខ្លួនជនរងគ្រោះដោយការជួញដូរមនុស្សសម្រាប់សកម្មភាពល្មើសច្បាប់របស់ពួកគេ ឬទេ។ វាមានសារៈសំខាន់ សម្រាប់ព្រះរាជអាជ្ញា ក្នុងការអនុវត្តន៍ឆន្ទានុសិទ្ធិរបស់ខ្លួនថាតើត្រូវកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្សសម្រាប់សកម្មភាពល្មើសច្បាប់ ឬទេ និងមានសារៈសំខាន់សម្រាប់មេធាវីការពារក្តី ដើម្បីការពារជនរងគ្រោះដោយការជួញដូរមនុស្ស ដែលស្ថិតក្រោមការជំនុំជម្រះទោសចំពោះសកម្មភាពល្មើសច្បាប់ ដែលជាផលវិបាកដោយផ្ទាល់នៃការជួញដូរមនុស្ស។

## វិធីសាស្រ្តក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម

| បញ្ហា (ឬការបង្ខិតបង្ខំ) | ការជំរុញឱ្យប្រព្រឹត្ត |
|---|---|
| សកម្មភាពល្មើសច្បាប់របស់ជនរងគ្រោះត្រូវបានបង្ខំដោយអ្នកជួញដូរ មានន័យថា សកម្មភាពទាំងនោះត្រូវបានអនុវត្តក្រោមការបង្ខិតបង្ខំ ឬការគំរាមកំហែង | សកម្មភាពល្មើសច្បាប់របស់ជនរងគ្រោះ គឺជាលទ្ធផលដោយផ្ទាល់នៃការជួញដូរមនុស្ស |

### ឧទាហរណ៍

| | |
|---|---|
| **អនុសញ្ញាស្តីពីសកម្មភាពប្រឆាំងការជួញដូរមនុស្ស (២០០៥)**<br>យោងតាមគោលការណ៍មូលដ្ឋាន នៃប្រព័ន្ធច្បាប់របស់ខ្លួន ភាគីនីមួយៗត្រូវផ្តល់លទ្ធភាពនៃការមិនដាក់ទោសទណ្ឌលើជនរងគ្រោះ សម្រាប់ការចូលរួមរបស់ពួកគេក្នុងសកម្ម ភាពល្មើសច្បាប់ ក្នុងកម្រិតដែលពួកគេត្រូវបានបង្ខំឱ្យធ្វើដូច្នោះ។<br>*អនុសញ្ញាក្រុមប្រឹក្សាអឺរ៉ុបស្តីពីសកម្មភាពប្រឆាំងការជួញដូរមនុស្ស* (មាត្រា ២៦) | **អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (២០១៥)**<br>អនុលោមតាមច្បាប់ គោលការណ៍ និងគោលនយោបាយជាតិ និងក្នុងករណីសមស្រប ភាគីនីមួយៗត្រូវពិចារណាចាត់ទុកជនរងគ្រោះដោយការជួញដូរមនុស្សថា មិនពាក់ព័ន្ធនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ឬខាងរដ្ឋបាលឡើយ ចំពោះសកម្មភាពល្មើសច្បាប់ ដែលពួកគេបានប្រព្រឹត្ត ប្រសិនបើសកម្មភាពបែបនោះ ជាប់ទាក់ទងដោយផ្ទាល់ទៅនឹងសកម្មភាពនៃការជួញដូរមនុស្ស។<br>***អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី*** |
| **ឥណ្ឌូនេស៊ី**<br>**ហ្វីលីពីន** | **ប្រ៊ុយណេដារូសាឡឹម**<br>(តែបទល្មើសដែលទាក់ទងនឹងអន្តោប្រវេសន៍ និងឯកសារប៉ុណ្ណោះ)<br>**ឡាវ**<br>(តែអន្តោប្រវេសន៍ខុសច្បាប់ និងពេស្យាកម្មប៉ុណ្ណោះ)<br>**ម៉ាឡេស៊ី**<br>(តែបទល្មើសដែលទាក់ទងនឹងអន្តោប្រវេសន៍ និងឯកសារប៉ុណ្ណោះ)<br>**មីយ៉ាន់ម៉ា**<br>(តែបទល្មើសជួញដូរមនុស្ស អន្តោប្រវេសន៍ ការងារ និងបទល្មើសដែលទាក់ទងនឹងឯកសារប៉ុណ្ណោះ)[39]<br><br>**ហ្វីលីពីន**<br>**វៀតណាម** |

រដ្ឋដែលព្រាង ឬកែប្រែច្បាប់របស់ខ្លួន គួរពិចារណាលើផលប៉ះពាល់ជាក់ស្តែងនៃវិធីសាស្ត្រណាមួយដែលពួកគេអនុវត្ត ព្រមទាំងដែនកំណត់ និងបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តន៍នីមួយៗ។

ច្បាប់គួរបញ្ជាក់ច្បាស់ដល់អ្នកអនុវត្តដែលកំពុងកាត់ទោស ឬការពារករណីដែលពាក់ព័ន្ធនឹងជនរងគ្រោះដោយការជួញដូរមនុស្ស អំពីរបៀបកំណត់ទំនាក់ទំនងរវាងបទល្មើស និងការជួញដូរមនុស្ស។

*នៅក្នុងយុត្តាធិការដែលអនុវត្តគំរូ 'ការបង្ខាប់បញ្ជា (compulsion model)'...*

វាជាការសំខាន់ដែលអ្នកអនុវត្ត ត្រូវយល់ពីវិធីសាស្ត្រគ្រប់បែបយ៉ាងដែលអ្នកជួញដូរមនុស្សអាចប្រើប្រាស់ ដើម្បីបំផ្លាញឆន្ទៈដោយសេរីរបស់ជនរងគ្រោះ។ រដ្ឋដែលអនុវត្តគំរូ "បង្ខិតបង្ខំ (compulsion model)" គួរយល់ពីការបង្ខិតបង្ខំឱ្យបានទូលំទូលាយ ដើម្បីបញ្ចូលរាល់ 'មធ្យោបាយ' ទាំងអស់ដែលអ្នកជួញដូរមនុស្សអាចប្រើប្រាស់ ដើម្បីបង្ខំជនរងគ្រោះជាមនុស្សពេញវ័យ ស្របតាមនិយមន័យអន្តរជាតិ និងនិយមន័យក្នុងតំបន់នៃការជួញដូរមនុស្ស។ ក្នុងយុត្តាធិការដែលអនុវត្តគំរូ "បង្ខិតបង្ខំ" ស្តង់ដារដែលទាមទារ មិនគួរដូចគ្នានឹងតម្រូវការដោយការការពារជាលក្ខណៈប្រពៃណីនៃការបង្ខិតបង្ខំ និងភាពចាំបាច់ដែលអាចតម្រូវឱ្យមានការគំរាមកំហែង ឬការស្លាប់ដែលកើតឡើង ឬអំពើហិង្សាលើរាងកាយ ដែលប្រាកដជានឹងកើតឡើងឡើយ។ ផ្ទុយទៅវិញ ស្តង់ដារបែបនេះគួរគិតពិចារណាអំពីវិធីកាន់តែល្អិតល្អន់ដែលជនរងគ្រោះដោយការជួញដូរមនុស្ស អាចត្រូវបាន 'បង្ខំ'។ ពោលគឺ គួរយល់ថា ជនរងគ្រោះអាចត្រូវបាន 'បង្ខំ' ឱ្យចូលរួមក្នុងសកម្មភាពល្មើសច្បាប់ តាមមធ្យោបាយនៃការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង ឬទម្រង់ដទៃទៀតនៃការបង្ខិតបង្ខំ ការចាប់ជំរិត ការបន្លំ ការឆបោក ការប្រើអំណាចរំលោភបំពាន ឬការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ ការផ្តល់ ឬការទទួលកម្រៃ ឬផលប្រយោជន៍នានា ដើម្បីសម្រេចបានការយល់ព្រមនៃមនុស្សម្នាក់ដែលមានអំណាចត្រួតត្រាលើមនុស្សណាម្នាក់ទៀត។[38]

ដូចគ្នាដែរ នៅពេលប្រើពាក្យ 'ការបង្ខំឱ្យប្រព្រឹត្តបទល្មើស' ដែលគេមិនគួរយល់ថា ទាល់តែជនរងគ្រោះត្រូវបានបង្ខំដោយកម្លាំងបាយឱ្យចូលរួមក្នុងសកម្មភាពបទឧក្រិដ្ឋ ប៉ុន្តែគួរយល់ថា វាបញ្ចូលមធ្យោបាយលាក់កំបាំងដែលអ្នកជួញដូរមនុស្សអាចប្រើប្រាស់ ដើម្បីកេងប្រវ័ញ្ចមនុស្សម្នាក់ រួមទាំងការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ។[39] ការប្រើប្រាស់ស្ថានភាពងាយរងគ្រោះមិនត្រឹមតែតម្រូវឱ្យមានអត្ថិភាពនៃភាពងាយរងគ្រោះរបស់ជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែក៏តម្រូវឱ្យមានការប្រើប្រាស់ស្ថានភាពងាយរងគ្រោះនោះដោយអ្នកជួញដូរមនុស្សផងដែរ។ ការណែនាំខាងក្រោមរបស់អង្គការសហប្រជាជាតិ ជួយឱ្យយល់ដឹងពី 'ការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ' សម្រាប់ជាមធ្យោបាយនៃការជួញដូរមនុស្ស។

ល្អបំផុត គួរវាយតម្លៃអត្ថិភាពនៃភាពងាយរងគ្រោះទៅតាមករណីនីមួយៗ ដោយពិចារណាលើស្ថានការណ៍ផ្ទាល់ខ្លួន ស្ថានភាព ឬកាលៈទេសៈរបស់ជនរងគ្រោះដែលរងការចោទប្រកាន់។ ឧទាហរណ៍ ភាពងាយរងគ្រោះផ្ទាល់ខ្លួនអាចទាក់ទង

[38] មធ្យោបាយទាំងនេះត្រូវបានបញ្ជាក់ទាំងក្នុងមាត្រា ២ នៃអនុសញ្ញា ACTIP និងមាត្រា ៣ នៃពិធីសារស្តីពីការជួញដូរមនុស្ស។

[39] សូមមើល៖ *ការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ និង 'មធ្យោបាយ' ផ្សេងទៀត ក្នុងនិយមន័យនៃការជួញដូរមនុស្ស* (UNODC ២០១៣) និងកំណត់សម្គាល់ណែនាំរបស់អង្គការសហប្រជាជាតិស្តីពី *ការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ ជាមធ្យោបាយនៃការជួញដូរមនុស្ស* ក៏មានផងដែរជាភាសា បាហាសាឥណ្ឌូនេស៊ី ភូមា ខ្មែរ ឡាវ ថៃ និងវៀតណាម។

នឹងពិការភាពផ្លូវកាយ ឬផ្លូវចិត្តរបស់បុគ្គល។ ភាពងាយរងគ្រោះក្នុងស្ថានភាពអាចទាក់ទងនឹងបុគ្គលដែលស្ថិតនៅបរទេសដោយខុសច្បាប់ ដែលគាត់ត្រូវបានកាត់ផ្តាច់ចេញពីសង្គម ឬភាសា។ ភាពងាយរងគ្រោះក្នុងកាលៈទេសៈអាចទាក់ទងនឹងភាពគ្មានការងារធ្វើ ឬភាពក្រខ្សត់របស់បុគ្គល។ ភាពងាយរងគ្រោះបែបនេះអាចមានស្រាប់ហើយ និងអាចត្រូវបានបង្កើតឡើងដោយអ្នកជួញដូរ មនុស្ស។ ភាពងាយរងគ្រោះដែលមានស្រាប់អាចទាក់ទងនឹង (ប៉ុន្តែមិនកំណត់ត្រឹម) ភាពក្រីក្រ ពិការភាពផ្លូវចិត្ត ឬផ្លូវកាយ ភាពក្មេង ឬចាស់ ភេទ ការមានផ្ទៃពោះ វប្បធម៌ ភាសា ជំនឿ ស្ថានភាពគ្រួសារ ឬស្ថានភាពខុសច្បាប់។ ភាពងាយរងគ្រោះដែលត្រូវបានបង្កើតឡើង អាចទាក់ទងនឹង (ប៉ុន្តែមិនកំណត់ត្រឹម) ការកាត់ផ្តាច់ចេញពីសង្គម វប្បធម៌ ឬភាសា ស្ថានភាពខុសច្បាប់ ឬការពឹងផ្អែកដែលបានបង្កើតឡើង តាមរយៈការញៀនគ្រឿងញៀន ឬចំណងស្នេហា ឬអារម្មណ៍ ឬតាមរយៈការប្រើពិធី ឬការអនុវត្តន៍ខាងវប្បធម៌ ឬសាសនា។

ជាពិសេស ភាពងាយរងគ្រោះរបស់ជនរងគ្រោះអាចជាសូចនាករបង្ហាញពី [ការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ] ប៉ុន្តែវានឹងមិនបង្កើតជាមធ្យោបាយនៃការជួញដូរមនុស្សឡើយ លុះត្រាតែស្ថានភាពងាយរងគ្រោះនោះត្រូវបានគេរំលោភបំពានដល់កម្រិតដែលមានការបដិសេធការយល់ព្រមរបស់ជនរងគ្រោះ។

ការបំពានលើស្ថានភាពងាយរងគ្រោះ កើតឡើងនៅពេលដែលភាពងាយរងគ្រោះផ្ទាល់ខ្លួន ស្ថានភាព ឬកាលៈទេសៈរបស់បុគ្គលម្នាក់ត្រូវបានគេប្រើដោយចេតនា ឬទាញប្រយោជន៍ ដើម្បីជ្រើសរើស ដឹកជញ្ជូន ផ្ទេរ ផ្តល់កន្លែងសំចត ឬទទួលបុគ្គលនោះ ក្នុងគោលបំណងកេងប្រវ័ញ្ចលើរូបគាត់ ដែលធ្វើឱ្យបុគ្គលនោះជឿថា ការធ្វើតាមឆន្ទៈរបស់អ្នករំលោភបំពាន គឺជាជម្រើសតែមួយគត់ដែលពិតប្រាកដ ឬអាចទទួលយកបាន ហើយជំនឿបែបនេះគឺសមហេតុផលទៅតាមស្ថានភាពរបស់ជនរងគ្រោះ។ ក្នុងការកំណត់ថាតើការណ៍ដែលជនរងគ្រោះជឿថា គាត់គ្មានជម្រើសដែលពិតប្រាកដ ឬអាចទទួលយកបាន គឺសមហេតុផល ឬអត់ គួរពិចារណាពីចរិតលក្ខណៈបុគ្គល និងកាលៈទេសៈរបស់ជនរងគ្រោះ។[40]

នៅក្នុងប្រទេសដែលច្បាប់កំណត់មធ្យោបាយដែលគេអាចប្រើប្រាស់ ដើម្បីកេងប្រវ័ញ្ចជនរងគ្រោះក្នុងសកម្មភាពល្មើសច្បាប់ គួរពិចារណាធ្វើវិសោធនកម្មច្បាប់ ឬចេញសេចក្តីណែនាំផ្នែកច្បាប់ ដើម្បីធានាថា ជនរងគ្រោះត្រូវបានការពារពីការដាក់ទោសទណ្ឌ ស្របតាមសិទ្ធិមនុស្សរបស់ពួកគេ។[41]

គំរូនេះមានលក្ខណៈទូលំទូលាយជាងលក្ខខណ្ឌនៃការបង្ខិតបង្ខំធម្មតា និងមិនគួរទាមទារភស្តុតាងដូចគ្នាឡើយ ព្រោះស្តង់ដារបែបនោះនឹងបដិសេធមិនឱ្យជនរងគ្រោះទទួលបានការការពារក្រោមគោលការណ៍នេះ។[42] អតីតអ្នករាយការណ៍

---

[40] *កំណត់សម្គាល់ណែនាំស្តីពី 'ការប្រើប្រាស់ភាពងាយរងគ្រោះ' ជាមធ្យោបាយនៃការជួញដូរមនុស្ស ក្នុងមាត្រា ៣ នៃពិធីសារដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង (UNODC,* ២០១២) កថាខណ្ឌ ២.៣ ដល់ ២.៥។

[41] ឧទាហរណ៍ ច្បាប់របស់ឥណ្ឌូនេស៊ីចែងថា "ជនរងគ្រោះដែលប្រព្រឹត្តបទល្មើសក្រោមការបង្ខិតបង្ខំដោយជនល្មើសដែលប្រព្រឹត្តអំពើព្រហ្មទណ្ឌនៃការជួញដូរមនុស្ស មិនត្រូវទទួលខុសត្រូវចំពោះការចោទប្រកាន់បទព្រហ្មទណ្ឌទេ" (មាត្រា ១៨, *ច្បាប់លេខ ២១ ស្តីពីការលុបបំបាត់អំពើព្រហ្មទណ្ឌ* នៃការជួញដូរមនុស្ស, ២០០៧)។ ក្នុងករណីនេះ គួរផ្តល់ការណែនាំដល់អ្នកអនុវត្តដើម្បីឱ្យពួកគេអាចយល់ដឹងពីវិធីជាច្រើនដែលជនរងគ្រោះអាចត្រូវបាន 'បង្ខិតបង្ខំ'។

[42] ការណែនាំស្តីពីការឆ្លើយតបសមស្របផ្នែកយុត្តិធម៌ព្រហ្មទណ្ឌចំពោះជនរងគ្រោះ ដែលត្រូវបានបង្ខំឱ្យប្រព្រឹត្តបទល្មើសដោយសារពួកគេត្រូវបានជួញដូរ ៖ ឯកសារសាវតារដែលរៀបចំឡើងដោយលេខាធិការដ្ឋានក្រុមការងារស្តីពីការជួញដូរមនុស្ស, វីយែន ថ្ងៃទី១០ និង ១១ ខែ កញ្ញា ឆ្នាំ ២០២០, ឯកសារ អ.ស.ប CTOC/COP/WG.4/2020/2 (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០), កថាខណ្ឌ ៦០។

ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ បានថ្លែងថា កម្រិតកំណត់សម្រាប់ប្រើប្រាស់បទចោទអ្វីមួយ គួរតែ "មិនទាមទារភស្តុតាងច្បាស់លាស់ តែផ្អែកលើមូលដ្ឋានសមហេតុផលដែលអាចជឿបានថា ការជួញដូរមនុស្សកំពុងកើតឡើង។"[43]

វិធានការការពារដែលអាចមានក្នុងច្បាប់ជាតិ គួរតែអនុវត្តចំពោះកុមារ ដោយមិនគិតពីមធ្យោបាយដែលបានប្រើប្រាស់ដើម្បីកេងប្រវ័ញ្ចពួកគេក្នុងសកម្មភាពបទឧក្រិដ្ឋ។ មិនចាំបាច់តម្រូវឱ្យបញ្ជាក់ពីមធ្យោបាយ ដើម្បីបង្ហាញថា កុមារត្រូវបានជួញដូរនោះទេ។ ដូច្នេះ ទំនាក់ទំនងរវាងស្ថានភាពរបស់ពួកគេក្នុងនាមជាជនរងគ្រោះដោយការជួញដូរមនុស្ស និងការចូលរួមរបស់ពួកគេក្នុងសកម្មភាពបទឧក្រិដ្ឋដែលបណ្តាលមកពីការជួញដូរនោះ គួរតែគ្រប់គ្រាន់ ដើម្បីអនុវត្តវិធានការការពារ។

***នៅក្នុងយុត្តាធិការដែលអនុវត្តគំរូ 'ហេតុ និងផល (causation model)'...***

គំរូ "ហេតុ និងផល" មិនទាមទារថា សកម្មភាពល្មើសច្បាប់ត្រូវតែបណ្តាលមកពីការប្រើប្រាស់មធ្យោបាយរបស់អ្នកជួញដូរមនុស្ស ដូចជា ការប្រើកម្លាំង ឬការបង្ខិតបង្ខំ ឬមធ្យោបាយផ្សេងទៀត ដើម្បី 'បង្ខំ' ពួកគេទេ។ ផ្ទុយទៅវិញ សកម្មភាពល្មើសច្បាប់របស់ពួកគេត្រូវតែជាលទ្ធផលដោយផ្ទាល់នៃការណ៍ដែលពួកគេត្រូវបានជួញដូរ។

អ្នកតាក់តែងច្បាប់គួរជានាថា មានការយល់យ៉ាងទូលំទូលាយអំពីពាក្យ ដូចជា 'ផលវិបាកដោយផ្ទាល់' ឬ 'លទ្ធផលដោយផ្ទាល់' និង 'ពាក់ព័ន្ធនឹង'។ អាចមានសំណួរពាក់ព័ន្ធនឹងពេលវេលា ពោលគឺថាតើ និងពេលណា ដែលពេលវេលាកន្លងផុតទៅ ឬការប្រែប្រួលកាលៈទេសៈ កាត់ផ្តាច់ទំនាក់ទំនងរវាងបទឧក្រិដ្ឋដែលបានចោទប្រកាន់ និងការជួញដូរមនុស្ស។ ការយល់ដឹងទូលំទូលាយ មិនទាមទារទំនាក់ទំនង 'ដោយផ្ទាល់ និងភ្លាមៗ' ទេ ប៉ុន្តែទទួលស្គាល់ថា អាចនៅតែមានទំនាក់ទំនងរវាងការជួញដូរមនុស្ស និងការប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់ ឧទាហរណ៍ ដោយសារការបន្តភ័យខ្លាច និងការបង្ខិតបង្ខំ។[44] ផ្ទុយទៅវិញ ជនរងគ្រោះដែលនៅតែស្ថិតក្នុងស្ថានភាពនៃការជួញដូរមនុស្ស អាចប្រព្រឹត្តបទល្មើសដែលមិនពាក់ព័ន្ធនឹងការជួញដូរមនុស្ស ដូច្នេះ ពួកគេនឹងមិនស្ថិតក្នុងវិសាលភាពនៃការការពារពីការដាក់ទោសទណ្ឌឡើយ។

អនុសញ្ញា ACTIP បានអនុវត្តគំរូ "ហេតុ និងផល"។ នេះក៏ជាគំរូដែលអ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស និងអ្នកជំនាញប្រឆាំងការជួញដូរមនុស្សផ្សេងទៀត និយមប្រើប្រាស់ផងដែរ ព្រោះវាមាន លក្ខណៈទូលំទូលាយ និងងាយស្រួលបញ្ជាក់ ជាងគំរូ "ការបង្ខិតបង្ខំ"។[45] គំរូ "ហេតុ និងផល" ជួយឱ្យគេទទួលស្គាល់ថា សកម្មភាពល្មើសច្បាប់កើតចេញពីកង្វះស្វ័យភាព និងឯករាជ្យភាពរបស់ជនរងគ្រោះ។ ដូច្នេះ ទំនាក់ទំនងរវាងបទល្មើសរបស់ជនរងគ្រោះ និងសកម្មភាពជួញ

---

43 ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ, ឯកសារ អ.ស.ប A/HRC/44/45 (ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០) [៣៦]

44 Ryszard Piotrowicz, *តើយើងអាចពង្រីកគោលការណ៍មិនដាក់ទណ្ឌកម្មបានឆ្ងាយប៉ុណ្ណា?* La Strada, ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១។

45 របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ, Maria Grazia Giammarinaro, ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០, ឯកសារ អ.ស.ប A/HRC/44/45, កថាខណ្ឌ. ៣៦។ ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ, Siobhán Mullaly, ឯកសារ អ.ស.ប A/HRC/47/34 (ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១) កថាខណ្ឌ ៥២

ជួរពួកគេ នឹងលេចឡើងយ៉ាងច្បាស់នៅពេលដែលជនរងគ្រោះត្រូវបានជួញដូរឱ្យប្រព្រឹត្តបទល្មើស ដូចជា ការដាំដុះ ឬការជួញដូរគ្រឿងញៀន ការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ឬការលួចហោប៉ៅ។

**បញ្ជាក់ច្បាស់អំពីបន្ទុក និងស្តង់ដារភស្តុតាងដែលត្រូវការចាំបាច់**

ការបញ្ជាក់ភស្តុតាង ដើម្បីកំណត់ទំនាក់ទំនងរវាងការជួញដូរមនុស្ស និងសកម្មភាពល្មើសច្បាប់របស់ជនរងគ្រោះ គឺជាបន្ទុករបស់រដ្ឋ។ បទបញ្ញត្តិមិនដាក់ទោសទណ្ឌ អាចព្រាងឡើងតាមរបៀបដែលដាក់បន្ទុកលើចុងចោទដែលជាជនរងគ្រោះ ឱ្យផ្តល់ភស្តុតាងបញ្ជាក់ថា គាត់គឺជាជនរងគ្រោះដោយការជួញដូរមនុស្ស។ ជាក់ស្តែង ជនរងគ្រោះអាចពិបាកបញ្ជាក់ពីភាពរងគ្រោះរបស់ពួកគេ ជាពិសេសនៅក្នុងយុត្តាធិការដែលការកេងប្រវ័ញ្ចក្នុងសកម្មភាពបទឧក្រិដ្ឋ មិនត្រូវបានទទួលស្គាល់ថាជាទម្រង់នៃការជួញដូរមនុស្ស ក្នុងច្បាប់ជាតិ។[46] ការដាក់បន្ទុកភស្តុតាងលើជនរងគ្រោះ ផ្ទុយនឹងការអនុវត្តន៍ល្អបំផុតនៃការធានាថា រដ្ឋតែងតែជាអ្នករ៉ាប់រងបន្ទុកនោះ ស្របតាមកាតព្វកិច្ចរបស់រដ្ឋក្នុងការកំណត់អត្តសញ្ញាណ និងការពារជនរងគ្រោះយ៉ាងសកម្ម។ ហេតុនេះ អាចពិចារណាកែប្រែច្បាប់ដើម្បីធានាថា រដ្ឋតែងតែជាអ្នកដែលត្រូវផ្តល់បន្ទុកភស្តុតាងដើម្បីបញ្ជាក់ថា មិនអាចអនុវត្តវិធានការការពារបានឡើយ ព្រោះជនរងគ្រោះមានចេតនាឧក្រិដ្ឋដែលត្រូវការចាំបាច់ ហើយការប្រើប្រាស់មធ្យោបាយរបស់អ្នកជួញដូរមនុស្សមិនធ្វើឱ្យខូចដល់ចេតនាឧក្រិដ្ឋនោះ។[47]

ទាក់ទងនឹងស្តង់ដារនៃការបញ្ជាក់ភស្តុតាងដែលត្រូវការចាំបាច់ ការណែនាំសម្រាប់ក្រុមការងារស្តីពីការជួញដូរមនុស្សក្រោមសន្និសីទនៃរដ្ឋភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន បានកំណត់ថា ជនរងគ្រោះដោយការជួញដូរមនុស្សដែលត្រូវបានចោទប្រកាន់បទល្មើស មិនចាំបាច់បញ្ជាក់ពីអត្ថិភាពនៃវិធានការការពារ ហួសពីវិមតិសង្ស័យទេ។ ផ្ទុយទៅវិញ ការផ្តន្ទាទោសត្រូវបញ្ជាក់ថា មិនអាចអនុវត្តវិធានការការពារបានឡើយ៖

ជនជាប់ចោទ មិនគួរត្រូវបានទាមទារឱ្យបញ្ជាក់ពីអត្ថិភាពនៃវិធានការការពារ ហួសពីវិមតិសង្ស័យ ឬសូម្បីតែផ្អែកលើភាពតុល្យភាពនៃលទ្ធភាពនានា ព្រោះការធ្វើបែបនេះអាចរំលោភលើការសន្មតទុកជាមុនថាគ្មានទោស។ នៅពេលដែលវិធានការការពារបានក្លាយជាបញ្ហាពិតប្រាកដក្នុងការជំនុំជម្រះ ព្រះរាជអាជ្ញាគួរតែត្រូវបានតម្រូវឱ្យបង្ហាញ ហួសពីវិមតិសង្ស័យ ថាវាមិនអាចអនុវត្តបាននោះទេ។[48]

ប្រហែលជាត្រូវអនុម័ត ឬកែប្រែច្បាប់ ដើម្បីបញ្ជាក់ច្បាស់ដល់អ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌថា នៅពេលមានការលើកឡើងពីវិធានការការពារ រដ្ឋ (ព្រះរាជអាជ្ញា) ជាអ្នកដែលត្រូវបង្ហាញថា វិធានការការពារទាំងនោះមិនអាចអនុវត្តបានឡើយ។

---

46 ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកគ្រឿងញៀន និងបទឧក្រិដ្ឋ, ស្ត្រីជាជនរងគ្រោះដោយការជួញដូរមនុស្សសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ ក្នុងនាមជាចុងចោទ៖ ការវិភាគច្បាប់យុត្តិសាស្ត្រ (អង្គការសហប្រជាជាតិ, វីយែន, ២០២០) ៦, ៧៦-៩៣

47 សេចក្តីសម្រេចឆ្នាំ ២០១៨ ដោយសាលាឧទ្ធរណ៍នៃចក្រភពអង់គ្លេស បានសម្រេចថា ការបង្ហាញភស្តុតាងគួរតែជាបន្ទុករបស់អយ្យការ មានន័យថា ព្រះរាជអាជ្ញាគួរតែជាអ្នកដែលត្រូវបដិសេធការអនុវត្តន៍វិធានការការពារដែលមានចែងក្នុងច្បាប់ ហួសពីវិមតិសង្ស័យ។ ការពិនិត្យឡើងវិញដោយឯករាជ្យលើច្បាប់ស្តីពីទាសភាពសម័យទំនើបឆ្នាំ ២០១៥ ៖ របាយការណ៍ចុងក្រោយ (រដ្ឋលេខាធិការក្រសួងមហាផ្ទៃ, ២០១៩) ១៨, ដោយយោងទៅលើ MK v R [២០១៨] EWCA Crim ៦៦៧

48 ការណែនាំស្តីពីការឆ្លើយតបសមស្របផ្នែកយុត្តិធម៌ព្រហ្មទណ្ឌចំពោះជនរងគ្រោះដែលត្រូវបានបង្ខំឱ្យប្រព្រឹត្តបទល្មើ ដោយសារពួកគេត្រូវបានជួញដូរ ៖ ឯកសារសាវតារដែលរៀបចំឡើងដោយលេខាធិការដ្ឋានក្រុមការងារស្តីពីការជួញដូរមនុស្ស, វីយែន ថ្ងៃទី១០ និង ១១ ខែកញ្ញា ឆ្នាំ២០២០, ឯកសារ អ.ស.ប CTOC/COP/WG.4/2020/2 (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០), កថាខណ្ឌ ៦៥។

## រៀបចំ និងផ្សព្វផ្សាយគោលការណ៍ណែនាំផ្នែកច្បាប់ស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្ម

ពេលខ្លះ អ្នកជំនាញក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌអាចមិនយល់ច្បាស់អំពីរបៀបកំណត់ទំនាក់ទំនងរវាងការប្រព្រឹត្តបទល្មើសរបស់ជនរងគ្រោះ និងសកម្មភាពនៃការជួញដូរជនរងគ្រោះ ដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម។ ដោយមិនគិតថាតើរដ្ឋបានអនុវត្តគំរូ "ការបង្ខិតបង្ខំ (compulsion) ឬហេតុ និងផល (causation)" គំរូទាំងពីរនេះ ឬគំរូមួយផ្សេងទៀត អ្នកជំនាញត្រូវតែយល់ពីគំរូទាំងនេះសិន។

ក្រោមការពិគ្រោះជាមួយអ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌ ស្ថាប័នអន្តរក្រសួងប្រឆាំងការជួញដូរមនុស្ស គួរពិចារណាអភិវឌ្ឍគោលការណ៍ណែនាំស្តីពីបទបញ្ញត្តិមិនដាក់ទោសទណ្ឌ និងច្បាប់ផ្សេងទៀតដែលអាចពាក់ព័ន្ធនឹងការមិនដាក់ទោសទណ្ឌ និងផ្សព្វផ្សាយលិខិតុបករណ៍ទាំងនោះដល់អ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌដែលអាចមិនដឹងថាមានបទបញ្ញត្តិទាំងនេះ ឬមិនដឹងពីរបៀបអនុវត្តបទបញ្ញត្តិទាំងនេះ។ គោលការណ៍ណែនាំបែបនេះមានសារៈសំខាន់ណាស់ ព្រោះវាធានាថា ព្រះរាជអាជ្ញា មេធាវីការពារក្តី និងមន្ត្រីតុលាការនឹងអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មឱ្យបានជាប់លាប់ និងជាប្រព័ន្ធនៅក្នុងប្រព័ន្ធយុត្តិធម៌ទាំងមូល។

ការណែនាំសម្រាប់អ្នកអនុវត្តគួរផ្តល់ការពន្យល់ជាភាសាដែលច្បាស់ៗ និងបង្កភាពងាយស្រួលៈ

ថាតើទំនាក់ទំនងរវាងសកម្មភាពល្មើសច្បាប់របស់ជនរងគ្រោះ និងការជួញដូរជនរងគ្រោះ ត្រូវបានសន្មតដោយផ្អែកលើគំរូ "ការបង្ខិតបង្ខំ (compulsion) ឬហេតុ និងផល (causation)"

របៀបដែលព្រះរាជអាជ្ញា និងមេធាវីការពារក្តី អាចនាំយកភស្តុតាង ដើម្បីកំណត់ថា បទល្មើសរបស់ជនរងគ្រោះ ពាក់ព័ន្ធ ឬមិនពាក់ព័ន្ធនឹងការជួញដូរជនរងគ្រោះ

ថា ពិធីសារស្តីពីការជួញដូរមនុស្ស និងអនុសញ្ញា ACTIP អាចយកជាសំអាង ក្នុងករណីគ្មានបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌក្នុងច្បាប់ជាតិ និង/ឬបំពេញបន្ថែមលើបទបញ្ញត្តិក្នុងច្បាប់ជាតិដែលកម្រិតវិសាលភាពនៃការការពារ

ថា លិខិតុបករណ៍អន្តរជាតិ និងលិខិតុបករណ៍ថ្នាក់តំបន់ស្តីពីការប្រឆាំងការជួញដូរមនុស្ស និងសិទ្ធិមនុស្ស មានសារៈសំខាន់សម្រាប់ការបកស្រាយលក្ខណ្ឌនៃការបង្ខិតបង្ខំ និងភាពចាំបាច់ នៅពេលដែលបុគ្គលម្នាក់បានប្រព្រឹត្តបទល្មើស ក្នុងបរិបទនៃការជួញដូរមនុស្ស។

វាមានសារៈសំខាន់ណាស់ក្នុងការផ្តល់ឯកសារណែនាំណាមួយដល់អ្នកអនុវត្តន៍ ក្នុងវិស័យប្រឆាំងការជួញដូរមនុស្ស ក៏ដូចជាអ្នកអនុវត្តទូទៅដែលអាចចូលរួមក្នុងការផ្តន្ទាទោស ឬការការពារមនុស្ស ទាក់ទងនឹងបទល្មើសដែលអាចប្រព្រឹត្តដោយជនរងគ្រោះដោយការជួញដូរមនុស្ស។ ដូច្នេះ គោលការណ៍ណែនាំគួរលើកឡើងពីបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្សក៏ដូចជាបទបញ្ញត្តិក្នុងច្បាប់ផ្សេងទៀតដែលអាចជាប្រយោជន៍ដល់ការការពារជនរងគ្រោះពីការដាក់ទោសទណ្ឌ។

## [២] ពង្រឹងបទបញ្ញត្តិផ្សេងទៀត (ដែលមិនពាក់ព័ន្ធនឹងការជួញដូរមនុស្ស) ដើម្បីការពារជនរងគ្រោះពីការដាក់ទោសទណ្ឌ

ក្រៅពីច្បាប់ស្តីពីការជួញដូរមនុស្ស (ដែលបានលើកមកពិភាក្សាក្នុងផ្នែក [១] ខាងលើ) រដ្ឋគួរពិចារណាអនុម័ត ឬកែប្រែច្បាប់ផ្សេងទៀត ដើម្បីកាត់បន្ថយហានិភ័យដែលជនរងគ្រោះដោយការជួញដូរមនុស្ស ត្រូវបានកាត់ទោសខុស សម្រាប់បទល្មើសដែលពួកគេបានប្រព្រឹត្ត ដោយសារពួកគេត្រូវបានជួញដូរ។ រដ្ឋអាចពិចារណាធ្វើវិសោធនកម្មច្បាប់ ដើម្បីកាត់បន្ថយហានិភ័យនៃការអនុវត្តន៍មិនបានត្រឹមត្រូវនូវច្បាប់អន្តោប្រវេសន៍ និងវិធានការគ្រប់គ្រងព្រំដែនផ្សេងទៀត ដើម្បីដាក់ជនរងគ្រោះដោយការជួញដូរមនុស្សឱ្យស្ថិតក្រោមទណ្ឌកម្មព្រហ្មទណ្ឌ និង/ឬទណ្ឌកម្មរដ្ឋបាល សម្រាប់ការរំលោភច្បាប់អន្តោប្រវេសន៍។ អ្នកអនុវត្តអាចរកឃើញបទបញ្ញត្តិជាក់លាក់ដែលជួយឱ្យពួកគេអនុវត្តបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌប្រកបដោយប្រសិទ្ធភាព ជំនួសឱ្យ ឬបំពេញបន្ថែមលើបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌ ដែលអាចមានចែងក្នុងច្បាប់ជាតិ។ ផ្នែកនេះផ្តល់គោលការណ៍ណែនាំស្តីពីឱកាសបន្ថែមទៀតដែលរដ្ឋអាចចាប់យក ដើម្បីពង្រឹងការការពារក្នុងទម្រង់ជាការមិនដាក់ទោសទណ្ឌ នៅក្នុងច្បាប់ជាតិរបស់ខ្លួន លើសពីការប្រើប្រាស់បទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌ។

**ពិនិត្យលទ្ធភាពកែសម្រួលបទបញ្ញត្តិព្រហ្មទណ្ឌ និងបទបញ្ញត្តិរដ្ឋបាល ដើម្បីកាត់បន្ថយហានិភ័យនៃការកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្ស**

រដ្ឋគួរពិចារណាកែប្រែច្បាប់ ដែលធ្វើឱ្យជនរងគ្រោះងាយប្រឈមនឹងការផ្តន្ទាទោស។ ឧទាហរណ៍ ការពិចារណាគួរផ្តោតលើរបៀបការពារជនរងគ្រោះពីបទល្មើសដែលមិនចាំបាច់មានការបញ្ជាក់ពីធាតុផ្សំអត្តនោម័ត (strict liability offences)។ ឧទាហរណ៍ ការអនុវត្តន៍បទបញ្ញត្តិព្រហ្មទណ្ឌ ឬបទបញ្ញត្តិរដ្ឋបាលសម្រាប់បទល្មើសអន្តោប្រវេសន៍ លើជនចំណាកស្រុកខុសច្បាប់ដែលជាជនរងគ្រោះដោយការជួញដូរមនុស្ស អាចរំលោភលើគោលការណ៍មិនដាក់ទណ្ឌកម្ម។ បទល្មើសដែលទាក់ទងនឹងសារធាតុញៀន អាចធ្វើឱ្យជនរងគ្រោះដែលត្រូវបានជួញដូរទៅក្នុងសកម្មភាពទាក់ទងនឹងគ្រឿងញៀនទាំងនោះ ប្រឈមនឹងការផ្តន្ទាទោស ដែលអាចបណ្តាលឱ្យមានការធ្វើទណ្ឌកម្មរាងកាយ ឬការប្រហារជីវិត។ មួយវិញទៀត អាចពិចារណាធ្វើវិសោធនកម្មច្បាប់ដែលហាមឃាត់ការប្រកបរបរផ្លូវភេទ សម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស និងក្រុមជួបការលំបាក និងងាយរងគ្រោះផ្សេងទៀត។ សម្រាប់កុមារ ការធ្វើឱ្យអាយុពេញវ័យក្លាយជាធាតុផ្សំនៃបទល្មើសដែលទាក់ទងនឹងឧស្សាហកម្មផ្លូវភេទ អាចមានន័យថា គេមិនអាចផ្តន្ទាទោសកុមារទៅតាមផ្លូវច្បាប់ (រួមទាំងជនរងគ្រោះដោយការជួញដូរមនុស្ស ក្នុងចំណោមកុមារទាំងនោះ) សម្រាប់ការពាក់ព័ន្ធរបស់ពួកគេបានឡើយ។[49]

---

[49] ឯកអគ្គរដ្ឋទូតជាន់ខ្ពស់ John Cotton Richmond ថ្លែងក្នុងកិច្ចពិភាក្សាគណៈកម្មការយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិត, Dressember និង Karana Rising, ម៉ោង ៧ ល្ងាច ET, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១។

**ប្រអប់៖ ឧទាហរណ៍**

នៅអាហ្សង់ទីន ការគ្មាន 'ការបង្ខំឱ្យប្រព្រឹត្តបទល្មើស' ជាគោលបំណងដាក់លាក់នៃការជួញដូរមនុស្ស ធ្វើឱ្យជនរងគ្រោះដោយការជួញដូរមនុស្សដែលត្រូវបានកេងប្រវ័ញ្ចឱ្យធ្វើជាអ្នករត់ពន្ធគ្រឿងញៀន មិនត្រូវបានកំណត់អត្តសញ្ញាណត្រឹមត្រូវជាជនរងគ្រោះ ប៉ុន្តែផ្ទុយទៅវិញ ត្រូវបានកាត់ទោសពីបទល្មើសគ្រឿងញៀន។ និយាយពីបញ្ហានេះ អ្នកការពារក្តីសហព័ន្ធម្នាក់បានកត់សម្គាល់ថា ពន្ធនាគារ "...ពេញដោយតំណភ្ជាប់ចុងក្រោយនៃអង្គការជួញដូរគ្រឿងញៀន ដែលប្រើស្ត្រីខ្វះខាត ជនមានពិការភាព និងក្នុងករណីជាច្រើន មនុស្សមិនចេះអក្សរ ដើម្បីបង្វែរចំណាប់អារម្មណ៍របស់អាជ្ញាធរ។" [52]

ដើម្បីប្រឈមមុខនឹងបញ្ហាប្រឈមនេះ ក្រសួងការពារសាធារណៈបានស្នើសុំឱ្យធ្វើវិសោធនកម្មច្បាប់ស្តីពីគ្រឿងញៀន ដើម្បីលើកលែងការទទួលខុសត្រូវខាងព្រហ្មទណ្ឌសម្រាប់អ្នកដែលត្រូវបានជួញដូរឱ្យដឹកជញ្ជូនសារធាតុញៀន ដែលត្រូវបានកំណត់ថាជាអ្នករត់ពន្ធគ្រឿងញៀន។ [50]

## កំណត់អាយុអប្បបរមាសមស្របសម្រាប់ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ

សម្រាប់គោលបំណងនៃការកំណត់អត្តសញ្ញាណ និងការការពារជនរងគ្រោះដោយការជួញដូរមនុស្ស កុមារគឺជាបុគ្គលដែលមានអាយុក្រោម ១៨ ឆ្នាំ។[51]

ដើម្បីការពារជនរងគ្រោះជាកុមារពីការកាត់ទោស ចាំបាច់ត្រូវកំណត់អាយុអប្បបរមាសមស្របសម្រាប់ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដើម្បីធានាការប្រព្រឹត្តសមស្របចំពោះកុមារដែលមានអាយុលើស ឬតិចជាងអាយុអប្បបរមានោះ។[52] មាត្រា ៤០ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ មិនបញ្ជាក់ពីអាយុអប្បបរមាសម្រាប់ការទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ ប៉ុន្តែគណៈកម្មាធិការសិទ្ធិកុមារ លើកទឹកចិត្តរដ្ឋឱ្យកត់សម្គាល់ភស្តុតាងវិទ្យាសាស្ត្រ និងបង្កើនអាយុសម្រាប់ការទទួលខុសត្រូវខាងព្រហ្មទណ្ឌដល់ ១៤ឆ្នាំ និងផ្តល់ឱ្យពួកគេនូវអត្ថប្រយោជន៍នៃការសង្ស័យ ប្រសិនបើមិនអាចបញ្ជាក់អាយុរបស់កុមារបាន។[53]

---

[50] Jean-Pierre Gauci និង Noemi Magugliani, *ការជួញដូរមនុស្ស និងសិទ្ធិរបស់ជនដែលត្រូវបានជួញដូរ៖ ការវិភាគបែបស្រាវជ្រាវលើការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម* (BIICL និង IBA, ២០២៣), ទំព័រ៣៤, យោងតាម Ministerio Público de la Defensa, *'El MPD planteó ante el Senado la necesidad de la reforma de la Ley de drogas'* (២០២០)

[51] ពិធីសារស្តីពីការជួញដូរមនុស្ស មាត្រា ៣(ឃ) អនុសញ្ញា ACTIP មាត្រា ២(ឃ)។

[52] មតិយោបល់ទូទៅលេខ ២៤ (២០១៩) ស្តីពីសិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌កុមារ, ឯកសារ អ.ស.ប CRC/C/GC/24, ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ [៦]

[53] មតិយោបល់ទូទៅលេខ ២៤ (២០១៩) ស្តីពីសិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌កុមារ, ឯកសារ អ.ស.ប CRC/C/GC/24, ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ [២២-២៤]

**ខិតខំកែប្រែ ឬអនុម័តច្បាប់ ដើម្បីអាចឱ្យមានការធ្វើមោឃភាព លុបចោល ឬបិទកំណត់ត្រាបទល្មើសរបស់ជនរងគ្រោះ**

រដ្ឋគួរពិនិត្យលទ្ធភាពកែសម្រួល ឬដាក់ចេញច្បាប់ថ្មី ដើម្បីអាចឱ្យមានការធ្វើមោឃភាព (ការផ្តន្ទាទោសត្រូវបានលើកលែង) លុបចោល (ការផ្តន្ទាទោសនៅតែមាន ប៉ុន្តែត្រូវបានដកចេញពីកំណត់ត្រាបទល្មើសរបស់ជនរងគ្រោះ) ឬបិទ (ការផ្តន្ទាទោសនៅតែមាន ប៉ុន្តែចាំបាច់ត្រូវមានដីកាតុលាការ ដើម្បីអាចចូលមើលកំណត់ត្រានោះបាន) ការផ្តន្ទាទោស និងកំណត់ត្រាបទល្មើសរបស់ជនរងគ្រោះដែលត្រូវបានជួញដូរ។

ច្បាប់បែបនេះ គឺជាដំណោះស្រាយដ៏សំខាន់សម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស ដើម្បីឱ្យ ពួកគេអាចបន្តជីវិតរស់នៅបាន។ ទោះបីជាពួកគេអាចបានរងទោសរួចទៅហើយ តាមរយៈការចាប់ខ្លួន ការកាត់ទោស និងការផ្តន្ទាទោសក៏ដោយ ប៉ុន្តែការធ្វើមោឃភាពការផ្តន្ទាទោស អាចជួយស្តារជំនឿទុកចិត្តរបស់ជនរងគ្រោះលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលពីមុនមក ចាត់ទុកពួកគេប្រៀបដូចជាឧក្រិដ្ឋជន។ ការធ្វើដូច្នេះអាចរំដោះពួកគេចេញពីភាពអាម៉ាស់ និងលុបបំបាត់របាំងរារាំងឱកាស។[54]

[54] សូមមើលគោលការណ៍ណែនាំទី ១៤។

# ផ្នែកទី ៣

# ការអនុវត្តន៍គោលការណ៍ ការមិនដាក់ទណ្ឌកម្ម ក្នុងការពិនិត្យបឋម និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស

## ផ្នែកទី ៣: ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មក្នុងការពិនិត្យបឋម និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស

ក្រោមច្បាប់អន្តរជាតិ និងច្បាប់ថ្នាក់តំបន់ រដ្ឋមានកាតព្វកិច្ចកំណត់វិធីសាស្ត្រគ្រប់ជ្រុងជ្រោយ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការពារជនរងគ្រោះដោយការជួញដូរមនុស្ស។ ការបំពេញកាតព្វកិច្ចទាំងនេះអាចទាមទារកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពរបស់អាជ្ញាធរអនុវត្តច្បាប់ អាជ្ញាធរអន្តោប្រវេសន៍ និងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត ក្នុងការកំណត់អត្តសញ្ញាណជនបង្ក ជនរងគ្រោះ និងស្ថានភាពនៃការជួញដូរមនុស្ស។

គោលការណ៍មិនដាក់ទណ្ឌកម្មត្រូវតែអនុវត្តទាំងក្នុងការពិនិត្យបឋម និងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងក្នុងដំណើរការនៃការការពារ និងផ្តល់ជំនួយដែលពួកគេទទួលបាន។ ការពិនិត្យបឋមសំដៅលើដំណើរការដែលសន្មតបុគ្គលម្នាក់ជាជនរងគ្រោះដោយការជួញដូរមនុស្ស ដោយផ្អែកលើសញ្ញា ឬសូចនាករដែលលេចឡើងតាមរយៈការសង្កេត ឬការប្រាស្រ័យទាក់ទងជាមួយបុគ្គលនោះ។ ការកំណត់អត្តសញ្ញាណសំដៅលើដំណើរការផ្លូវការ ដែលអាជ្ញាធរមានសមត្ថកិច្ចធ្វើការកំណត់ជាផ្លូវការថា បុគ្គលម្នាក់គឺជាជនរងគ្រោះដោយការជួញដូរមនុស្ស ហើយដូច្នេះ គាត់អាចទទួលបានសិទ្ធិ និងអត្ថប្រយោជន៍ជាច្រើនដោយផ្អែកលើស្ថានភាពនោះ។[55] គួរអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចកំណត់ថាមានទំនាក់ទំនងគ្រប់គ្រាន់រវាងសកម្មភាពល្មើសច្បាប់ និងការជួញដូរអ្នកដែលអាចជាជនរងគ្រោះ/អ្នកដែលសន្មតថាជាជនរងគ្រោះ ដើម្បីចាត់ទុកគាត់ជាជនរងគ្រោះដោយការជួញដូរមនុស្ស សម្រាប់គោលបំណងកំណត់អត្តសញ្ញាណ។

ការពិនិត្យ និងការកំណត់អត្តសញ្ញាណជនរងគ្រោះបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព គឺជាចំណុចចាប់ផ្តើមសម្រាប់ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម។ ប្រសិនបើជនរងគ្រោះដោយការជួញដូរមនុស្សមិនត្រូវបានពិនិត្យថាជាអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស ពួកគេមិនអាចទទួលបានការការពារពីការដាក់ទោសទណ្ឌឡើយ។ នៅពេលដែលបុគ្គលម្នាក់ត្រូវបានគេចាត់ទុកប្រៀបដូចជា ជនល្មើស គេពិបាកនឹងបង្វែរគាត់ទៅរកការការពារណាស់។ ដូច្នេះ គួរអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម មុនពេលចាប់ផ្តើមដំណើរការយុត្តិធម៌ព្រហ្មទណ្ឌណាមួយ គឺនៅពេលដែលអាជ្ញាធរជួបប្រទះបុគ្គលដែលពួកគេសន្មតថាជាជនរងគ្រោះដោយការជួញដូរមនុស្ស។ ក្នុងករណីដែលមានសូចនាករនៃការជួញដូរមនុស្ស មន្ត្រីជួរមុខគួរបញ្ជូនអ្នកដែលសន្មតថាជាជនរងគ្រោះ ទៅយន្តការបញ្ជូនថ្នាក់ជាតិ។ ក្នុងករណីកុមារ ឬបុគ្គលដែលសង្ស័យថាជាកុមារ គួរធ្វើការវាយតម្លៃ និងការកំណត់ផលប្រយោជន៍ល្អបំផុតជាមុនសិន រួចទាក់ទងទៅសេវាការពារកុមារ។

ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម មិនគួរផ្អែកលើលក្ខខណ្ឌនៃការកំណត់អត្តសញ្ញាណជនរងគ្រោះជាផ្លូវការ ឬការកាត់ទោសអ្នកជួញដូរមនុស្សដែលត្រូវបានចោទប្រកាន់នោះទេ ហើយវាក៏មិនគួរផ្អែកលើលក្ខខណ្ឌនៃកិច្ចសហការរបស់ជនរងគ្រោះជាមួយអាជ្ញាធរក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌដែរ។ អ្នកអនុវត្តមិនមែនកំពុងជួយដល់ជនរងគ្រោះ ដោយការកំណត់

55 សូមមើលឧទាហរណ៍, Surtees, Rebecca និង Laura S. Johnson, *ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស៖ គោលការណ៍ណែនាំសម្រាប់អ្នកអនុវត្តន៍* (បាងកក៖ ការិយាល័យគាំទ្រថ្នាក់តំបន់នៃដំណើរការបាលី (RSO) និងវ៉ាស៊ីនតោន ឌីស៊ី៖ NEXUS Institute, ២០២១) ទំព័រ ២

អត្តសញ្ញាណពួកគេថាជាជនរងគ្រោះដោយការជួញដូរមនុស្សនោះទេ។ ផ្ទុយទៅវិញ ពួកគេកំពុងបំពេញកាតព្វកិច្ចផ្លូវច្បាប់របស់ខ្លួន និងត្រូវការការគាំទ្រពីជនរងគ្រោះដើម្បីអនុវត្តតួនាទីរបស់ពួកគេប្រកបដោយប្រសិទ្ធភាព។

ការឆ្លើយតបប្រឆាំងការជួញដូរមនុស្ស ទាមទារឱ្យមានយន្តការដើម្បីធានាថា ជនរងគ្រោះអាចទទួលបានយុត្តិធម៌ និងរាយការណ៍ទៅមន្ត្រីប្រកបដោយសុវត្ថិភាព ដោយមិនភ័យខ្លាចថា ពួកគេនឹងត្រូវបានឃុំខ្លួន និរទេស ឬដាក់ទោសតាមវិធីផ្សេងទៀត។ គួរឱ្យសោកស្ដាយដែលរដ្ឋជាច្រើនបានចាត់វិធានការប្រតិកម្មខ្លាំង ជាជាងស៊ើបអង្កេតករណីជួញដូរមនុស្សយ៉ាងសកម្ម ព្រោះអាជ្ញាធរអាចពឹងផ្អែកលើជនរងគ្រោះដើម្បីកំណត់អត្តសញ្ញាណពួកគេ។[56] ប៉ុន្តែក្នុងការអនុវត្តន៍ជាក់ស្តែង មនុស្សភាគច្រើនដែលជាជនរងគ្រោះដោយការជួញដូរមនុស្សមិនកំណត់អត្តសញ្ញាណខ្លួនឯងទេ។ ជនរងគ្រោះខ្លះអាចមិនទទួលស្គាល់ថា ពួកគេជាជនរងគ្រោះដោយការជួញដូរមនុស្ស សូម្បីតែបន្ទាប់ពីពេលដែលពួកគេត្រូវបានកំណត់អត្តសញ្ញាណក៏ដោយ។ មានហេតុផលជាច្រើនដែលជនរងគ្រោះអាចមិនចង់ត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះ ដូចជា ការភ័យខ្លាចការសងសឹកដោយអ្នកជួញដូរមនុស្ស ឬភាពស្មោះត្រង់របស់ពួកគេចំពោះជនទាំងនោះ ក៏ដូចជាការបារម្ភខ្លាចការដាក់ទោសទណ្ឌដោយមន្ត្រីរដ្ឋ។ ការកំណត់អត្តសញ្ញាណដោយខ្លួនឯង មិនមែនជាការទទួលខុសត្រូវរបស់ជនរងគ្រោះទេ។ ផ្ទុយទៅវិញ វាជាការទទួលខុសត្រូវរបស់មន្ត្រីរដ្ឋក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស និងបញ្ជូនពួកគេទៅបណ្តាញការពារ និងជំនួយ។ មន្ត្រីជួរមុខដែលយល់ពីស្ថានភាពផ្លូវចិត្តរបស់មនុស្សដែលពួកគេជួបប្រទះ អាចធ្វើការពិនិត្យប្រកបដោយប្រសិទ្ធភាពបំផុត។ ដូច្នេះ រដ្ឋគួរអនុវត្តវិធីសាស្ត្រពិនិត្យ និងកំណត់អត្តសញ្ញាណដែលផ្អែកលើសិទ្ធិមនុស្ស គិតគូរពីយេនឌ័រ យកចិត្តទុកដាក់ចំពោះជនរងគ្រោះ និងផ្អែកតាមរបួសផ្លូវចិត្ត និងច្រើនតែទទួលបានលទ្ធផលពិនិត្យកាន់តែសុក្រឹត។[57]

គោលការណ៍ណែនាំខាងក្រោមគឺសម្រាប់ជួយរដ្ឋក្នុងការពង្រឹងសមត្ថភាពមន្ត្រីជួរមុខ ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះដែលពាក់ព័ន្ធក្នុងទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ច រួមទាំងក្នុងសកម្មភាពល្មើសច្បាប់ និងបញ្ជូនពួកគេទៅកាន់បណ្តាញការពារ ប្រកបដោយប្រសិទ្ធភាព។

---

56 *របាយការណ៍សកលស្តីពីការជួញដូរមនុស្សឆ្នាំ ២០២២* (UNODC, ២០២៣) បានបង្ហាញថា ជនរងគ្រោះភាគច្រើននៅក្នុងរឿងក្តីដែលបានវិនិច្ឆ័យគឺ 'ជនរងគ្រោះដែលជួយសង្គ្រោះខ្លួនឯង' មានន័យថា ការខិតខំកំណត់អត្តសញ្ញាណនៅតែមានកម្រិត។

57 សូមមើលឧទាហរណ៍, *វិធីសាស្ត្រដែលផ្អែកលើសិទ្ធិមនុស្ស គិតគូរពីយេនឌ័រ និងយកចិត្តទុកដាក់លើកុមារ ចំពោះករណីជួញដូរមនុស្សសម្រាប់មន្ត្រីជួរមុខ៖ សៀវភៅបណ្តុះបណ្តាល* (គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស, ២០២៣) ទំព័រ ៣៦ និង *គោលការណ៍ណែនាំរបស់អាស៊ានស្តីពី "ការមិនបង្កគ្រោះថ្នាក់" សម្រាប់អ្នកឆ្លើយតបជួរមុខ* (គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស និង ASEAN-ACWC) ទំព័រ ៧១-៧២

### *[៣] ពង្រឹងសមត្ថភាពមន្ត្រីជួរមុខ ក្នុងការកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស ក្នុងចំណោមជនល្មើសដែលពួកគេជួបប្រទះ*

កសាងសមត្ថភាពរបស់នគរបាល មន្ត្រីអន្តោប្រវេសន៍ និងមន្ត្រីពាក់ព័ន្ធ ក្នុងការកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស ក្នុងចំណោមមនុស្សដែលពួកគេអាចជួបប្រទះ ទោះក្នុងបរិបទនៃអន្តោប្រវេសន៍ខុសច្បាប់ ការធ្វើអាជីវកម្មផ្លូវភេទ (commercial sex) កសិកម្ម ឬក្នុងវិស័យ ព្រហ្មទណ្ឌ ដូចជា ការជួញដូរគ្រឿងញៀន ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ ឬការបោកបន្លំតាមអ៊ីនធឺណិត ឬវិស័យផ្សេងទៀត។ ត្រូវលុបបំបាត់ការយល់ខុស និងផ្ទត់គំនិតចំពោះអ្នកដែលជា "ជនរងគ្រោះពិត" ឬ "សមជាជនរងគ្រោះ" ដើម្បីឱ្យមន្ត្រីជួរមុខអាចពិនិត្យជនរងគ្រោះ សូម្បីតែក្នុងចំណោមអ្នកដែលពាក់ព័ន្ធក្នុងសកម្មភាពល្មើសច្បាប់។

### ពង្រឹងការយល់ដឹងពីធាតុផ្សំនៃបទល្មើសជួញដូរមនុស្ស

អ្នកអនុវត្តត្រូវយល់ពីនិយមន័យនៃការជួញដូរមនុស្ស ដើម្បីកត់សម្គាល់អ្នកដែលអាចជាជនរងគ្រោះក្នុងចំណោមមនុស្សដែលពួកគេជួបប្រទះ ដែលពាក់ព័ន្ធក្នុងសកម្មភាពស្របច្បាប់ និងសកម្មភាពល្មើសច្បាប់។ ខណៈដែលមានចំណុចខុសគ្នាខ្លះៗក្នុងចំណោមរដ្ឋសមាជិកអាស៊ាន រដ្ឋសមាជិកទាំងអស់បានឯកភាពលើនិយមន័យអន្តរជាតិ និងកម្រិតតំបន់នៃការជួញដូរមនុស្ស ដែលរួមបញ្ចូលសកម្មភាពមួយ តាមមធ្យោបាយផ្សេងៗ ក្នុងករណីជនរងគ្រោះជាមនុស្សពេញវ័យ សម្រាប់គោលបំណងនៃការកេងប្រវ័ញ្ច។ ការយល់ដឹងជារួមបែបនេះស្ដីពីជនរងគ្រោះ មានសារៈសំខាន់នៅក្នុងតំបន់អាស៊ាន ព្រោះវាធានាថា អ្នកដែលត្រូវបានការពារក្នុងនាមជាជនរងគ្រោះក្នុងប្រទេសមួយ មិនត្រូវបានទុកចោលដោយគ្មានការការពារ ក្នុងប្រទេសមួយផ្សេងទៀត។

អ្នកអនុវត្តត្រូវយល់ថា នៅពេលដែលអ្នកជួញដូរមនុស្សប្រើប្រាស់ 'មធ្យោបាយ' ក្នុងករណីមនុស្សពេញវ័យ[58] ការយល់ព្រមណាមួយដែលជនរងគ្រោះអាចផ្ដល់ឱ្យ គឺមិនពាក់ព័ន្ធនឹងការកំណត់ថាតើពួកគេត្រូវបានជួញដូរ ឬអត់ឡើយ ហើយការយល់ព្រមរបស់កុមារគឺតែងតែមិនពាក់ព័ន្ធ ដោយមិនគិតពីការប្រើប្រាស់មធ្យោបាយរបស់អ្នកជួញដូរមនុស្ស។[59]

ទោះក្នុងករណីដែលជនរងគ្រោះដោយការជួញដូរមនុស្ស មានកិច្ចសន្យាជាលាយលក្ខណ៍អក្សរក៏ដោយ ក៏កិច្ចសន្យានោះមិនបដិសេធអង្គហេតុនៃការកេងប្រវ័ញ្ចដែរ។ ក្នុងករណីខ្លះ អត្ថិភាពនៃកិច្ចសន្យាអាចជាភស្តុតាងមានប្រយោជន៍ដែលបញ្ជាក់ពីសកម្មភាពបទល្មើស ឧទាហរណ៍ នៅពេលដែលអ្នកជួញដូរមនុស្សចុះកិច្ចសន្យាជាមួយជនរងគ្រោះ ដើម្បីធ្វើ

[58] កម្លាំង និងទម្រង់ដទៃទៀតនៃការបង្ខិតបង្ខំ ការចាប់ជំរិត ការបន្លំ ការបោកបញ្ឆោត ឬការប្រើអំណាចរំលោភបំពាន ឬការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ ឬការផ្ដល់ ឬទទួលកម្រៃ ឬផលប្រយោជន៍នានា ដើម្បីសម្រេចការយល់ព្រមនៃមនុស្សម្នាក់ដែលមានអំណាចត្រួតត្រាលើមនុស្សណាម្នាក់ទៀត គឺជា 'មធ្យោបាយ' ដូចការបញ្ជាក់ក្នុងមាត្រា ៣(ក) នៃពិធីសារស្ដីពីការជួញដូរមនុស្ស និងមាត្រា ២(ក) នៃអនុសញ្ញា ACTIP។

[59] "កុមារ" សំដៅដល់ជនទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំ។ ពិធីសារស្ដីពីការជួញដូរមនុស្ស, មាត្រា ៣ (ឃ)

សកម្មភាពបោកបន្លំ និងសកម្មភាពល្មើសច្បាប់ផ្សេងទៀត។ មន្ត្រីដែលជួបប្រទះជនរងគ្រោះដែលត្រូវបានកេងប្រវ័ញ្ចក្នុងសកម្មភាពល្មើសច្បាប់ ត្រូវយល់ថា បុគ្គលមិនអាចចុះកិច្ចសន្យាដើម្បីប្រព្រឹត្តបទល្មើសបានឡើយ។ កិច្ចសន្យាបែបនេះចាត់ទុកជាមោឃៈ និងអាចជាភស្តុតាងមានប្រយោជន៍ដែលបញ្ជាក់ពីគោលបំណងកេងប្រវ័ញ្ចរបស់អ្នកជួញដូរមនុស្ស ក៏ដូចជាគោលបំណងរបស់ពួកគេក្នុងការប្រព្រឹត្តបទល្មើសផ្សេងទៀត។

**ប្រអប់: ឧទាហរណ៍ (បទល្មើសពាក់ព័ន្ធនឹងឯកសារ)**

ក្នុងអំឡុងពេលនៃការត្រួតពិនិត្យកប៉ាល់ អាជ្ញាធរសមុទ្រដែលស៊ើបអង្កេតការនេសាទខុសច្បាប់ គ្មានការរាយការណ៍ និងគ្មានការគ្រប់គ្រងត្រឹមត្រូវ (IUU) បានត្រួតពិនិត្យអត្តសញ្ញាណ និងសៀវភៅនាវិករបស់ "ក" និងមនុស្សផ្សេងទៀតដែលត្រូវបានរក្សាទុកលើកប៉ាល់អស់រយៈពេលជាច្រើនខែ។ "ក" និងអ្នកផ្សេងទៀតត្រូវបានពិន័យសម្រាប់បទល្មើសពាក់ព័ន្ធនឹងឯកសារ និងដាក់ក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ រង់ចាំការនីរទេសចេញ។ មន្ត្រីម្នាក់បានប្រាប់ "ក" ថា គាត់មានសំណាងដែលមិនត្រូវបានចោទប្រកាន់ពីបទនេសាទខុសច្បាប់ គ្មានការរាយការណ៍ និងគ្មានការគ្រប់គ្រងត្រឹមត្រូវ (IUU) ។

ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ នៅមន្ទីរឃុំខ្លួនអន្តោប្រវេសន៍ មន្ត្រីអន្តោប្រវេសន៍ដែលទទួលបានការបណ្តុះបណ្តាល បានប្រាស្រ័យទាក់ទងជាមួយ "ក" និងសង្ស័យថា "ក" គឺជាជនរងគ្រោះដោយការជួញដូរមនុស្ស។ "ក" ត្រូវបានយកចេញពីមន្ទីរឃុំឃាំងអន្តោប្រវេសន៍ និងបញ្ជូនតាមរយៈយន្តការបញ្ជូនថ្នាក់ជាតិ។ ដោយសារ "ក" មានស្ថានភាពខុសច្បាប់ គេបានផ្តល់រយៈពេលឆ្លុះបញ្ចាំងដល់គាត់ ដូច្នេះ គាត់អាចស្នាក់នៅក្នុងប្រទេសនោះ ដើម្បីទទួលបានការការពារ និងការគាំទ្រ មុនពេលសម្រេចពីជំហានបន្ទាប់របស់គាត់។ "ក" ត្រូវបានជូនដំណឹងអំពីសិទ្ធិរបស់គាត់ក្នុងការស្វែងរកសំណង សម្រាប់ការឃុំខ្លួនគាត់ដោយខុសច្បាប់។

## ពង្រឹងការយល់ដឹងពីទិដ្ឋភាពប្រទាក់ក្រឡាគ្នានៃការជួញដូរមនុស្ស

ចាំបាច់ត្រូវបង្កើនការយល់ដឹងរបស់មន្ត្រីជួរមុខស្តីពីរបៀបដែលអាយុ ភេទ ជាតិពន្ធុ សញ្ជាតិ ស្ថានភាពអន្តោប្រវេសន៍ ស្ថានភាពសេដ្ឋកិច្ចសង្គម បទពិសោធន៍ជីវិត កម្រិតភាពពេញវ័យ ពិការភាព និងកត្តាផ្សេងទៀតរបស់ជនរងគ្រោះ អាចប្រទាក់ក្រឡាគ្នាជះឥទ្ធិពលលើរបៀបដែលពួកគេត្រូវបានជួញដូរ។ កត្តាទាំងនេះក៏អាចជះឥទ្ធិពលលើសកម្មភាពល្មើសច្បាប់ដែលជនរងគ្រោះអាចពាក់ព័ន្ធ ផលជះនៃការជួញដូរមនុស្សលើពួកគេ និងការយល់ឃើញចំពោះពួកគេ រួមទាំងការយល់ឃើញរបស់មន្ត្រីជួរមុខដែលអាចជួបនឹងពួកគេ។[60] ឧទាហរណ៍ នៅពេលដែលអ្នកស៊ើបអង្កេតចំណាយពេលស្វែងយល់ពីមូល

---

[60] វិធីសាស្ត្រ 'ប្រទាក់ក្រឡាគ្នា' សម្រាប់ការជួញដូរមនុស្ស ពិចារណាពីរបៀបដែលបទពិសោធន៍របស់បុរស ស្ត្រី និងបុគ្គលមានយេនឌ័រផ្សេងទៀត ធ្វើអន្តរកម្មជាមួយកត្តាផ្សេងទៀត ដូចជា វណ្ណៈ ពូជសាសន៍ អាយុ ជាតិពន្ធុ អត្តសញ្ញាណផ្លូវភេទ ឬអត្តសញ្ញាណផ្សេងទៀត ក្នុងលក្ខណៈដែលជះឥទ្ធិពលលើការយល់ឃើញចំពោះពួកគេនៅក្នុងសង្គម។ វិធីសាស្ត្រ "ប្រទាក់ក្រឡាគ្នា" គឺជាឧបករណ៍ជួយឱ្យមន្ត្រីជួរមុខយល់ពីបទពិសោធន៍របស់មនុស្សដែលពួកគេបានជួប។ សូមមើល ឧទាហរណ៍, *កញ្ចប់ឧបករណ៍ស្តីពីការបញ្ជ្រាបយេនឌ័រ និងសិទ្ធិមនុស្សក្នុងការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង* (UNODC, ២០២៣) ទំព័រ ៩-១៧ និង *វិធី*

ហេតុដែលបុគ្គលពាក់ព័ន្ធក្នុងសកម្មភាពល្មើសច្បាប់ ពួកគេអាចមានសមត្ថភាពជាងមុនក្នុងការកំណត់អត្តសញ្ញាណបុគ្គលទាំងនោះថាជាអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស។ ចាំបាច់ត្រូវបង្កើនការយល់ដឹងរបស់អ្នកអនុវត្តស្តីពីទំនាក់ទំនងដ៏ស្មុគស្មាញរវាងអ្នកជួញដូរមនុស្ស និងជនរងគ្រោះរបស់ពួកគេ ដែលអាចនាំឱ្យមានការរួមផ្សំដ៏ស្មុគស្មាញនៃការប៉ះទង្គិចផ្លូវចិត្ត ការភ័យខ្លាចអ្នកជួញដូរមនុស្ស ឬផ្ទុយទៅវិញ ភាពស្មោះត្រង់ចំពោះពួកគេ និងការភ័យខ្លាច ឬការប្រឆាំងនឹងអាជ្ញាធរ។

ជនរងគ្រោះដែលភ័យខ្លាចការផ្តន្ទាទោស និងការដាក់ទោសទណ្ឌ ច្រើនតែមិនរាយការណ៍ពីអ្នកដែលជួញដូរពួកគេទៅមន្ត្រីអនុវត្តច្បាប់។ អ្នកជួញដូរមនុស្ស អាចផ្តោតគោលដៅលើអ្នកដែលធ្លាប់មានបញ្ហាជាមួយច្បាប់ ឬមានទំនាក់ទំនងមិនល្អជាមួយអាជ្ញាធរ ដែលធ្វើឱ្យពួកគេងាយត្រូវបានគេឆបោក។ អ្នកជួញដូរមនុស្ស អាចប្រាប់ជនរងគ្រោះថា អាជ្ញាធរនឹងមិនជឿពួកគេទេ ប៉ុន្តែនឹងចាត់ទុកពួកគេថាជាឧក្រិដ្ឋជនសម្រាប់បទល្មើសដែលពួកគេបានប្រព្រឹត្ត។ នៅពេលដែលអាជ្ញាធរចាត់ទុកជនរងគ្រោះថាអាចជាជនល្មើស នេះសបញ្ជាក់ថា អ្នកជួញដូរមនុស្សនិយាយត្រូវ និងអាចបំផ្លាញទំនុកចិត្តរបស់ជនរងគ្រោះចំពោះអាជ្ញាធរ។

ការសំខាន់គឺមន្ត្រីជួរមុខត្រូវយល់ថា មិនគួរភ្ជាប់ការទទួលស្គាល់បុគ្គលម្នាក់ថាជាជនរងគ្រោះ ទៅនឹងឆន្ទៈរបស់គាត់ក្នុងការសហការជាមួយប៉ូលីស ឬសូម្បីតែការយល់ឃើញដោយជនរងគ្រោះផ្ទាល់ថា គាត់ជាជនរងគ្រោះដោយការជួញដូរមនុស្សឡើយ។ វាជាការទទួលខុសត្រូវរបស់មន្ត្រីជួរមុខក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ ពោលគឺជនរងគ្រោះមិនទទួលខុសត្រូវលើការកំណត់អត្តសញ្ញាណខ្លួនឯងនោះទេ។

### ប្រអប់: ឧទាហរណ៍ (បទល្មើសការងារ)

អធិការការងារបានធ្វើប្រតិបត្តិការចុះបង្ក្រាបនៅកសិដ្ឋានមួយដែល "ក" និងកម្មករផ្សេងទៀត ត្រូវបានបង្ខំឱ្យធ្វើការច្រើនម៉ោង។ "ក" អាចចេញចូលតាមទំនើងចិត្ត ប៉ុន្តែគេប្រាប់គាត់ថា ប្រសិនបើគាត់ចាកចេញ ម្តាយរបស់គាត់នៅឯភូមិកំណើត នឹងមានគ្រោះថ្នាក់។ អធិការការងារដែលធ្វើប្រតិបត្តិការវាយឆ្មក់ មិនបានសួរនាំ "ក" ទេ ប៉ុន្តែបានពិនិត្យឯកសាររបស់គាត់។ ពួកគេប្រាប់គាត់ថា គាត់បានធ្វើការដោយខុសច្បាប់នៅក្នុងប្រទេសនេះ ប៉ុន្តែនឹងមិនចោទប្រកាន់គាត់ទេ ប្រសិនបើគាត់ស្ម័គ្រចិត្តវិលត្រឡប់ទៅប្រទេសកំណើតរបស់គាត់ភ្លាមៗ។

ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ បន្ទាប់ពីបានវិលត្រឡប់ទៅប្រទេសកំណើតវិញអាជ្ញាធរកត់សម្គាល់សូចនាករថាគាត់អាចជាជនរងគ្រោះដោយការជួញដូរមនុស្ស ឱ្យធ្វើជាទាសករលើកប៉ាល់។ ពួកគេ ផ្តល់អង្គហេតុនេះទៅអាជ្ញាធរនៅប្រទេសគោលដៅ ពីកន្លែងដែលគាត់ត្រូវបានបញ្ជូនត្រឡប់មកវិញ។ ក្រោយមក ការស៊ើបអង្កេតលើកប៉ាល់នេសាទបង្ហាញថា មានមនុស្សច្រើននាក់នៅលើកប៉ាល់ដែលត្រូវបានជួញដូរឱ្យធ្វើជាទាសករ។ អាជ្ញាធរបានទាក់ទងទៅប្រទេសកំណើតរបស់ "ក" ក្នុងដំណើរការស៊ើបអង្កេតរបស់ពួកគេ ហើយបានកំណត់អត្តសញ្ញាណគាត់ជាជនរងគ្រោះដោយការជួញដូរមនុស្ស។ "ក" ត្រូវបានជូនដំណឹងអំពីសិទ្ធិរបស់គាត់ក្នុងការទាមទារសំណងសម្រាប់ការឃុំខ្លួនគាត់ដោយខុសច្បាប់។

---

*សាស្ត្រដែលគិតគូរពីយេនឌ័រ និងយកចិត្តទុកដាក់ចំពោះជនរងគ្រោះ សម្រាប់អ្នកឆ្លើយតបជួរមុខ ៖ វិធីសាស្ត្រក្នុងការធ្វើការជាមួយជនរងគ្រោះដោយការជួញដូរមនុស្ស* (ASEAN ACWC និង ASEAN-ACT, ២០២៣) ទំព័រ ១៣។

## បំពាក់បំប៉នសមត្ថភាពមន្ត្រីក្នុងការអនុវត្តការសន្មតថាជាជនរងគ្រោះ និងជាអនីតិជន

មន្ត្រីអនុវត្តច្បាប់ត្រូវយល់ថា ការជួញដូរមនុស្សគឺជាដំណើរការមួយ និងជាបទល្មើសដែលមានគោលបំណងកេងប្រវ័ញ្ចជាពិសេស។ ល្អបំផុត គួរកំណត់អត្តសញ្ញាណជនរងគ្រោះ នៅមុនដំណាក់កាលកេងប្រវ័ញ្ច ប៉ុន្តែវាអាចពិបាកក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស មុនពេលពួកគេត្រូវបានកេងប្រវ័ញ្ច។ ឧទាហរណ៍ បុគ្គលម្នាក់ដែលត្រូវបានកេងប្រវ័ញ្ចនៅក្នុងអាគារឆបោកអនឡាញ ឬក្នុងផ្ទះបន ឬក្នុងទីតាំងផលិតគ្រឿងញៀន អាចត្រូវបានកំណត់អត្តសញ្ញាណយ៉ាងងាយស្រួលថាជាជនរងគ្រោះដោយការជួញដូរមនុស្ស ជាងបុគ្គលដែលត្រូវបានស្កាត់ចាប់តាមផ្លូវទៅកាន់គោលដៅទាំងនោះ ដែលផ្ទុយទៅវិញអាចត្រូវបានកំណត់អត្តសញ្ញាណខុសថាជាជនចំណាកស្រុកខុសច្បាប់ដែលចេញដំណើរទៅធ្វើការងារមិនជាប់លាប់ ឬខុសច្បាប់។

អ្នកអនុវត្តដែលជួបប្រទះអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស គួរទទួលបានការ បំពាក់បំប៉នសមត្ថភាពឱ្យចេះប្រើប្រាស់ការសន្មតថាជាជនរងគ្រោះ ដើម្បីឱ្យពួកគេប្រព្រឹត្តចំពោះបុគ្គលដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្សប្រៀបដូចជាជនរងគ្រោះតែម្តង សម្រាប់គោលបំណងនៃការ អនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម។ ដូច្នេះ ក្នុងករណីដែលមានភស្តុតាងមិនគ្រប់គ្រាន់ដើម្បីកំណត់ថា ការជួញដូរមនុស្សបានកើតឡើង ការសន្មតថាជាជនរងគ្រោះនឹងអនុញ្ញាតឱ្យមានការប្រព្រឹត្តចំពោះជនរងគ្រោះ ស្របតាមគោលការណ៍មិនដាក់ទណ្ឌកម្ម។ សម្រាប់គោលបំណងកំណត់អត្តសញ្ញាណជនរងគ្រោះ រដ្ឋសមាជិកអាស៊ានទាំងអស់គួរអនុវត្តនិយមន័យនៃកុមារ ដែលមានចែងក្នុងពិធីសារស្តីពីការជួញដូរមនុស្ស និងអនុសញ្ញា ACTIP ដែលកំណត់ថា កុមារជាបុគ្គលដែលមានអាយុក្រោម ១៨ ឆ្នាំ។[61]

នៅពេលដែលអ្នកអនុវត្តមានហេតុផលអាចជឿបានថា ជនរងគ្រោះដោយការជួញដូរមនុស្សអាចជាកុមារ គួរអនុវត្តការសន្មតថាជាអនីតិជនក្នុងដំណើរការពិនិត្យ ដើម្បីឱ្យមានការប្រព្រឹត្តចំពោះបុគ្គលនោះប្រៀបដូចជាកុមារ សម្រាប់គោលបំណងនៃការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម។ ប្រសិនបើមានការចោទប្រកាន់ការប្រឆាំងនឹងបុគ្គលណាម្នាក់សម្រាប់សកម្មភាពល្មើសច្បាប់ដែលទាក់ទងនឹងការជួញដូរពួកគេ ពួកគេមិនគួរត្រូវបានដាក់ទោសទាល់តែសោះ។ ប្រសិនបើសកម្មភាពល្មើសច្បាប់ទាំងនោះមិនទាក់ទងនឹងសកម្មភាពនៃការជួញដូរពួកគេ គួរពិចារណាពីអាយុរបស់ជនប្រព្រឹត្តបទល្មើស-ជាជនរងគ្រោះ ទាក់ទងនឹងការអនុវត្តន៍វិធានការការពារដែលអាចមាន ឬក្នុងការសម្រាលទោស នៅដំណាក់កាលកាត់ទោស។

61 មាត្រា ៣(ឃ) នៃពិធីសារស្តីពីការជួញដូរមនុស្ស និង មាត្រា ២(ឃ) នៃអនុសញ្ញា ACTIP។

### អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ

រដ្ឋត្រូវតែធានាថា ជនរងគ្រោះជាកុមារមិនត្រូវបានដាក់ទោសសម្រាប់អំពើល្មើសច្បាប់ដែលទាក់ទងនឹងការណ៍ដែលពួកគេត្រូវបានជួញដូរ។ ក្នុងករណីដែលមិនច្បាស់ពីអាយុរបស់ជនរងគ្រោះ និងមានហេតុផលអាចជឿបានថាជនរងគ្រោះគឺជាកុមារ ត្រូវសន្មតជនរងគ្រោះថាជាកុមារ និងត្រូវផ្តល់វិធានការការពារពិសេសរង់ចាំការផ្ទៀងផ្ទាត់អាយុរបស់គាត់។ នៅពេលដែលមានការកំណត់ទំនាក់ទំនងរវាងបទល្មើសដែលបានប្រព្រឹត្ត និងស្ថានភាពរបស់កុមារក្នុងនាមជាជនរងគ្រោះដោយការជួញដូរមនុស្ស ដែលត្រូវបានសន្មត ឬកំណត់អត្តសញ្ញាណ ត្រូវទទួលយកទំនាក់ទំនងនោះថាចាំបាច់ និងមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបញ្ឈប់ដំណើរការនីតិវិធី ឬលុបចោលការផ្តន្ទាទោសដែលបានចេញរួចហើយ ក៏ដូចជាដោះលែងកុមារចេញពីកន្លែងឃុំឃាំងភ្លាមៗ។ ចំពោះកុមារ ដោយសារតែគ្មានមធ្យោបាយចាំបាច់ ដើម្បីកំណត់ស្ថានភាពរបស់ពួកគេជាជនរងគ្រោះដោយការជួញដូរមនុស្ស មិនអាចអនុវត្តការធ្វើតេស្តលើការបង្ខិតបង្ខំបានឡើយ។[62]

## លុបបំបាត់ការយល់ខុស និងភាពលម្អៀងដែលមិនដឹងខ្លួនចំពោះការជួញដូរមនុស្ស និងភាពជាជនរងគ្រោះ

ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះប្រកបដោយប្រសិទ្ធភាព អ្នកអនុវត្តត្រូវជម្នះភាពលម្អៀង និងការយល់ខុសដែលពួកគេអាចមានចំពោះអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស និងអ្នកដែលគួរបានប្រយោជន៍ពីគោលការណ៍មិនដាក់ទណ្ឌកម្ម។ មន្ត្រីមិនគួរទាញការសន្និដ្ឋានថា នរណា 'ល្អ' ឬ 'អាក្រក់' ឬនរណាជា 'ជនរងគ្រោះពិត' ឬមិនមែនឡើយ។ ការមាក់ងាយ និងភាពលម្អៀងចំពោះមនុស្សមួយចំនួនអាចបណ្តាលឱ្យមានឥរិយាបថស្តីពីអ្នក 'ដែលសមជាជនរងគ្រោះ' ជាងអ្នកដទៃទៀត។ នេះនឹងនាំឱ្យមនុស្សមួយចំនួនងាយនឹងទទួលទោស ជាជាងទទួលបានការការពារ។ ឧទាហរណ៍ ជនរងគ្រោះជាជនចំណាកស្រុកដែលមានស្ថានភាពខុសច្បាប់ ឬធ្លាប់ចម្រូងចម្រាស់ជាមួយច្បាប់ ឬមានបញ្ហាសេពគ្រឿងស្រវឹង ឬគ្រឿងញៀន ឬមានពិការភាព ឬជាជនជាតិនៃប្រទេសជាក់លាក់ ឬមានជាតិពន្ធុ អត្តសញ្ញាណផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រជាក់លាក់ អាចរងការរើសអើងក្នុងលក្ខណៈដែលរំលោភលើគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាននៃការមិនរើសអើង និងធ្វើឱ្យខូចដល់សមត្ថភាពមន្ត្រីអនុវត្តច្បាប់ក្នុងការទទួលស្គាល់ពួកគេ។

អ្នកអនុវត្តក៏អាចមានភាពលម្អៀងដែលមិនដឹងខ្លួន ចំពោះអ្នកដែលពាក់ព័ន្ធក្នុងវិស័យមួយចំនួនផងដែរ ឧទាហរណ៍ ក្នុងឧស្សាហកម្មផ្លូវភេទ ឬឧស្សាហកម្មឆបោក។ ជាឧទាហរណ៍ មន្ត្រីអនុវត្តច្បាប់ និងគ្រួសាររបស់ពួកគេ ប្រហែលជាធ្លាប់ក្លាយជាជនរងគ្រោះដោយសារអ្នកឆបោក ដែលធ្វើឱ្យពួកគេមានភាពលម្អៀងដោយមិនដឹងខ្លួនចំពោះអ្នកដែលពាក់ព័ន្ធ ក្នុងលក្ខណៈដែលរាំងស្ទះដល់សមត្ថភាពរបស់ពួកគេ ក្នុងការកត់សម្គាល់អ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរ ក្នុងចំណោមអ្នកទាំងនោះ។

[62] ប្រភព៖ *ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ*, *Siobhán Mullally*, ឯកសារ អ.ស.ប A/HRC/47/34, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១, [៦២]

## លើកកម្ពស់ការមិនរើសអើងក្នុងដំណើរការពិនិត្យ និងកំណត់អត្តសញ្ញាណ

ការលើកកម្ពស់ការមិនរើសអើង ក្នុងចំណោមមនុស្សដែលមានតួនាទីកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស មានសារៈសំខាន់សម្រាប់ការបង្កើនសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើដូច្នោះ។ គួរបង្កើនសមត្ថភាពរបស់អ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌឱ្យយល់ថា គោលការណ៍មិនដាក់ទណ្ឌកម្ម អនុវត្តចំពោះជនរងគ្រោះទាំងអស់ ក្នុងករណីដែលមានទំនាក់ទំនងរវាងសកម្មភាពល្មើសច្បាប់របស់ពួកគេ និងការជួញដូរពួកគេ ដោយគ្មានការរើសអើង។ ក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មដោយមិនរើសអើង អ្នកអនុវត្តគួរយល់ពីរបៀបដែលស្ថានភាពអន្តោប្រវេសន៍របស់មនុស្សម្នាក់ អាចប្រទាក់ក្រឡាជាមួយកត្តាផ្សេងទៀត ដូចជា ពូជសាសន៍ ពណ៌សម្បុរ ភេទ យេនឌ័រ អត្តសញ្ញាណយេនឌ័រ ភាសា ពិការភាព សាសនា ទស្សនៈនយោបាយ ឬទស្សនៈផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ស្ថានភាពសេដ្ឋកិច្ចសង្គម ទ្រព្យសម្បត្តិ កំណើតឬស្ថានភាពផ្សេងទៀត ក្នុងលក្ខណៈដែលធ្វើឱ្យពួកគេងាយរងគ្រោះដោយការរើសអើង។[63]

រដ្ឋមានកាតព្វកិច្ចធានាការបញ្ចូលជនមានពិការភាព ទៅក្នុងវិធានការប្រឆាំងការជួញដូរមនុស្សទាំងអស់ រួមទាំងទាក់ទងនឹងការមិនដាក់ទោសទណ្ឌ។ នេះជាកាតព្វកិច្ចបន្ទាន់ ក្នុងករណីដែលជនមានពិការភាពប្រឈមនឹងហានិភ័យខ្ពស់នៃការកេងប្រវ័ញ្ច រួមទាំងសម្រាប់គោលបំណងនៃការបង្ខំឱ្យប្រព្រឹត្តបទល្មើស។[64] ក្នុងករណីអ្នកដែលសន្មតថាជាជនរងគ្រោះដែលមានពិការភាពផ្នែកចិត្តសង្គម សតិបញ្ញា ឬកាយសម្បទា ការមិនរើសអើងតម្រូវឱ្យមានការផ្តល់ផាសុកសមរម្យដើម្បីធានាថា ជនមានពិការភាពអាចទទួលបាននីតិវិធីកំណត់អត្តសញ្ញាណ និងនីតិវិធីការពារដែលពាក់ព័ន្ធនឹងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មដោយស្មើភាពគ្នាជាមួយអ្នកដទៃ។[65]

---

63 សូមមើលមាត្រា ២៦ នៃ *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* និងមាត្រា ២ នៃ *សេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្ស*។ សូមមើលផងដែរមាត្រា ២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ, មាត្រា ១ នៃ*អនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ* និងមាត្រា ៥ នៃ *អនុសញ្ញាស្តីពីសិទ្ធិជនពិការ*។ សម្រាប់ព័ត៌មានបន្ថែមស្តីពីភាពប្រទាក់ក្រឡាគ្នា និងការរើសអើង សូមមើល *កំណត់សម្គាល់ណែនាំស្តីពីភាពប្រទាក់ក្រឡាគ្នា ការរើសអើងពូជសាសន៍ និងការការពារជនជាតិភាគតិច* (UN,២០២២) និង *គោលការណ៍ និងគោលការណ៍ណែនាំ ដែលគាំទ្រដោយការណែនាំនៃការអនុវត្តន៍ ស្តីពីការការពារសិទ្ធិមនុស្សចំពោះជនចំណាកស្រុកដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ* (UN, ២០១៨)។

64 *ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ Siobhán Mullally, ឯកសារ អ.ស.ប. A/HRC/47/34,* ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១, [២៧]

65 មាត្រា ២, *អនុសញ្ញាស្តីពីសិទ្ធិជនពិការ*។

**អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ**

រដ្ឋត្រូវធានាការការពារស្មើភាពគ្នាក្រោមច្បាប់ និងសមភាពចំពោះមុខច្បាប់ ក្នុងគ្រប់វិធានការប្រឆាំងការជួញដូរមនុស្សទាំងអស់ រួមទាំងការធានាការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវគោលការណ៍មិនដាក់ទណ្ឌកម្មសម្រាប់ជនមានពិការភាពដែលត្រូវបានជួញដូរ។ រដ្ឋត្រូវតែចាត់វាល់វិធានការសមស្របទាំងអស់ ដើម្បីធានាការមិនរើសអើងដោយសារពិការភាព និងធានាការផ្តល់ផាសុកសមរម្យ រួមទាំងការផ្តល់ការសម្របសម្រួលផ្នែកនីតិវិធី និងការសម្របសម្រួលដែលសមស្របតាមអាយុ ដើម្បីសម្រួលដល់ការទទួលបានយុត្តិធម៌ប្រកបដោយប្រសិទ្ធភាព និងការចូលរួមរបស់ជនមានពិការភាពដែលត្រូវបានជួញដូរ នៅក្នុងនីតិវិធីផ្លូវច្បាប់ទាំងអស់ រួមទាំងនីតិវិធីកំណត់អត្តសញ្ញាណ និងនៅដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលដំបូងៗផ្សេងទៀត។[68]

## លើកកម្ពស់ជំនាញកុមារមេត្រី ការយកចិត្តទុកដាក់ចំពោះយេនឌ័រ ការប៉ះទង្គិចផ្លូវចិត្ត ក្នុងការពិនិត្យ និងការកំណត់អត្តសញ្ញាណរកភាពរងគ្រោះនៃអំពើជួញដូរមនុស្ស

អ្នកដែលទទួលខុសត្រូវលើការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស ត្រូវតែមានជំនាញគ្រប់គ្រាន់ក្នុងការចូលរួមជាមួយមនុស្សម្នាក់ ដើម្បីបំពេញមុខងាររបស់ពួកគេ។ មានន័យថា ត្រូវប្រព្រឹត្តចំពោះអ្នកដែលអាចជាជនរងគ្រោះ រួមទាំងអ្នកដែលអាចបានប្រព្រឹត្តបទល្មើស ប្រកបដោយការគោរព និងស្របតាមគោលការណ៍អន្តរជាតិ និងគោលការណ៍ថ្នាក់តំបន់ស្តីពីការកំណត់អត្តសញ្ញាណ និងការការពារជនរងគ្រោះ។ បុគ្គលម្នាក់មិនចាំបាច់ទាល់តែជាមនុស្សរួសរាយទើបអាចពន្យល់យ៉ាងច្បាស់អំពីអ្វីដែលបានកើតឡើងចំពោះគាត់ ដើម្បីឱ្យគេទទួលស្គាល់ថា គាត់ជាជនរងគ្រោះដោយការជួញដូរមនុស្សនោះទេ ហើយគាត់ក៏មិនចាំបាច់ទាល់តែចេះនិយាយភាសាក្នុងស្រុកដែរ។ ផ្ទុយទៅវិញ មន្ត្រីរដ្ឋជាអ្នកមានកាតព្វកិច្ចអនុវត្តជំនាញរបស់ខ្លួន ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនរងគ្រោះប្រកបដោយប្រសិទ្ធភាព។

## ដេញដោលគោលនយោបាយរដ្ឋាភិបាល ដែលបង្កើនហានិភ័យនៃការដាក់ទោសទណ្ឌជនរងគ្រោះដោយការជួញដូរមនុស្ស

បរិបទនៃការជួបជនរងគ្រោះជាលើកដំបូងក្នុងនាមជាជនល្មើស អាចបង្កបញ្ហាប្រឈមជាក់លាក់ដល់ការកំណត់អត្តសញ្ញាណជនរងគ្រោះ។ ឧទាហរណ៍ ការឆ្មក់ចូលទីតាំងដែលជនរងគ្រោះដោយការជួញដូរមនុស្ស អាចកំពុងរស់នៅ និងធ្វើការ រួមទាំងកន្លែងដែលមានការធ្វើអាជីវកម្មផ្លូវភេទ (commercial sex) ឬនៅក្នុងបរិវេណអគារដែលមានការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា អាចបណ្តាលឱ្យមានការដាក់ទោសព្រហ្មទណ្ឌលើជនរងគ្រោះ ជាជាងការកំណត់អត្តសញ្ញាណរកភាពរងគ្រោះរបស់ពួកគេ។

---

66 ប្រភព៖ *ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ Siobhán Mullally*, ឯកសារ អ.ស.ប A/HRC/47/34, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១, [៦១]

ក្នុងដំណើរការគ្រប់គ្រងអន្តោប្រវេសន៍ អាជ្ញាធរអាចនឹងចោទប្រកាន់ជនរងគ្រោះដោយការជួញដូរមនុស្សសម្រាប់បទល្មើសដែលទាក់ទងនឹងអន្តោប្រវេសន៍ និងឯកសារ ជាជាងទទួលស្គាល់ពួកគេថាជាជនរងគ្រោះ។ ហានិភ័យនេះរីកធំឡើងនៅពេលដែលការជួញដូរមនុស្សត្រូវបានលាយឡំជាមួយនឹងការធ្វើចំណាកស្រុកខុសច្បាប់។ ទន្ទឹមនឹងនេះ ការមិនកំណត់អត្តសញ្ញាណក៏ងាយនឹងកើតឡើងផងដែរ នៅពេលដែលរដ្ឋមានគោលនយោបាយបែបអរិភាពចំពោះជនចំណាកស្រុកដែលគ្មានឯកសារបញ្ជាក់ រួមទាំងការដាក់ទោសទណ្ឌព្រហ្មទណ្ឌលើការធ្វើចំណាកស្រុកដោយខុសច្បាប់ និងការតម្រូវឱ្យឃុំខ្លួន។

បញ្ហាអាទិភាព ដូចជា 'សង្គ្រាមប្រឆាំងគ្រឿងញៀន' ក៏អាចជះផលអន្តរាយលើការកំណត់អត្តសញ្ញាណជនរងគ្រោះផងដែរ ហើយនេះនឹងនាំឱ្យមានការដាក់ទោសទណ្ឌព្រហ្មទណ្ឌលើជនរងគ្រោះដែលត្រូវបានជួញដូរឱ្យចូលរួមក្នុងបទល្មើសគ្រឿងញៀន ជាជាងការកំណត់អត្តសញ្ញាណរកភាពរងគ្រោះ និងការបញ្ជូនពួកគេទៅសេវាការពារ។ ស្ថាប័នរដ្ឋដែលមានអាណត្តិប្រឆាំងការជួញដូរមនុស្ស ដើម្បីដោះស្រាយការជួញដូរមនុស្ស ដើរតួនាទីសំខាន់ក្នុងការជេញដោល និងលើកកម្ពស់ការយល់ដឹងអំពីរបៀបដែលគោលនយោបាយរដ្ឋធ្វើឱ្យចុះខ្សោយដល់គោលបំណង និងកាតព្វកិច្ចប្រឆាំងការជួញដូរមនុស្ស។

**អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ**

គោលការណ៍មិនដាក់ទណ្ឌកម្ម គួរត្រូវបានអនុវត្ត៖

(ក) ដោយអាជ្ញាធរក្នុងស្រុកទាំងអស់ដែលពាក់ព័ន្ធ រួមទាំងនគរបាល មន្ត្រីអន្តោប្រវេសន៍ និងមន្ត្រីព្រំដែន អធិការការងារ និងទីភ្នាក់ងារអនុវត្តច្បាប់ ឬមន្ត្រីផ្សេងទៀត ហើយពួកគេគួរទទួលការបណ្តុះបណ្តាល និងមានគុណសម្បត្តិគ្រប់គ្រាន់ ក្នុងការកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស

(ខ) ភ្លាមៗ នៅពេលដែលមានមូលដ្ឋានសមហេតុផលអាចឱ្យជឿបានថា មនុស្សម្នាក់ត្រូវបានជួញដូរ ឬភ្លាមៗ នៅពេលដែលជនដែលត្រូវបានជួញដូរ ឬតំណាងស្របច្បាប់របស់ពួកគេ លើកឡើងពីវិធានការការពារក្នុងករណីជួញដូរមនុស្ស ដើម្បីឱ្យជនដែលត្រូវបានជួញដូរទទួលបានការការពារប្រកបដោយប្រសិទ្ធភាព និងពេញលេញ។

រដ្ឋមានកាតព្វកិច្ចធានាការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស ឱ្យបានលឿនរហ័ស និងប្រកបដោយប្រសិទ្ធភាព។ គួរផ្តល់ជំនួយផ្លូវច្បាប់ក្នុងដំណើរការកំណត់អត្តសញ្ញាណទាំងមូល ដើម្បីធានាការកំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបានឆាប់ ការបញ្ជូនទៅរកជំនួយ និងការការពារ និងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មប្រកបដោយប្រសិទ្ធភាព។ [69]

## *[៤] កសាងការយល់ដឹងរបស់មន្ត្រីជួរមុខស្តីពីសូចនាករនានាដើម្បីត្រួតពិនិត្យ និងកំណត់អត្តសញ្ញាណជនរងគ្រោះ*

សូចនាករ ដែលជាសញ្ញាបង្ហាញថា ការជួញដូរមនុស្សអាចនឹងបានកើតឡើង មិនមែនជាភស្តុតាងចុងក្រោយថា មនុស្សម្នាក់ជាជនរងគ្រោះដោយការជួញដូរមនុស្សនោះទេ ប៉ុន្តែជាចំណុចចាប់ផ្តើមសម្រាប់ការសាកសួរបន្ថែម។ អ្នកអនុវត្តដែលទទួលខុសត្រូវលើការកំណត់អត្តសញ្ញាណជនចំណាកស្រុកខុសច្បាប់ ឬការត្រួតពិនិត្យកន្លែងធ្វើការដើម្បីរកមើលការរំលោភបំពានក្នុងការងារ ឬការស៊ើបអង្កេតជនដែលប្រព្រឹត្តបទល្មើសតូចតាច ឬបទល្មើសធ្ងន់ធ្ងរ ត្រូវតែទទួលបានកម្រងសូចនាករនានា ដើម្បីឱ្យពួកគេអាចកត់សម្គាល់ជនរងគ្រោះដោយការជួញដូរមនុស្ស ក្នុងចំណោមអ្នកដែលអាចជាជនល្មើសដែលពួកគេបានជួបប្រទះ។

### ប្រមូល ពិនិត្យ និងកែសម្រួលសូចនាករដែលមានស្រាប់ឱ្យស្របតាមបរិបទ

គេបានចំណាយពេលវេលា ធនធាន និងជំនាញយ៉ាងច្រើន ដើម្បីរៀបចំសូចនាករ និងធ្វើឱ្យរដ្ឋសមាជិកអាស៊ានអាចប្រើប្រាស់សូចនាករទាំងនោះដោយសេរី។ សូចនាករមួយចំនួនមានលក្ខណៈជាក់លាក់សម្រាប់ប្រភេទជាក់លាក់នៃការកេងប្រវ័ញ្ច ឬវិស័យដែលមានការជួញដូរមនុស្ស។ ឧទាហរណ៍ UNODC បានបង្កើតសូចនាករសម្រាប់ការជួញដូរមនុស្សបង្ខំឱ្យប្រព្រឹត្តបទល្មើស គឺការប្រព្រឹត្តបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា (ការជួញដូរចូលទៅក្នុងបរិវេណអគារឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា)។

អាជ្ញាធរទទួលខុសត្រូវនៅក្នុងរដ្ឋសមាជិកអាស៊ាន គួរប្រមូល និងពិនិត្យឡើងវិញលើសំណុំសូចនាករដែលមានស្រាប់ និងកែសម្រួលសូចនាករទាំងនោះទៅតាមគោលបំណងរបស់ខ្លួន។

**ប្រអប់៖ឧទាហរណ៍នៃសូចនាករពីប្រភពបើកទូលាយដែលអាចប្រើប្រាស់បានដោយរដ្ឋសមាជិកអាស៊ាន**

សូចនាករទូទៅសម្រាប់អ្នកអនុវត្ត ដែលត្រូវបានអនុម័តដោយអាស៊ាន និងគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីក្នុងអនុតំបន់ទន្លេមេគង្គដែលមានការសម្របសម្រួលប្រឆាំងនឹងការជួញដូរមនុស្ស (ដំណើរការ COMMIT) នៅគួឡាឡាំពួរ ថ្ងៃទី១៥-១៦ ខែធ្នូ បានបង្កើតឡើងក្នុង *ការពិនិត្យឡើងវិញថ្នាក់តំបន់លើច្បាប់ គោលនយោបាយ និងការអនុវត្តន៍ក្នុងអាស៊ាន ទាក់ទងនឹងការកំណត់អត្តសញ្ញាណ ការគ្រប់គ្រង និងការប្រព្រឹត្តចំពោះជនរងគ្រោះដោយការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ* (អាស៊ាន, ២០១៦), ទំព័រ ៣២-៣៣

សូចនាករទូទៅរបស់ UNODC *សូចនាករនៃការជួញដូរមនុស្ស*

សូចនាករប្រតិបត្តិការរបស់ ILO *សូចនាករប្រតិបត្តិការនៃការជួញដូរមនុស្ស*

គោលការណ៍ណែនាំគោលនយោបាយដំណើរការបាលី ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស រួមទាំងសំណុំសូចនាករ មានជាភាសា ភូមា អង់គ្លេស ហ្វីលីពីន ខ្មែរ ម៉ាឡេ វៀតណាម និង ថៃ ព្រមទាំងភាសាផ្សេងទៀត។

សូចនាករជាក់លាក់ ដើម្បីគាំទ្រដល់ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្សក្នុងមជ្ឈ មណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ក្នុងតំបន់អាស៊ាន៖

*សូចនាករសំខាន់ៗនៃការជួញដូរមនុស្សបង្ខំឱ្យប្រព្រឹត្តបទល្មើស ដើម្បីប្រព្រឹត្តបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត* (UNODC, ២០២៣)។

*សូចនាករសំខាន់ៗនៃការជួញដូរមនុស្សសម្រាប់គោលបំណងនៃការដកហូតសរីរាង្គ* ឧបករណ៍.៣ នៃ*កញ្ចប់ឧបករណ៍ស្តីពីការស៊ើបអង្កេតនិងការកាត់ទោសករណីជួញដូរមនុស្សសម្រាប់ការដកហូតសរីរាង្គ* (UNODC, ២០២២)។

### ធានាថា សូចនាករមិនផាត់ចេញអ្នកដែលអាចជាជនរងគ្រោះ

សារៈតាររបស់ជនរងគ្រោះមិនគួរកំណត់ថាតើពួកគេត្រូវបានទទួលស្គាល់ថាជាជនរងគ្រោះដោយការជួញដូរមនុស្ស ឬអត់នោះទេ។ បណ្តាប្រទេសអាស៊ានគឺជាប្រទេសគោលដៅសម្រាប់ការជួញដូរទាំងជនរងគ្រោះពីក្នុងតំបន់ និងពីបណ្តាប្រទេសនៅឆ្ងាយពីតំបន់។ សូចនាករត្រូវតែឆ្លើយតប ចំពោះអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស

(ឧទាហរណ៍) មនុស្សដែលមានសាវតារ និងភេទជាក់លាក់ ទំនងជាត្រូវបានកេងប្រវ័ញ្ចក្នុងវិស័យជាក់លាក់) ហើយក្នុងពេលជាមួយគ្នានោះ បញ្ចៀសភាពលម្អៀង ឬការសន្មតណាមួយអំពីអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស (ដោយផ្អែកលើសញ្ជាតិ ជាតិពន្ធុ ពូជសាសន៍ អាយុ យេនឌ័រ ភេទ អត្តសញ្ញាណ ស្ថានភាពអន្តោប្រវេសន៍ ស្ថានភាពសេដ្ឋកិច្ចសង្គម ឬស្ថានភាពផ្សេងទៀត)។

ប្រភេទសកម្មភាពល្មើសច្បាប់ដែលមនុស្សម្នាក់ពាក់ព័ន្ធ មិនគួរកំណត់ថាតើមនុស្សម្នាក់ត្រូវបានទទួលស្គាល់ថាជាជនរងគ្រោះ ឬអត់នោះទេ។ ជនរងគ្រោះអាចពាក់ព័ន្ធក្នុងសកម្មភាពល្មើសច្បាប់ផ្សេងៗ ដោយសារតែពួកគេត្រូវបានជួញដូរ ចាប់ពីបទល្មើសអន្តោប្រវេសន៍ និងបទល្មើសរដ្ឋបាល រហូតដល់បទល្មើសតូចតាច ឬបទល្មើសធ្ងន់ធ្ងរ។ ពួកគេអាចប្រព្រឹត្តបទល្មើសជាច្រើន។ សូចនាករត្រូវតែឆ្លុះបញ្ចាំងពី តថភាពទាំងនេះ ដើម្បីកាត់បន្ថយហានិភ័យនៃការដាក់ទោសជនរងគ្រោះដែលមិនត្រូវបានកំណត់អត្តសញ្ញាណ។

## ធ្វើបច្ចុប្បន្នភាពសូចនាករជាទៀងទាត់

ស្ថាប័នអន្តរទីភ្នាក់ងារប្រឆាំងការជួញដូរមនុស្ស ត្រូវតាមដានឱ្យទាន់និន្នាការនៃការជួញដូរមនុស្ស និងវិធីសាស្ត្ររបស់អ្នកជួញដូរមនុស្ស ដើម្បីឱ្យសូចនាករនៅតែពាក់ព័ន្ធនឹងរបៀបដែលជនរងគ្រោះពាក់ព័ន្ធក្នុងសកម្មភាពល្មើសច្បាប់។[68] ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្សទៅក្នុងប្រភេទផ្សេងៗនៃការកេងប្រវ័ញ្ច (ទោះបីជាការកេងប្រវ័ញ្ចផ្លូវភេទ ការងារដោយបង្ខំ ការដកហូតសរីរាង្គ ឬការកេងប្រវ័ញ្ចក្នុងសកម្មភាពបទល្មើសក៏ដោយ) អាចត្រូវការជំនាញផ្សេងៗគ្នា និងសូចនាករជាក់លាក់។

ការធានាថា សូចនាករនៅតែសមស្របសម្រាប់គោលបំណង តម្រូវឱ្យមានការស្រាវជ្រាវ ការប្រមូលទិន្នន័យ និងការពិគ្រោះយោបល់ជាទៀងទាត់ជាមួយអ្នកអនុវត្ត ដែលអាចស្គាល់ពីរបៀបដែលការជួញដូរមនុស្សកំពុងវិវត្ត របៀបដែលជនរងគ្រោះត្រូវបានកេងប្រវ័ញ្ច និងប្រភេទសកម្មភាពល្មើសច្បាប់ដែលជនរងគ្រោះដោយការជួញដូរមនុស្ស អាចពាក់ព័ន្ធ។ ស្ថាប័នរដ្ឋដែលប្រឆាំងការជួញដូរមនុស្ស គួរពិចារណាស្នើសុំការគាំទ្រពីអ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌ និងតួអង្គមិនមែនរដ្ឋ ដូចជាអង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងតួអង្គផ្សេងទៀត ដើម្បីធានាថា សូចនាករឆ្លើយតបទៅនឹងនិន្នាការនៃការជួញដូរមនុស្សដែលវិវត្តឥតឈប់ឈរ និងប្រភេទសកម្មភាពល្មើសច្បាប់ដែលជនរងគ្រោះ អាចពាក់ព័ន្ធ។

## ផ្សព្វផ្សាយសូចនាករទៅអ្នកពាក់ព័ន្ធដែលអាចជួបប្រទះជនរងគ្រោះ

ស្ថាប័នប្រឆាំងការជួញដូរមនុស្សគួរធានាថា អ្នកពាក់ព័ន្ធអាចទទួលបានសូចនាករដែលពាក់ព័ន្ធនឹងការងាររបស់ពួកគេ។ គួរកសាងការយល់ដឹងអំពីសូចនាករនានាសម្រាប់មន្ត្រីអនុវត្តច្បាប់ អធិការការងារ អាជ្ញាធរអន្តោប្រវេសន៍ ក៏ដូចជាសមាជិកក្រុមការងារពហុវិស័យដែលបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងបទល្មើសធ្ងន់ធ្ងរ ដែលអាចជាការកេងប្រវ័ញ្ចលើជនដែលត្រូវបានជួញដូរ ដូចជា ការជួញដូរគ្រឿងញៀន ឬការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។ តួអង្គជាច្រើនដែលជួបប្រទះ

[68] ឧទាហរណ៍ នៅក្នុងប្រទេសមួយចំនួន គេធ្លាប់តែយល់ថាមានតែស្ត្រី និងកុមារប៉ុណ្ណោះជាជនរងគ្រោះដែលត្រូវបានជួញដូរទៅក្នុងការកេងប្រវ័ញ្ចផ្លូវភេទ ប៉ុន្តែឥឡូវនេះ គេយល់ដឹងថា មនុស្សគ្រប់វ័យ និងគ្រប់យេនឌ័រសុទ្ធតែអាចត្រូវបានជួញដូរសម្រាប់ទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ច។ ដូចគ្នានេះដែរ គេធ្លាប់តែយល់ថាមានតែមនុស្សមកពីក្រុមសេដ្ឋកិច្ចសង្គមអន់ថយដែលមានកម្រិតអប់រំទាបប៉ុណ្ណោះដែលត្រូវបានជួញដូរ ប៉ុន្តែការវិភាគថ្មីៗស្ដីពីការជួញដូរមនុស្សបង្ខំឱ្យប្រព្រឹត្តបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត បង្ហាញថា មនុស្សដែលមានកម្រិតអប់រំខ្ពស់ អាចជាគោលដៅរបស់អ្នកជួញដូរមនុស្សដែរ។

ជនរងគ្រោះដោយការជួញដូរមនុស្ស មិនមែនជាផ្នែកមួយនៃស្ថាប័ន ឬបណ្ដាញអន្តរទីភ្នាក់ងារប្រឆាំងការជួញដូរមនុស្សទេ។ ដូច្នេះ តួអង្គទាំងនោះអាចទទួលបានប្រយោជន៍ពីការរួមបញ្ចូលសូចនាករទៅក្នុងនីតិវិធីប្រតិបត្តិការស្តង់ដាររបស់ពួកគេ។

ជនរងគ្រោះដោយការជួញដូរមនុស្ស អាចស្វែងរកការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល និងចូលរួមជាមួយអ្នកផ្ដល់សេវាសុខភាព បុគ្គលិកគាំការកុមារ និងអ្នកផ្សេងទៀត។ ខណៈដែលអ្នកពាក់ព័ន្ធទាំងនេះមិនមែនជាអាជ្ញាធរមានសមត្ថកិច្ចសម្រាប់ការកំណត់អត្តសញ្ញាណ ពួកគេអាចនៅតែពាក់ព័ន្ធក្នុងការជួយដល់ការកំណត់អត្តសញ្ញាណបឋម ដូច្នេះ ពួកគេគួរទទួលបានសូចនាករត្រឹមត្រូវ និងមានបច្ចុប្បន្នភាព ដើម្បីបំពេញតួនាទីនេះប្រកបដោយប្រសិទ្ធភាព។ អ្នកពាក់ព័ន្ធទាំងនេះក៏មានតួនាទីដ៏សំខាន់ ក្នុងការធ្វើបច្ចុប្បន្នភាពសូចនាករផងដែរ។

### កសាងការយល់ដឹងរបស់អ្នកអនុវត្តស្ដីពីរបៀបប្រើប្រាស់សូចនាករក្នុងការអនុវត្តន៍ជាក់ស្ដែង

អ្នកអនុវត្តគួរទទួលបានការបង្កើនការយល់ដឹង ដើម្បីឱ្យពួកគេដឹងថា ជនរងគ្រោះដោយការជួញដូរមនុស្សអាចពាក់ព័ន្ធក្នុងសកម្មភាពល្មើសច្បាប់ផ្សេងៗ ដោយសារតែពួកគេត្រូវបានជួញដូរ ដោយមិនគិតពីប្រភេទនៃការកេងប្រវ័ញ្ចដែលពួកគេទទួលរងដោយសារការជួញដូរនោះ។ ឧទាហរណ៍ មនុស្សម្នាក់ដែលពាក់ព័ន្ធក្នុងសកម្មភាពល្មើសច្បាប់ក្នុងឧស្សាហកម្មផ្លូវភេទ ក៏អាចបានរំលោភបទបញ្ញត្តិអន្តោប្រវេសន៍ ឬបទបញ្ញត្តិការងារផងដែរ។ មនុស្សម្នាក់ដែលត្រូវបានជួញដូរឱ្យធ្វើកសិកម្មអាចបានប្រព្រឹត្តបទល្មើសតូចតាច ដើម្បីរស់រាន។ ស្ថានភាពនីមួយៗមានលក្ខណៈពិសេសរៀងៗខ្លួន មានន័យថា អ្នកអនុវត្តត្រូវមានជំនាញ និងខិតខំពិនិត្យមើលស្ថានភាពបុគ្គលឱ្យបានម៉ត់ចត់ ដើម្បីកំណត់ថាតើមនុស្សម្នាក់អាចជាជនរងគ្រោះដោយការជួញដូរមនុស្ស ឬទេ។

### គាំទ្រសូចនាករដែលស៊ីសង្វាក់គ្នានៅទូទាំងតំបន់អាស៊ាន

អ្នកជួញដូរមនុស្ស កេងប្រវ័ញ្ចមនុស្សក្នុងរបៀបស្រដៀងគ្នានៅទូទាំងតំបន់អាស៊ាន មានន័យថាមានមេរៀនល្អៗដែលត្រូវរៀនសូត្រ និងចែករំលែក ដើម្បីសម្រេចបានការឆ្លើយតបដែលស្មើភាព និងមានប្រសិទ្ធភាព។ ដោយមិនគិតពីធាតុផ្សំនៃបទល្មើសជួញដូរមនុស្សក្នុងច្បាប់ជាតិ គួរពង្រឹងសូចនាករនៃការក្លាយជាជនរងគ្រោះ ដើម្បីគាំទ្រការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មនៅទូទាំងតំបន់អាស៊ាន។ ស្ថាប័នប្រឆាំងការជួញដូរនៅក្នុងប្រទេសជាសមាជិកអាស៊ាន នីមួយៗ គួររក្សាឱ្យស្ថាប័នតាមវិស័យរបស់អាស៊ានបានជ្រាបអំពីនិន្នាការនៃការជួញដូរមនុស្សដែលវិវត្តឥតឈប់ឈរ ឈានទៅរកការកសាងការយល់ដឹងអំពីការជួញដូរមនុស្សនៅទូទាំងតំបន់ និងសូចនាករគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស ដែលពាក់ព័ន្ធក្នុងសកម្មភាពល្មើសច្បាប់។

## *[៨] បង្កើនភាពអង់អាចដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម*

មន្ត្រីគួរអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មភ្លាមៗ នៅពេលពួកគេមានហេតុផលអាចសន្មតបានថា បុគ្គលម្នាក់អាចជាជនរងគ្រោះដោយការជួញដូរមនុស្ស ដោយមិនគិតថាតើជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណជាផ្លូវការ ឬអ្នកជួញដូរមនុស្សត្រូវបានចោទប្រកាន់ ឬអត់នោះទេ។[71] ក្នុងករណីដែលកាលៈទេសៈនាំឱ្យមានការសង្ស័យដែលអាចជឿបានថា បុគ្គលដែលត្រូវបានសង្ស័យថាត្រូវបានកេងប្រវ័ញ្ចឱ្យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ អាចត្រូវបានជួញដូរ គួរអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម។ ដូច្នេះ ចាំបាច់ត្រូវមានការវាយតម្លៃភ្លាមៗដោយបុគ្គលដែលបានទទួលការបណ្ដុះបណ្ដាល និងមានគុណវុឌ្ឍិ ដើម្បីកំណត់ថាតើបុគ្គលនោះបានក្លាយជាជនរងគ្រោះនៃបទល្មើសជួញដូរមនុស្ស ដូចដែលបានកំណត់ក្នុងលិខិតុបករណ៍អន្តរជាតិ លិខិតុបករណ៍ថ្នាក់តំបន់ និងលិខិតុបករណ៍ក្នុងស្រុក។ ច្បាប់ស្ដីពីការមិនដាក់ទោសទណ្ឌ (សូមមើលផ្នែកទី ២) ក៏អាចបង្កើនភាពអង់អាចដល់មន្ត្រីចាប់ខ្លួន ក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម និងការពារពួកគេពីការចោទប្រកាន់ថា ពួកគេបានចាប់ខ្លួនមនុស្សខុស ឬមិនបានធ្វើការចាប់ខ្លួន នៅពេលពួកគេគួរធ្វើ ផងដែរ។

## ជានាថា មន្ត្រីជួរមុខយល់ និងដឹងពីរបៀបប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន

អ្នកអនុវត្តដែលជួបជនរងគ្រោះដោយការជួញដូរមនុស្ស គួរតែយល់ពីឆន្ទានុសិទ្ធិដែលពួកគេមាន និងដឹងពីរបៀបប្រើប្រាស់ឆន្ទានុសិទ្ធិនោះ។ អ្នកស៊ើបអង្កេតគួរតែសម្រេចថាតើត្រូវចោទប្រកាន់បុគ្គលម្នាក់ ឬទេ ដោយផ្អែកលើធាតុផ្សំសត្យានុម័ត (*actus reus*) និងធាតុផ្សំអត្តនោម័ត (*mens rea*) នៃបទល្មើស។ អ្នកស៊ើបអង្កេតដែលមានជំនាញ នឹងមិនចោទប្រកាន់បុគ្គលម្នាក់សម្រាប់បទល្មើសដែលពួកគេមិនមានបំណងប្រព្រឹត្តទេ ប៉ុន្តែនឹងពិនិត្យមើលធាតុផ្សំនៃចេតនា ក្នុងការកំណត់ថាតើត្រូវចាប់ខ្លួន និងចោទប្រកាន់បុគ្គលម្នាក់ ឬអត់។

នៅក្នុងយុត្តាធិការដែលអ្នកស៊ើបអង្កេតមានឆន្ទានុសិទ្ធិ ពួកគេត្រូវតែសម្រេចថាតើពួកគេនឹងបន្តដាក់បទចោទប្រកាន់ និង/ឬណែនាំឱ្យដាក់បទចោទប្រកាន់។ ឆន្ទានុសិទ្ធិមិនចាប់ខ្លួន និងមិនដាក់បទចោទប្រកាន់ អាចមានចែងក្នុងច្បាប់ និងគោលនយោបាយដែលពន្យល់អំពីឆន្ទានុសិទ្ធិ និងការពិចារណាដែលអាចផ្តល់មូលដ្ឋានព័ត៌មានដល់ឆន្ទានុសិទ្ធិនោះ រួមទាំងថាតើការចោទប្រកាន់បុគ្គលម្នាក់ បម្រើឱ្យផលប្រយោជន៍សាធារណៈ ឬអត់។ គោលការណ៍មិនដាក់ទណ្ឌកម្ម ក៏អាចស្ថែងឡើងក្នុងផែនការសកម្មភាព និងគោលនយោបាយស្តីពីការប្រឆាំងការជួញដូរមនុស្សផងដែរ (សូមមើលឧបសម្ព័ន្ធ ២)។

**ប្រអប់៖ គោលនយោបាយស្តីពីការមិនដាក់ទណ្ឌកម្ម ក្នុងករណីគ្មានបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌ**

កម្ពុជាគ្មានបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌនៅក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់ខ្លួនទេ ប៉ុន្តែមានគោលការណ៍ណែនាំដែលបញ្ជាក់ថា "ជនបរទេសដែលត្រូវបានកំណត់អត្តសញ្ញាណជាផ្លូវការថាជាជនរងគ្រោះ នឹងមិនត្រូវបានឃុំខ្លួន ឬចោទប្រកាន់ពីបទអន្តោប្រវេសន៍ខុសច្បាប់ និង/ឬពេស្យាចារឡើយ។"[72]

ស្រដៀងគ្នាដែរ ប្រទេសអូស្ត្រាលីមិនបានអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មក្នុងច្បាប់របស់ខ្លួនទេ។ ទោះយ៉ាងណា ប៉ូលីសសហព័ន្ធអូស្ត្រាលី និងប្រធានអយ្យការរដ្ឋនៃកុំមិនវែល (Commonwealth Director of Public Prosecutions) ធ្វើឱ្យគោលនយោបាយមានប្រសិទ្ធភាពតាមរយៈ *គោលនយោបាយស្តីពីការផ្តន្ទាទោសនៃកុំមិនវែល* ដែលតម្រូវឱ្យពិចារណាថាតើការផ្តន្ទាទោសបម្រើឱ្យផលប្រយោជន៍សាធារណៈ ឬទេ។[73]

ក្នុងយុត្តាធិការដែលអ្នកស៊ើបអង្កេតមានឆន្ទានុសិទ្ធិមានកម្រិត ឬគ្មានឆន្ទានុសិទ្ធិស្តីពីថាតើត្រូវដាក់បទចោទប្រកាន់ ឬអត់ ការសម្រេចថាតើត្រូវបន្តការផ្តន្ទាទោសបទល្មើស ឬអត់ ត្រូវបានផ្ទេរទៅព្រះរាជអាជ្ញា ឬតុលាការ។ ក្នុងករណីបែបនេះ នៅពេលមន្ត្រីចាប់ខ្លួនបញ្ជូនករណីទៅព្រះរាជអាជ្ញា ពួកគេគួរបញ្ជូនភ្លាមៗនូវព័ត៌មាន ឬភស្តុតាងដែលពួកគេអាចមាន

---

[69] គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប (NCCT, ២០១៥), ចំណុចទី ២ នៅទំព័រ ១២

[70] សូមមើល៖ គោលនយោបាយស្តីពីការចោទប្រកាន់របស់ប្រទេសកុំមិនវែល៖ គោលការណ៍ណែនាំសម្រាប់ការធ្វើសេចក្តីសម្រេចក្នុងដំណើរការផ្តន្ទាទោស (CDPP, ២០១១) ទំព័រ ៤-៧ និងការពិនិត្យដោយមានគោលដៅលើបទល្មើសទាសភាពសម័យទំនើប ក្នុងផ្នែកទី ២៧០ និង ២៧១ នៃ *ច្បាប់ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៩៥* (Cth)៖ របាយការណ៍លទ្ធផលរកឃើញ (កុំមិនវែលអូស្ត្រាលី, ២០២៣), ទំព័រ ១១៨

សម្រាប់ការជឿថា បុគ្គលម្នាក់គឺជាជនរងគ្រោះដោយការជួញដូរមនុស្ស។ សំណុំរឿងអាចរួមបញ្ចូលផ្នែកស្តង់ដារមួយស្តីពីការមិនដាក់ទោសទណ្ឌ ដើម្បីបញ្ចូលព័ត៌មានស្តីពីថាតើគោលការណ៍មិនដាក់ទណ្ឌកម្មត្រូវបានអនុវត្ត ឬទេ និងឈរលើមូលដ្ឋានច្បាប់អ្វី។

**ប្រអប់៖ឧទាហរណ៍ (ការឆបោកដោយប្រើប្រាស់បច្ចេកវិទ្យា)**

"ក" មានសញ្ញាបត្រផ្នែកទីផ្សារ និងដាក់ពាក្យសុំធ្វើការផ្នែកលក់នៅបរទេស។ បន្ទាប់ពីការសម្ភាសន៍ជាច្រើនជុំ គាត់ត្រូវបានគេផ្តល់ការងារ។ បន្ទាប់ពីគាត់បានមកដល់កន្លែងធ្វើការ គាត់ដឹងថា អ្វីៗហាក់ខុសប្រក្រតីនៅពេលនិយោជករបស់គាត់ដកយកលិខិតឆ្លងដែន និងទូរស័ព្ទរបស់គាត់។ ពួកគេប្រាប់គាត់ថា គាត់នឹងចូលរួមក្នុងការងារឆបោកមនុស្សយកប្រាក់ជាច្រើន ដោយបង្កើតគណនីក្លែងក្លាយតាមអ៊ីនធឺណិត និងបញ្ចុះបញ្ចូលក្រុមគោលដៅឱ្យវិនិយោគលើការឆបោក។ គាត់ពូកែក្នុងការងារនេះ ដូច្នេះ គាត់មិនរងការវាយដំដូចសហការីមួយចំនួនឡើយ។ ថ្ងៃមួយ គាត់ និងកម្មករផ្សេងទៀតត្រូវបានប្រាប់ថា ប្រតិបត្តិការរបស់ពួកគេនឹងត្រូវរើទីតាំង និងថាពួកគេ នឹងត្រូវបានបញ្ជូនទៅប្រទេសមួយផ្សេងទៀត។ ពួកគេត្រូវបានបញ្ជូនទៅប្រទេសជិតខាង និងត្រូវបានឃាត់ខ្លួនដោយអាជ្ញាធរអន្តោប្រវេសន៍ និងចាប់ខ្លួនពីបទរំលោភច្បាប់អន្តោប្រវេសន៍។

ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ "ខ" ជាមន្ត្រីប៉ូលីសជាន់ខ្ពស់ដែលជំនាញខាងប្រឆាំងការជួញដូរមនុស្ស បានដឹងអំពីស្ថានភាពរបស់ "ក"។ គាត់ធ្វើដំណើរពីរាជធានីទៅកាន់តំបន់ព្រំដែនដែល "ក" និងអ្នកផ្សេងទៀត កំពុងត្រូវបានឃុំខ្លួននៅប៉ុស្តិ៍ប៉ូលីស។ គាត់ជូនដំណឹងដល់អធិការអំពីការសង្ស័យរបស់គាត់ថា បុគ្គលដែលស្ថិតក្រោមការឃុំឃាំងរបស់គាត់ គឺជាជនរងគ្រោះដោយការជួញដូរមនុស្ស។ ក្រោយបញ្ចប់ការពិនិត្យបឋម ដើម្បីកំណត់អត្តសញ្ញាណថាតើនរណាខ្លះក្នុងចំណោមពួកគេ អាចជាអ្នករៀបចំប្រតិបត្តិការ និងនរណាខ្លះជាអ្នកដែលអាចសន្មតជាជនរងគ្រោះ។ គាត់រៀបចំឱ្យមានការយកក្រុមក្រោយនេះ រួមទាំង "ក" ចេញពីការឃុំខ្លួនរបស់ប៉ូលីស និងបញ្ជូនទៅរកការការពារ និងជំនួយ។ គាត់ត្រូវបានផ្តល់កន្លែងស្នាក់នៅឯជម្រកសុវត្ថិភាពសម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស។ ព្រះរាជអាជ្ញាសម្រេចមិនចោទប្រកាន់ "ក"។

## ជំរុញឱ្យមានការផ្តួចផ្តើមស៊ើបអង្កេតយ៉ាងសកម្មលើករណីជួញដូរមនុស្ស

ដោយមិនគិតថាតើអ្នកស៊ើបអង្កេតមាន ឬអនុវត្តធន្ទានុសិទ្ធិ ឬអត់ វាជាការសំខាន់ណាស់ដែលពួកគេត្រូវបំពេញភារកិច្ចរបស់ខ្លួន ដើម្បីប្រមូលភស្តុតាងដែលអាចរកបានទាំងអស់នៃបទល្មើសដែលត្រូវបានចោទប្រកាន់ រួមទាំងកាលៈទេសៈជុំវិញណាមួយដែលអាចឈានដល់អង្គហេតុថា ជនល្មើសបានក្លាយជាជនរងគ្រោះដោយការជួញដូរមនុស្ស។ ភស្តុតាងបែបនេះអាចមានភាពពាក់ព័ន្ធ ក្នុងការចង្អុលបង្ហាញវិធានការការពារដែលអាចប្រើប្រាស់ដោយជនរងគ្រោះដែលកំពុងស្ថិតក្រោមការជំនុំជម្រះទោស។[71] ភស្តុតាងនេះក៏អាចមានសារៈសំខាន់ក្នុងការកំណត់អត្តសញ្ញាណ និងជួយសង្គ្រោះជនរងគ្រោះផ្សេងទៀត និងចាប់ខ្លួនអ្នកជួញដូរមនុស្សផងដែរ។

---

[71] ការណែនាំស្តីពីការឆ្លើយតបសមស្របផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ចំពោះជនរងគ្រោះដែលត្រូវបានបង្ខំឱ្យប្រព្រឹត្តបទល្មើសដោយសារតែពួកគេត្រូវបានជួញដូរ៖ ឯកសារសាវតារដែលរៀបចំឡើងដោយលេខាធិការដ្ឋានក្រុមការងារស្តីពីការជួញដូរមនុស្ស, វីយែន ថ្ងៃទី១០ និងទី ១១ ខែកញ្ញា ឆ្នាំ២០២០, ឯកសារ អ.ស.ប CTOC/COP/WG.4/2020/2 (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០), កថាខណ្ឌ ៤០-៤២។

ក្នុងករណីដែលកិច្ចខិតខំប្រឹងប្រែងស៊ើបអង្កេត ផ្តោតលើសកម្មភាពល្មើសច្បាប់របស់ជនរងគ្រោះ ជាជាងទំនាក់ទំនងរវាងសកម្មភាពទាំងនោះ និងអ្នកជួញដូរពួកគេ ការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌចំពោះការជួញដូរមនុស្ស នឹងចុះខ្សោយ។ អ្នកជួញដូរមនុស្ស អាចប្រើប្រាស់ជនរងគ្រោះជាអ្នកតំណាងសម្រាប់ការប្រព្រឹត្តបទល្មើស ដែលជាផ្នែកមួយនៃវិធីសាស្ត្ររបស់ពួកគេដើម្បីបង្វែរការយកចិត្តទុកដាក់ផ្នែកយុត្តិធម៌ព្រហ្មទណ្ឌចេញពីពួកគេ និងផ្តោតទៅលើជនរងគ្រោះវិញ ដូច្នេះ គឺជនរងគ្រោះដែលត្រូវប្រឈមនឹងការចាប់ខ្លួន។[72]

គេអាចសម្រេចបានភស្តុតាងប្រឆាំងនឹងអ្នកជួញដូរមនុស្ស រួមទាំងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តែងដែលចូលរួមក្នុងឧក្រិដ្ឋកម្មកម្រិតខ្ពស់ តែតាមរយៈការខិតខំស៊ើបអង្កេតប៉ុណ្ណោះ។ អ្នកអនុវត្តច្បាប់ត្រូវតែយល់ពីឱណាមិកនៃការប្រព្រឹត្តបទល្មើសដោយជនរងគ្រោះ និងស៊ើបអង្កេតយ៉ាងសកម្មលើភាគីដែលអាចពាក់ព័ន្ធក្នុងការត្រួតត្រា ឬគ្រប់គ្រងមនុស្ស ទ្រព្យសម្បត្តិ ឬគ្រឹះស្ថានដែលមានការរកឃើញជនរងគ្រោះដោយការជួញដូរមនុស្ស ដើម្បីកំណត់ថាតើពួកគេជាអ្នកជួញដូរមនុស្ស ឬជាជនរងគ្រោះ។[73]

គួរពិនិត្យឡើងវិញលើការអនុវត្តន៍របស់នគរបាល ដើម្បីពិចារណាពីរបៀបគាំទ្រ និងលើកទឹកចិត្តអ្នកស៊ើបអង្កេតឱ្យប្រើប្រាស់ពេលវេលា ជំនាញ កិច្ចខិតខំប្រឹងប្រែង និងធនធានរបស់ពួកគេ ដើម្បីស៊ើបអង្កេតករណីធ្ងន់ធ្ងរ និងស្មុគស្មាញ ជាជាងធ្វើការចាប់ខ្លួនដោយងាយស្រួលនូវជនល្មើសកម្រិតទាបដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស។ ក្នុងទិដ្ឋភាពនេះ គួរកសាងការយល់ដឹងរបស់អ្នកស៊ើបអង្កេតអំពីកាតព្វកិច្ចវិជ្ជមានរបស់រដ្ឋ ក្នុងការស៊ើបអង្កេតករណីដែលអាចជាការជួញដូរមនុស្ស។

## ប្រអប់៖ឧទាហរណ៍ (បទល្មើសពាក់ព័ន្ធនឹងឯកសារ)

“ក” ត្រូវបានជ្រើសរើសដោយទីភ្នាក់ងារមួយឱ្យធ្វើការជាអ្នកបម្រើតាមផ្ទះនៅប្រទេសមួយផ្សេងទៀត។ ទីភ្នាក់ងារជ្រើសរើស បានផ្តល់ឱ្យនាងនូវឯកសារធ្វើដំណើរ និងឯកសារអត្តសញ្ញាណដែលនាងត្រូវការ។ នៅឯផ្ទះដែលនាងធ្វើការ នាងត្រូវបានគេធ្វើបាប និងផ្តល់អាហារឱ្យមិនគ្រប់គ្រាន់។ នាងបានទៅកាន់ទីភ្នាក់ងារជ្រើសរើស ដើម្បីសុំជំនួយ ប៉ុន្តែបុគ្គលិករបស់ទីភ្នាក់ងារនោះបានប្រាប់នាងថា ប្រសិនបើនាងមិនត្រឡប់ទៅនិយោជករបស់នាងវិញទេ នគរបាលនឹងចាប់ខ្លួននាងពីបទប្រើប្រាស់ឯកសារក្លែងក្លាយ។ ក បានគិតថា នាងស្ថិតនៅក្នុងប្រទេសនេះដោយស្របច្បាប់ ដូច្នេះ នាងក៏បានទៅប៉ុស្តិ៍ប៉ូលីស ដើម្បីសុំជំនួយ។ នៅពេលនាងផ្តល់ឯកសាររបស់នាងដល់ប៉ូលីស ពួកគេបានចោទប្រកាន់នាងពីបទប្រើឯកសារក្លែងក្លាយ និងដាក់នាងក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍។

ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ អង្គការមិនមែនរដ្ឋាភិបាលមួយនៅក្នុងប្រទេសនេះដឹងពីស្ថានភាពរបស់ក។ ពួកគេបានរៀបចំជំនួយផ្លូវច្បាប់ ហើយរួមជាមួយអង្គការមិនមែនរដ្ឋាភិបាល និងមេធាវីរបស់ ក ពួកគេបានរៀបចំឱ្យទម្លាក់បទចោទប្រកាន់ប្រឆាំងនឹង ក។ ពួកគេប្រមូលភស្តុតាង (រួមទាំងឯកសារធ្វើដំណើរ និងឯកសារអត្តសញ្ញាណដែលត្រូវបានរៀបចំសម្រាប់ ក) នៃការជួញដូរមនុស្សដែលអាចកើតលើរូបនាង និងផ្តល់ព័ត៌មានទាំងនេះទៅនគរបាល ដើម្បីធ្វើការស៊ើបអង្កេត។

---

72 របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ, Maria Grazia Giammarinaro, ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០, ឯកសារ អ.ស.ប A/HRC/44/45, កថាខណ្ឌ. ២៩

73 Marcelo Colombo, ប្រធានព្រះរាជអាជ្ញា, ការិយាល័យឯកទេសសម្រាប់ការស៊ើបអង្កេតរឿងក្តីចាប់ជំរិត និងករណីជួញដូរមនុស្ស (PROTEX), អាហ្សង់ទីន និយាយអំពីគោលការណ៍នៃការមិនដាក់ទណ្ឌកម្មជនរងគ្រោះដោយការជួញដូរមនុស្ស, ជាព្រឹត្តិការណ៍បន្ទាប់បន្សំនៃសម័យប្រជុំលើកទី ៤៧ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១, ម៉ោង ១៣:០០ - ១៤:៣០ CET។

## បង្កើតបណ្តាញអ្នកអនុវត្ត ដើម្បីគាំទ្រការពិនិត្យ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ

សេវាសង្គម អ្នកផ្តល់សេវាថែទាំសុខភាព អង្គការសង្គមស៊ីវិល ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ និងតួអង្គផ្សេងទៀត (ទាំងតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ) មានតួនាទីក្នុងការគាំទ្រជនរងគ្រោះ។ ស្ថាប័នប្រឆាំងការជួញដូរមនុស្ស គួរបង្កើតបណ្តាញអ្នកអនុវត្តដ៏រឹងមាំ។ ធ្វើដូច្នេះ អ្នកអនុវត្តច្បាប់ដែលប្រាស្រ័យទាក់ទងជាមួយអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស នឹងដឹងថាត្រូវទាក់ទងនរណាដើម្បីទទួលបានការគាំទ្រ និងជំបូន្មាន និងមានព័ត៌មានទំនាក់ទំនងត្រឹមត្រូវ ក្នុងករណីដែលពួកគេកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស។ ការប្រើប្រាស់ក្រុមពហុជំនាញ ដើម្បីគាំទ្រដំណើរការពិនិត្យ និងកំណត់អត្តសញ្ញាណ អាចជាវិធីដ៏មានប្រសិទ្ធភាពមួយក្នុងការធានាថា គោលការណ៍មិនដាក់ទណ្ឌកម្ម ត្រូវបានអនុវត្តចំពោះអ្នកដែលត្រូវបានសន្មតជាជនរងគ្រោះដោយការជួញដូរមនុស្សនៅក្នុងដំណាក់កាលទាំងអស់នៃដំណើរការកំណត់អត្តសញ្ញាណ។ ប្រហែលជាត្រូវមានបណ្តាញអ្នកអនុវត្តដ៏ទូលំទូលាយ ដើម្បីការពារជនរងគ្រោះដោយការជួញដូរមនុស្សពីហានិភ័យដែលពួកគេអាចប្រឈម ជាពិសេសនៅពេលពួកគេត្រូវបានធ្វើឱ្យក្លាយជាជនរងគ្រោះដោយក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង។

សំខាន់បំផុតគឺ នៅពេលមានប្រតិបត្តិការអនុវត្តន៍ច្បាប់ ទោះនៅក្នុងបរិវេណអគារឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ឬនៅទីតាំងផ្សេងទៀតដែលមនុស្សអាចត្រូវបានជួញដូរ ដូចជា កសិកម្ម ឧស្សាហកម្មអាហារសមុទ្រ ឬឧស្សាហកម្មផ្លូវភេទ គួររៀបចំផែនការជាមុន និងលម្អិត ដើម្បីកំណត់ថាតើនរណាទទួលខុសត្រូវលើការកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនរងគ្រោះ ដែលពួកគេបានជួប និងនរណាទទួលខុសត្រូវលើការការពារ និងជួយដល់បុគ្គលទាំងនោះ។ ទស្សនៈយល់ឃើញរបស់អាជ្ញាធរដែលត្រូវបានបណ្តុះបណ្តាលឱ្យចេះកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស គួរតែមានអាទិភាពជាងទស្សនៈយល់ឃើញរបស់អ្នកដទៃ ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ។

## លុបបំបាត់កត្តាបន្ទុចបង្អាក់ និងបង្កើតកត្តាលើកទឹកចិត្ត ដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម

នៅពេលដែលការអនុវត្តន៍ការងាររបស់នគរបាលត្រូវបានវាស់វែងដោយចំនួននៃការចាប់ខ្លួន និងបទចោទប្រកាន់ដែលបានដាក់ នេះអាចជាការបន្ទុចបង្អាក់មិនឱ្យនគរបាលអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មចំពោះអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស ក្នុងចំណោមជនល្មើសដែលពួកគេបានជួប។ ដូច្នេះ គួរពិចារណាពីរបៀបលើកទឹកចិត្តឱ្យនគរបាលអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ដូចជា ការវាស់វែងការអនុវត្តន៍ការងារ ដែលឆ្លុះបញ្ចាំងពីការណ៍ដែលពួកគេអនុវត្តគោលការណ៍នេះបានយ៉ាងសមស្រប។ ឧទាហរណ៍ ការបញ្ជូនបុគ្គលសម្រាប់ការត្រួតពិនិត្យ ដែលពួកគេត្រូវបានបញ្ជាក់ថា ជាជនរងគ្រោះដោយការជួញដូរមនុស្ស អាចជាសូចនាករដែលត្រូវបានប្រើប្រាស់ ដើម្បីវាស់វែងជាវិជ្ជមានលើការអនុវត្តន៍ការងាររបស់នគរបាល។

ក្រៅពីនេះ គេអាចចាត់វិធានការ ដើម្បីធានាថា អ្នកអនុវត្តច្បាប់ដែលមិនធ្វើការចាប់ខ្លួន និងដាក់បទចោទប្រកាន់ប្រឆាំងនឹងជនរងគ្រោះដោយការជួញដូរមនុស្ស ដោយផ្អែកលើគោលការណ៍មិនដាក់ទណ្ឌកម្ម មិនទទួលខុសត្រូវចំពោះការចោទប្រកាន់ពីបទធ្វេសប្រហែសក្នុងភារកិច្ចរបស់ពួកគេ ប៉ុន្តែត្រូវបានកោតសរសើរចំពោះការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម។ ត្រូវបង្កើតឱ្យមានការលើកទឹកចិត្តបែបនេះ ដើម្បីមិនធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចអនុវត្តច្បាប់ទូលំទូលាយក្នុងការស៊ើបអង្កេត និងចាប់ខ្លួនជនល្មើស។ ដូច្នេះ គេអាចផ្តោតលើការពិចារណាផ្តល់រង្វាន់ដល់នគរបាល ដែលបានកសាងកស្តុតាងប្រឆាំងនឹងឧក្រិដ្ឋជន រួមទាំងការអនុវត្តន៍វិធីសាស្ត្រស្ទាត់ជំនាញក្នុងការស៊ើបអង្កេតជនល្មើសដែលអាចជាជនរងគ្រោះ និងជាសាក្សីនៃការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងទៀតដែលមានអង្គការចាត់តាំង។

## ធានាថា មន្ត្រីដឹងពីរបៀបបញ្ជូនជនរងគ្រោះទៅកាន់បណ្តាញការពារ

រដ្ឋត្រូវមាននីតិវិធី និងយន្តការដើម្បីធានាថា នគរបាល មន្ត្រីអន្តោប្រវេសន៍ និងមន្ត្រីការងារដែលជួបជនរងគ្រោះដោយការជួញដូរមនុស្ស អាចបញ្ជូនអ្នកដែលអាចជាជនរងគ្រោះទៅកាន់យន្តការបញ្ជូនថ្នាក់ជាតិយ៉ាងឆាប់រហ័ស ដោយអនុលោមតាមមាត្រា ១៤(១) នៃអនុសញ្ញា ACTIP។[74] បណ្តាញការពារទាំងនោះត្រូវតែសមស្រប ដើម្បីការពារសិទ្ធិមនុស្សរបស់ជនរងគ្រោះ រួមទាំងតាមរយៈការការពារដែលគិតគូរពីអាយុ និងយេនឌ័រ ផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត និងមិនរើសអើង។

ក្នុងករណីដែលយន្តការបញ្ជូនថ្នាក់ជាតិមិនទាន់ត្រូវបានប្រើប្រាស់ និងអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីបង្វែរជនរងគ្រោះពីការដាក់ទោសទណ្ឌ ចាំបាច់ត្រូវកំណត់រក និងដោះស្រាយឧបសគ្គរាំងការការពារ ទោះបីតាមរយៈការផ្សព្វផ្សាយព័ត៌មាន ការផ្តល់ការបណ្តុះបណ្តាលជំនាញ ឬវិធានការផ្សេងទៀតក៏ដោយ។ អ្នកដែលប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះដោយការជួញដូរមនុស្ស គួរទទួលបានព័ត៌មានទំនាក់ទំនងថ្មីៗបំផុតសម្រាប់អ្នកពាក់ព័ន្ធដែលគួរទាក់ទងទៅ ក្នុងករណីបានជួបអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស រួមទាំងអាជ្ញាធរការពារកុមារ ក្នុងករណីដែលជនរងគ្រោះជាអនីតិជន។

ក្នុងករណីដែលជនល្មើសជាកុមារ អាចជាជនរងគ្រោះដោយការជួញដូរមនុស្ស មន្ត្រីជួរមុខគួរចូលរួមជាមួយអាជ្ញាធរការពារកុមារឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ គួរអនុវត្តការសន្មតថាជាអនីតិជនក្នុងការប្រព្រឹត្តចំពោះអ្នកដែលអាចជាកុមារ ក្នុងករណីដែលគ្មានភស្តុតាងបញ្ជាក់ច្បាស់ពីអាយុ។ កុមារដែលមានទំនាស់ជាមួយច្បាប់ រួមទាំងបទល្មើសធ្ងន់ធ្ងរក្នុងបរិបទនៃក្រុមប្រដាប់អាវុធ ឬក្រុមភេរវករ គួរទទួលបានអត្ថប្រយោជន៍ពីគោលការណ៍មិនដាក់ទណ្ឌកម្ម និងត្រូវបានទទួលស្គាល់ថាជាជនរងគ្រោះដោយការជួញដូរមនុស្ស ដែលជាជនរងគ្រោះដោយការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌។ គួរផ្តោតអាទិភាពលើការស្តារឡើងវិញ ការធ្វើសមាហរណកម្ម និងការរស់ជួបជុំគ្រួសាររបស់ពួកគេឡើងវិញ។[75] អាយុនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ក៏ពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះកុមារដែលចូលរួមក្នុងសកម្មភាពល្មើសច្បាប់ក្នុងដំណើរការនៃការជួញដូរពួកគេ និងប្រហែលជាត្រូវដំឡើងអាយុ។[76]

---

74 មាត្រា ១៤(១) នៃអនុសញ្ញា ACTIP ចែងថា "ភាគីនីមួយៗត្រូវរៀបចំគោលការណ៍ណែនាំ ឬនីតិវិធីសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្សឱ្យបានត្រឹមត្រូវ និងក្នុងករណីសមស្រប អាចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការជួយជនរងគ្រោះ។"

75 សូមមើលសេចក្តីសម្រេចលេខ ២៣៨៨ របស់ក្រុមប្រឹក្សាសន្តិសុខ ឆ្នាំ ២០១៧។

76 សូមមើលគោលការណ៍ណែនាំទី ២។

### អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ

ដោយទទួលស្គាល់ថាការជួញដូរមនុស្សគឺជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម មិនគួរផ្អែកលើការកំណត់អត្តសញ្ញាណជនរងគ្រោះជាផ្លូវការ ឬការកាត់ទោសអ្នកជួញដូរមនុស្សដែលរងការចោទប្រកាន់ឡើយ។ ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម មិនត្រូវផ្អែកលើកិច្ចសហប្រតិបត្តិការរបស់ជនរងគ្រោះក្នុងនីតិវិធីព្រហ្មទណ្ឌឡើយ។

ដើម្បីធានាការអនុវត្តន៍តាមគោលការណ៍មិនដាក់ទណ្ឌកម្ម ត្រូវរំដោះជនរងគ្រោះដោយការជួញដូរមនុស្សទាំងអស់ដែលត្រូវបានសន្មត ឬកំណត់អត្តសញ្ញាណ ចេញពីការឃុំខ្លួន ឬស្ថានភាពដកហូតសេរីភាពឱ្យបានទាន់ពេលវេលា ហើយផ្តល់ជំនួយ និងការការពារដល់ពួកគេ។

គោលការណ៍មិនដាក់ទណ្ឌកម្ម ត្រូវតែអនុវត្តដោយគ្មានការរើសអើងចំពោះជនរងគ្រោះដោយការជួញដូរមនុស្សទាំងអស់ រួមទាំងជនរងគ្រោះដោយការជួញដូរមនុស្សដែលស្វែងរកសិទ្ធិជ្រកកោន ឬទម្រង់ផ្សេងៗនៃការការពារពីអន្តរជាតិ។[80]

---

[77] ប្រភព៖ *ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ Siobhán Mullally*, ឯកសារ អ.ស.ប A/HRC/47/34, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១, [៥៨-៦០]

## [៦] ធានាថា មន្ត្រីនគរបាលយុត្តិធម៌បំពេញកាតព្វកិច្ចរបស់ពួកគេចំពោះជនដែលត្រូវបានចាប់ខ្លួន

ការចាប់ខ្លួនជនរងគ្រោះដោយការជួញដូរ អាចផ្ទុយនឹងវិធីសាស្ត្រសម្រាប់ការជួញដូរមនុស្សដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ និងកាតព្វកិច្ចរបស់រដ្ឋក្នុងការការពារជនរងគ្រោះដោយការជួញដូរមនុស្ស។ ប៉ុន្តែក្នុងករណីផ្សេងទៀត វាអាចជាការសមស្របក្នុងការចាប់ខ្លួនជនប្រព្រឹត្តបទល្មើស-ជាជនរងគ្រោះ សម្រាប់សកម្មភាពល្មើសច្បាប់ដែលមិនទាក់ទងដោយផ្ទាល់ទៅនឹងការជួញដូរពួកគេ។ នៅពេលដែលមន្ត្រីចាប់ខ្លួនសម្រេចចាប់ខ្លួនអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស ពួកគេត្រូវតែបំពេញកាតព្វកិច្ចរបស់ខ្លួន រួមទាំងកាតព្វកិច្ចសិទ្ធិមនុស្សជាមូលដ្ឋាន ចំពោះអ្នកដែលពួកគេចាប់ខ្លួនដើម្បីកាត់បន្ថយហានិភ័យនៃការបង្កគ្រោះថ្នាក់បន្ថែមទៀត។

### កសាងការយល់ដឹងរបស់មន្ត្រីជួរមុខស្តីពីផលប៉ះពាល់នៃការចាប់ខ្លួនជនរងគ្រោះដោយការជួញដូរមនុស្ស

មន្ត្រីជួរមុខត្រូវតែយល់ដឹងអំពីផលប៉ះពាល់នៃការចាប់ខ្លួនលើជនរងគ្រោះដោយការជួញដូរមនុស្ស ដូចជា ការធ្វើឱ្យពួកគេក្លាយជាជនរងគ្រោះម្តងទៀតដោយសាររដ្ឋ និងភាពអាម៉ាស់នៃការត្រូវបានចាប់ខ្លួន ការថតរូប យកស្នាមម្រាមដៃ ដាក់ខ្នោះដៃ និងពេលខ្លះ ត្រូវបានបង្ខំឱ្យទទួលយកការពិនិត្យផ្នែកវេជ្ជសាស្ត្រដោយគ្មានការយល់ព្រមដោយផ្អែកលើព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ។ ពួកគេត្រូវយល់ដឹងផងដែរថា ការចាប់ខ្លួនធ្វើឱ្យជនរងគ្រោះមានភាពអាម៉ាស់ និងរាំងដល់ការស្តារ និងការធ្វើសមាហរណកម្មពួកគេឡើងវិញក្រោយពេលត្រូវបានជួញដូរ។

លើសពីនេះ មន្ត្រីជួរមុខត្រូវតែយល់ដឹងថាតើការចាប់ខ្លួនជនរងគ្រោះបង្កផលអាក្រក់របៀបណាដល់ការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌចំពោះការជួញដូរមនុស្ស។ ក្នុងករណីដែលអ្នកស៊ើបអង្កេតមិនបានខិតខំស៊ើបអង្កេតលើការជួញដូរមនុស្ស ជនរងគ្រោះអាចជាភស្តុតាងចម្បង ឬជាភស្តុតាងតែមួយគត់ក្នុងករណីជួញដូរមនុស្ស។ នៅពេលដែលជនរងគ្រោះបាត់បង់ការជឿទុកចិត្តលើអាជ្ញាធរ ពួកគេប្រហែលជាមិនសហការក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌប្រឆាំងនឹងអ្នកជួញដូរមនុស្សឡើយ។

### ធានាថា មន្ត្រីនគរបាលយុត្តិធម៌គោរពសិទ្ធិទទួលបានព័ត៌មានរបស់ជនដែលត្រូវបានចាប់ខ្លួន

រដ្ឋមានកាតព្វកិច្ចចំពោះមនុស្សដែលពួកគេចាប់ខ្លួន។ ការបំពេញកាតព្វកិច្ចទាំងនោះមានសារៈសំខាន់សម្រាប់ការធានាថា ជនរងគ្រោះដោយការជួញដូរមនុស្សដែលត្រូវបានចាប់ខ្លួន ទទួលបានដំបូន្មាន និងការគាំទ្រសមស្របពីអាជ្ញាធរ ដើម្បីរួចផុតពីការដាក់ទោសទណ្ឌបន្ថែមទៀតសម្រាប់បទល្មើសដែលពួកគេបានប្រព្រឹត្តដោយសារតែពួកគេត្រូវបានជួញដូរ។ ដូច្នេះ រដ្ឋត្រូវតែចាត់វិធានការធានាថា មន្ត្រីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ពួកគេចំពោះជនដែលត្រូវបានចាប់ខ្លួន។ សំខាន់បំផុត ជនដែលត្រូវបានចាប់ខ្លួន រួមទាំងជនរងគ្រោះដោយការជួញដូរមនុស្ស មានសិទ្ធិទទួលបានការជូនដំណឹងអំពីមូលហេតុនៃការចាប់ខ្លួនពួកគេ បទចោទប្រកាន់ណាមួយដែលបានដាក់ និងការនាំទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រម ឬមន្ត្រីផ្សេងទៀត ជាបន្ទាន់។[78]

[78] មាត្រា ៩(២) *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*

មាត្រា ៣៦ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ចែងថា ជនបរទេសដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួន ត្រូវទទួលបានព័ត៌មានស្តីពីសិទ្ធិរបស់ពួកគេក្នុងការជូនដំណឹងដល់ស្ថានទូតរបស់ខ្លួន ដើម្បីទទួលបានជំបូន្មាន និងការគាំទ្រពីស្ថានកុងស៊ុល។ ពួកគេក៏គួរទទួលបានព័ត៌មានស្តីពីសិទ្ធិរបស់ខ្លួនក្នុងការទទួលបានតំណាងការទូត និងកុងស៊ុលពីប្រទេសដែលពួកគេជាពលរដ្ឋផងដែរ ដោយកត់សម្គាល់ថាជនភៀសខ្លួន ឬអ្នកស្វែងរកសិទ្ធិជ្រកកោន អាចមិនចង់មានទំនាក់ទំនង ឬចែករំលែកព័ត៌មានជាមួយតំណាងរបស់រដ្ឋ។ វិធីសាស្ត្រនេះស្របតាមមាត្រា ១៤(៣) នៃអនុសញ្ញា ACTIP ដែលបានចែងថា ការកំណត់អត្តសញ្ញាណគួរត្រូវបានជូនដំណឹងដល់ប្រទេសជាអ្នកបញ្ជូន ដោយគ្មានការពន្យារពេលដែលមិនសមហេតុផល "លើកលែងតែជនរងគ្រោះផ្តល់ព័ត៌មានផ្សេង។"

### *(៧) ទទួលស្គាល់ស្ថានភាពជាជនរងគ្រោះរបស់បុគ្គល ដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងរដ្ឋសមាជិកអាស៊ានផ្សេងទៀត*

ជនរងគ្រោះដោយការជួញដូរមនុស្សដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងរដ្ឋសមាជិកអាស៊ាន គួរតែមានស្ថានភាពដែលត្រូវបានទទួលស្គាល់នៅកន្លែងផ្សេងទៀតក្នុងតំបន់ ស្របតាមមាត្រា ១៤(២) នៃអនុសញ្ញា ACTIP៖

ក្នុងករណីដែលការជួញដូរមនុស្សកើតឡើងនៅក្នុងប្រទេសច្រើនជាងមួយ ភាគីនីមួយៗត្រូវគោរព និងទទួលស្គាល់ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស ដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសជាអ្នកទទួល។

ក្នុងករណីដែលជនរងគ្រោះដោយការជួញដូរមនុស្ស មិនត្រូវបានទទួលស្គាល់ថាជាជនរងគ្រោះនៅក្នុងយុត្តាធិការផ្សេងទៀត គាត់នឹងត្រូវបានការពារពីការដាក់ទោសទណ្ឌនៅក្នុងប្រទេសមួយ ប៉ុន្តែអាចត្រូវបានដាក់ទោសទណ្ឌនៅក្នុងប្រទេសមួយទៀត។

### ខិតខំកែប្រែកិច្ចព្រមព្រៀងទ្វេភាគីដែលមានស្រាប់ ដើម្បីពង្រឹងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម

មានកិច្ចព្រមព្រៀងទ្វេភាគី និងអនុស្សរណៈនៃការយោគយល់គ្នា (MOUs) មួយចំនួនរវាងរដ្ឋសមាជិកអាស៊ាន ដែលរួមបញ្ចូលដាក់លាក់នូវបទបញ្ញត្តិស្តីពីការមិនដាក់ទណ្ឌកម្មជនរងគ្រោះដោយការជួញដូរមនុស្ស (សូមមើលឧបសម្ព័ន្ធ ៣)។ ទោះយ៉ាងណាក៏ដោយ បទបញ្ញត្តិមួយចំនួនអនុវត្តតែចំពោះបទល្មើសមួយចំនួនតូចប៉ុណ្ណោះ (ឧ. បទល្មើសទាក់ទងនឹងអន្តោប្រវេសន៍ និងពេស្យាចារ)។ បទបញ្ញត្តិខ្លះមានលក្ខណៈរើសអើង ដោយសារវាអនុវត្តតែចំពោះជនរងគ្រោះមួយចំនួនប៉ុណ្ណោះ (ឧ. ស្ត្រី និងកុមារ) ប៉ុន្តែមិនអនុវត្តចំពោះអ្នកផ្សេងទៀត (ឧ. បុរស)។

រដ្ឋគួរពិចារណាកែប្រែកិច្ចព្រមព្រៀងទ្វេភាគីរបស់ខ្លួន ដើម្បីឆ្លុះបញ្ចាំងគោលការណ៍មិនដាក់ទណ្ឌកម្ម ស្របតាមច្បាប់អន្តរជាតិ និងច្បាប់ក្នុងស្រុក ដើម្បីធានាថា៖

ក) យល់ដឹងអំពីការជួញដូរមនុស្ស ស្របតាមនិយមន័យអន្តរជាតិ និងនិយមន័យក្នុងតំបន់សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងទ្វេភាគី ដើម្បីកែតម្រូវចំណុចខុសគ្នាក្នុងនិយមន័យក្រោមច្បាប់ជាតិ សម្រាប់គោលបំណងនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ។

ខ) បទបញ្ញត្តិមិនដាក់ទោសទណ្ឌ មិនមានការរើសអើងទេ ដូច្នេះ វាអនុវត្តចំពោះជនរងគ្រោះទាំងអស់ដោយមិនគិតពីអាយុ ភេទ សញ្ជាតិ ឬស្ថានភាពផ្សេងទៀតរបស់ពួកគេ។

គ) មានការកំណត់វិសាលភាពនៃការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ប៉ុន្តែអនុវត្តចំពោះសកម្មភាព ឬបទល្មើសខុសច្បាប់ណាមួយ និងទាំងអស់ដែលជនរងគ្រោះដោយការជួញដូរមនុស្ស អាចពាក់ព័ន្ធដោយផ្ទាល់ ដោយសារតែពួកគេត្រូវបានជួញដូរ។

ក្នុងករណីគ្មានកិច្ចព្រមព្រៀងទ្វេភាគីពេញលេញ រដ្ឋសមាជិកអាស៊ានគួរពិចារណាប្រើប្រាស់អនុសញ្ញា ACTIP ជាមូលដ្ឋានសម្រាប់ការទទួលស្គាល់ទៅវិញទៅមកនូវស្ថានភាពជាជនរងគ្រោះ ឬ UNTOC និងពិធីសារបំពេញបន្ថែមស្តីពីការជួញដូរមនុស្ស នៅពេលដែលប្រទេសប្រភពដើម ប្រទេសឆ្លងកាត់ និង/ឬប្រទេសគោលដៅដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស ស្ថិតនៅក្រៅតំបន់អាស៊ាន។

## អនុវត្តកិច្ចព្រមព្រៀងមានស្រាប់ដែលទាក់ទងនឹងគោលការណ៍មិនដាក់ទណ្ឌកម្ម

អាជ្ញាធរប្រឆាំងការជួញដូរមនុស្សនៅក្នុងរដ្ឋសមាជិកអាស៊ាន ត្រូវកសាងការយល់ដឹងរបស់អ្នកអនុវត្តស្តីពីកិច្ចព្រមព្រៀងទ្វេភាគី ដែលរួមបញ្ចូលប្រការចែងដែលពាក់ព័ន្ធនឹងគោលការណ៍មិនដាក់ទណ្ឌកម្ម (រួមទាំងប្រការចែងដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធ ៣)។ មួយវិញទៀត អាជ្ញាធរទាំងនោះគួរគាំទ្រដល់អ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងទាំងនេះ ដើម្បីច្រានចោលការចោទប្រកាន់ប្រឆាំងនឹងជនរងគ្រោះ ទទួលស្គាល់ស្ថានភាពជាជនរងគ្រោះរបស់បុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងប្រទេសផ្សេងទៀត និង/ឬអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ដើម្បីគាំទ្រដល់គោលការណ៍មិនដាក់ទណ្ឌកម្ម។ តួអង្គប្រឆាំងការជួញដូរមនុស្ស ក៏គួរតែកំណត់វិសាលភាពផងដែរ ដើម្បីស្វែងយល់ថាហេតុអ្វីបានជាកិច្ចព្រមព្រៀងទ្វេភាគីដែលពាក់ព័ន្ធនឹងការមិនដាក់ទោសទណ្ឌ មិនត្រូវបានអនុវត្តក្នុងស្ថានភាពជាក់ស្តែង និងចាត់វិធានការដើម្បីដោះស្រាយឧបសគ្គដែលបានកត់សម្គាល់ក្នុងច្បាប់ គោលនយោបាយ និងការអនុវត្តន៍។

# ផ្នែកទី ៤

# ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មនៅពេលដែលជនរងគ្រោះកំពុងប្រឈមមុខនឹងការកាត់ក្តី

## ផ្នែកទី ៤. ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម នៅពេលជនរងគ្រោះកំពុងប្រឈមនឹងការជំនុំជម្រះទោស

ក្នុងករណីដែលគ្មានការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស ពួកគេអាចត្រូវបានកាត់ទោសសម្រាប់បទល្មើសដែលពួកគេបានប្រព្រឹត្ត ក្នុងអំឡុងពេលដែលពួកគេត្រូវបានជួញដូរ។ ក្នុងស្ថានភាពផ្សេងទៀត ជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណ ប៉ុន្តែអាចនៅតែមានការចេញសេចក្តីសម្រេចកាត់ទោសពួកគេ។ ក្នុងករណីទាំងពីរនេះ ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មជាការទទួលខុសត្រូវរបស់អ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌដែលកំពុងកាត់ទោស ឬការពារជនប្រព្រឹត្តបទល្មើស-ជាជនរងគ្រោះ និងត្រូវតែគោរពសិទ្ធិរបស់ពួកគេក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។[79]

អ្នកអនុវត្តទទួលបានគាំទ្រក្នុងការបំពេញកាតព្វកិច្ចរបស់ពួកគេ ក្នុងករណីដែលច្បាប់ជាតិដែលពួកគេអាចប្រើប្រាស់បានឆ្លុះបញ្ចាំងពីគោលការណ៍មិនដាក់ទណ្ឌកម្ម និងមិនកំណត់ថា វាអនុវត្តតែចំពោះសកម្មភាពល្មើសច្បាប់មួយចំនួន (សូមមើលគោលការណ៍ណែនាំទី ១)។ ទោះយ៉ាងណាក៏ដោយ រដ្ឋសមាជិកអាស៊ានស្ថិតក្នុងដំណាក់កាលខុសៗគ្នានៃការបន្សីច្បាប់របស់ពួកគេទៅនឹងកាតព្វកិច្ចក្នុងតំបន់ និងកាតព្វកិច្ចអន្តរជាតិ។ សម្រាប់រយៈពេលអន្តរកាល ក្នុងករណីគ្មានគោលការណ៍ច្បាស់លាស់ស្តីពីការមិនដាក់ទណ្ឌកម្ម ឬក្នុងករណីដែលបទបញ្ញត្តិជាធរមានស្តីពីការមិនដាក់ទោសទណ្ឌ កម្រិតវិសាលភាពនៃការការពារ អ្នកអនុវត្តគួរតែនៅព្យាយាមអនុវត្តតាមគោលការណ៍មិនដាក់ទណ្ឌកម្ម ដូចបានចែងក្នុងមាត្រា ១៤ (៧) នៃអនុសញ្ញា ACTIP និងកាតព្វកិច្ចអន្តរជាតិ។

ព្រះរាជអាជ្ញាត្រូវមានសមត្ថភាពកំណត់ថាតើពេលណាដែលសមស្រប ឬមិនសមស្របក្នុងការកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្ស អាស្រ័យលើទំនាក់ទំនងរវាងសកម្មភាពល្មើសច្បាប់ និងសកម្មភាពនៃការជួញដូរជនរងគ្រោះ។ ព្រះរាជអាជ្ញាត្រូវតែយល់ពីរបៀបអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន និងរបៀបអនុវត្តបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌ ក៏ដូចជាវិធានការការពារដែលអាចមានចែងក្នុងច្បាប់ជាតិ។ ក្នុងករណីដែលគ្មានការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ដើម្បីការពារជនរងគ្រោះពីការនាំខ្លួនទៅជំនុំជម្រះទោស មេធាវីការពារក្តីត្រូវតែមានសមត្ថភាពក្នុងការអនុវត្តវិធានការការពារប្រកបដោយប្រសិទ្ធភាពដើម្បីផលប្រយោជន៍របស់កូនក្តី។ មន្ត្រីតុលាការក៏ត្រូវយល់ពីតួនាទីរបស់ខ្លួនក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ក្នុងដំណើរការតុលាការផងដែរ។

ខាងក្រោមនេះជាគោលការណ៍ណែនាំ ដើម្បីគាំទ្រដល់រដ្ឋក្នុងការពង្រឹងសមត្ថភាពរបស់ព្រះរាជអាជ្ញា មេធាវីការពារក្តី និងមន្ត្រីតុលាការ ក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម នៅពេលជនរងគ្រោះកំពុងប្រឈមនឹងការជំនុំជម្រះទោស។

---

[79] សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ មានចែងក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ២០(១) នៃសេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្ស។

## (៨) ពង្រឹងសមត្ថភាពរបស់ព្រះរាជអាជ្ញា ក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម

ដើម្បីឱ្យជនរងគ្រោះទទួលបានផលប្រយោជន៍ពីគោលការណ៍មិនដាក់ទណ្ឌកម្ម ត្រូវតែមានទំនាក់ទំនងរវាងបទល្មើស និងការជួញដូរមនុស្ស ទោះបីជាដោយសារតែជនរងគ្រោះត្រូវបានបង្ខំដោយអ្នកជួញដូរមនុស្សឱ្យប្រព្រឹត្តបទល្មើស (ការបង្ខិតបង្ខំ) ឬក៏បទល្មើសនោះគឺជាផលវិបាកដោយផ្ទាល់នៃការណ៍ដែលជនរងគ្រោះត្រូវបានគេជួញដូរ (ហេតុ និងផល) ក៏ដោយ។ សូម្បីតែនៅពេលដែលគ្មានទំនាក់ទំនងរវាងបទល្មើស និងការជួញដូរមនុស្ស ក៏រដ្ឋនៅតែអាចសម្រេចមិនកាត់ទោសជនរងគ្រោះ ព្រោះការធ្វើបែបនេះគឺផ្ទុយនឹងកាតព្វកិច្ចរបស់រដ្ឋក្នុងការការពារជនរងគ្រោះ និងស៊ើបអង្កេត និងកាត់ទោសអ្នកជួញដូរមនុស្ស ឬមិនបម្រើឱ្យផលប្រយោជន៍សាធារណៈ។ ក្នុងករណីមានការចេញសេចក្ដីសម្រេច ដើម្បីកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្ស ត្រូវពន្យល់ពីមូលហេតុនៃការសម្រេចបែបនេះឱ្យបានច្បាស់ និងប្រកបដោយតម្លាភាព។

ជាក់ស្ដែង ព្រះរាជអាជ្ញាច្រើនតែមានភាពងាយស្រួលក្នុងការកាត់ទោស ដោយផ្អែកលើក្រមព្រហ្មទណ្ឌ ជាជាងមិនកាត់ទោសដោយផ្អែកលើបទបញ្ញត្តិក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្ស។ ដូច្នេះ អ្នកពាក់ព័ន្ធក្នុងការប្រឆាំងការជួញដូរមនុស្ស ត្រូវជួយធ្វើយ៉ាងណាឱ្យព្រះរាជអាជ្ញាយល់ និងអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការមិនកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្សសម្រាប់បទល្មើស ដែលជាផលវិបាកដោយផ្ទាល់នៃការជួញដូរពួកគេ ឬបញ្ឈប់ការកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្ស ក្នុងករណីដែលភស្តុតាង ឬការពិចារណាផលប្រយោជន៍សាធារណៈ គាំទ្រការសម្រេចបែបនោះ។

### បញ្ជាក់ពីទំនាក់ទំនងរវាងស្ថានភាពជាជនរងគ្រោះ និងការមិនកាត់ទោស

រដ្ឋសមាជិកអាស៊ាន ត្រូវកំណត់ថាតើការកំណត់ស្ថានភាពជនរងគ្រោះមានផលប៉ះពាល់អ្វីខ្លះលើ លទ្ធភាព ឬអលទ្ធភាពក្នុងការកាត់ទោសជនរងគ្រោះ។[80] អ្នកពាក់ព័ន្ធក្នុងប្រឆាំងការជួញដូរមនុស្ស គួរបង្កើនការយល់ដឹងរបស់ព្រះរាជអាជ្ញា ស្ដីពីផលប៉ះពាល់នៃការកំណត់ស្ថានភាពជាជនរងគ្រោះលើសេចក្ដីសម្រេចរបស់ខ្លួន ដែលរួមបញ្ចូលទាំងការផ្ដល់ព័ត៌មានដល់ពួកគេអំពីបទល្មើសនៃការជួញដូរមនុស្ស និងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម។

ព្រះរាជអាជ្ញាគួរយល់ច្បាស់ពីនិយមន័យនៃការជួញដូរមនុស្ស សូចនាករនៃការជួញដូរមនុស្ស និងយន្តការដែលអាចឱ្យមានការដកអ្នកដែលអាចជាជនរងគ្រោះ ចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចសម្រាប់ការកំណត់អត្តសញ្ញាណជាផ្លូវការ។ មួយវិញទៀត ព្រះរាជអាជ្ញាគួរយល់ច្បាស់ពីបទបញ្ញត្តិស្ដីពីការមិនដាក់ទណ្ឌកម្មនៅក្នុងច្បាប់ គោលនយោបាយ និងឯកសារណែនាំដែលមានស្រាប់ និងកិច្ចព្រមព្រៀងអន្តរជាតិ និងទ្វេភាគី ក្នុងស្ថានភាពដែលបុគ្គលម្នាក់ត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះដោយការជួញដូរមនុស្ស នៅក្នុងយុត្តាធិការមួយផ្សេងទៀត។

**ជានាថា ព្រះរាជអាជ្ញាយល់ពីឆន្ទានុសិទ្ធិរបស់ខ្លួន និងដឹងពីរបៀបអនុវត្តឆន្ទានុសិទ្ធិនោះ**

[80] ចំណុចសំខាន់គឺ ការមិនដាក់ទោសទណ្ឌជនរងគ្រោះតាំងពីដំបូង មិនគួរអាស្រ័យលើការកំណត់អត្តសញ្ញាណជនរងគ្រោះ ឬអ្នកជួញដូរជនរងគ្រោះ ជាផ្លូវការនោះទេ។ កម្រិតសម្រាប់ការអនុវត្តគោលការណ៍នេះពីដំបូង គួរតែជាមូលដ្ឋានសមហេតុផលអាចឱ្យជឿបានថា មានការជួញដូរមនុស្ស។

ព្រះរាជអាជ្ញាគួរតែស្ថិតក្រោមកាតព្វកិច្ចច្បាស់លាស់ក្នុងការមិនកាត់ទោស ឬបញ្ឈប់នីតិវិធីប្រឆាំងនឹងជនរងគ្រោះសម្រាប់បទល្មើសដែលទាក់ទងនឹងការជួញដូរពួកគេ។ នៅក្នុងយុត្តាធិការមួយចំនួន ព្រះរាជអាជ្ញាអាចមានកាតព្វកិច្ចចាប់ផ្តើមការកាត់ទោសប្រឆាំងនឹងបុគ្គល ដែលរងការចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស។ នៅក្នុងយុត្តាធិការផ្សេងទៀត ព្រះរាជអាជ្ញាអាចមានឆន្ទានុសិទ្ធិមិនចាប់ផ្តើមនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងជនរងគ្រោះដោយការជួញដូរមនុស្ស ឬក្នុងករណីដែលការកាត់ទោសកំពុងដំណើរការរួចទៅហើយ បញ្ឈប់នីតិវិធី នៅពេលមានភស្តុតាងបង្ហាញថា បុគ្គលម្នាក់ដែលកំពុងស្ថិតក្រោមការជំនុំជម្រះ គឺជាជនរងគ្រោះដោយការជួញដូរមនុស្ស។

ក្នុងការសម្រេចថាតើត្រូវកាត់ទោស ឬអត់ ព្រះរាជអាជ្ញាអាចវាយតម្លៃថាតើពួកគេជឿថាមានភស្តុតាងគ្រប់គ្រាន់ ដើម្បីតម្រូវឱ្យមានការកាត់ទោសដោយផ្អែកលើធាតុផ្សំនៃបទល្មើសដែលកំពុងស្ថិតក្រោមការពិចារណា (រួមទាំងធាតុផ្សំ "កំហុស") ដោយគិតទៅលើវិធានការការពារដែលមាន និងការពិចារណាផលប្រយោជន៍សាធារណៈដែលគាំទ្រ ឬប្រឆាំងនឹងការបន្តនីតិវិធីកាត់ទោស។[81]

## ប្រអប់៖ ឧទាហរណ៍ (ឃាតកម្ម)

"ក" ត្រូវបានឃាត់ឃាំងលើនាវានៅសមុទ្រអស់រយៈពេលជាច្រើនខែ និងត្រូវបានបង្ខំឱ្យធ្វើការក្រោមលក្ខខណ្ឌដ៏សាហាវព្រៃផ្សៃ។ ជាញឹកញាប់ គាត់ និងមនុស្សផ្សេងទៀតនៅលើនាវា ត្រូវបានវាយដំដោយអ្នកដែលចាប់ពួកគេ។ ថ្ងៃមួយ មិត្តរបស់ "ក" (ច) ស្ទើរតែបាត់បង់ដៃរបស់គាត់នៅក្នុងសំណាញ់។ ពួកគេបានអង្វរអ្នកគ្រប់គ្រងពួកគេឱ្យរៀបចំជំនួយវេជ្ជសាស្ត្រ ប៉ុន្តែជំនួសឱ្យការជួយដល់ "ច" អ្នកគ្រប់គ្រងពួកគេបានបង្ខំឱ្យ "ក" រុញ "ច" ទម្លាក់ទឹក ដើម្បីទុកជាមេរៀនដល់កម្មករដទៃទៀតស្តីពីផលវិបាកនៃការរងរបួស

ថ្ងៃមួយ អធិការជលផលបានឡើងនាវានោះ ដើម្បីពិនិត្យឯកសាររបស់កម្មករ។ "ក" គិតថានេះជាឱកាសក្នុងការរត់គេចខ្លួន ដូច្នេះ គាត់ចាប់ផ្តើមប្រាប់អធិការថា គាត់ចង់ចាកចេញពីនាវានោះ។ មុនពេលគាត់អាចធ្វើដូច្នេះបាន កាពីតែន ប្រាប់អាជ្ញាធរថា "ក" បានសម្លាប់សមាជិកក្រុមម្នាក់។ "ក" សារភាពថាបានសម្លាប់ "ច" និងត្រូវបានកាត់ទោសពីបទឃាតកម្ម។

*ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖* មេធាវីការពារក្តីដែលត្រូវបានចាត់តាំងឱ្យតំណាង "ក" គ្មានបទពិសោធន៍ក្នុងករណីជួញដូរមនុស្សទេ ដូច្នេះ គាត់មិនបានទទួលស្គាល់ស្ថានភាពរបស់ "ក" ថាជាអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្សទេ។ មេធាវីបានពន្យល់ប្រាប់ "ក" ថា គាត់នឹងការពារគាត់ដោយយោងទៅលើការបង្ខិតបង្ខំ ដោយសារការគំរាមបង្ករបួសរាងកាយធ្ងន់ធ្ងរដែលគាត់បានប្រឈម។ ព្រះរាជអាជ្ញាសាធារណៈដែលត្រូវបានតែងតាំងឱ្យកាត់ទោស "ក" មានបទពិសោធន៍ក្នុងការកាត់ទោសករណីជួញដូរមនុស្ស និងសង្ស័យថា "ក" ជាជនរងគ្រោះដោយការជួញដូរមនុស្ស។ ព្រះរាជាអាជ្ញាបានស្នើសុំឱ្យបញ្ឈប់សំណុំរឿងនេះ និងស្នើឱ្យបញ្ជូន "ក" ទៅរកការការពារ។ "ក" ត្រូវបានរំដោះចេញពីការឃុំខ្លួន និងបញ្ជូនទៅរកការពិនិត្យ និងការការពារ តាមរយៈយន្តការបញ្ជូនថ្នាក់ជាតិ។ គេបានចាប់ផ្តើមការស៊ើបអង្កេតស្តីពីសកម្មភាពរបស់នាវាដែល "ក" ត្រូវបានចាប់ខ្លួន។

---

81 ក្រុមសម្របសម្រួលអន្តរទីភ្នាក់ងារប្រឆាំងការជួញដូរមនុស្ស ការមិនដាក់ទោសទណ្ឌជនរងគ្រោះដោយការជួញដូរមនុស្ស (ICAT, Issue Brief 8/2020) ៤; ការណែនាំស្តីពីការឆ្លើយតបសមស្របផ្នែកយុត្តិធម៌ព្រហ្មទណ្ឌចំពោះជនរងគ្រោះដែលត្រូវបានបង្ខំឱ្យប្រព្រឹត្តបទល្មើសដោយសារតែពួកគេត្រូវបានជួញដូរ៖ ឯកសារសាវតារដែលរៀបចំឡើងដោយលេខាធិការដ្ឋានក្រុមការងារស្តីពីការជួញដូរមនុស្ស វីយែន ថ្ងៃទី ១០ និងទី ១១ ខែកញ្ញា ឆ្នាំ២០២០, ឯកសារ អ.ស.ប CTOC/COP/WG.4/2020/2 (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០), កថាខណ្ឌ ៤៤-៤៥។

### អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ

ដើម្បីធានាការអនុលោមតាមគោលការណ៍មិនដាក់ទណ្ឌកម្ម ក្នុងការចេញសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា រដ្ឋត្រូវធានាថា៖

(ក) ព្រះរាជអាជ្ញាស្ថិតក្រោមកាតព្វកិច្ចបញ្ឈប់នីតិវិធីប្រឆាំងនឹងជនដែលត្រូវបានជួញដូរ សម្រាប់បទល្មើសទាំងអស់ដែលបានប្រព្រឹត្ត ដែលជាលទ្ធផលដោយផ្ទាល់នៃស្ថានភាពរបស់ពួកគេក្នុងនាមជាជនរងគ្រោះដោយការជួញដូរមនុស្ស។ ប្រសិនបើអាជ្ញាធរផ្តន្ទាទោសមិនបានធ្វើដូច្នេះ តុលាការក្នុងស្រុកគួរតែមានសមត្ថកិច្ចបញ្ជាឱ្យបញ្ឈប់នីតិវិធី ដោយឈរលើមូលដ្ឋាននៃការរំលោភបំពានដំណើរការ ឬដោយផ្អែកលើមូលដ្ឋានដែលការកាត់ទោស នឹងរំលោភកាតព្វកិច្ចមិនដាក់ទោសទណ្ឌ។

(ខ) អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ និងព្រះរាជអាជ្ញាទទួលបានការបណ្តុះបណ្តាលពេញលេញ ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស និងបទល្មើសដែលទាក់ទងនឹងការជួញដូរមនុស្ស និងបញ្ជា ឬស្នើឱ្យបញ្ឈប់នីតិវិធីឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ [85]

### តម្រូវឱ្យព្រះរាជអាជ្ញាត្រួតពិនិត្យជាតុផ្សំអត្តនោម័ត (*mens rea*) នៃបទល្មើសដែលជនរងគ្រោះត្រូវបានចោទប្រកាន់

ព្រះរាជអាជ្ញាត្រូវតែយល់ និងពិនិត្យមើលជាតុផ្សំអត្តនោម័ត (*mens rea*) សម្រាប់បទល្មើសណាមួយដែលពួកគេធ្វើការកាត់ទោស។ ព្រះរាជអាជ្ញាគួរវាយតម្លៃថាតើការប្រើប្រាស់វិធីសាស្ត្រណាមួយដោយអ្នកជួញដូរមនុស្ស (ដូចជាការប្រើកម្លាំង ការឆបោក ការបង្ខិតបង្ខំ ឬវិធីសាស្ត្រផ្សេងទៀតដែលបានបញ្ជាក់ក្នុងមាត្រា ៣(ក) នៃពិធីសារស្តីពីការជួញដូរមុស្ស និងមាត្រា ២(ក) នៃអនុសញ្ញា ACTIP) អាចបានបំផ្លាញចេតនារបស់ជនជាប់សង្ស័យក្នុងការប្រព្រឹត្តបទល្មើសដែលរងការចោទប្រកាន់ដែរ ឬទេ។[83] ការអនុវត្តន៍ការត្រួតពិនិត្យបែបនេះ អាចបញ្ចៀសស្ថានភាពដែលជនរងគ្រោះដោយការជួញដូរមនុស្សត្រូវបាននាំខ្លួនមកជំនុំជម្រះទោស និងត្រូវបានកាត់ទោសសម្រាប់បទល្មើសដែលពួកគេមិនមានចេតនាប្រព្រឹត្ត។

ក្នុងករណីកុមារ ដែលមិនតម្រូវឱ្យមានមធ្យោបាយ ដើម្បីកំណត់ស្ថានភាពរបស់ពួកគេជាជនរងគ្រោះដោយការជួញដូរមនុស្ស វាគួរតែគ្រប់គ្រាន់ក្នុងការកំណត់ទំនាក់ទំនងរវាងបទល្មើសដែលបានប្រព្រឹត្ត និងស្ថានភាពរបស់កុមារក្នុងនាមជាជនរងគ្រោះដោយការជួញដូរមនុស្ស ដើម្បីមិនចាប់ផ្តើម ឬបញ្ឈប់នីតិវិធីណាមួយប្រឆាំងនឹងពួកគេ។

---

[82] ប្រភព៖ *ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ Siobhán Mullally*, ឯកសារ អ.ស.ប A/HRC/47/34, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១, [៦៤]

[83] 'មធ្យោបាយ' ដូចមានចែងក្នុងមាត្រា ៣ នៃពិធីសារស្តីពីការជួញដូរមនុស្ស និងមាត្រា ២(ក) នៃអនុសញ្ញា ACTIP គឺជាការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង និងទម្រង់ដទៃទៀតនៃការបង្ខិតបង្ខំ ការចាប់ជំរិត ការបន្លំ ការបោកបញ្ឆោត ឬការប្រើអំណាចរំលោភបំពាន ឬការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ ឬការផ្តល់ ឬទទួលកម្រៃ ឬផលប្រយោជន៍នានា ដើម្បីសម្រេចការយល់ព្រមនៃមនុស្សម្នាក់ដែលមានអំណាចត្រួតត្រាលើមនុស្សណាម្នាក់ទៀត។

ជាទូទៅ ការអនុវត្តន៍ការងាររបស់ព្រះរាជអាជ្ញាត្រូវបានវាស់វែង ដោយការចោទប្រកាន់ទោសដែលពួកគេធ្វើឡើង ជាជាងការចោទប្រកាន់ទោសដែលពួកគេមិនបានធ្វើ។ ព្រះរាជអាជ្ញាអាចភ័យខ្លាចការចោទប្រកាន់លើការធ្វេសប្រហែស នៅពេលពួកគេមិនធ្វើការកាត់ទោស។ ដើម្បីលើកទឹកចិត្តព្រះរាជអាជ្ញាឱ្យអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ការអនុវត្តន៍ការងាររបស់ព្រះរាជអាជ្ញាអាចវាស់វែងធៀបនឹងថាតើពួកគេបានត្រួតពិនិត្យជាតុផ្សំ "ចេតនា" នៃបទល្មើសដែលត្រូវបានចោទប្រកាន់ មុននឹងធ្វើការកាត់ទោស ឬទេ។ មួយវិញទៀត គួររក្សាឱ្យព្រះរាជអាជ្ញាទទួលខុសត្រូវលើការកាត់ទោសបទល្មើស ក្នុងករណីគ្មានចេតនាគ្រប់គ្រាន់ក្នុងការប្រព្រឹត្តបទល្មើស។

## គាំទ្រព្រះរាជអាជ្ញាឱ្យសំអាងហេតុ តាមរយៈសេចក្តីសម្រេចរបស់ខ្លួនថាតើត្រូវកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្ស ឬទេ

ក្នុងការវាយតម្លៃករណីនីមួយៗ ព្រះរាជអាជ្ញានឹងពិចារណាយ៉ាងប្រុងប្រយ័ត្នលើកត្តាទាំងអស់ មុននឹងសម្រេចថាតើត្រូវចោទប្រកាន់ទោសបុគ្គល ដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយការជួញដូរមនុស្ស ឬទេ។ ឧទាហរណ៍ សំអាងហេតុរបស់ព្រះរាជអាជ្ញា សម្រាប់ការចោទប្រកាន់ទោសបុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយការជួញដូរមនុស្ស អាចដោយសារតែគ្មានទំនាក់ទំនងរវាងការប្រព្រឹត្តបទល្មើសរបស់បុគ្គលនោះ និងការជួញដូររូបគាត់ និងដោយសារតែការចោទប្រកាន់ទោសរូបគាត់ គឺដើម្បីបម្រើផលប្រយោជន៍សាធារណៈ។

តុលាការសិទ្ធិមនុស្សអឺរ៉ុបក្នុងករណី *V.C.L និង A.N. ទល់នឹង ចក្រភពអង់គ្លេស* (សង្ខេបក្នុងឧបសម្ព័ន្ធ ៤) ផ្តល់ការយល់ដឹងជាប្រយោជន៍ស្តីពីសារៈសំខាន់នៃការវាយតម្លៃការជួញដូរមនុស្សដោយ អាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីនោះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានរកឃើញថា សេចក្តីសម្រេចរបស់ចក្រភពអង់គ្លេសក្នុងការកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្ស សម្រាប់ការផលិតកញ្ឆា បានរំលោភសិទ្ធិមនុស្សរបស់ពួកគេ។[84]

...ដោយហេតុថាស្ថានភាពរបស់បុគ្គលម្នាក់ក្នុងនាមជាជនរងគ្រោះដោយការជួញដូរមនុស្ស អាចប៉ះពាល់ដល់ថាតើមានភស្តុតាងគ្រប់គ្រាន់ ដើម្បីកាត់ទោស និងថាតើការធ្វើដូច្នេះបម្រើឱ្យផលប្រយោជន៍សាធារណៈ ឬទេ ការសម្រេចណាមួយថាតើត្រូវកាត់ទោសអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស ឬទេ គួរធ្វើឡើង (ក្នុងកម្រិតដែលអាចធ្វើទៅបាន) តែបន្ទាប់ពីមានការវាយតម្លៃការជួញដូរមនុស្ស ដោយបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ នេះមានសារៈសំខាន់ជាពិសេស នៅពេលពាក់ព័ន្ធនឹងកុមារ។[85]

ក្នុងករណីនោះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសង្កត់ធ្ងន់ថា គ្មានការហាមឃាត់ទូទៅលើការកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្សទេ។ ទោះយ៉ាងណាក៏ដោយ ចក្រភពអង់គ្លេសមិនបានផ្តល់សំអាងហេតុសម្រាប់ការបន្តកាត់ទោសបុគ្គលដែលពាក់ព័ន្ធឡើយ ទោះបីជាមានការសង្ស័យគួរឱ្យជឿជាក់ថា ពួកគេជាជនរងគ្រោះដោយការជួញដូរមនុស្សឱ្យដាំកញ្ឆាក៏ដោយ។ តុលាការអឺរ៉ុបបានពន្យល់ ក្នុងលក្ខខណ្ឌដែលមានប្រយោជន៍ក្នុងការណែនាំដល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញានៅក្នុងអាស៊ាន ថា៖

[84] ជាពិសេស, មាត្រា ៤ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ហាមឃាត់ទាសភាព ឬសេវាគតិភាព និងការងារដោយបង្ខំ ឬគាបសង្កត់ និងមាត្រា ៦ ដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះទោសដោយយុត្តិធម៌។

[85] *ករណី V.C.L និង A.N. ទល់នឹង ចក្រភពអង់គ្លេស, (ពាក្យបណ្តឹងលេខ ៧៧៥៨៧/១២ និង ៧៤៦០៣/១២) សាលក្រម Strasbourg, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១, កថាខណ្ឌ ១៦១។*

បន្ទាប់ពីមានការវាយតម្លៃការជួញដូរមនុស្ស ដោយបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សេចក្តីសម្រេចជាបន្តបន្ទាប់របស់ព្រះរាជអាជ្ញា ត្រូវតែពិចារណាលើការវាយតម្លៃនោះ។ ខណៈដែលព្រះរាជអាជ្ញាអាចនឹងមិនត្រូវបានចងកាតព្វកិច្ចដោយលទ្ធផលរកឃើញពីដំណើរការវាយតម្លៃការជួញដូរមុស្សបែបនោះ ព្រះរាជអាជ្ញាត្រូវមានសំអាងហេតុច្បាស់លាស់ដែលស្របតាមនិយមន័យនៃការជួញដូរមនុស្ស នៅក្នុងពិធីសារ Palermo និងអនុសញ្ញាស្តីពីការប្រឆាំងនឹងការជួញដូរមនុស្សសម្រាប់ការមិនយល់ស្របនឹងលទ្ធផលរកឃើញទាំងនោះ។[86]

## ប្រអប់៖ ឧទាហរណ៍ (ការជួញដូរមនុស្ស)

"ក" ត្រូវបានចាប់ខ្លួនជាមួយនឹងបុគ្គលម្នាក់ផ្សេងទៀត "ខ" ដោយសង្ស័យថាបានជួញដូរមនុស្សទៅក្នុងការកេងប្រវ័ញ្ចផ្លូវភេទ។ នៅផ្ទះបន "ក" មើលការខុសត្រូវលើស្ត្រីផ្សេងទៀត ប៉ុន្តែមិនបានប្រើការបង្ខិតបង្ខំលើពួកគេទេ។ ចម្លើយពីជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណនៅផ្ទះបន និងរបាយការណ៍ខ្សែអាត់សំឡេងបង្ហាញថា ជនរងគ្រោះមិនបានចាត់ទុក "ក" ជាជនសង្ស័យទេ ប៉ុន្តែជាជនរងគ្រោះម្នាក់ទៀត។ នាងក៏ធ្វើការក្នុងឧស្សាហកម្មផ្លូវភេទ និងប្រគល់ប្រាក់របស់នាងទៅឱ្យជនជាប់ចោទផងដែរ។ នាងស្ថិតក្រោមឥទ្ធិពលរបស់ "ខ" ដែលបានសន្យាថា នឹងរួមរស់ជាមួយនាង ហើយនាងស្រឡាញ់គាត់។ "ក" គ្រប់គ្រងស្ត្រីផ្សេងទៀត ដើម្បីការពារជនសង្ស័យមិនឱ្យធ្វើបាប ឬគំរាមកំហែងពួកនាងម្តងទៀត ហើយនាងខ្លាច "ខ"។

ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ សាលាដំបូងបានរកឃើញថា "ក" មិនមែនជាជនរងគ្រោះដោយការជួញដូរមនុស្សទេ នៅពេលដែលនាងបានប្រព្រឹត្តបទល្មើស ព្រោះនាងបានក្លាយទៅជាអ្នកជួញដូរមនុស្ស។ ទាំង "ក" និង "ខ" សុទ្ធតែត្រូវបានផ្តន្ទាទោសពីបទជួញដូរមនុស្ស។ នៅក្នុងបណ្តឹងឧទ្ធរណ៍ សាលាឧទ្ធរណ៍បានសំអាងហេតុថា គោលការណ៍មិនដាក់ទណ្ឌកម្មត្រូវបានអនុវត្ត ដើម្បីការពារការដាក់ទោសទណ្ឌជនរងគ្រោះសម្រាប់សកម្មភាពបទល្មើសដែលពួកគេបានប្រព្រឹត្ត ក្រោមការបង្ខិតបង្ខំ។ សាលាឧទ្ធរណ៍បានសំអាងហេតុថា ព្រះរាជអាជ្ញាគួរតែបានចេញសេចក្តីសម្រេចដូចគ្នា ដោយផ្អែកលើភស្តុតាងនៃខ្សែអាត់សំឡេង និងចម្លើយរបស់ជនរងគ្រោះផ្សេងទៀត។ តុលាការបានសម្រេចឱ្យ "ក" រួចខ្លួន និងតម្រូវឱ្យ "ខ" បង់សំណងការខូចខាត។[90]

[86] *ករណី V.C.L និង A.N. ទល់នឹង ចក្រភពអង់គ្លេស,* (ពាក្យបណ្តឹងលេខ ៧៧៥៨៧/១២ និង ៧៤៦០៣/១២) សាលក្រម Strasbourg, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១, កថាខណ្ឌ ១៦២។

[87] ឧទាហរណ៍នេះផ្អែកលើករណី ECLI:NL:RBSGR:2009:BK8237 ជាករណីពីព្រះរាជាណាចក្រហូឡង់ ដែលមានការអនុវត្តន៍មាត្រា ២៦ នៃអនុសញ្ញាក្រុមប្រឹក្សាអឺរ៉ុបស្តីពីសកម្មភាពប្រឆាំងនឹងការជួញដូរមនុស្ស (ការមិនដាក់ទោសទណ្ឌ)។

### ធានាថា ជនរងគ្រោះទទួលបានព័ត៌មានស្តីពីសេចក្តីសម្រេចកាត់ទោសពួកគេ

អ្នកដែលកំពុងស្ថិតក្រោមការជំនុំជម្រះទោស គួរត្រូវបានពន្យល់អំពីដំណើរការ និងសេចក្តីសម្រេចរបស់តុលាការ។ តុលាការគួរតែផ្តល់ព័ត៌មានជាភាសាដែលសាមញ្ញ សមស្របតាមអាយុ មានបរិយាបន្នពិការភាព មិនប្រើពាក្យច្បាប់ និងជាភាសាដែលពួកគេអាចយល់បាន រួមទាំងព័ត៌មានស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្ម ដើម្បីឱ្យពួកគេយល់ថា ពួកគេមិនគួរត្រូវបានដាក់ទោសសម្រាប់បទល្មើសដែលទាក់ទងដោយផ្ទាល់ទៅនឹងការជួញដូរពួកគេ។[88]

ជាឧទាហរណ៍ ប្រទេសឡាវមានសៀវភៅណែនាំស្តីពីការគ្រប់គ្រងករណីជួញដូរមនុស្សនៅក្នុងតុលាការ ដែលកំណត់ថា តុលាការត្រូវផ្តល់ព័ត៌មាន និងឯកសារសមស្របក្នុងទម្រង់ផ្សេងៗដល់ជនរងគ្រោះតាមរបៀបសាមញ្ញ ដោយមិនប្រើពាក្យច្បាប់ និងជាភាសាដែលងាយយល់។ ព័ត៌មានដែលបានផ្តល់ ត្រូវរួមបញ្ចូលគោលការណ៍នៃការមិនដាក់ទណ្ឌកម្ម ដើម្បីឱ្យជនរងគ្រោះយល់ថា ពួកគេមិនមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ឬរដ្ឋបាលសម្រាប់សកម្មភាពល្មើសច្បាប់ដែលពួកគេបានប្រព្រឹត្ត ប្រសិនបើសកម្មភាពទាំងនោះទាក់ទងដោយផ្ទាល់ទៅនឹងការជួញដូរមនុស្ស ស្របតាមមាត្រា ១៤(៧) នៃអនុសញ្ញា ACTIP។ វិធីសាស្ត្រដូចគ្នានេះ (ការផ្តល់ព័ត៌មានដល់ជនរងគ្រោះដោយការជួញដូរមនុស្ស) ក៏គួរអនុវត្តផងដែរ នៅពេលពួកគេកំពុងស្ថិតក្រោមការជំនុំជម្រះទោសសម្រាប់សកម្មភាពល្មើសច្បាប់ ដែលពួកគេបានចូលរួមដោយសារតែពួកគេត្រូវបានជួញដូរ។

## [៩] ពង្រឹងសមត្ថភាពរបស់មេធាវីការពារក្តី ក្នុងការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម

ការបញ្ចូលបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌទៅក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្ស និងការផ្តល់វិធានការការពារក្រោមក្រមព្រហ្មទណ្ឌ គឺមិនគ្រប់គ្រាន់ឡើយ។ ត្រូវមានការប្រតិបត្តិបទបញ្ញត្តិទាំងនេះក្នុងការអនុវត្តន៍ជាក់ស្តែងដោយអ្នកច្បាប់ដែលមានជំនាញគ្រប់គ្រាន់ ដើម្បីអនុវត្តឱ្យស្របទៅនឹងស្ថានភាពរបស់ជនរងគ្រោះដោយការជួញដូរមនុស្ស ដែលកំពុងប្រឈមនឹងការកាត់ទោស ដោយគោរពសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ ដូច្នេះ អ្នកអនុវត្តច្បាប់ត្រូវទទួលបានការបណ្តុះបណ្តាលជាបន្តបន្ទាប់ ដើម្បីធានាថាពួកគេយល់ពីគោលការណ៍មិនដាក់ទណ្ឌកម្ម ហើយត្រូវតែមានយន្តការត្រួតពិនិត្យ ដើម្បីធានាថា ពួកគេពិតជាអនុវត្តគោលការណ៍នេះប្រាកដមែន។

---

[88] សូចនាករតុលាការដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះដោយការជួញដូរមនុស្ស, កម្មវិធី ASEAN-ACT, ៤.១(ខ)។ សូមមើលផងដែរ *តុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ៖ សៀវភៅណែនាំសម្រាប់រដ្ឋសមាជិកអាស៊ាន* (ASEAN-ACT, ២០២២) អភិវឌ្ឍដោយកម្មវិធី ASEAN-ACT រួមជាមួយនឹងរដ្ឋសមាជិកអាស៊ាន។

### ជានាថា ជនរងគ្រោះដោយការជួញដូរមនុស្សដែលកំពុងប្រឈមនឹងការដាក់ទោសទណ្ឌ ទទួលបានជំនួយផ្នែកច្បាប់

ជំនួយផ្នែកច្បាប់ គឺជាសមាសភាគសំខាន់មួយនៃសិទ្ធិមនុស្សក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។[89] ដូច្នេះ រដ្ឋសមាជិកអាស៊ានមានកាតព្វកិច្ចផ្តល់ជំនួយផ្នែកច្បាប់ដល់បុគ្គលដែលកំពុងស្ថិតក្រោមការជំនុំជម្រះទោស រួមទាំងជនរងគ្រោះដោយការជួញដូរមនុស្សដែលកំពុងប្រឈមនឹងការកាត់ទោស។ មានការប្តេជ្ញាចិត្តខ្ពស់ ជាពិសេសក្នុងស្ថានភាពដែលជនរងគ្រោះកំពុងប្រឈមនឹងការធ្វើទណ្ឌកម្មរាងកាយ ឬការប្រហារជីវិតសម្រាប់បទល្មើសដែលទាក់ទងនឹងការជួញដូរជនរងគ្រោះ។

ការផ្តល់ជំនួយផ្នែកច្បាប់គឺជាការទទួលខុសត្រូវរបស់រដ្ឋ ប៉ុន្តែភាគីពាក់ព័ន្ធក្នុងវិជ្ជាជីវៈច្បាប់ អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល អាចចូលរួមក្នុងការផ្តល់ជំនួយផ្នែកច្បាប់ ឬផ្តល់មូលនិធិដល់ជំនួយបែបនេះ។[90] អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល អាចដើរតួនាទីសំខាន់ក្នុងការគាំទ្ររដ្ឋឱ្យផ្តល់ជំនួយផ្នែកច្បាប់ និងជួយជនរងគ្រោះដែលកំពុងស្ថិតក្រោមការជំនុំជម្រះទោស ឱ្យយល់ពីដំណើរការតុលាការ និងបណ្តឹងឧទ្ធរណ៍។ ដូច្នេះ គួររៀបចំឱ្យមានយន្តការសម្រាប់កិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ឧទាហរណ៍ តាមរយៈការបង្កើតវេទិការួមសម្រាប់ការសម្របសម្រួល ការបែងចែកធនធាន និងការចែករំលែកព័ត៌មានស្តីពីការអនុវត្តន៍ល្អបំផុតក្នុងជំនួយផ្នែកច្បាប់។

**ប្រអប់៖ ឧទាហរណ៍ (បទល្មើសរដ្ឋបាល)**

ក្នុងអំឡុងវិបត្តិកូវីដ-១៩ អតិថិជនបានឈប់ទៅផ្ទះបនដែល "ក" ត្រូវបានបង្ខំឱ្យធ្វើការ។ អ្នកគ្រប់គ្រងរបស់ "ក" បានបង្ខំនាងឱ្យចេញទៅបម្រើអតិថិជនតាមផ្ទះ ដើម្បីបន្តសងបំណុលរបស់នាង។ ល្ងាចថ្ងៃមួយ នៅពេលនាងកំពុងត្រឡប់ទៅផ្ទះបនវិញបន្ទាប់ពីបានទៅបម្រើអតិថិជនតាមផ្ទះ នាងត្រូវបាននគរបាលចាប់ខ្លួន និងត្រូវបានចោទប្រកាន់ពីបទរំលោភបំរាមគោចរ។ "ក" ភ័យខ្លាចថា នាងនឹងត្រូវបានចោទប្រកាន់ពីបទប្រឡូកក្នុងឧស្សាហកម្មផ្លូវភេទផងដែរ។ ដូច្នេះ នាងមិនបាននិយាយអ្វីទៅកាន់នគរបាលអំពីស្ថានភាពរបស់នាងឡើយ។

*__ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖__* "ក" ត្រូវបានចាត់តាំងឲ្យមានមេធាវីជំនួយផ្នែកច្បាប់ម្នាក់ ដើម្បីតំណាងឱ្យរូបនាង។ បន្ទាប់ពីការសន្ទនាជាច្រើនលើក ទីបំផុត "ក" បានប្រាប់មេធាវីពីកន្លែងដែលនាងបានចេញចូលនៅយប់នោះ និងចែករំលែកព័ត៌មានលម្អិតមួយចំនួនស្តីពីស្ថានភាពរបស់នាង។ មេធាវីសង្ស័យថា "ក" គឺជាជនរងគ្រោះដោយការជួញដូរមនុស្ស។ មេធាវីបានបញ្ជូន "ក" តាមរយៈយន្តការបញ្ជូនថ្នាក់ជាតិ និងរៀបចំឱ្យមានការទម្លាក់បទចោទប្រកាន់លើរូបនាង។ នគរបាលបានបើកការស៊ើបអង្កេតករណីជួញដូរមនុស្សលើអ្នកគ្រប់គ្រងរបស់ "ក" នៅផ្ទះបន។

---

89 ICCPR មាត្រា ១៤ សេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្ស មាត្រា ២០(១)។

90 *គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) - ការសិក្សាតាមមូលបទស្តីពីជំនួយផ្នែកច្បាប់* (ហ្សាការតា៖ លេខាធិការដ្ឋានអាស៊ាន, ខែកក្កដា ឆ្នាំ២០១៩) ទំព័រ ១៣

**ធានាថា មេធាវីការពារក្តីដឹងពីរបៀបអនុវត្តវិធានការការពារដែលមានចែងក្នុងច្បាប់ជាតិ សម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស**

ជាពិសេស នៅក្នុងប្រទេសដែលមិនរួមបញ្ចូលបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌជាក់លាក់សម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស ក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់ខ្លួន អ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌត្រូវពឹងផ្អែកលើវិធានការការពារទូទៅដែលបានកំណត់ក្នុងច្បាប់ព្រហ្មទណ្ឌរបស់ពួកគេជំនួសវិញ។ វិធានការការពារដែលអាចពាក់ព័ន្ធនឹងការការពារជនរងគ្រោះដោយការជួញដូរមនុស្ស រួមមានការបង្ខិតបង្ខំ ការដាក់អន្ទាក់ ភាពចាំបាច់ និងការការពារខ្លួន។ ឧទាហរណ៍ បុគ្គលម្នាក់អាចបានប្រព្រឹត្តបទល្មើស ព្រោះបុគ្គលម្នាក់ទៀតបានគំរាមកំហែងថានឹងសម្លាប់ ឬធ្វើឱ្យរងរបួសធ្ងន់ធ្ងរដល់ជនរងគ្រោះ ឬសមាជិកគ្រួសាររបស់គាត់ប្រសិនបើគាត់បដិសេធ។

ស្ថាប័នប្រឆាំងការជួញដូរមនុស្ស គួរធានាការផ្តល់ឱកាសពង្រឹងសមត្ថភាព និងឯកសារណែនាំដល់មេធាវីការពារក្តីស្តីពីរបៀបកំណត់អត្តសញ្ញាណជនរងគ្រោះ និងអនុវត្តវិធានការការពារទូទៅដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ក្នុងការការពារជនរងគ្រោះ–ជនល្មើស ដែលកំពុងស្ថិតក្រោមការជំនុំជម្រះ។[91]

**ប្រអប់៖ ឧទាហរណ៍ (ការសម្លាប់មនុស្សដោយអចេតនា)**

"ក" បានជាប់ផុងក្នុងស្ថានភាពនៃការកេងប្រវ័ញ្ចផ្លូវភេទអស់រយៈពេលជាច្រើនខែ។ នាងត្រូវបានគ្រប់គ្រងដោយបុរសម្នាក់ (ខ) ដែលឃ្លាំមើលរាល់សកម្មភាពរបស់នាង និងដាក់ទោសនាងដោយការវាយដំប្រសិនបើនាងមិនព្រមទទួលយកការស្នើសុំរបស់គាត់ឱ្យបម្រើអតិថិជន។ ថ្ងៃមួយ នាងមើលឃើញឱកាស ដើម្បីគេចខ្លួន។ នៅពេលដែល "ខ" នៅលើកំពូលជណ្តើរចោតមួយ នាងបានរុញគាត់មួយទំហឹង។ "ខ" ធ្លាក់តាមជណ្តើរ ហើយក៏បាក់ក។ "ក" រត់ចេញពីអគារ និងស្វែងរកជំនួយ។ នាងរកផ្លូវទៅប៉ុស្តិ៍នគរបាល និងប្រាប់ពួកគេពីអ្វីដែលនាងបានធ្វើ។ នាងត្រូវបានចាប់ខ្លួនពីបទសម្លាប់មនុស្សដោយអចេតនា។

*ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖* បទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌដែលអាចអនុវត្តបាននៅក្នុងប្រទេសនោះ មិនការពារ "ក" ពីការចោទប្រកាន់បទឃាតកម្មទេ។ នាងត្រូវបានទទួលស្គាល់ថាជាជនរងគ្រោះដោយការជួញដូរមនុស្ស។ មេធាវីការពារក្តីរបស់ "ក" បង្ហាញភស្តុតាងទៅតុលាការ ដើម្បីបង្ហាញពីលក្ខខណ្ឌដែល "ក" បានឆ្លងកាត់ និងលើកឡើងពីការការពារខ្លួន។ តុលាការបានច្រានចោលសំណុំរឿងប្រឆាំងនឹង "ក"។

[91] ឧទាហរណ៍ មាត្រា ៣៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០១៧ របស់ប្រទេសឡាវលើកលែងការទទួលខុសត្រូវចំពោះអ្នកដែលប្រព្រឹត្តបទល្មើសក្រោមការបង្ខំដោយកម្លាំង ឬការបង្ខិតបង្ខំ ខណៈដែលមាត្រា ៦៥ សម្រាលការទទួលខុសត្រូវខាងព្រហ្មទណ្ឌនៅពេលដែលបទល្មើសធ្ងន់ធ្ងរត្រូវបានប្រព្រឹត្តក្រោមការបង្ខំដោយកម្លាំង ឬការគំរាមកំហែង ឬការប្រើកម្លាំង។ ក្នុងន័យដូចគ្នានេះដែរ មាត្រា ២២ នៃក្រមព្រហ្មទណ្ឌរបស់វៀតណាមចែងថា 'ការប្រើកម្លាំងសមហេតុផលក្នុងការការពារខ្លួន' មិនបង្កើតជាបទល្មើសព្រហ្មទណ្ឌទេ។

## ប្រអប់៖ ឧទាហរណ៍ (ការលួចឥវ៉ាន់តាមហាង)

"ក" កំពុងធ្វើការសងបំណុលបុគ្គលដែលបាននាំនាងមកទីក្រុង ដោយធ្វើការនៅក្នុងរោងចក្រ។ ពួកគេប្រាប់នាងថា នាងមិនអាចចាកចេញពីការងាររបស់នាងបានទេរហូតដល់នាងសងបំណុលអស់។ ថ្លៃផ្ទះជួលរបស់នាងត្រូវបានកាត់ចេញពីប្រាក់ខែរបស់នាង ហើយតម្លៃម្ហូបអាហារដែលនាងទិញពីពួកគេ ត្រូវបានបូកបន្ថែមទៅក្នុងបំណុលរបស់នាង ក្នុងតម្លៃគុណនឹង ៣ លើសពីតម្លៃជាក់ស្តែង ប្រសិនបើនាងទិញពីកន្លែងផ្សេង។ ដើម្បីសន្សំប្រាក់ និងកាត់បន្ថយពេលវេលារបស់នាងនៅទីនោះ នាងញុំាត្បិតត្បៀត ដូច្នេះ ហើយនាងតែងតែឃ្លានជាប់ជានិច្ច។ ថ្ងៃមួយ នាងបានទៅហាងក្នុងមូលដ្ឋាន។ នាងទិញចំណីអាហារមួយចំនួនពីហាងនោះ ហើយក៏បានលួចដាក់ចំណីអាហារទៅក្នុងកាបូបរបស់នាងដែរ។ នាងត្រូវបានគេតាមទាន់ និងចាប់ខ្លួនពីបទលួចឥវ៉ាន់តាមហាង។

*ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖* តំណាងផ្លូវច្បាប់របស់ "ក" បានដឹងពីកាលៈទេសៈនៃការលួចឥវ៉ាន់តាមហាងរបស់ "ក" ហើយគាត់បានជូនដំណឹងដល់អាជ្ញាធរប្រឆាំងការជួញដូរមនុស្សអំពីការសង្ស័យរបស់គាត់ថា "ក" គឺជាជនរងគ្រោះដោយការជួញដូរមនុស្ស និងផ្តល់ឱ្យពួកគេនូវភស្តុតាងច្រើនបំផុតតាមដែលគាត់អាចធ្វើទៅបាន ដើម្បីគាំទ្រការអះអាងនោះ ដោយសង្ឃឹមថា នគរបាលនឹងចាប់ផ្តើមធ្វើការស៊ើបអង្កេត។ ក្នុងពេលជាមួយគ្នា នៅឯសវនាការ គាត់បានលើកឡើងពីគោលការណ៍មិនដាក់ទណ្ឌកម្មនៅចំពោះមុខតុលាការ ដោយផ្អែកលើមូលដ្ឋានច្បាប់ប្រទេសរបស់គាត់ដែលការពារជនរងគ្រោះដោយការជួញដូរមនុស្សពីការដាក់ទោសទណ្ឌសម្រាប់បទល្មើសដែលពួកគេបានប្រព្រឹត្ត ដោយសារតែជាផលវិបាកនៃបទល្មើសរបស់ពួកគេ។ ទោះយ៉ាងណាក៏ដោយ ព្រះរាជអាជ្ញានគរបាល (police prosecutor) ចង្អុលបង្ហាញថា បទបញ្ញត្តិនេះមានតែសម្រាប់បទល្មើសទាក់ទងនឹងអន្តោប្រវេសន៍ និងពេស្យាចារប៉ុណ្ណោះ។ ផ្ទុយទៅវិញ មេធាវីរបស់ "ក" បានលើកឡើងពីលក្ខខណ្ឌនៃភាពចាំបាច់។ គាត់គាំទ្រទឡ្ហីករណ៍របស់គាត់ដោយប្រើសក្ខីកម្មរបស់សាក្សីជំនាញពីវេជ្ជបណ្ឌិតម្នាក់ ដែលបញ្ជាក់ពីស្ថានភាពស្គមស្គាំងរបស់ "ក" នៅពេលដែលនាងត្រូវបានចាប់ខ្លួន។

វិធីសាស្ត្រតឹងរ៉ឹងសម្រាប់វិធានការការពារទូទៅ អាចមិនបញ្ចូលភាពស្មុគស្មាញនៃការជួញដូរមនុស្ស និងស្តែងឡើងជាឧបសគ្គរារាំងការការពារពីការដាក់ទោសទណ្ឌ។ អាស្រ័យលើរបៀបគូសបញ្ជាក់ និងបកស្រាយលក្ខខណ្ឌនៃការបង្ខិតបង្ខំ វាអាចបញ្ចូលតែស្ថានភាពដែលជនរងគ្រោះធ្វើសកម្មភាពដោយសារតែការគំរាមកំហែងធ្ងន់ធ្ងរ ឬការគំរាមកំហែងដែលនឹងធ្វើឡើង ប៉ុន្តែមិនបានបញ្ចូលមធ្យោបាយកាន់តែល្អិតល្អន់ដែលអ្នកជួញដូរមនុស្សប្រើប្រាស់ ដើម្បីបង្ខិតបង្ខំ និងឆបោកជនរងគ្រោះរបស់ពួកគេ ដូចជា ការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ។

ជាឧទាហរណ៍ សូមពិចារណាពីស្ថានភាពរបស់ជនរងគ្រោះដែលត្រូវបានជួញដូរទៅក្នុងការកេងប្រវ័ញ្ចផ្លូវភេទដែលបានឡើងកម្រិតពីការបម្រើអតិថិជនទៅជាការគ្រប់គ្រងជនរងគ្រោះផ្សេងទៀតជំនួសវិញ។ ស្ថានភាពនេះកើតឡើងតាមរយៈទំនាក់ទំនងស្នេហារបស់នាង និងស្ថានភាពនៃការពឹងផ្អែកលើអ្នកជួញដូរមនុស្ស។ តុលាការដែលអនុវត្តវិធីសាស្ត្រតូចចង្អៀតចំពោះលក្ខខណ្ឌនៃការបង្ខិតបង្ខំ អាចពិចារណាថា ជនរងគ្រោះមិនត្រូវបានបង្ខំឱ្យបំពេញតួនាទីនេះទេ ហើយដូច្នេះ នឹងចាត់ទុកនាងជាអ្នកជួញដូរមនុស្សដោយមិនអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម។ វិធីសាស្ត្រកាន់តែទូលំទូលាយចំពោះលក្ខខណ្ឌនៃការបង្ខិតបង្ខំ អាចពិចារណាពីកាលៈទេសៈរបស់ជនរងគ្រោះ រួមទាំងស្ថានភាពងាយរងគ្រោះរបស់នាង ទំនាក់ទំនងនៃការពឹងផ្អែកលើ និងការភ័យខ្លាចថា អ្នកជួញដូរមនុស្សនឹងទម្លាក់នាងទៅស្ថានភាពដុនដាបម្តងទៀត។ វិធី

សាស្ត្រទូលំទូលាយនោះអាចទទួលស្គាល់ទម្រង់កាន់តែល្អិតល្អន់នៃការបង្ខិតបង្ខំ ដែលអាចត្រូវបានប្រើប្រាស់ ដើម្បីអនុវត្តលក្ខខណ្ឌនៃការបង្ខិតបង្ខំ និងការពារជនរងគ្រោះពីការដាក់ទោសទណ្ឌ។[92]

**ប្រអប់៖ ឧទាហរណ៍ (ការជួញដូរមនុស្ស)**

មនុស្សពីរនាក់ (ក និង ខ) ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទជួញដូរមនុស្ស ដោយសារពួកគេបានប្រើប្រាស់ស្ថានភាពងាយរងគ្រោះរបស់ក្មេងស្រីពីរនាក់ និងស្ត្រីវ័យក្មេងម្នាក់ ដើម្បីដឹកជញ្ជូន និងផ្តល់កន្លែងសំចតដល់ពួកគេនៅក្នុងទីក្រុង ក្នុងគោលបំណងកេងប្រវ័ញ្ចពួកគេក្នុងពេស្យាចារ។ ទាំង "ក" និង "ខ" សុទ្ធតែត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទជួញដូរមនុស្ស។

*ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖* សាលាដំបូងបានសម្រេចថា "ក" មិនមែនជាជនរងគ្រោះដោយការជួញដូរមនុស្សទេ នៅពេលដែលនាងបានប្រព្រឹត្តបទល្មើសនោះ។ ខណៈដែលពីដំបូងនាងត្រូវបានជួញដូរ នាងបានប្រែក្លាយពីជនរងគ្រោះទៅជាអ្នកជួញដូរមនុស្ស ហើយជាអ្នកជួញដូរមនុស្សនៅពេលដែលនាងបានប្រព្រឹត្តបទល្មើស។ សាលាឧទ្ធរណ៍បានច្រានចោលករណីប្រឆាំងនឹង "ក" ដោយសារតែនាងមានលក្ខណៈនៃភាពក្រីក្រ និងភាពងាយរងគ្រោះដូចគ្នា ដែលត្រូវបានរំលោភបំពានដោយចុងចោទម្នាក់ទៀត និងដោយសារតែការគេចខ្លួនរបស់នាងពីការធ្វើជាពេស្យាខ្លួន គឺដោយសារតែជំនួយហិរញ្ញវត្ថុរបស់ចុងចោទ។[96]

## ជានាថា មេធាវីការពារក្តីយល់ថា ភាពមិនពាក់ព័ន្ធនៃការយល់ព្រម ជាវិធានការការពារចំពោះករណីជួញដូរមនុស្ស

ពិធីសារស្តីពីការជួញដូរមនុស្ស និងអនុសញ្ញា ACTIP ចែងថា ការយល់ព្រមរបស់ជនរងគ្រោះដោយការជួញដូរមនុស្សចំពោះការកេងប្រវ័ញ្ច នឹងមិនចាត់ទុកថាបានការឡើយ (ជាវិធានការការពារ) ក្នុងករណីប្រើប្រាស់មធ្យោបាយចំពោះមនុស្សពេញវ័យ និងជានិច្ចកាលចំពោះករណីកុមារ ដែលមិនចាំបាច់បង្ហាញថាមានការប្រើប្រាស់មធ្យោបាយ។[93]

មេធាវីដែលតំណាងឱ្យមនុស្សពេញវ័យជាជនរងគ្រោះដោយការជួញដូរមនុស្ស ដែលកំពុងត្រូវបានជំនុំជម្រះទោស គួរតែយល់ដឹងអំពីភាពមិនពាក់ព័ន្ធនៃការយល់ព្រមរបស់ជនរងគ្រោះ ដើម្បីឱ្យពួកគេអាចប្រឆាំងនឹងទឡ្ហីករណ៍ដែលលើកឡើងដោយព្រះរាជអាជ្ញាថា ជនរងគ្រោះបានយល់ព្រមចូលរួមក្នុងសកម្មភាពល្មើសច្បាប់។[94] មេធាវីការពារក្តីគួរតែត្រូវបានបំពាក់បំប៉ន ដើម្បីប្រឆាំងនឹងទឡ្ហីករណ៍ដែលលើកឡើងដោយព្រះរាជអាជ្ញា ដើម្បីបញ្ជាក់ពីធាតុផ្សំកំហុស (*ធាតុផ្សំអត្តនោម័ត*) នៃបទល្មើសដែលជនរងគ្រោះត្រូវបានចោទប្រកាន់។ ដោយបង្ហាញពីរបៀបដែលការប្រើប្រាស់មធ្យោបាយដោយអ្នកជួញដូរមនុស្ស បានធ្វើឱ្យចុះខ្សោយដល់ការយល់ព្រមរបស់ជនរងគ្រោះក្នុងការចូលរួមក្នុងសកម្មភាពល្មើសច្បាប់ ពួកគេអាចបញ្ជាក់

---

[92] សូមមើលឧទាហរណ៍ករណី C.M.S និង Guillemet Gastón, សង្ខេបនៅទីនេះ៖ https://sherloc.unodc.org/cld//case-law-doc/traffickingpersonscrimetype/arg/2018/c.m.s._y_guillemet_gaston_.html?lng=en&tmpl=sherloc

[93] សូមមើលមាត្រា ២(ខ) នៃអនុសញ្ញា ACTIP និងមាត្រា ៣(ខ) នៃពិធីសារស្តីពីការជួញដូរមនុស្សមនុស្ស។

[94] សម្រាប់ព័ត៌មានបន្ថែមស្តីពីភាពមិនពាក់ព័ន្ធនៃការយល់ព្រមក្នុងការជួញដូរមនុស្ស សូមមើល៖ តួនាទីនៃ 'ការយល់ព្រម' ក្នុងពិធីសារស្តីពីការជួញដូរមនុស្សមនុស្ស (UNODC, ២០១៤)

ថា ជនរងគ្រោះខ្វះការគិតថាមានកំហុស (guilty mind) ដែលត្រូវការចាំបាច់ ដើម្បីទទួលខុសត្រូវចំពោះបទល្មើសដែលពួកគេរងការចោទប្រកាន់ថាបានប្រព្រឹត្ត។[95]

ដូចដែលបានពិភាក្សាខាងលើ មធ្យោបាយដែលត្រូវបានប្រើប្រាស់ដោយអ្នកជួញដូរមនុស្ស ដើម្បីធ្វើឱ្យខូចខាតដល់ការយល់ព្រមណាមួយ ដែលជនរងគ្រោះអាចនឹងបានផ្តល់ សម្រាប់ការកេងប្រវ័ញ្ចរបស់ពួកគេ អាចជាមធ្យោបាយបើកចំហ (ដូចជា កម្លាំង) ព្រមទាំងមធ្យោបាយកាន់តែល្អិតល្អន់ (ដូចជា ការបង្ខិតបង្ខំ និងការប្រើប្រាស់ស្ថានភាពងាយរងគ្រោះរបស់ជនរងគ្រោះ)។ មានហានិភ័យថា បន្ទុកភស្តុតាងត្រូវធ្លាក់លើជនរងគ្រោះវិញ ដោយពួកគេត្រូវបង្ហាញភស្តុតាងនៃការគំរាមកំហែង មានន័យថា វិធានការការពារជនរងគ្រោះមានលក្ខណៈចង្អៀតជាងគោលការណ៍មិនដាក់ទណ្ឌកម្មទូទៅ។[96] ដូច្នេះ វិធានការការពារទូទៅគួរតែត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ដើម្បីធានាការបញ្ចូលទម្រង់ដ៏ល្អិតល្អន់នៃការបង្ខិតបង្ខំ រួមទាំង 'មធ្យោបាយ' ទាំងអស់ដែលមានចែងក្នុងនិយមន័យនៃការជួញដូរ ក្នុងមាត្រា ៣ នៃពិធីសារស្តីពីការជួញដូរ និងមាត្រា ២(ក) នៃអនុសញ្ញា ACTIP។[97] ក្នុងករណីកុមារដែលមិនចាំបាច់បង្ហាញថាមានការប្រើប្រាស់មធ្យោបាយដើម្បីកំណត់ថា ពួកគេត្រូវបានជួញដូរ គួរអនុវត្តវិធានការការពារដែលបានកំណត់ក្នុងច្បាប់ជាតិដោយមិនគិតពី 'មធ្យោបាយ' ដែលត្រូវបានប្រើប្រាស់ ដើម្បីជួញដូរពួកគេ។

ដើម្បីគាំទ្រមេធាវីការពារក្តីក្នុងការងាររបស់ពួកគេ រដ្ឋគួរពិចារណាបណ្តុះបណ្តាលអ្នកអនុវត្តអំពីរបៀបប្រមូល និងបង្ហាញភស្តុតាងបញ្ជាក់ពី 'មធ្យោបាយ' ដែលត្រូវបានប្រើប្រាស់ដោយអ្នកជួញដូរមនុស្ស ដើម្បីត្រួតត្រាជនរងគ្រោះ និងធ្វើឱ្យខូចខាតដល់ការយល់ព្រមរបស់ពួកគេ។ ការកសាងសមត្ថភាពអាចរួមបញ្ចូលការបណ្តុះបណ្តាលឯកទេស តាមរយៈការផ្តល់ករណីសិក្សា ការគ្រាប់តាម និងការធ្វើបច្ចុប្បន្នភាពជាទៀងទាត់លើវិធីសាស្ត្រការពារ។ ចាំបាច់ត្រូវផ្តល់ធនធានគ្រប់គ្រាន់ដល់មេធាវី ដើម្បីចូលប្រើប្រាស់ឯកសារណែនាំ និងការគាំទ្រផ្នែកបច្ចេកទេស ក្នុងការដោះស្រាយករណីស្មុគស្មាញ។

95 'មធ្យោបាយ' ដូចមានចែងក្នុងមាត្រា ៣ នៃពិធីសារស្តីពីការជួញដូរមនុស្ស និងមាត្រា ២(ក) នៃអនុសញ្ញា ACTIP គឺជាការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង និងទម្រង់ដទៃទៀតនៃការបង្ខិតបង្ខំ ការចាប់ជំរិត ការបន្លំ ការបោកបញ្ឆោត ឬការប្រើអំណាចរំលោភបំពាន ឬការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ ឬការផ្តល់ ឬទទួលកម្រៃ ឬផលប្រយោជន៍នានា ដើម្បីសម្រេចការយល់ព្រមនៃមនុស្សម្នាក់ដែលមានអំណាចត្រួតត្រាលើមនុស្សណាម្នាក់ទៀត។

96 ឧទាហរណ៍ អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ញែកដាច់ពីគ្នារវាងលក្ខខណ្ឌនៃការបង្ខិតបង្ខំដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងការអនុវត្តន៍របស់លក្ខន្តិកៈនេះក្នុងករណី រដ្ឋអាជ្ញា ទល់នឹង Dominic Ongwen ពីគោលការណ៍មិនដាក់ទណ្ឌកម្មទូទៅ។ សូមមើល ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ, Siobhán Mullaly, ឯកសារ អ.ស.ប A/HRC/47/34 (ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១) កថាខណ្ឌ ៥១។

97 សូមមើល៖ ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ, Siobhán Mullaly, ឯកសារ អ.ស.ប A/HRC/47/34 (ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១), កថាខណ្ឌ ៥៨។

**អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ**

ក្នុងពេលរង់ចាំការអនុវត្តន៍បទបញ្ញត្តិច្បាប់ជាក់លាក់ស្តីពីការមិនដាក់ទោសទណ្ឌ រដ្ឋគួរអនុលោមតាមកាតព្វកិច្ចមិនដាក់ទោសទណ្ឌរបស់ខ្លួន ដោយបកស្រាយបទដ្ឋានច្បាប់ជាតិដែលមានស្រាប់ រួមទាំងលក្ខខណ្ឌនៃការបង្ខិតបង្ខំ ឬស្ថានភាពនៃភាពចាំបាច់ ជាប្រការចែងទូទៅនៃការលើកលែងការទទួលខុសត្រូវ។ រដ្ឋគួរតែធានាថា វិធានការការពារទាំងនោះត្រូវបានកែសម្រួលទៅតាមបរិបទនៃការជួញដូរមនុស្ស ដោយទទួលស្គាល់ទម្រង់លាក់កំបាំងជាច្រើននៃការបង្ខិតបង្ខំដែលជនរងគ្រោះដោយការជួញដូរមនុស្សធ្លាប់ជួបប្រទះ រួមទាំងការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ និងមធ្យោបាយទាំងអស់ ដែលមានចែងក្នុងនិយមន័យនៃការជួញដូរមនុស្ស។[102]

## ១០) ពង្រឹងសមត្ថភាពរបស់មន្ត្រីតុលាការ ដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម

ចៅក្រមដែលជំនុំជម្រះក្តីសម្រាប់បទល្មើសដែលជនរងគ្រោះអាចកំពុងស្ថិតក្រោមកាត់ទោសសម្រាប់ការប្រព្រឹត្តបទល្មើសនោះ អាចមិនស្គាល់ច្បាស់អំពីបទល្មើសស្មុគស្មាញនៃការជួញដូរមនុស្ស។ ក្នុងករណីដែលចៅក្រមខ្វះការយល់ដឹងអំពីការជួញដូរមនុស្ស ពួកគេអាចមិនពិចារណាអំពីទំនាក់ទំនងរវាងបទល្មើសរបស់ជនជាប់ចោទ និងស្ថានភាពរបស់គាត់ក្នុងនាមជាជនរងគ្រោះដោយការជួញដូរមនុស្ស។ ចៅក្រមក៏អាចមិនដឹងអំពីគោលការណ៍មិនដាក់ទណ្ឌកម្មផងដែរ។ ដូច្នេះ ចាំបាច់ត្រូវកសាងការយល់ដឹងរបស់មន្ត្រីតុលាការស្តីពីការជួញដូរមនុស្ស ព្រមទាំងគោលការណ៍មិនដាក់ទណ្ឌកម្ម និងការអនុវត្តន៍គោលការណ៍នេះចំពោះជនល្មើសដែលកំពុងស្ថិតក្រោមការកាត់ទោសសម្រាប់បទល្មើសដែលពួកគេបានប្រព្រឹត្ត ដែលទាក់ទងនឹងការណ៍ដែលពួកគេត្រូវបានជួញដូរ។

### កសាងការយល់ដឹងរបស់ចៅក្រមស្តីពីជាតុផ្សំនៃការជួញដូរមនុស្ស និងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម

អ្នកពាក់ព័ន្ធក្នុងប្រឆាំងនឹងការជួញដូរមនុស្ស គួរបង្កើនការយល់ដឹងរបស់មន្ត្រីតុលាការស្តីពីនិយមន័យនៃការជួញដូរមនុស្ស និងទំនាក់ទំនងរវាងជាតុផ្សំរបស់វា និងការប្រព្រឹត្តបទល្មើសរបស់ជនរងគ្រោះ។ ចៅក្រមគួរយល់ច្បាស់អំពីបទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌណាមួយនៅក្នុងច្បាប់ជាតិរបស់ខ្លួន គោលនយោបាយ និងឯកសារណែនាំ ព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិ និងទ្វេភាគី និងឈ្វេងយល់ពីឱកាសដែលពួកគេមាន ដើម្បីបញ្ឈប់ករណីប្រឆាំងនឹងជនរងគ្រោះ នៅពេលដែលមានទំនាក់ទំនងរវាងការប្រព្រឹត្តបទល្មើសរបស់ជនរងគ្រោះ និងការជួញដូរពួកគេ។ ចៅក្រមក៏គួរទទួលបានឱកាសកសាងសមត្ថភាពជាបន្តបន្ទាប់ផងដែរ រួមទាំងទាក់ទងនឹងកាតព្វកិច្ចសិទ្ធិមនុស្សក្នុងប្រទេស និងជាអន្តរជាតិ ទន្ទឹមគ្នា

នឹងលក្ខខណ្ឌតម្រូវនៃការមិនដាក់ទោសទណ្ឌ ដើម្បីរក្សាឱ្យចំណេះដឹងរបស់ពួកគេមានបច្ចុប្បន្នភាព និងភាពពាក់ព័ន្ធ និងដើម្បីធានាថា ពួកគេការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធបានយ៉ាងត្រឹមត្រូវ។

ចៅក្រមគួរពិចារណាថា តើប្រព័ន្ធច្បាប់អាចសម្របសម្រួលការអនុវត្តន៍វិធានការការពារពាក់ព័ន្ធដោយប្រសិទ្ធភាព ដោយមិនពឹងផ្អែកទាំងស្រុងលើការផ្តួចផ្តើមដោយមេធាវីការពារក្តី ឬព្រះរាជអាជ្ញា យ៉ាងដូចម្តេច។ ជាការល្អ តុលាការគួរពិចារណាលើវិធានការការពារដែលពាក់ព័ន្ធ ដែលអាចមានសម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស សូម្បីតែនៅពេលដែលមេធាវីការពារក្តី ឬព្រះរាជអាជ្ញា មិនបានលើកឡើងក៏ដោយ។[98]

## ធានាថា ចៅក្រមយល់ដឹងអំពីតួនាទី និងទំនួលខុសត្រូវរបស់ខ្លួនចំពោះជនរងគ្រោះដែលត្រូវបានឃុំខ្លួន

ជនរងគ្រោះដោយការជួញដូរមនុស្ស ត្រូវទទួលបានការការពារពីការឃុំខ្លួនតាមទំនើងចិត្តក្នុងបរិបទព្រហ្មទណ្ឌ ឬអន្តោប្រវេសន៍ និងក្នុងបរិបទនៃការដាក់ក្នុងជម្រកសុវត្ថិភាពបិទជិត។ ទាំងសេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សុទ្ធតែការពារសិទ្ធិរបស់បុគ្គលក្នុងការមិនត្រូវបានឃុំខ្លួនតាមទំនើងចិត្ត។[99] ចៅក្រមមានតួនាទីក្នុងការបញ្ជាឱ្យដោះលែងពីការឃុំខ្លួននូវជនណាមួយដែលត្រូវបានឃុំខ្លួនតាមទំនើងចិត្តផ្ទុយពីគោលការណ៍មិនដាក់ទណ្ឌកម្ម និងកាតព្វកិច្ចសិទ្ធិមនុស្សផ្សេងទៀត ដោយបញ្ជាឱ្យមានដំណោះស្រាយ រួមទាំងសំណងជំងឺចិត្តសម្រាប់ការឃុំខ្លួនខុសច្បាប់ដោយរដ្ឋ។ ឧទាហរណ៍ ច្បាប់ក្នុងប្រទេសហ្វីលីពីនផ្តល់សិទ្ធិដល់ជនដែលត្រូវបានឃុំខ្លួនដោយអយុត្តិធម៌ ឬត្រូវបានឃុំខ្លួនតាមទំនើងចិត្តដោយអាជ្ញាធររដ្ឋ ក្នុងការដាក់ពាក្យស្នើសុំសំណងជំងឺចិត្ត។[100]

ស្ថាប័នប្រឆាំងការជួញដូរមនុស្ស និងស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ (ក្នុងករណីដែលមានស្ថាប័នទាំងនេះ) គួរខិតខំជួយឱ្យមន្ត្រីតុលាការយល់ដឹងអំពីតួនាទីនៃគោលការណ៍មិនដាក់ទណ្ឌកម្ម នៅក្នុងសវនាការនៃការទាមទារដីកាបញ្ជាឱ្យចូលខ្លួន (*habeas corpus*) ណាមួយដែលត្រូវបានបង្ហាញនៅចំពោះមុខពួកគេដោយជនរងគ្រោះដោយការជួញដូរមនុស្ស ដែលត្រូវបានឃុំខ្លួន។ រដ្ឋគួរធានាថាមានគោលការណ៍ណែនាំជាស្រេច ដើម្បីឱ្យជនរងគ្រោះដែលត្រូវបានផ្តន្ទាទោសខុស យល់ពីរបៀបចូលប្រើប្រាស់បណ្តាញទាមទារសំណងជំងឺចិត្ត។

យន្តការត្រួតពិនិត្យ និង/ឬវាយតម្លៃ អាចជួយឱ្យយល់ដឹងថាតើគោលការណ៍មិនដាក់ទណ្ឌកម្មកំពុងត្រូវបានអនុវត្ត ឬអត់។ ស្ថាប័នប្រឆាំងការជួញដូរមនុស្ស និងស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ អាចដើរតួនាទីយ៉ាងសកម្មក្នុងការគាំទ្រការតាមដាន និងវាយតម្លៃការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម នៅពេលដែលជនរងគ្រោះដោយការជួញដូរមនុស្ស កំពុងប្រឈមនឹងការកាត់ទោស។

[98] ការណែនាំស្តីពីការឆ្លើយតបសមស្របផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ចំពោះជនរងគ្រោះដែលត្រូវបានបង្ខំឱ្យប្រព្រឹត្តបទល្មើសដោយសារតែពួកគេត្រូវបានជួញដូរ ៖ ឯកសារសាវតារដែលរៀបចំឡើងដោយលេខាធិការដ្ឋានក្រុមការងារស្តីពីការជួញដូរមនុស្ស, វីយែន ថ្ងៃទី១០ និងទី ១១ ខែកញ្ញា ឆ្នាំ២០២០, ឯកសារ អ.ស.ប CTOC/COP/WG.4/2020/2 (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០), កថាខណ្ឌ ៦៦។

[99] ICCPR មាត្រា ៩(៤) និងសេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្ស មាត្រា ១២។

[100] ច្បាប់លេខ ៧៣០៩ របស់សាធារណរដ្ឋហ្វីលីពីន (ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩២) (*ច្បាប់ស្តីពីការបង្កើតគណៈកម្មការទាមទារនៅក្រោមក្រសួងយុត្តិធម៌សម្រាប់ជនរងគ្រោះដោយការដាក់ក្នុងពន្ធនាគារ ឬការឃុំខ្លួនដោយអយុត្តិធម៌ និងជនរងគ្រោះដោយបទល្មើសហិង្សា និងសម្រាប់គោលបំណងផ្សេងទៀត*) ផ្តល់សិទ្ធិដល់មនុស្សដូចខាងក្រោមក្នុងការដាក់ពាក្យស្នើសុំសំណងជំងឺចិត្ត រួមទាំងអ្នកដែលត្រូវបានឃុំខ្លួនដោយអយុត្តិធម៌ និងត្រូវបានដោះលែងដោយគ្មានការចោទប្រកាន់ ឬអ្នកដែលត្រូវបានឃុំខ្លួនតាមទំនើងចិត្តដោយអាជ្ញាធរ។

## កសាងការយល់ដឹងដល់ចៅក្រមស្តីពីរបៀបដែលសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គាំទ្រការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម

ដំណើរការត្រឹមត្រូវ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មានសារៈសំខាន់ណាស់សម្រាប់ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មប្រកបដោយប្រសិទ្ធភាព ក្នុងករណីដែលជនរងគ្រោះដោយការជួញដូរមនុស្សកំពុងស្ថិតក្រោមការកាត់ទោស។ មាត្រា ២០(១) នៃសេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្សចែងថា៖

ជនគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ត្រូវបានសន្មតថាគ្មានទោស រហូតដល់ត្រូវបានបញ្ជាក់ថាមានទោសតាមច្បាប់ ក្នុងការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ ដោយតុលាការដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលជាទីដែលជនជាប់ចោទត្រូវបានធានាសិទ្ធិទទួលបានការការពារ។

ក្នុងករណីដែលវិធានការការពារត្រូវបានរំលេចឡើង ប្រទេសនានាអាចអនុវត្តវិធីសាស្រ្តផ្សេងៗពាក់ព័ន្ធនឹងភាគីដែលត្រូវរ៉ាប់រងបន្ទុក និងស្តង់ដារនៃការបង្ហាញភស្តុតាង។ ក្នុងប្រទេសមួយចំនួន បន្ទុកបង្ហាញភស្តុតាងអាចធ្លាក់លើជនជាប់ចោទ ដើម្បីលើកឡើងអំពីស្ថានភាពរបស់គាត់ក្នុងនាមជាជនដែលត្រូវបានជួញដូរ ដើម្បីរំលេចវិធានការការពារ ប៉ុន្តែបន្ទុកក្នុងការបដិសេធការអនុវត្តន៍វិធានការការពារនោះ នៅតែស្ថិតលើមេធាវីការពារក្តី។ នៅប្រទេសផ្សេងទៀត ជនដែលត្រូវបានជួញដូរអាចត្រូវបញ្ជាក់ថា គាត់ត្រូវបានជួញដូរ និងថា ការប្រព្រឹត្តបទល្មើសបណ្តាលមកពីការជួញដូរនោះ ឬក៏ជនជាប់ចោទអាចនឹងត្រូវលើកឡើងពីវិធានការការពារ ដោយបង្វែរបន្ទុកទៅរដ្ឋក្នុងការបង្ហាញហួសពីវិមតិសង្ស័យថា ចុងចោទមិនត្រូវបានជួញដូរ។ ក្រៅពីនេះ តុលាការអាចអនុវត្តវិធីសាស្រ្តផ្សេងៗ ពាក់ព័ន្ធនឹងតម្លៃជាភស្តុតាងនៃសេចក្តីសម្រេចដោយអាជ្ញាធរមានសមត្ថកិច្ចអំពីស្ថានភាពជាជនរងគ្រោះ ដោយដាក់សំពាធលើតម្លៃជាភស្តុតាងនៅក្នុងករណីខ្លះ និងមិនតម្រូវឱ្យមានការកំណត់អត្តសញ្ញាណបុគ្គលជាផ្លូវការនៅក្នុងករណីផ្សេងទៀត។[101]

ដូច្នេះ ចៅក្រមត្រូវដឹងថាតើបន្ទុកភស្តុតាងស្ថិតនៅផ្នែកណា ក្នុងយុត្តាធិការរបស់ខ្លួន ដើម្បីអាចធានាបានថា គោលការណ៍មិនដាក់ទណ្ឌកម្មត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនៅក្នុងការជំនុំជម្រះដែលពួកគេវិនិច្ឆ័យ។ ចៅក្រមត្រូវយល់ដឹងពីទំនួលខុសត្រូវរបស់ខ្លួនទាក់ទងនឹងកាតព្វកិច្ចនេះ ជាអាទិ៍ ការតែងតាំងមេធាវីការពារក្តីសាធារណៈ ដើម្បីតំណាងជនរងគ្រោះដោយការជួញដូរមនុស្ស ជាមួយនឹងសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ដើម្បីអាចផ្តល់វិធានការការពារប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះដោយការជួញដូរមនុស្ស ដែលកំពុងស្ថិតក្រោមការកាត់ទោស។

ចៅក្រមត្រូវធានាថា ជនរងគ្រោះដែលកំពុងស្ថិតក្រោមការកាត់ទោស មានលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់។ ស្ថាប័នប្រឆាំងការជួញដូរមនុស្ស គួរផ្តល់គោលការណ៍ណែនាំ និងស្តង់ដារដល់ចៅក្រម ដើម្បីធានាការផ្តល់ជំនួយផ្នែកច្បាប់ដែលមានគុណភាពខ្ពស់ ដល់ជនរងគ្រោះដោយការជួញដូរមនុស្ស។[102]

---

[101] Jean–Pierre Gauci និង Noemi Magugliani, *ការជួញដូរមនុស្ស និងសិទ្ធិរបស់អ្នកដែលត្រូវបានជួញដូរ ៖ ការវិភាគបែបពន្យល់ស្តីពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម* (BIICL និង IBA, ២០២៣), ទំព័រ ៣៧–៣៩

[102] សូមមើលឧទាហរណ៍៖ *គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) — ការសិក្សាតាមមូលបទស្តីពីជំនួយផ្នែកច្បាប់* (ហ្សាការតា: លេខាធិការដ្ឋានអាស៊ាន, ខែកក្កដា ឆ្នាំ២០១៩)

## [១១] អនុវត្តយុត្តិធម៌ស្តារឡើងវិញ ជាជាងយុត្តិធម៌សងសឹកសម្រាប់ ជនល្មើស-ជាជនរងគ្រោះ

> អាចមានជម្រើសផ្សេងទៀត (ក្រៅពីការផ្តន្ទាទោស និងការដាក់ក្នុងពន្ធនាគារ) សម្រាប់មនុស្សមួយចំនួនដែលបានប្រព្រឹត្តប្រភេទបទល្មើសមួយចំនួន ក្នុងគោលបំណងសម្រេចបានយុត្តិធម៌ស្តារឡើងវិញ ជាជាងយុត្តិធម៌បែបសងសឹក។ ក្នុងករណីជនរងគ្រោះដោយការជួញដូរមនុស្ស ការប្រើប្រាស់យុត្តិធម៌ស្តារឡើងវិញអាចបង្វែរជនរងគ្រោះចេញពីដំណើរការយុត្តិធម៌ព្រហ្មទណ្ឌឆ្ពោះទៅរកការការពារ និងជំនួយ។ រដ្ឋសមាជិកអាស៊ានគួរពិនិត្យពិច័យថាតើតុលាការ និងដំណើរការតុលាការ អាចអនុវត្តយុត្តិធម៌ស្តារឡើងវិញដោយរបៀបណា ដើម្បីបញ្ចៀសការដាក់ទោសទណ្ឌជនល្មើសដែលបានប្រព្រឹត្តបទល្មើស ដោយសារតែពួកគេត្រូវបានជួញដូរ។

### រិះរកឱកាសអនុវត្តគំរូយុត្តិធម៌ស្តារឡើងវិញចំពោះជនរងគ្រោះដោយការជួញដូរមនុស្ស ដែលកំពុងស្ថិតក្រោមការកាត់ទោស

មន្ត្រីតុលាការគួរពិចារណាអនុវត្តវិធីសាស្ត្រយុត្តិធម៌ស្តារឡើងវិញ ជាមធ្យោបាយនៃការបង្វែរជនរងគ្រោះចេញពីដំណើរការយុត្តិធម៌ព្រហ្មទណ្ឌដែលមានគោលបំណងសងសឹក។ មន្ត្រីតុលាការគួរដឹងពីឱកាសដែលពួកគេមាន និងថាតើឱកាសទាំងនោះអាចត្រូវបានកែតម្រូវដោយរបៀបណាឱ្យស្របនឹងបរិបទរបស់ជនរងគ្រោះដោយការជួញដូរមនុស្ស ដែលបានប្រព្រឹត្តបទល្មើស។

ដើម្បីគាំទ្រតុលាការក្នុងការងារនេះ ស្ថាប័នប្រឆាំងការជួញដូរមនុស្ស និងស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិនៅក្នុងរដ្ឋសមាជិកអាស៊ានដែលមានស្ថាប័នទាំងនេះ គួរវាយតម្លៃឱកាសយុត្តិធម៌ស្តារឡើងវិញដែលតុលាការ និងដំណើរការតុលាការអាចប្រើប្រាស់ជាប្រយោជន៍ដល់មនុស្សពេញវ័យ និងកុមារដែលជាជនរងគ្រោះដោយការជួញដូរមនុស្ស។ អ្នកពាក់ព័ន្ធទាំងនេះមានតួនាទីក្នុងការគាំទ្រវិធីជំនួស ដើម្បីបង្វែរជនរងគ្រោះចេញពីការដាក់ទោសទណ្ឌ។ រដ្ឋសមាជិកអាស៊ានគួរបង្កើត និងអនុវត្តគំរូជាក់លាក់ និងគោលការណ៍ណែនាំសម្រាប់យុត្តិធម៌ស្តារឡើងវិញ សម្រាប់អនុវត្តក្នុងករណីជួញដូរមនុស្ស។ គំរូបែបនេះគួរគិតពិចារណាអំពីបរិបទ និងលក្ខខណ្ឌក្នុងស្រុក ដើម្បីធានាថា វិធីសាស្ត្រដែលបានអនុវត្ត មានប្រសិទ្ធភាព និងគិតគូរពីតម្រូវការរបស់ភាគីពាក់ព័ន្ធ។

មេធាវីការពារក្តី ព្រះរាជអាជ្ញា និងចៅក្រមគួរទទួលបានការបណ្តុះបណ្តាលសមស្រប និងជាបន្តបន្ទាប់ ដើម្បីធានាការអនុវត្តត្រឹមត្រូវនូវគោលការណ៍ និងការអនុវត្តន៍យុត្តិធម៌ស្តារឡើងវិញ។ ការបណ្តុះបណ្តាលបែបនេះគួររួមបញ្ចូលរបៀបកំណត់រកករណីសមស្របសម្រាប់វិធីសាស្ត្រនេះ និងរបៀបគ្រប់គ្រងដំណើរការយុត្តិធម៌ស្តារឡើងវិញ ដោយមានការគិតគូរដល់តម្រូវការរបស់ជនប្រព្រឹត្តបទល្មើស-ជាជនរងគ្រោះ។

ទីភ្នាក់ងារប្រឆាំងការជួញដូរមនុស្ស និងស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ មានតួនាទីលើកកម្ពស់ការគោរពតាមស្តង់ដារទាំងនេះក្នុងចំណោមអ្នកពាក់ព័ន្ធដែលជាតួអង្គរដ្ឋនៅក្នុងប្រទេសរបស់ខ្លួន។ អ្នកពាក់ព័ន្ធទាំងនេះគួរវាយតម្លៃយន្តការយុត្តិធម៌ស្តារឡើងវិញដែលមានស្រាប់ ដើម្បីធានាការអនុវត្តន៍ដោយយុត្តិធម៌ និងប្រសិទ្ធភាពចំពោះប្រភេទជនរងគ្រោះផ្សេងៗ រួមទាំងកុមារ។ ផ្អែកតាមការវាយតម្លៃនោះ អាចចាំបាច់ត្រូវមានការកែតម្រូវ ដើម្បីធានាថាយន្តការយុត្តិធម៌ស្តារឡើងវិញសមស្របទៅនឹងករណី ដែលជនល្មើសគឺជាជនរងគ្រោះដោយការជួញដូរមនុស្ស។

សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលដែលមានបទពិសោធន៍ក្នុងការអនុវត្តន៍យុត្តិធម៌ស្តារឡើងវិញ និងកិច្ចការពារកុមារ ចំពោះស្ថានភាពរបស់ជនរងគ្រោះដោយការជួញដូរមនុស្សដែលកំពុងប្រឈមមុខនឹងការកាត់ទោស គួរចូលរួមក្នុងការរៀបចំ និងការអនុវត្តន៍យន្តការយុត្តិធម៌ស្តារឡើងវិញ។ អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល អាចផ្តល់ទស្សនៈបន្ថែម រួមទាំងទស្សនៈរបស់ជនរងគ្រោះដោយការជួញដូរមនុស្ស ដើម្បីគាំទ្រដល់ការអភិវឌ្ឍ និងការសម្រេចបានការអនុវត្តន៍ល្អបំផុត។

## ធានាថា វិធីសាស្ត្រយុត្តិធម៌ស្តារឡើងវិញត្រូវបានអនុវត្តចំពោះជនរងគ្រោះជាកុមារដែលប្រព្រឹត្តបទល្មើស

ក្នុងករណីកុមារដែលប្រព្រឹត្តបទល្មើសក្នុងបរិបទនៃការជួញដូរមនុស្ស គួរអនុវត្តវិធានការក្រៅប្រព័ន្ធតុលាការ ដើម្បីផ្តោតលើការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មកុមារ ជំនួសឱ្យការកាត់ទោស និងតម្រូវការដំណើរការត្រឹមត្រូវសម្រាប់កុមារទាំងអស់ដែលពាក់ព័ន្ធជាមួយកងកម្លាំងប្រដាប់អាវុធ និងក្រុមផ្សេងៗ។ គោលការណ៍មិនដាក់ទណ្ឌកម្មមានសារៈសំខាន់ដូចដំណើរការត្រឹមត្រូវដែរ។[103]

ការផ្តោតចម្បងក្នុងករណីកុមារ គួរតែជាការស្តារឡើងវិញ ការធ្វើសមាហរណកម្ម និងការរស់នៅជួបជុំគ្រួសារឡើងវិញ។ គួរធ្វើការវាយតម្លៃផលប្រយោជន៍ល្អបំផុត និងការកំណត់ផលប្រយោជន៍ល្អបំផុត សម្រាប់កុមារទាំងអស់ដែលមានទំនាស់ជាមួយច្បាប់ រួមទាំងជនរងគ្រោះដោយការជួញដូរមនុស្សដែលបានពាក់ព័ន្ធក្នុងសកម្មភាពល្មើសច្បាប់។ អាទិភាពក្នុងករណីទាំងនេះ គួរតែជាការបំពេញតម្រូវការរបស់ពួកគេប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍផែនការគ្រប់ជ្រុងជ្រោយសម្រាប់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មពួកគេ។

ឧទាហរណ៍ ក្នុងករណីដែលកុមារដែលមានទំនាស់ជាមួយច្បាប់នៅប្រទេសហ្វីលីពីន ត្រូវបានរកឃើញថាទទួលខុសត្រូវលើបទល្មើស គណៈកម្មាធិការបង្វែរសំណុំរឿង (diversion committee) អាចកំណត់ថា កុមារគួរត្រូវបានបង្វែរ និងបញ្ជូនទៅវិធានការ ឬសេវាជំនួស។ ដូចគ្នានេះដែរ នៅប្រទេសថៃ នាយកដ្ឋានសង្កេតការណ៍ និងការពារអនីតិជន បានដាក់ចេញកម្មវិធីបង្វែរសំណុំរឿង (diversion program) ដោយផ្អែកលើយុត្តិធម៌ស្តារឡើងវិញ។

ក្នុងករណីកុមារដែលត្រូវបានជួញដូរទៅក្នុងជម្លោះប្រដាប់អាវុធ និងអំពើភេរវកម្ម ដែលងាយប្រឈមនឹងការដាក់ទោសទណ្ឌ សេចក្តីសម្រេចលេខ ២៣៨៨ (២០១៧) របស់ក្រុមប្រឹក្សាសន្តិសុខ ទទូចឱ្យរដ្ឋសមាជិកមិនដាក់ទោសទណ្ឌកុមារដែលជាជនរងគ្រោះដោយការជួញដូរមនុស្ស។ សេចក្តីសម្រេចលេខ ២៤២៧ (២០១៨) សំដៅលើការប្រព្រឹត្តចំពោះកុមារដែលពាក់ព័ន្ធជាមួយក្រុមប្រដាប់អាវុធមិនមែនរដ្ឋ រួមទាំងអ្នកដែលប្រព្រឹត្តអំពើភេរវកម្ម និងអំពាវនាវឱ្យបង្កើតនីតិវិធីប្រតិបត្តិការស្តង់ដារ ដើម្បីធានាការប្រព្រឹត្តចំពោះកុមារឱ្យបានសមស្រប។

ស្ថាប័នប្រឆាំងការជួញដូរមនុស្សនៅក្នុងរដ្ឋសមាជិកអាស៊ាន គួរតាមដានការគោរពតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ដូចរៀបរាប់ខាងលើ។ ក្រៅពីនេះ រដ្ឋសមាជិកអាស៊ានគួរអនុម័តនីតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំច្បាស់លាស់ ដើម្បីធានាការប្រព្រឹត្តចំពោះកុមារដែលពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធដោយអនុលោមតាមសេចក្តីសម្រេចទាំងនេះ។ ការរៀបចំនីតិវិធីប្រតិបត្តិការស្តង់ដារ គួរមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ ដែលរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមទីភ្នាក់ងារការពារកុមារ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងក្រុមសហគមន៍មូលដ្ឋាន ដើម្បីធានាការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មចំពោះកុមារដែលពាក់ព័ន្ធជាមួយក្រុមប្រដាប់អាវុធ ប្រកបដោយសង្គតិភាព និងប្រសិទ្ធភាព។

[103] ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ, Siobhán Mullaly, ឯកសារ អ.ស.ប A/HRC/47/34 (ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១) កថាខណ្ឌ ៣៩។

ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិនៅក្នុងរដ្ឋសមាជិកអាស៊ាន គួរបន្តលើកកម្ពស់ការយល់ដឹង និងការអនុលោមតាមស្តង់ដារអន្តរជាតិ ទាក់ទងនឹងការប្រព្រឹត្តចំពោះកុមារដែលពាក់ព័ន្ធជាមួយក្រុមប្រដាប់អាវុធ។ ការតស៊ូមតិនេះជាកត្តាសំខាន់ដើម្បីជះឥទ្ធិពលលើគោលនយោបាយ និងការអនុវត្តន៍ទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ រាជរដ្ឋាភិបាលថៃបានគាំទ្រការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងបទឧក្រិដ្ឋ ក្នុងការផលិត*សៀវភៅណែនាំស្តីពីយុត្តិធម៌ស្តារឡើងវិញ* ដោយសហការជាមួយវិទ្យាស្ថានយុត្តិធម៌នៃព្រះរាជាណាចក្រថៃ។[104] នេះជាធនធានសមស្របសម្រាប់គាំទ្រការអនុវត្តន៍វិធីសាស្ត្រយុត្តិធម៌ស្តារឡើងវិញចំពោះបរិបទនៃជនរងគ្រោះដោយការជួញដូរមនុស្ស។

**ប្រអប់៖ ឧទាហរណ៍ (អំពើភេរវកម្ម/ជម្លោះប្រដាប់អាវុធ)**

នៅអាយុ ១៣ ឆ្នាំ "ក" ត្រូវបានចាប់ពង្រាត់ពីភូមិរបស់គាត់ដោយក្រុមប្រដាប់អាវុធមួយ។ គាត់ត្រូវបានបង្ខំឱ្យចូលរួមក្នុងសកម្មភាពជាច្រើន ចាប់ពីការធ្វើកិច្ចការកំប៉ិចកំប៉ុកតាមបញ្ជាពីមេបញ្ជាការរបស់គាត់ រហូតដល់ការគ្រប់គ្រង និងពេលខ្លះ វាយដំមនុស្សផ្សេងទៀតដែលត្រូវបានចាប់ខ្លួនដោយក្រុមនេះ។ កុមារម្នាក់ទៀត គឺ "ខ" មានអាយុ ១៦ ឆ្នាំនៅពេលដែលគាត់ត្រូវបានចាប់ខ្លួនជាមួយ "ក"។ ដំបូង គាត់ធ្វើជាជំនួយការមេបញ្ជាការជាន់ខ្ពស់មួយរូប។ បន្ទាប់ពីត្រូវបានផ្តួចផ្តើមឱ្យចូលរួមក្នុងតួនាទីខ្ពស់ជាងមុន តាមរយៈការឱ្យប្រហារជីវិតអ្នកទោសម្នាក់ គាត់ត្រូវបានផ្តល់តួនាទីប្រយុទ្ធដែលសកម្មជាងមុន គឺការវាយប្រហារលើគោលដៅ។ គាត់ក៏បានរំលោភសេពសន្ថវៈយ៉ាងព្រៃផ្សៃលើក្មេងស្រីមួយចំនួនដែលត្រូវបានចាប់ខ្លួនដោយក្រុមនេះផងដែរ។ បន្ទាប់ពីបានរស់នៅក្នុងជីវិតបែបនេះអស់រយៈពេលបីឆ្នាំ ក្រុមនេះត្រូវបានចាប់ខ្លួន។

<u>*ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖*</u> អាជ្ញាធរបានទទួលស្គាល់ថា "ក" គឺជាជនរងគ្រោះដោយការជួញដូរមនុស្ស (ត្រូវបានជ្រើសរើស និងចាប់ជំរិតសម្រាប់ការកេងប្រវ័ញ្ច) និងជាជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ "ក" ត្រូវបានប្រគល់ទៅឱ្យភ្នាក់ងារការពារកុមារ ដើម្បីឱ្យគាត់បានស្តារនីតិសម្បទា ធ្វើសមាហរណកម្ម និងរស់នៅជួបជុំគ្រួសារឡើងវិញ។[1 10]

"ខ" ត្រូវបានទទួលស្គាល់ថាជាកុមាររងគ្រោះដោយការជួញដូរមនុស្ស ទោះបីជានៅពេលដែលគាត់ត្រូវបានចាប់ខ្លួន គាត់មានអាយុ ១៨ ឆ្នាំក៏ដោយ។ ទោះយ៉ាងណាក៏ដោយ អាជ្ញាធរមានទស្សនៈផ្សេងចំពោះស្ថានភាពរបស់គាត់ពាក់ព័ន្ធនឹងបទល្មើសដែលគាត់បានចូលរួម។ ទោះបីជាពួកគេទទួលស្គាល់ថា លក្ខខណ្ឌការបង្ខិតបង្ខំ និងភាពចាំបាច់ គួរតែពិចារណាអំពីបរិបទនៃការជួញដូររូបគាត់ក៏ដោយ ក៏ពួកគេបានពិចារណាថា បទល្មើសមួយចំនួនដែលគាត់បានប្រព្រឹត្ត មិនពាក់ព័ន្ធនឹងស្ថានភាពនៃការជួញដូររូបគាត់ទេ។ បទល្មើសមួយចំនួនដែល "ខ" បានប្រព្រឹត្ត រួមទាំងការរំលោភសេពសន្ថវៈយ៉ាងព្រៃផ្សៃលើក្មេងស្រី អាចបញ្ចៀសបាន និងមិនត្រូវបានប្រព្រឹត្តដោយសារតែលទ្ធភាពនៃការគំរាមកំហែងដល់គាត់នោះទេ។ ដូច្នេះ គាត់ត្រូវបានចាត់ទុកថាទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះបទល្មើសទាំងនោះ។[111]

---

104 *<u>សៀវភៅណែនាំស្តីពីយុត្តិធម៌ស្តារឡើងវិញ</u>* (បោះពុម្ពលើកទី ២, UNODC, ២០២០)

105 សូមមើលសេចក្តីសម្រេចលេខ ២៤២៧ (២០១៨) របស់ក្រុមប្រឹក្សាសន្តិសុខ, អាចអនុវត្តបានចំពោះការប្រព្រឹត្តចំពោះកុមារដែលពាក់ព័ន្ធ ឬត្រូវបានចោទថាពាក់ព័ន្ធជាមួយក្រុមប្រដាប់អាវុធមិនមែនរដ្ឋ រួមទាំងអ្នកដែលប្រព្រឹត្តអំពើភេរវកម្ម។

106 សូមមើល ឧទាហរណ៍ ករណី *<u>រដ្ឋអាជ្ញា ទល់នឹង Dominic Ongwen</u>* <u>ICC-02/04-01/15</u> ទាក់ទងនឹងអតីតទាហានកុមារម្នាក់ដែលត្រូវបានរកឃើញថាមានទោសដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅឆ្នាំ ២០២០ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំនួន ៦១ និងឧក្រិដ្ឋកម្មសង្គ្រាមនៅអ៊ុយហ្គង់ដា នៅអំឡុងខែកក្កដា ឆ្នាំ ២០០២ ដល់ខែធ្នូ ឆ្នាំ ២០០៥។

### អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ

កុមារដែលត្រូវបានឃុំខ្លួនដោយសារការពាក់ព័ន្ធជាមួយក្រុមប្រដាប់អាវុធ រួមទាំងក្រុមភេរវកម្មដែលត្រូវបានកំណត់ គួរត្រូវបានទទួលស្គាល់ថាជាជនរងគ្រោះនៃការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌។ គួរផ្តោតអាទិភាពលើការស្តារឡើងវិញ ការធ្វើសមាហរណកម្ម និងការរស់នៅជួបជុំគ្រួសារឡើងវិញ មិនមែនការដាក់ទោសទណ្ឌនោះទេ។ ដោយរំលឹកឡើងវិញនូវសេចក្តីសម្រេចលេខ ២៣៨៨ (២០១៧) របស់ក្រុមប្រឹក្សាសន្តិសុខ រដ្ឋទាំងអស់គួរចៀសវាងអនុវត្តការឃុំខ្លួនខាងរដ្ឋបាលចំពោះកុមារដែលជាជនរងគ្រោះដោយការជួញដូរមនុស្ស រួមទាំងកុមារដែលពាក់ព័ន្ធ ឬសង្ស័យថាពាក់ព័ន្ធជាមួយក្រុមប្រដាប់អាវុធមិនមែនរដ្ឋទាំងអស់ រួមទាំងក្រុមដែលប្រព្រឹត្តអំពើភេរវកម្ម។ គួរអនុវត្តនីតិវិធីប្រតិបត្តិការស្តង់ដារ ដើម្បីធានាការប្រគល់កុមារដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ទៅកាន់ភ្នាក់ងារការពារកុមារជាជនស៊ីវិល ឱ្យបានទាន់ពេលវេលា។ [112]

# ផ្នែកទី ៥



# ការអនុវត្តន៍គោលការណ៍ មិនដាក់ទណ្ឌកម្ម នៅពេលដែល ជនរងគ្រោះ ត្រូវបានកាត់ទោស

## ផ្នែកទី ៥. ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មនៅពេលជនរងគ្រោះត្រូវបានផ្តន្ទាទោស

ក្នុងករណីដែលវិធានការការពារមិនឱ្យមានការដាក់ទោស បរាជ័យក្នុងការការពារជនរងគ្រោះពីការកាត់ទោស និងការផ្តន្ទាទោស អាចមានឱកាសនៅដំណាក់កាលផ្តន្ទាទោស ដើម្បីការពារជនរងគ្រោះពីការដាក់ទោសទណ្ឌបន្ថែមទៀត។ ក្នុងករណីដែលជនរងគ្រោះដោយការជួញដូរមនុស្ស ត្រូវបានផ្តន្ទាទោសខុស ផ្ទុយនឹងគោលការណ៍មិនដាក់ទណ្ឌកម្ម ពួកគេត្រូវតែមានលទ្ធភាពទទួលបានដំណោះស្រាយ រួមទាំងសំណងបដិទាន និងសំណងជំងឺចិត្តសម្រាប់ទង្វើខុសឆ្គងរបស់រដ្ឋចំពោះពួកគេ គឺបរាជ័យក្នុងការការពារសិទ្ធិរបស់ពួកគេ។

មនុស្សគ្រប់រូប រួមទាំងអ្នកដែលត្រូវបានផ្តន្ទាទោស សុទ្ធតែមានសិទ្ធិមនុស្សដែលរដ្ឋត្រូវតែគោរព។ ជនរងគ្រោះអាចរងផលប៉ះពាល់ពីការផ្តន្ទាទោសយូរ បន្ទាប់ពីការជំនុំជម្រះទោសពួកគេត្រូវបានបញ្ចប់។ កំណត់ត្រាព្រហ្មទណ្ឌ ឬទណ្ឌកម្មរដ្ឋបាល សូម្បីតែសម្រាប់បទល្មើសតូចតាច ក៏អាចបង្កឧបសគ្គដល់ការស្តារឡើងវិញ និងការធ្វើសមាហរណកម្មរបស់ជនរងគ្រោះ។ កំណត់ត្រាព្រហ្មទណ្ឌសម្រាប់បទល្មើសដែលបានប្រព្រឹត្តក្នុងអំឡុងពេលដែលជនរងគ្រោះត្រូវបានជួញដូរ អាចបង្កឧបសគ្គដល់ជនរងគ្រោះក្នុងការទទួលបានសំណងជំងឺចិត្ត។[107] កំណត់ត្រាទាំងនេះអាចធ្វើឱ្យប៉ះពាល់ដល់ការទាមទារសិទ្ធិជ្រកកោន ឬនិវាសនដ្ឋាន និងការធ្វើដំណើរ។ កំណត់ត្រាទាំងនេះអាចបដិសេធពួកគេពីការទទួលបានលំនៅឋាន ការអប់រំ និងឱកាសការងារ។ កំណត់ត្រាព្រហ្មទណ្ឌអាចមានន័យថា ពួកគេមិនអាចដាក់ពាក្យស្នើសុំកម្ចី ឬអាជ្ញាប័ណ្ណ ឬសន្តិសុខសង្គម និងអាចបង្កឧបសគ្គដល់ការឃុំគ្រងកូនៗរបស់ពួកគេ។ តថភាពទាំងនេះចង្អុលបង្ហាញពីភាពចាំបាច់បំផុតក្នុងការធ្វើមោឃភាព លុបចោល ឬបិទកំណត់ត្រាព្រហ្មទណ្ឌ។

គោលការណ៍ណែនាំខាងក្រោមនេះគឺដើម្បីគាំទ្រដល់រដ្ឋក្នុងការពង្រឹងសមត្ថភាពរបស់ខ្លួន ដើម្បីការពារជនរងគ្រោះពីការដាក់ទោសទណ្ឌបន្ថែមទៀត និងផ្តល់ដំណោះស្រាយដល់ជនរងគ្រោះដែលត្រូវបានផ្តន្ទាទោសខុស។

### *[១២] បញ្ចៀស ឬសម្រាលទោសសម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្សដែលត្រូវបានផ្តន្ទាទោស*

សមាជិកនៃអង្គចៅក្រមអាចមានសមត្ថភាពបញ្ឈប់ដំណើរការនីតិវិធី លើកលែងទោសជនរងគ្រោះ ឬជាជម្រើសចុងក្រោយ សម្រាលទោសដែលបានដាក់លើជនរងគ្រោះដែលត្រូវបានផ្តន្ទាទោស។ ការបញ្ចៀស ឬការសម្រាលទោសមិនការពារជនរងគ្រោះពីបទពិសោធន៍នៃការទទួលទោសព្រហ្មទណ្ឌទេ។ គួរមានការការពារពីការចាប់ខ្លួន ការកាត់ទោស និងការផ្តន្ទាទោស តាំងពីដំបូង។ ដូច្នេះ ការសម្រាលទោសតែម្យ៉ាង មិនបំពេញកាតព្វកិច្ចរបស់រដ្ឋក្នុងការការពារជនរងគ្រោះពីការដាក់ទោសទណ្ឌទេ ប៉ុន្តែអាចជាខ្សែការពារចុងក្រោយដ៏សំខាន់។

[107] *យន្តការបញ្ជូនថ្នាក់ជាតិ៖ កិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីការពារសិទ្ធិរបស់ជនដែលត្រូវបានជួញដូរ* (បោះពុម្ពលើកទី ២, *OSCE, ODIHR,* ២០២២), ទំព័រ ២៣៣។

### ពិចារណាអំពីរបៀបដែលច្បាប់ទាក់ទងនឹងការសម្រាលទោស អាចផ្តល់ការសង្គ្រោះពីការដាក់ទោសទណ្ឌ

ច្បាប់ទាក់ទងនឹងការសម្រាលទោស នឹងក្លាយជាឧបករណ៍ដ៏មានប្រយោជន៍ដើម្បីផ្តល់ឱ្យជនរងគ្រោះនូវការជួយសម្រាលខ្លះពីការដាក់ទោសទណ្ឌ ក្នុងករណីដែលពួកគេមិនត្រូវបានការពារពីការផ្តន្ទាទោស។[108] សមាជិកនៃអង្គចៅក្រមគួរតែមានវិធីប្រើប្រាស់ច្បាប់ ដែលអនុញ្ញាតឱ្យពួកគេមិនផ្តន្ទាទោសជនរងគ្រោះដោយការជួញដូរមនុស្ស ទោះបីជាមានការកំណត់ការទទួលខុសត្រូវរបស់ជនរងគ្រោះក៏ដោយ។ នៅក្នុងយុត្តាធិការផ្សេងទៀត ច្បាប់ទូទៅអាចត្រូវបានអនុវត្ត ដើម្បីឆ្លុះបញ្ចាំងពីភាពគួរឱ្យស្តីបន្ទោសលើជនល្មើសក្នុងការផ្តន្ទាទោស។

### ធានាថា ការផ្តន្ទាទោសដែលបានដាក់ ឆ្លុះបញ្ចាំងពីកំហុសរបស់ជនប្រព្រឹត្តបទល្មើស-ជាជនរងគ្រោះ

នៅពេលដែលជនរងគ្រោះដោយការជួញដូរមនុស្ស ត្រូវបានរកឃើញថាមានទោសសម្រាប់បទល្មើសមួយការផ្តន្ទាទោសដែលបានដាក់ គួរតែឆ្លុះបញ្ចាំងពីកម្រិតនៃការទទួលខុសត្រូវរបស់ជនប្រព្រឹត្តបទល្មើស-ជាជនរងគ្រោះ និងភាពធ្ងន់ធ្ងរនៃបទល្មើសដែលបានប្រព្រឹត្ត។ សមាជិកនៃអង្គចៅក្រមគួរតែមានសមត្ថភាពវិភាគអំពីកំហុសរបស់ជនរងគ្រោះដោយការជួញដូរមនុស្សដែលបានប្រព្រឹត្តបទល្មើស ដោយស្វែងយល់ពីទំនាក់ទំនងរវាងការប្រព្រឹត្តបទល្មើស និងការជួញដូរជនរងគ្រោះ។

ក្នុងការកំណត់កម្រិតនៃកំហុសនៅក្នុងស្ថានភាពបែបនេះ គេអាចសន្មតបានថា នៅពេលមានទំនាក់ទំនងកាន់តែខ្លាំងរវាងការប្រព្រឹត្តបទល្មើស និងការជួញដូរមនុស្ស មនុស្សម្នាក់នឹងកាន់តែមានកំហុសតិច។ ក្រៅពីនេះ សមាជិកនៃអង្គចៅក្រមគួរពិនិត្យមើលភាពលម្អៀង និងការសន្មតរបស់ខ្លួនចំពោះជនរងគ្រោះដោយការជួញដូរមនុស្ស និងការប្រព្រឹត្តបទល្មើសរបស់ពួកគេដើម្បីឱ្យសេចក្តីសម្រេចរបស់ខ្លួនមានភាពយុត្តិធម៌និងមិនលម្អៀង។ សមាជិកនៃអង្គចៅក្រមគួរដឹងច្បាស់ពីស្ថានសម្រាលទោស ដែលអាចអនុវត្តបានក្នុងស្ថានភាពនៅពេលដែលជនរងគ្រោះ ដោយការជួញដូរមនុស្សពាក់ព័ន្ធក្នុងបទល្មើស។[109]

---

108 ការណែនាំស្តីពីការឆ្លើយតបសមស្របផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ចំពោះជនរងគ្រោះដែលត្រូវបានបង្ខំឱ្យប្រព្រឹត្តបទល្មើសដោយសារតែពួកគេត្រូវបានជួញដូរ៖ ឯកសារសាវតារដែលរៀបចំឡើងដោយលេខាធិការដ្ឋានក្រុមការងារស្តីពីការជួញដូរមនុស្ស, វីយែន ថ្ងៃទី១០ និងទី ១១ ខែកញ្ញា ឆ្នាំ២០២០, ឯកសារ អ.ស.ប CTOC/COP/WG.4/2020/2 (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០), កថាខណ្ឌ ៤៦

109 ឧទាហរណ៍ មាត្រា ៥១ នៃក្រមព្រហ្មទណ្ឌវៀតណាម ចែងពីអង្គហេតុសម្រាលទោសដែលអាចពាក់ព័ន្ធ រួមទាំងក្នុងករណីដែលបទល្មើសត្រូវបានប្រព្រឹត្តក្រោមការបង្កហេតុ ការគំរាមកំហែង ឬការបង្ខិតបង្ខំ ឬដោយសារជនល្មើសខ្វះការយល់ដឹង។ ដូចគ្នានេះដែរ ស្ថានសម្រាលទោសត្រូវបានចែងក្នុងមាត្រា ៩ នៃ *ច្បាប់ស្តីពីការដោះស្រាយការរំលោភបំពានខាងផ្លូវចិត្ត។*

### ប្រអប់៖ ឧទាហរណ៍ (ការជួញដូរគ្រឿងញៀន)

"ក" គឺជាស្ត្រីមេម៉ាយវ័យក្មេងម្នាក់ ដែលប្រឹងប្រែងផ្គត់ផ្គង់កូនប្រុសរបស់នាង និងម្តាយចាស់។ នាងលង់ស្នេហ៍បុរសអ្នកមាន និងស្រស់សង្ហាម្នាក់មកពីប្រទេសមួយផ្សេងទៀត ដែលមកទីក្រុងរបស់នាងជាញឹកញាប់ ដើម្បីដំណើរការអាជីវកម្មនាំចេញ នាំចូលរបស់គាត់។ បន្ទាប់ពីការជួបគ្នាជាច្រើនខែនៅពេលដែលបុរសនោះមកទីក្រុង គាត់បានទិញសំបុត្រយន្តហោះឱ្យនាងមកលេងគាត់ពេញមួយសប្តាហ៍។ "ក" រីករាយដែលបានទៅលេងបុរសនោះនៅទីក្រុងរបស់គាត់ជាលើកដំបូង។ គាត់ស្នើឱ្យនាងទៅយករបស់របរខ្លះពី សហការីម្នាក់របស់គាត់នៅតាមផ្លូវទៅអាកាសយានដ្ឋាន រួចយកមកឱ្យគាត់។ "ក" អនុវត្តតាមសំណើនេះ។ បន្ទាប់ពីនាងចុះចតនៅក្នុងទីក្រុង នាងត្រូវបានអាជ្ញាធរនាំខ្លួន ព្រោះបានរកឃើញគ្រឿងញៀននៅក្នុងវ៉ាលីរបស់នាង។ នាងត្រូវបានចាប់ខ្លួនពីបទជួញដូរកូកាអ៊ីន។

*__ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖__* ព្រះរាជអាជ្ញាស្នើសុំឱ្យតុលាការលើកលែងទោស "ក" ដោយផ្អែកលើគោលការណ៍មិនដាក់ទណ្ឌកម្ម។ ខណៈដែលចៅក្រមទទួលស្គាល់ថា "ក" ត្រូវបានជួញដូរបង្ខំឱ្យប្រព្រឹត្តបទល្មើស ចៅក្រមបានគូសបញ្ជាក់ថាច្បាប់ជាតិមិនទទួលស្គាល់ការបង្ខំឱ្យប្រព្រឹត្តបទល្មើសថាជាគោលបំណងនៃការជួញដូរមនុស្សទេ និងថា បទបញ្ញត្តិមិនដាក់ទោសទណ្ឌត្រូវបានកម្រិតត្រឹមការការពារជនរងគ្រោះពីការដាក់ទោសទណ្ឌសម្រាប់បទល្មើសពាក់ព័ន្ធនឹងអន្តោប្រវេសន៍ និងពេស្យាចារ។ ផ្អែកលើមូលដ្ឋាននេះ ចៅក្រមបានផ្តន្ទាទោស "ក" ទាំងស្ទាក់ស្ទើរ។ ទោះយ៉ាងណាក៏ដោយ ចៅក្រមបានសម្រាលទោសរបស់ "ក" ដោយផ្អែកលើកាលៈទេសៈផ្ទាល់ខ្លួនរបស់"ក"និងផ្តន្ទាទោសនាងឱ្យជាប់ពន្ធនាគាររយៈពេលខ្លីបំផុត ដែលត្រូវបានព្យួរទោសសម្រាប់អំឡុងពេលសាកល្បង។

## *[១៣] ផ្តល់ឱ្យជនរងគ្រោះនូវដំណោះស្រាយសម្រាប់ការដាក់ទោសទណ្ឌខុស*

បរាជ័យរបស់អាជ្ញាធរក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ដើម្បីការពារជនរងគ្រោះដោយការជួញដូរមនុស្សពីការផ្តន្ទាទោស ឬការដាក់ទោសទណ្ឌខុស គឺជាការរំលោភសិទ្ធិមនុស្សរបស់ពួកគេ។ ជនរងគ្រោះមានសិទ្ធិទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងអាចអនុវត្តបាន សម្រាប់ការរំលោភសិទ្ធិរបស់ពួកគេទាំងក្រោមច្បាប់អន្តរជាតិ និងដោយអនុលោមតាមមាត្រា ៥ នៃសេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្ស។ គោលការណ៍ "ពិនិត្យផ្ទៀងផ្ទាត់បញ្ជាក់ភាពត្រឹមត្រូវ" តម្រូវឱ្យរដ្ឋចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីដោះស្រាយបរាជ័យនេះ ដោយលុបចោល ឬធ្វើមោឃភាពការផ្តន្ទាទោស បិទកំណត់ត្រាបទល្មើស និងដកចេញនូវរាល់ការដាក់ទណ្ឌកម្មខុស (រួមទាំងការពិន័យ) ដោយផ្អែកលើសេចក្តីសម្រេចផ្នែករដ្ឋបាលអន្តោប្រវេសន៍ រដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬសេចក្តីសម្រេចផ្សេងទៀត។

### រិះរកឱកាសដែលមានស្រាប់ ដើម្បីឱ្យជនរងគ្រោះស្វែងរកដំណោះស្រាយសម្រាប់ការដាក់ទោសទណ្ឌខុស

ដូចបុគ្គលគ្រប់រូបដែលមានសិទ្ធិដែរ ជនរងគ្រោះដោយការជួញដូរមនុស្សមានសិទ្ធិទទួលបានសំណងសម្រាប់ការផ្តន្ទាទោសខុស ឬការប្រព្រឹត្តដោយអយុត្តិធម៌។[110] រដ្ឋសមាជិកអាស៊ានគួរធានាថា ជនរងគ្រោះដោយការជួញដូរមនុស្សដែលត្រូវបានផ្តន្ទាទោសខុស ផ្ទុយពីគោលការណ៍មិនដាក់ទណ្ឌកម្ម មានសិទ្ធិប្តឹងឧទ្ធរណ៍។ ឧទាហរណ៍ ច្បាប់នៅប្រទេសហ្វីលីពីន

[110] ICCPR មាត្រា ១៤(៦) សេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្ស មាត្រា ៥។

អនុញ្ញាតឱ្យមានការស្វែងរកសំណងជំងឺចិត្តដោយមនុស្សច្រើនប្រភេទ រួមទាំងអ្នកដែលត្រូវបានចោទប្រកាន់ ផ្តន្ទាទោស និងដាក់ក្នុងពន្ធនាគារដោយអយុត្តិធម៌។[111] ច្បាប់នៅប្រទេសឡាវ អនុញ្ញាតឱ្យមានការធ្វើមោឃភាព ឬកែប្រែសេចក្តីសម្រេចរបស់តុលាការ ដោយផ្អែកលើមូលដ្ឋានជាក់លាក់។[112]

គួរកំណត់រក និងជម្នះឧបសគ្គដែលរារាំងប្រភេទជនរងគ្រោះមួយចំនួនក្នុងការទទួលបានបណ្តាញផ្លូវច្បាប់។ ការវាយតម្លៃល្អិតល្អន់លើឧបសគ្គទាំងនោះគួររួមបញ្ចូលឧបសគ្គដែលទាក់ទងនឹងមូលដ្ឋាននៃការរើសអើង ទោះជាដោយសារសញ្ជាតិ ស្ថានភាព ពិការភាព ភាសា ប្រភេទនៃការជួញដូរមនុស្ស ឬមូលដ្ឋានផ្សេងទៀតក៏ដោយ។ ក្រៅពីនេះ គួរតែវាយតម្លៃផងដែរអំពីកម្រិតដែលការដាក់ទោសទណ្ឌជនរងគ្រោះផ្ទាល់គឺជាឧបសគ្គរាំងការទទួលបានយុត្តិធម៌។ ឧបសគ្គទាំងនោះអាចជាលទ្ធផលនៃកំណត់ត្រាបទល្មើសដែលបានដាក់លើពួកគេ ធ្វើឱ្យពួកគេមានការលំបាកក្នុងការទទួលបានដំណោះស្រាយ ឬការហាមឃាត់ការធ្វើដំណើរដែលបានដាក់ដោយសារការរំលោភច្បាប់អន្តោប្រវេសន៍ ដែលធ្វើឱ្យជនរងគ្រោះមិនអាចធ្វើដំណើរ ដើម្បីទទួលបានសំណងជំងឺចិត្ត។ ឧបសគ្គក៏អាចបណ្តាលមកពីការណ៍ដែលជនរងគ្រោះត្រូវបានទទួលស្គាល់ថាជាជនរងគ្រោះនៅក្នុងប្រទេសអាស៊ានមួយ មិនត្រូវបានទទួលស្គាល់ស្ថានភាពដូច្នេះនៅក្នុងប្រទេសផ្សេងទៀត ផងដែរ។

គួរមានយន្តការបណ្តឹងតវ៉ាសម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស ដែលត្រូវបានដាក់ទោសខុស ផ្ទុយពីគោលការណ៍មិនដាក់ទណ្ឌកម្ម។ គួរបង្កើត ឬកែសម្រួលមូលនិធិដើម្បីបង្កលក្ខណៈងាយស្រួលសម្រាប់ជនរងគ្រោះដែលមានការរំលោភសិទ្ធិ តាមរយៈការដាក់ទោសទណ្ឌខុស។[113] គួរមានផ្តល់ដំណោះស្រាយសម្រាប់ជនរងគ្រោះដែលត្រូវបានដាក់ទោសខុស ដោយគ្មានការរើសអើងចំពោះជនរងគ្រោះដែលបានរងការដាក់ទោសទណ្ឌខុស ទោះបីដោយសារការនិរទេស ការឃុំខ្លួន ការបញ្ជូនត្រឡប់មកវិញ ឬការផ្តន្ទាទោសក៏ដោយ។

---

111 សូមមើលហ្វីលីពីន (ថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៩២) ច្បាប់សាធារណរដ្ឋលេខ ៧៣០៩ (*ច្បាប់ស្តីពីការបង្កើតគណៈកម្មការទាមទារនៅក្រោមក្រសួងយុត្តិធម៌សម្រាប់ជនរងគ្រោះដោយការដាក់ក្នុងពន្ធនាគារ ឬការឃុំខ្លួនដោយអយុត្តិធម៌ និងជនរងគ្រោះដោយបទល្មើសហិង្សា និងសម្រាប់គោលបំណងផ្សេងទៀត*) ផ្តល់សិទ្ធិដល់មនុស្សដូចខាងក្រោមក្នុងការដាក់ពាក្យស្នើសុំសំណងជំងឺចិត្ត ៖ អ្នកដែលត្រូវបានចោទប្រកាន់ ផ្តន្ទាទោស និងដាក់ក្នុងពន្ធនាគារដោយអយុត្តិធម៌ និងបន្ទាប់មកត្រូវបានលើកលែងទោស អ្នកដែលត្រូវបានឃុំខ្លួនដោយអយុត្តិធម៌ និងត្រូវបានដោះលែងដោយគ្មានការចោទប្រកាន់ អ្នកដែលត្រូវបានឃុំខ្លួនតាមទំនើងចិត្តដោយអាជ្ញាធរ ឬអ្នកដែលជាជនរងគ្រោះដោយបទល្មើសហិង្សា រួមទាំងការរំលោភសេពសន្ថវៈ និងបទល្មើសដែលប្រព្រឹត្តដោយការព្យាបាទដែលបណ្តាលឱ្យស្លាប់ ឬរបួសរាងកាយ និង/ឬផ្លូវចិត្តធ្ងន់ធ្ងរ អសមត្ថភាពជាអចិន្ត្រៃយ៍ ឬពិការ ឆ្កួតលីលា វលូតកូន ប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ ឬប្រព្រឹត្តដោយការធ្វើទារុណកម្ម ភាពឃោរឃៅ ឬភាពព្រៃផ្សៃ។

112 *ក្រមនីតិវិធីព្រហ្មទណ្ឌ*របស់ឡាវ អនុញ្ញាតឱ្យមានការប្តឹងឧទ្ធរណ៍ និងសំណើសុំជំទាស់ប្រឆាំងនឹងសេចក្តីសម្រេចរបស់តុលាការ (មាត្រា ២១៤)។ មាត្រា ២២៣ អនុញ្ញាតឱ្យមានការធ្វើមោឃភាព ឬកែប្រែសេចក្តីសម្រេច ដោយផ្អែកលើមូលដ្ឋានជាក់លាក់ រួមទាំង ១. ការស៊ើបអង្កេត-ការសួរចម្លើយ ឬការជំនុំជម្រះសំណុំរឿង មិនគ្រប់ជ្រុងជ្រោយ មិនស៊ីជម្រៅ ឬមិនមានលក្ខណៈសត្យានុម័ត ២. សំអាងហេតុរបស់តុលាការមិនស្របតាមអង្គហេតុជាក់ស្តែងនៃសំណុំរឿង ៣. ការដាក់ទោសមិនសមស្របនឹងលក្ខណៈ កម្រិតនៃគ្រោះថ្នាក់នៃបទល្មើសចំពោះសង្គម និងបុគ្គលិកលក្ខណៈរបស់ជនល្មើស ៤. មានការរំលោភបទបញ្ញត្តិក្នុងនីតិវិធីព្រហ្មទណ្ឌ ឬការប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌមិនត្រឹមត្រូវ។

113 ចំណុច ៣ នៃសេចក្តីប្រកាសអាស៊ានស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការការពារ និងជួយសាក្សី និងជនរងគ្រោះដោយឧក្រិដ្ឋកម្មឆ្លងដែន (ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣) លើកទឹកចិត្តឱ្យរដ្ឋសមាជិកអាស៊ាន "បង្កើតនីតិវិធី ដើម្បីផ្តល់លទ្ធភាពទទួលបានសំណងជំងឺចិត្ត និងសំណងបដិទានសម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម រួមទាំងឧក្រិដ្ឋកម្មឆ្លងដែន និងដើម្បីអនុញ្ញាតឱ្យមានការបង្ហាញ និងពិចារណាលើទស្សនៈ និងកង្វល់របស់ជនរងគ្រោះ នៅដំណាក់កាលសមស្របនៃនីតិវិធីព្រហ្មទណ្ឌ។"

### ប្រអប់៖ ឧទាហរណ៍ (ការជួញដូរគ្រឿងញៀន)

"ក" គឺជាជនពិការអាយុ ១៩ ឆ្នាំ ដែលត្រូវជិះរទេះរុញ។ គាត់គ្មានការងារធ្វើជាច្រើនខែមកហើយ និងកំពុងមានការលំបាកក្នុងការចិញ្ចឹមផ្គត់ផ្គង់ម្តាយចាស់របស់គាត់។ ក្រុមជួញដូរគ្រឿងញៀនក្នុងមូលដ្ឋានបានជ្រើសរើសគាត់ឱ្យលក់គ្រឿងញៀន ដោយប្រាប់គាត់ថា ប្រសិនបើគាត់មិនលក់គ្រឿងញៀនឱ្យពួកគេទេ ពួកគេនឹងឱ្យម្តាយរបស់គាត់ធ្វើជំនួសវិញ។ ពួកគេប្រាប់គាត់ថា គាត់នឹងទទួលបានជោគជ័យក្នុងការជួញដូរគ្រឿងញៀន ព្រោះអាជ្ញាធរនឹងមិនសង្ស័យថា បុរសជិះរទេះរុញជាអ្នកជួញដូរគ្រឿងញៀននោះទេ។ "ក" ទទួលបានប្រាក់ចំណេញ មួយភាគរយ ពីការលក់គ្រឿងញៀននៅតាមដងផ្លូវ។ ថ្ងៃមួយ គាត់បានលក់គ្រឿងញៀនទៅឱ្យនគរបាលបង្កប់ខ្លួន ហើយគាត់ត្រូវបានចាប់ខ្លួន។

ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ ភស្តុតាងត្រូវបានបង្ហាញនៅក្នុងការជំនុំជម្រះទោស "ក" រួមទាំងសក្ខីកម្មពីនគរបាលបង្កប់ខ្លួន គ្រឿងញៀនដែលគាត់បានទិញ និងប្រាក់ទទួលបានពីការគ្រឿងញៀនទាំងនោះដែលត្រូវបានរឹបអូសពី "ក" បញ្ជាក់ថា "ក" បានលក់គ្រឿងញៀនខុសច្បាប់។ គាត់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារជាច្រើនឆ្នាំ។ ក្រោយជាប់ពន្ធនាគារបានប៉ុន្មានខែ "ក" បានពិនិត្យសុខភាពជាមួយវេជ្ជបណ្ឌិត។ ក្នុងអំឡុងពេលនៃការសន្ទនារវាង "ក" និងវេជ្ជបណ្ឌិត វេជ្ជបណ្ឌិតមានការព្រួយបារម្ភថា "ក" អាចត្រូវបានជួញដូរឱ្យប្រព្រឹត្តបទល្មើសដែលគាត់ត្រូវបានកាត់ទោស។ អាជ្ញាធរមានសមត្ថកិច្ចបានកំណត់អត្តសញ្ញាណ "ក" ថាជាជនរងគ្រោះដោយការជួញដូរមនុស្ស ដែលត្រូវបានជ្រើសរើសឱ្យប្រព្រឹត្តបទល្មើសតាមរយៈការគំរាមកំហែងលើម្តាយរបស់គាត់ និងការប្រើប្រាស់ស្ថានភាពងាយរងគ្រោះរបស់គាត់។ ករណីនេះត្រូវបានប្តឹង ឧទ្ធរណ៍។ សាលាឧទ្ធរណ៍បានច្រានចោលករណីប្រឆាំងនឹង "ក" ដោយផ្អែកលើភស្តុតាងនៃស្ថានភាពជាជនរងគ្រោះរបស់គាត់ និងបានបញ្ជាឱ្យទូទាត់សំណងបដិទានសម្រាប់ការផ្តន្ទាទោសខុសលើរូបគាត់។

## រិះរកឱកាស ដើម្បីធ្វើមោឃភាព លុបចោល ឬបិទការផ្តន្ទាទោសជនរងគ្រោះដោយការជួញដូរមនុស្ស

មន្ត្រីតុលាការ និងអ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌ គួរយល់ច្បាស់ពីច្បាប់មោឃភាព (vacatur law) ដែលមានស្រាប់ និងកាលៈទេសៈដែលជនរងគ្រោះដោយការជួញដូរមនុស្ស អាចប្រើប្រាស់ច្បាប់ទាំងនោះ។ ពួកគេត្រូវតែយល់ពីដំណើរការនៃការប្រើប្រាស់ជម្រើសនានា ដើម្បីធ្វើមោឃភាព (ធ្វើឱ្យការផ្តន្ទាទោសក្លាយជាមោឃៈ) លុបចោល (លុបការផ្តន្ទាទោសចេញពីកំណត់ត្រាបទល្មើស) ឬបិទ (តម្រូវឱ្យមានដីកាតុលាការ ដើម្បីអាចឆែកមើលការផ្តន្ទាទោស) ការផ្តន្ទាទោស ដើម្បីផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះ។ អ្នកជំនាញច្បាប់មានតួនាទីគាំទ្រដល់ជនរងគ្រោះក្នុងការដាក់ពាក្យបណ្តឹងនៅតុលាការ ដើម្បីលុបការផ្តន្ទាទោសរបស់ពួកគេ និងគួរតែបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការស្វែងរកដំណោះស្រាយសម្រាប់ជនរងគ្រោះ រួមទាំងតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិឆ្លងព្រំដែនផងដែរ។

ស្ថាប័នប្រឆាំងការជួញដូរមនុស្ស និងស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ (ក្នុងករណីដែលមានស្ថាប័នទាំងនេះ) គួរវាយតម្លៃច្បាប់មោឃភាព នៅក្នុងយុត្តាធិការរបស់ខ្លួន។ ពួកគេគួរកំណត់ថាតើសេចក្តីសម្រេចរបស់តុលាការក្នុងការបង្វែរការផ្តន្ទាទោសនៅក្នុងយុត្តាធិការរបស់ពួកគេ ផ្តល់សិទ្ធិឱ្យជនរងគ្រោះនិយាយថា គាត់ឬនាង មិនត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសឬទេ ឬក៏បណ្តាលឱ្យមានការលុបបទចោទប្រកាន់ពីកំណត់ត្រារបស់ជនរងគ្រោះ ប៉ុន្តែការផ្តន្ទាទោសនៅតែមាន។[114]

មួយវិញទៀត ស្ថាប័នទាំងនេះគួរកំណត់រកដែនកំណត់ និងឧបសគ្គណាមួយដែលអាចពាក់ព័ន្ធនឹងឱកាសក្នុងការធ្វើមោឃភាព លុបចោល ឬបិទកំណត់ត្រាបទល្មើស ដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មឱ្យមានប្រសិទ្ធភាពពេញលេញសម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស។ ឧទាហរណ៍ គោលការណ៍មួយចំនួនអាចនឹងអនុវត្តតែចំពោះបទល្មើសជាក់លាក់ (ដូចជា បទល្មើសទាក់ទងនឹងអន្តោប្រវេសន៍ ឬពេស្យាចារ) ប៉ុន្តែមិនអនុវត្តចំពោះបទល្មើសផ្សេងទៀតដែលជនរងគ្រោះដោយការជួញដូរមនុស្សអាចនឹងបានប្រព្រឹត្តដោយសារតែពួកគេត្រូវបានជួញដូរ។ តុលាការគួរធ្វើការបកស្រាយទូលំទូលាយលើច្បាប់មោឃភាព ក្នុងបរិបទនៃករណីដែលពាក់ព័ន្ធនឹងជនល្មើសដែលជាជនរងគ្រោះដោយការជួញដូរមនុស្ស។

## កំណត់រក និងដោះស្រាយឧបសគ្គដែលជនរងគ្រោះជួបប្រទះ ក្នុងការជំរុញឱ្យលុបចោលការផ្តន្ទាទោស

ស្ថាប័នប្រឆាំងការជួញដូរមនុស្ស និងស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ គួរកំណត់រក និងដោះស្រាយឧបសគ្គផ្នែកច្បាប់ និងនីតិវិធី និងឧបសគ្គជាក់ស្តែងដែលជនរងគ្រោះជួបប្រទះ ក្នុងការជំរុញឱ្យធ្វើមោឃភាព ឬលុបចោលកំណត់ត្រាបទល្មើសរបស់ពួកគេ។ គួរផ្តោតការយកចិត្តទុកដាក់លើការស្វែងរកការគាំទ្រពីតួអង្គមិនមែនរដ្ឋរួម ទាំងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីកំណត់រក និងដោះស្រាយឧបសគ្គទាំងនេះ។

ការធានាលទ្ធភាពទទួលបានដំណោះស្រាយ អាចតម្រូវឱ្យរដ្ឋសមាជិកអាស៊ានបែងចែកថវិកាគ្រប់គ្រាន់សម្រាប់តុលាការ ដើម្បីឱ្យអាចអនុវត្តច្បាប់មោឃភាព រួមទាំងការផ្តល់ជំនួយផ្នែកច្បាប់ ដើម្បីកាត់បន្ថយបន្ទុកមិនសមស្របលើជនរងគ្រោះក្នុងការបញ្ជាក់ថា ការផ្តន្ទាទោសធ្វើឡើងដោយមិនត្រឹមត្រូវ។[115]

---

114 ការណែនាំស្តីពីការឆ្លើយតបសមស្របផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ចំពោះជនរងគ្រោះដែលត្រូវបានបង្ខំឱ្យប្រព្រឹត្តបទល្មើសដោយសារតែពួកគេត្រូវបានជួញដូរ ៖ ឯកសារសាវតារដែលរៀបចំឡើងដោយលេខាធិការដ្ឋានក្រុមការងារស្តីពីការជួញដូរមនុស្ស, វីយែន ថ្ងៃទី១០ និងទី ១១ ខែកញ្ញា ឆ្នាំ២០២០, ឯកសារ អ.ស.ប CTOC/COP/WG.4/2020/2 (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០), កថាខណ្ឌ ៥០។

115 ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ, Siobhán Mullaly, ឯកសារ អ.ស.ប A/HRC/47/34 (ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១) កថាខណ្ឌ ៥០។

ប្រហែលជាចាំបាច់ ត្រូវរៀបចំឱ្យមានវិធានការ ដើម្បីលុបបំបាត់ការរើសអើងដែលអាចជាឧបសគ្គរាំងជនរងគ្រោះមួយចំនួនក្នុងការទទួលបានដំណោះស្រាយ។ ឧទាហរណ៍ ត្រូវបង្ហាញព័ត៌មានស្តីពីដំណោះស្រាយក្រោយការផ្តន្ទាទោស ជាភាសាដែលអាចយល់បានដោយជនរងគ្រោះដែលត្រូវបានផ្តន្ទាទោស។ ក្រៅពីនេះ ត្រូវបង្ហាញព័ត៌មាន និងអនុវត្តដំណើរការតាមវិធីដែលយកចិត្តទុកដាក់ចំពោះកុមារ និងបង្កលក្ខណៈងាយស្រួលដល់កុមារ និងយុវជន ហើយត្រូវមានបរិយាបន្នពិការភាព ស្របតាមលក្ខខណ្ឌតម្រូវក្រោមច្បាប់អន្តរជាតិទាក់ទងនឹងការទទួលបានយុត្តិធម៌ និងដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។ [116]

### អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ

នៅពេលដែលអាជ្ញាធរក្នុងស្រុកខកខានមិនបានអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ហើយមានការផ្តន្ទាទោស ឬការកាត់ទោសប្រឆាំងនឹងជនដែលត្រូវបានជួញដូរ គោលការណ៍ "ពិនិត្យផ្ទៀងផ្ទាត់បញ្ជាក់ភាពត្រឹមត្រូវ" តម្រូវឱ្យរដ្ឋដោះស្រាយការខកខានបែបនេះ។ ការធានាការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មឱ្យពេញលេញ និងមានប្រសិទ្ធភាព តម្រូវឱ្យមានបទបញ្ញត្តិសម្រាប់ការលុបចោល ឬការបិទកំណត់ត្រាបទល្មើសទាំងអស់ដែលពាក់ព័ន្ធ និងការជួយសម្រាលទោសដែលបានដាក់ រួមទាំងការពិន័យ ឬទណ្ឌកម្មរដ្ឋបាលផ្សេងទៀត។ គួរមានការជួយសម្រាលបែបនេះនៅក្នុងវិធានការច្បាប់ និងវិធានការចាំបាច់ផ្សេងទៀត និងត្រូវបានគាំទ្រតាមរយៈការផ្តល់ជំនួយផ្នែកច្បាប់ ដើម្បីបញ្ចៀសការដាក់បន្ទុកមិនសមស្របលើជនដែលត្រូវបានជួញដូរ និងអាចឱ្យមានការស្តារឡើងវិញពេញលេញ។

រដ្ឋគួរតែធានាថា ការផ្តន្ទាទោសជនដែលត្រូវបានជួញដូរដែលបណ្តាលមកពីការខកខានមិនអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ឬបណ្តាលមកពីការសង្ស័យថា ជនដែលត្រូវបានជួញដូរ បានចូលរួមក្នុងបទល្មើសទាក់ទងនឹងការជួញដូរមនុស្ស នឹងមិនបណ្តាលឱ្យមានការបដិសេធលិខិតអនុញ្ញាតការស្នាក់នៅ ឬរយៈពេលស្តារនីតិសម្បទា និងពិចារណាឡើងវិញ (recovery and reflection period) ការបដិសេធសន្តិសុខសង្គម ឬអត្ថប្រយោជន៍ផ្សេងទៀត ការរឹតត្បិតលើការទទួលបានការងារ ឬការអប់រំ ឬការរឹតត្បិតលើការទទួលបានសំណងជំងឺចិត្តឡើយ។[122]

[116] ប្រភព៖ *ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ Siobhán Mullally*, ឯកសារ អ.ស.ប A/HRC/47/34, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១, [៦៥-៦៦]

# ផ្នែកទី ៦

# តាមដាន និងរាយការណ៍ អំពីការអនុវត្តន៍ន៍គោលការណ៍ មិនដាក់ទណ្ឌកម្ម

## ផ្នែកទី ៦. ការតាមដាន និងរាយការណ៍ស្តីពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម

នៅកម្រិតតំបន់ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) គឺជាស្ថាប័នសម្របសម្រួលកិច្ចខិតខំប្រឹងប្រែង ដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មនៅក្នុងច្បាប់ គោលនយោបាយ និងការអនុវត្តន៍របស់រដ្ឋសមាជិកអាស៊ាន។ SOMTC ក៏ទទួលខុសត្រូវផងដែរលើការរាយការណ៍អំពីការអនុវត្តន៍អនុសញ្ញា ACTIP មកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (AMMTC)។ ដូចមានចែងក្នុងអនុសញ្ញា ACTIP៖

**មាត្រា ២៤**

**ការតាមដាន ការពិនិត្យ និងការរាយការណ៍**

១. កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) មានភារៈទទួលខុសត្រូវជំរុញការតាមដាន ការត្រួតពិនិត្យ និងការរាយការណ៍ជាទៀងទាត់មកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (AMMTC) ស្តីពីការអនុវត្តន៍អនុសញ្ញានេះឱ្យមានប្រសិទ្ធភាព។

២. លេខាធិការដ្ឋានអាស៊ាន ត្រូវផ្តល់ការគាំទ្រដល់ការដឹកនាំ និងការសម្របសម្រួលលើការអនុវត្តន៍អនុសញ្ញានេះ និងជួយ SOMTC លើគ្រប់កិច្ចការ ដែលទាក់ទងនឹងការអនុសញ្ញានេះ។

SOMTC គួរស្វែងរកឱកាសដើម្បីលើកឡើងពីគោលការណ៍មិនដាក់ទណ្ឌកម្ម នៅក្នុងការងារតាមដាន ពិនិត្យ និងរាយការណ៍របស់ខ្លួន រួមទាំងតាមរយៈផែនការការងារពហុវិស័យអាស៊ានប្រឆាំងការជួញដូរមនុស្ស (២០២៣-២០២៨)។ AICHR អាចគាំទ្រ SOMTC ក្នុងការងារតាមដាន ពិនិត្យ និងរាយការណ៍របស់ខ្លួន ដោយធានាថាការពិចារណាអំពីសិទ្ធិមនុស្សត្រូវបានដាក់បញ្ចូលយ៉ាងមានប្រសិទ្ធភាពទៅក្នុងលក្ខណៈវិនិច្ឆ័យតាមដាន រួមទាំងទាក់ទងនឹងមាត្រា ១៤(៧) នៃអនុសញ្ញា ACTIP និងធានាថាវិធីសាស្ត្រតាមដាន អនុលោមតាមស្តង់ដារសិទ្ធិមនុស្ស។

## *[១៨] បញ្ចូលការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មទៅក្នុងយន្តការតាមដានថ្នាក់ជាតិ*

> រដ្ឋសមាជិកអាស៊ានគួរធានាថា យន្តការថ្នាក់ជាតិដើម្បីតាមដានការឆ្លើយតបក្នុងការប្រឆាំងការជួញដូរមនុស្ស រួមបញ្ចូលយ៉ាងច្បាស់នូវការតាមដានការអនុវត្តន៍មាត្រា ១៤(៧) នៃអនុសញ្ញា ACTIP។

### បង្កើតសូចនាករ ដើម្បីវាស់វែងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម

ផែនការការងារពហុវិស័យអាស៊ានប្រឆាំងការជួញដូរមនុស្ស ២០២៣-២០២៨ (ផែនការការងារ TIP Bohol ២.០) ស្នើឱ្យប្រើប្រាស់សូចនាករខាងក្រោមសម្រាប់វាស់វែងសមិទ្ធផលទាក់ទងនឹងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម៖

- ចំនួនជនរងគ្រោះដោយការជួញដូរមនុស្ស ដែលទទួលបានអត្ថប្រយោជន៍ពីគោលការណ៍មិនដាក់ទណ្ឌកម្ម
- ចំនួនជនរងគ្រោះដោយការជួញដូរមនុស្ស ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ និងត្រូវបានផ្ទេរចេញពីមន្ទីរឃុំឃាំងអន្តោប្រវេសន៍ទៅជម្រកសុវត្ថិភាព ឬកន្លែងស្នាក់នៅសមស្របផ្សេងទៀតសម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស។

រដ្ឋគួរតែបង្កើតសូចនាករបន្ថែមទៀត ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយអ្នកអនុវត្តច្បាប់ ព្រះរាជអាជ្ញា មេធាវីការពារក្តី មន្ត្រីតុលាការ ក្រុមសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត។ គួរបង្កើតសូចនាករដើម្បីវាស់វែងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋ ជាអាទិ៍ ៖

- បែងចែកធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ដើម្បីគាំទ្រការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មស្របតាមគោលការណ៍ណែនាំនេះ
- អនុម័តច្បាប់ និងគោលនយោបាយថ្មីដែលពង្រឹងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម
- តស៊ូមតិឱ្យមានការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម
- កសាងសមត្ថភាពមន្ត្រីជួរមុខ ក្នុងការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម រួមទាំងការផ្តល់ឱ្យពួកគេនូវសូចនាករថ្មីៗ ដើម្បីពិនិត្យរកជនរងគ្រោះដោយការជួញដូរមនុស្សដែលអាចពាក់ព័ន្ធក្នុងសកម្មភាពល្មើសច្បាប់
- បង្វែរអ្នកដែលត្រូវបានសន្មតជាជនរងគ្រោះ ពីបណ្តាញយុត្តិធម៌ព្រហ្មទណ្ឌទៅកាន់បណ្តាញការពារ
- កសាងសមត្ថភាពអ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម រួមទាំងតាមរយៈការដាក់បញ្ចូលគោលការណ៍មិនដាក់ទណ្ឌកម្មទៅក្នុងកម្មវិធីសិក្សាបណ្តុះបណ្តាល
- បង្កើនចំនួនសេចក្តីសម្រេចរបស់តុលាការ ឬសេចក្តីសម្រេចផ្នែករដ្ឋបាល ដែលផ្តល់គោលការណ៍មិនដាក់ទណ្ឌកម្មដល់អ្នកដែលត្រូវបានសន្មតជាជនរងគ្រោះដោយការជួញដូរមនុស្ស។

សូចនាករគួរតែមានលក្ខណៈជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន មានភាពពាក់ព័ន្ធ និងមានពេលវេលាកំណត់។ ការបង្កើតសូចនាករបែបនេះគួរផ្អែកតាមចំណេះដឹងដែលផ្តល់ដោយតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ និងជនរងគ្រោះដោយការជួញដូរមនុស្ស ដែលតម្រូវឱ្យមានការរៀបចំយន្តការជាស្រេច ដើម្បីប្រមូលធាតុចូលរបស់ពួកគេ។

## ប្រមូល ការពារ បូកសរុប និងវិភាគទិន្នន័យស្តីពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម

ស្ថាប័នប្រឆាំងការជួញដូរមនុស្សគួរកំណត់ពីរបៀបដែលទិន្នន័យបែបបរិមាណវិស័យ និងទិន្នន័យបែបគុណវិស័យអាចត្រូវបានប្រមូល ការពារ បូកសរុប និងវិភាគ ស្របតាមសិទ្ធិឯកជនភាព។ អាជ្ញាធររដ្ឋគួរតែកំណត់ពីរបៀបដែលទិន្នន័យអាចត្រូវបានប្រមូលផ្តុំក្នុងប្រព័ន្ធតែមួយ និងវិភាគ ដើម្បីកំណត់ថាតើជនរងគ្រោះដោយការជួញដូរមនុស្សត្រូវបានការពារពីការដាក់ទោសទណ្ឌឬទេ និងថាតើអ្នកដែលត្រូវបានដាក់ទោសខុស អាចទទួលបានសំណងជំងឺចិត្ត ឬទេ។ ពួកគេគួរពិចារណាពីប្រភពព័ត៌មានផ្សេងទៀតដែលអាចជួយដល់ស្ថាប័នតាមដាន ក្នុងការកំណត់ពីកម្រិតដែលគោលការណ៍មិនដាក់ទណ្ឌកម្មត្រូវបាន ឬមិនត្រូវបានអនុវត្តជាក់ស្តែងនៅក្នុងយុត្តាធិការរបស់ពួកគេ។ ការពិចារណាអាចផ្តោតលើការបញ្ចូលការមិនដាក់ទោសទណ្ឌនៅក្នុងសំណុំរឿង ដើម្បីកត់ត្រាថាតើមានការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ឬទេ នៅក្នុងករណីជាក់លាក់មួយ និងថាតើសេចក្តីសម្រេចធ្វើឡើងដោយផ្អែកលើមូលដ្ឋានផ្លូវច្បាប់បែបណា។

ក្រៅពីទិន្នន័យបែបបរិមាណវិស័យ រដ្ឋក៏គួរផ្តល់ទិន្នន័យបែបគុណវិស័យផងដែរ។ ក្នុងចំណោមព័ត៌មានបែបគុណវិស័យដែលត្រូវបានចែករំលែកសម្រាប់ជាប្រយោជន៍ដល់អ្នកអនុវត្តនៅក្នុងរដ្ឋ និងកន្លែងផ្សេងទៀត គួរតែមានព័ត៌មានស្តីពីបញ្ហាប្រឈមដែលរដ្ឋបានជួបប្រទះក្នុងការបំពេញកាតព្វកិច្ចមិនដាក់ទោសទណ្ឌរបស់ខ្លួន ព្រមទាំងការអនុវត្តន៍ល្អបំផុត និងមេរៀនដែលទទួលបានពីការរៀបចំច្បាប់។ អ្វីដែលជាការអនុវត្តន៍ល្អផងដែរនោះ គឺរដ្ឋគួរប្រមូលទិន្នន័យស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងប្រភេទនៃសកម្មភាពល្មើសច្បាប់ដែលជនរងគ្រោះបានចូលរួមក្នុងអំឡុងពេលដែលពួកគេត្រូវបានជួញដូរ។ ក្រៅពីនេះ គេអាចទទួលបានមេរៀនល្អៗ ក៏ដូចជាកំណត់រក និងដោះស្រាយបញ្ហាប្រឈម តាមរយៈការប្រមូលទិន្នន័យបែបគុណវិស័យស្តីពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ចំពោះជនរងគ្រោះដែលកំពុងស្ថិតក្រោមការជំនុំជម្រះទោស និង/ឬត្រូវបានផ្តន្ទាទោសសម្រាប់បទល្មើស។

## អនុវត្តវិធីសាស្ត្រពហុភាគី ក្នុងការតាមដានការអនុវត្តន៍

ស្ថាប័នជាតិប្រឆាំងការជួញដូរមនុស្ស និងស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ (ក្នុងករណីដែលមានស្ថាប័នទាំងនេះ) មានតួនាទីសំខាន់ក្នុងការតាមដានការគោរពតាមគោលការណ៍មិនដាក់ទណ្ឌកម្ម។ ស្ថាប័នទាំងនេះក៏ត្រូវរក្សាឱ្យមន្ត្រីរដ្ឋទទួលខុសត្រូវ ចំពោះការខកខានមិនអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មនៅក្នុងសេចក្តីសម្រេចណាមួយ ដើម្បីចាប់ខ្លួន ឃុំខ្លួន និរទេស កាត់ទោស និងផ្តន្ទាទោសជនរងគ្រោះដោយការជួញដូរមនុស្សផងដែរ។ ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិគួរតាមដានដំណើរការកំណត់អត្តសញ្ញាណ ព្រមទាំងការជំនុំជម្រះទោសជនរងគ្រោះដោយការជួញដូរមនុស្ស ដែលកំពុងត្រូវបានកាត់ទោសសម្រាប់ការចូលរួមក្នុងអំពើល្មើសច្បាប់។ ស្ថាប័នទាំងនេះគួរតែកំណត់ឱ្យដំណើរការតុលាការអនុលោមតាមបទដ្ឋាន និងស្តង់ដារសិទ្ធិមនុស្សដែលចាំបាច់ ដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម។ ស្ថាប័នទាំងនេះគួរបង្កើតប្រព័ន្ធដើម្បីឱ្យភាគីពាក់ព័ន្ធផ្សេងទៀត រួមទាំងជនរងគ្រោះ អាចផ្តល់ធាតុចូលទៅក្នុងយន្តការតាមដានថ្នាក់ជាតិ ដោយមិនភ័យខ្លាចការបំភិតបំភ័យ។

តួអង្គមិនមែនរដ្ឋ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល មានតួនាទីក្នុងការគាំទ្រស្ថាប័នប្រឆាំងការជួញដូរមនុស្ស និងស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ ដើម្បីតាមដានការអនុវត្តន៍គោលការណ៍នេះឱ្យបានជាក់ស្តែង។ ឧទាហរណ៍ ពួកគេអាចជួយដល់តួអង្គរដ្ឋក្នុងការកំណត់សូចនាករ និងដំណើរការផ្អែកលើសិទ្ធិមនុស្សសម្រាប់ការតាមដាន។ ពួកគេក៏អាចគាំទ្រដល់រដ្ឋក្នុងការដាក់បញ្ចូលទស្សនៈ និងបទពិសោធន៍របស់ជនរងគ្រោះដោយការជួញដូរមនុស្ស ទៅក្នុងការរៀបចំយន្តការតាមដានផងដែរ។ សំខាន់បំផុត តួអង្គមិនមែនរដ្ឋ និងតួអង្គសង្គមស៊ីវិល អាចនឹងអាចផ្តល់ការតាមដានដោយឯករាជ្យ និងតម្លាភាពលើការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មដោយរដ្ឋ។ ការតាមដានដោយឯករាជ្យអាចគាំទ្រដល់ការវិភាគដោយអ្នកជំនាញ និងបែបសត្យានុម័ត លើរបៀបដែលរដ្ឋបំពេញកាតព្វកិច្ចរបស់ខ្លួន។ ការយល់ដឹងដែលទទួលបានតាមរយៈការតាមដានដោយឯករាជ្យ អាចនឹងទូលំទូលាយជាងការយល់ដឹងដែលស្តែងឡើង នៅពេលរដ្ឋតាមដានសកម្មភាពរបស់ខ្លួនផ្ទាល់។

## *[១៨] របាយការណ៍អំពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម*

ការវាស់វែងការអនុវត្តន៍នឹងមិនមែនជាការងារដ៏មានតម្លៃនោះទេ ដរាបណាតែលទ្ធផលនៃអ្វីដែលបានរៀនត្រូវបានរាយការណ៍ និងចាត់វិធានការ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ។ សំខាន់បំផុត របាយការណ៍គួរនាំឱ្យមានការចាត់វិធានការ ដើម្បីដោះស្រាយចំណុចខ្វះខាតណាមួយ។ រដ្ឋត្រូវបានផ្តល់អនុសាសន៍ឲ្យមានការវិនិយោគធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានផ្សេងទៀតលើការពង្រឹងការអនុវត្តន៍គោលការណ៍មិនដាក់ទោស ដោយផ្អែកលើការយល់ដឹងដែលទទួលបានតាមរយៈការរាយការណ៍។ រដ្ឋសមាជិកអាស៊ានគួរគាំទ្រកិច្ចខិតខំប្រឹងប្រែងរាយការណ៍អំពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម នៅទូទាំងតំបន់អាស៊ាន។

### របាយការណ៍អំពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម ទៅ SOMTC

SOMTC មានភារៈទទួលខុសត្រូវជំរុញតាមដានការពិនិត្យ និងការរាយការណ៍ជាទៀងទៀតមក AMMTC ស្តីពីការអនុវត្តន៍អនុសញ្ញា ACTIP ឱ្យមានប្រសិទ្ធភាព។[117]

រដ្ឋសមាជិកអាស៊ានគួរពន្លឿនការចាត់តាំងតំណាងអនុសញ្ញា ACTIP ថ្នាក់ជាតិ ស្របតាមលក្ខខណ្ឌយោងដែលឯកភាពដោយ AMMTC នៅឆ្នាំ ២០២២។[118] តំណាងអនុសញ្ញា ACTIP ថ្នាក់ជាតិគួរត្រូវបានផ្តល់អាណត្តិ ដើម្បីលើកកម្ពស់ តាមដាន ពិនិត្យឡើងវិញ និងរាយការណ៍ទៅ SOMTC អំពីការអនុវត្តន៍មាត្រា១៤(៧) នៃគោលការណ៍មិនដាក់ទណ្ឌកម្ម។ ក្នុងសមត្ថកិច្ចនោះ តំណាងអនុសញ្ញា ACTIP ថ្នាក់ជាតិអាចប្រមូល និងបូកសរុបទិន្នន័យពីកំណត់ត្រាតុលាការ និងកំណត់ត្រាការអនុវត្តច្បាប់ដើម្បីកំណត់រកសមិទ្ធផល បញ្ហាប្រឈម និងការអនុវត្តន៍ល្អបំផុត ក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម។

---

117 អនុសញ្ញា ACTIP មាត្រា ២៤។

118 សូមមើល លក្ខខណ្ឌយោងតំណាងថ្នាក់ជាតិសម្រាប់ការអនុវត្តន៍អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (អនុសញ្ញា ACTIP) តំណាងអនុសញ្ញា ACTIP ថ្នាក់ជាតិ អនុម័តដោយកិច្ចប្រជុំ AMMTC លើកទី ១៦ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២។

រដ្ឋសមាជិកអាស៊ានគួររាយការណ៍អំពីការអនុវត្តន៍សកម្មភាព/កម្មវិធី ដើម្បីអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មមក SOMTC ស្តីពីការជួញដូរមនុស្ស (ក្រុមការងារ SOMTC ស្តីពីការជួញដូរមនុស្ស)។[119] ក្រុមការងារ SOMTC ស្តីពីការជួញដូរមនុស្ស មានកាតព្វកិច្ចទទួលរបាយការណ៍ប្រចាំឆ្នាំពីរដ្ឋសមាជិកអាស៊ានដែលចូលរួមក្នុង ផែនការការងារ TIP Bohol ២.០)

**បង្កើត និងអនុវត្តវិធីសាស្រ្តស្តង់ដារសម្រាប់ការរាយការណ៍អំពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម**

ក្រុមការងារ SOMTC ស្តីពីការជួញដូរមនុស្ស គួរបង្កើតគំរូរបាយការណ៍ស្តង់ដារស្របតាមក្របខណ្ឌតាមដាន វាយតម្លៃ រាយការណ៍ និងរៀនសូត្រ (MERL) របស់ខ្លួន។ គំរូរបាយការណ៍បែបនេះគួរបញ្ចូលការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម និងត្រូវផ្សព្វផ្សាយនៅថ្នាក់ជាតិ។ AICHR អាចផ្តល់ជំនាញផ្នែកសិទ្ធិមនុស្សក្នុងការរៀបចំ និងអភិវឌ្ឍគំរូបែបនេះ និងគាំទ្រដល់ការប្រើប្រាស់គំរូនេះ ដើម្បីពិនិត្យមើលការអនុវត្តន៍របស់រដ្ឋសមាជិកអាស៊ាន។ គួរអនុវត្តវិធីសាស្រ្តឆ្លងវិស័យសម្រាប់ការកំណត់ និងរៀបចំអនុសាសន៍ ដើម្បីកែលម្អការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មនៅថ្នាក់ជាតិ។

**បោះពុម្ពផ្សាយរបាយការណ៍ស្តីពីការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម**

កិច្ចខិតខំប្រឹងប្រែងអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម គួរតែមានតម្លាភាព។ គួរបោះពុម្ពផ្សាយលទ្ធផលនៃការតាមដាន ដើម្បីឱ្យរដ្ឋសមាជិកផ្សេងទៀត និងប្រទេសនៅក្រៅតំបន់ អាចរៀនសូត្រអំពីសមិទ្ធផល បញ្ហាប្រឈម និងការអនុវត្តន៍ល្អបំផុតរបស់រដ្ឋសមាជិកអាស៊ាន ក្នុងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម។

[119] Bohol ២.០, B.១.៤.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១ ៖ បទបញ្ញត្តិច្បាប់ក្នុងរដ្ឋសមាជិកអាស៊ានស្តីពីការមិនដាក់ទណ្ឌកម្ម

| | |
|---|---|
| **ប្រ៊ុយណេដារូសាឡឹម** (សម្រាប់តែបទល្មើសពាក់ព័ន្ធនឹងអន្តោប្រវេសន៍ និងឯកសារប៉ុណ្ណោះ) | ជនរងគ្រោះដោយការជួញដូរមនុស្ស នឹងមិនត្រូវទទួលខុសត្រូវចំពោះការកាត់ទោសបទព្រហ្មទណ្ឌទាក់ទងនឹង (ក) ការចូលមកប្រទេសប្រ៊ុយណេដារូសាឡឹមដោយខុសច្បាប់ (ខ) រយៈពេលនៃការស្នាក់នៅដោយខុសច្បាប់ក្នុងប្រទេសប្រ៊ុយណេដារូសាឡឹម ឬ (គ) ការទទួលបាន ឬការកាន់កាប់ឯកសារធ្វើដំណើរ ឬអត្តសញ្ញាណក្លែងក្លាយណាមួយដែលគាត់បានទទួល ឬត្រូវបានផ្តល់ជូនគាត់ ដើម្បីចូលមកប្រទេសប្រ៊ុយណេដារូសាឡឹម ដែលអំពើបែបនេះគឺជាផលវិបាកដោយផ្ទាល់នៃបទល្មើសជួញដូរមនុស្សដែលត្រូវបានចោទប្រកាន់ ឬត្រូវបានប្រព្រឹត្ត។ មាត្រា ៤៧ *ច្បាប់ប្រឆាំងការជួញដូរមនុស្ស* ជំពូក ២៣០។ |
| **កម្ពុជា** | គ្មានបទបញ្ញត្តិច្បាស់លាស់ស្តីពីការមិនដាក់ទោសទណ្ឌ |
| **ឥណ្ឌូនេស៊ី** | ជនរងគ្រោះដែលប្រព្រឹត្តបទល្មើសក្រោមការបង្ខិតបង្ខំ ដោយជនល្មើសនៃបទល្មើសជួញដូរមនុស្សនឹងមិនត្រូវទទួលខុសត្រូវចំពោះការចោទប្រកាន់បទព្រហ្មទណ្ឌឡើយ (មាត្រា ១៨ *ច្បាប់លេខ ២១ ស្តីពីការលុបបំបាត់បទល្មើស* ជួញដូរមនុស្ស ឆ្នាំ ២០០៧) |
| **ឡាវ** (សម្រាប់តែអន្តោប្រវេសន៍ខុសច្បាប់ និងពេស្យាចារប៉ុណ្ណោះ) | ជនរងគ្រោះដោយការជួញដូរមនុស្ស មានសិទ្ធិដូចខាងក្រោម៖ [...] ៧. ត្រូវបានលើកលែងពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ និងមិនត្រូវបានឃុំខ្លួនសម្រាប់បទល្មើសពេស្យាចារ និងអន្តោប្រវេសន៍ខុសច្បាប់។ (មាត្រា ៣៩ *ច្បាប់លេខ ២១ ស្តីពីការលុបបំបាត់បទល្មើសជួញដូរមនុស្ស* ឆ្នាំ ២០០៧) |
| **ម៉ាឡេស៊ី** (សម្រាប់តែបទល្មើសពាក់ព័ន្ធនឹងអន្តោប្រវេសន៍ និងឯកសារប៉ុណ្ណោះ) | ជនរងគ្រោះដោយការជួញដូរមនុស្ស នឹងមិនត្រូវទទួលខុសត្រូវចំពោះការកាត់ទោសបទព្រហ្មទណ្ឌ ទាក់ទងនឹង ៖<br>(ក) ការចូលទៅក្នុងប្រទេសទទួល ឬប្រទេសឆ្លងកាត់ដោយខុសច្បាប់<br>(ខ) រយៈពេលនៃការស្នាក់នៅដោយខុសច្បាប់នៅក្នុងប្រទេសទទួល ឬប្រទេសឆ្លងកាត់ ឬ (គ) ការទទួលបាន ឬការកាន់កាប់ឯកសារធ្វើដំណើរ ឬអត្តសញ្ញាណក្លែងក្លាយណាមួយដែលគាត់បានទទួល ឬត្រូវបានផ្តល់ជូនគាត់ ដើម្បីចូលមកប្រទេសទទួល ឬប្រទេសឆ្លងកាត់ ដែលអំពើបែបនេះគឺជាផលវិបាកដោយផ្ទាល់នៃអំពើជួញដូរមនុស្សដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ឬត្រូវបានប្រព្រឹត្ត។ |

| | |
|---|---|
| | ផ្នែកទី ២៥ *ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការគេចពន្ធជនទេសន្តរប្រវេសក៍* ឆ្នាំ ២០០៧ |
| **មីយ៉ាន់ម៉ា**<br>(បទល្មើសជួញដូរមនុស្ស ការចូល ឆ្លងកាត់ ការចេញដោយខុសច្បាប់ ការស្នាក់នៅដោយខុសច្បាប់ ការងារ បទល្មើសពាក់ព័ន្ធនឹងឯកសារ) | ១៦. ជនរងគ្រោះដោយការជួញដូរមនុស្ស នឹងមិនត្រូវទទួលរងចំណាត់ការ ចាប់ខ្លួនឃុំឃាំង ឬដាក់ទោសក្រោមការជួញដូរមនុស្សដែលទាក់ទងនឹងអំពើណាមួយដូចខាងក្រោម៖<br>(ក) ការចូលរួមរបស់ជនរងគ្រោះដោយការជួញដូរមនុស្ស ទោះដោយមាន ឬ គ្មានការយល់ព្រមក៏ដោយ;<br>(ខ) ការចូល ការឆ្លងកាត់ ឬការចេញដោយខុសច្បាប់ ការស្នាក់នៅដោយខុសច្បាប់ ឬការធ្វើការនៅបរទេស;<br>(គ) ការទទួលបាន ឬការកាន់កាប់កស្តុតាងធ្វើដំណើរ ឬឯកសារក្លែងក្លាយណាមួយ។<br>១៧. ប្រសិនបើស្ថានភាពមួយដែលជនរងគ្រោះដោយការជួញដូរមនុស្ស ត្រូវបានរកឃើញថា មានទោសពាក់ព័ន្ធនឹងការចូលរួមក្នុងបទល្មើសណាមួយក្រោមច្បាប់ជាធរមាន ទាក់ទងនឹងការជួញដូរមនុស្សដែលនាំឱ្យមានការចាត់វិធានការលើរូបគាត់ កងកម្លាំងប៉ូលីសអនុវត្តច្បាប់ មន្ត្រីអនុវត្តច្បាប់ និងការិយាល័យស៊ើបអង្កេតត្រូវស្វែងរកការអនុម័តពីស្ថាប័នបង្គោលតាមរយៈគណៈកម្មាធិការការងារពាក់ព័ន្ធ។<br>*ច្បាប់ស្តីពីការទប់ស្កាត់ និងបង្ក្រាបការជួញដូរមនុស្ស* (ច្បាប់លេខ ៤១/២០២២) |
| **ហ្វីលីពីន** | ជនដែលត្រូវបានជួញដូរ ត្រូវបានទទួលស្គាល់ថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស មួយ ឬច្រើន ហើយដូច្នេះ នឹងមិនត្រូវដាក់ទោសសម្រាប់អំពើល្មើសច្បាប់ដែលបានប្រព្រឹត្ត ដែលជាលទ្ធផលដោយផ្ទាល់ ឬជាឧប្បត្តិហេតុ ឬទាក់ទងនឹងការណ៍ដែលគាត់ត្រូវបានជួញដូរ ដោយផ្អែកលើសកម្មភាពនៃការជួញដូរមនុស្សដែលមានរៀបរាប់ក្នុងច្បាប់នេះ ឬបានប្រព្រឹត្តដោយស្តាប់តាមបញ្ជារបស់អ្នកជួញដូរមនុស្សទាក់ទងនឹងបញ្ហានោះ។ ក្នុងន័យនេះ ការយល់ព្រមរបស់ជនរងគ្រោះដោយការជួញដូរមនុស្ស ទៅតាមចេតនាកេងប្រវ័ញ្ចដែលមានចែងក្នុងច្បាប់នេះនឹងមិនពាក់ព័ន្ធឡើយ។<br>ជនរងគ្រោះដោយការជួញដូរមនុស្សសម្រាប់គោលបំណងពេស្យាចារ ដូចបានកំណត់ក្នុងផ្នែកទី ៤ នៃច្បាប់នេះ មិនស្ថិតក្រោមវិសាលភាពនៃមាត្រា ២០២ នៃក្រមព្រហ្មទណ្ឌដែលបានធ្វើវិសោធនកម្ម ហើយដូច្នេះ នឹងមិនត្រូវកាត់ទោសពិន័យ ឬដាក់ទណ្ឌកម្មក្រោមច្បាប់នេះឡើយ។ ផ្នែកទី ១៧ *ច្បាប់ប្រឆាំងការជួញដូរមនុស្ស* ឆ្នាំ ២០០៣ (RA No. 9208) ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ប្រឆាំងការជួញដូរមនុស្ស ឆ្នាំ ២០១២ ដែលត្រូវបានពង្រីកបន្ថែម (RA 10364) |
| **សិង្ហបុរី** | គ្មានបទបញ្ញត្តិច្បាស់លាស់ស្តីពីការមិនដាក់ទោសទណ្ឌ |

| | |
|---|---|
| **ថៃ**<br>(សម្រាប់តែបទល្មើសពាក់ព័ន្ធនឹងអន្តោប្រវេសន៍ ឯកសារ និងពេស្យាចារប៉ុណ្ណោះ) | ប្រសិនបើរដ្ឋមន្ត្រីយុត្តិធម៌មិនផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរទេ មន្ត្រីស៊ើបអង្កេត ត្រូវបានហាមឃាត់មិនឱ្យចាត់វិធានការព្រហ្មទណ្ឌប្រឆាំងនឹងជនរងគ្រោះដោយការជួញដូរមនុស្សណាមួយ ទាក់ទងនឹងបទល្មើសនៃការចូល ការចាកចេញ ឬការស្នាក់នៅក្នុងព្រះរាជាណាចក្រថៃដោយគ្មានការអនុញ្ញាត ក្រោមច្បាប់អន្តោប្រវេសន៍ ការផ្តល់ព័ត៌មានក្លែងក្លាយដល់មន្ត្រី ការក្លែងបន្លំ ឬការប្រើប្រាស់ឯកសារធ្វើដំណើរក្លែងក្លាយ ក្រោមក្រមព្រហ្មទណ្ឌ បទល្មើសក្រោមច្បាប់ស្តីពីការទប់ស្កាត់ និងបង្ក្រាបពេស្យាចារ ជាពិសេសទាក់ទងនឹងការទាក់ទង ការបញ្ចុះបញ្ចូល ការណែនាំ និងការល្បួងមនុស្សម្នាក់សម្រាប់គោលបំណងពេស្យាចារ និងការប្រមូលផ្តុំគ្នានៅក្នុងកន្លែងពេស្យាចារសម្រាប់គោលបំណងពេស្យាចារ ឬបទល្មើសនៃការណ៍ដែលជនបរទេសធ្វើការដោយគ្មានការអនុញ្ញាត ក្រោមច្បាប់ស្តីពីការងាររបស់ជនបរទេស។<br>ផ្នែកទី ៤១ *ច្បាប់ប្រឆាំងការជួញដូរមនុស្ស* B.E. 2551 (2008) |
| **វៀតណាម** | អាស្រ័យលើករណីជាក់លាក់ និងបទបញ្ញត្តិច្បាប់ពាក់ព័ន្ធ ជនរងគ្រោះដែលអំពើល្មើសច្បាប់របស់ពួកគេជាលទ្ធផលដោយផ្ទាល់នៃការជួញដូរមនុស្ស អាចនឹងមិនត្រូវទទួលទណ្ឌកម្មរដ្ឋបាល ឬការកាត់ទោសព្រហ្មទណ្ឌសម្រាប់អំពើបែបនោះ។<br>មាត្រា ៤(៥). *ច្បាប់លេខ ៥៣/២០២៤/QH១៥ ស្តីពីការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស* ត្រូវបានអនុម័តនៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០២៤ ដើម្បីចូលជាធរមាននៅថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០២៥ |

## ឧបសម្ព័ន្ធ ២ ៖ បទបញ្ញត្តិគោលនយោបាយក្នុងរដ្ឋសមាជិកអាស៊ានស្តីពីការមិនដាក់ទណ្ឌកម្ម

| | |
|---|---|
| **ប្រ៊ុយណេដារូសាឡឹម** | *ផែនការសកម្មភាពជាតិស្តីពីការជួញដូរមនុស្ស (២០២០ -២០២៤)*<br>*នីតិវិធីប្រតិបត្តិស្តង់ដារថ្នាក់ជាតិសម្រាប់ការជួញដូរមនុស្ស (២០២១)*<br>ដោយសាររកមិនឃើញឯកសារទាំងពីរនេះ យើងមិនអាចកំណត់ថាតើឯកសារទាំងនេះមានរៀបរាប់អំពីគោលការណ៍មិនដាក់ទណ្ឌកម្ម ឬក៏អត់ឡើយ។ |
| **កម្ពុជា** | *គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប (២០១៥)។*<br>*"ក្នុងដំណើរការនៃការកំណត់អត្តសញ្ញាណបឋម... ជនរងគ្រោះបរទេសដែលត្រូវបានកំណត់អត្តសញ្ញាណជាផ្លូវការ មិនត្រូវបានឃុំខ្លួន ឬចោទប្រកាន់ពីបទអន្តោប្រវេសន៍ខុសច្បាប់ និង/ឬពេស្យាចារឡើយ ហើយពួកគេត្រូវទទួលបានជម្រក និងកិច្ចការពារ ក្នុងពេលរង់ចាំដំណើរការផ្ញើមាតុភូមិនិវត្តន៍ជាផ្លូវការទៅកាន់ប្រទេសរបស់ខ្លួនវិញ។" (២.គ, ២)*<br>*សេចក្តីសម្រេចស្តីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយការជួញដូរនៃព្រះរាជាណាចក្រកម្ពុជា (NCCT, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧)*<br>*កុមាររងគ្រោះដោយការជួញដូរ គឺជាជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស។ កុមារទាំងនេះមិនត្រូវបានចាត់ទុកថាជាអ្នកប្រព្រឹត្តបទល្មើស ឬទទួលរងទណ្ឌកម្ម ឬទទួលរងការគំរាមកំហែងដោយការដាក់ទណ្ឌកម្មឧក្រិដ្ឋ សម្រាប់ការប្រព្រឹត្តបទល្មើស ដែលទាក់ទងនឹងស្ថានភាពរបស់ពួកគេជាកុមាររងគ្រោះដោយការជួញដូរឡើយ (ប្រការ ៤, ២.៣(ក))*<br>*គោលការណ៍ណែនាំស្តីពីការអនុវត្តន៍ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ការបកប្រែក្រៅផ្លូវការដោយ UNIAP ឆ្នាំ ២០០៨) គោលការណ៍ណែនាំទូទៅ*<br>*(៤) ស្រ្តីពេស្យាត្រូវចាត់ទុកជាជនរងគ្រោះដោយការជួញដូរឱ្យប្រឡូកក្នុងពេស្យាចារ។ ពេស្យាចារមិនមែនជាបទល្មើសទេ ដូច្នេះ ស្រ្តីពេស្យាជាបុគ្គលមិនត្រូវបានដាក់ទោសជាជនល្មើស ក្រោមច្បាប់ថ្មីទេ។*<br>*គោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ២០០៩)*<br>*"យើងដឹងថាជនរងគ្រោះដោយការជួញដូរមនុស្ស គឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មឆ្លងដែន និងមិនមែនជាជនអន្តោប្រវេសន៍ខុសច្បាប់ឡើយ ទោះបីជារឿងរ៉ាវរបស់ពួក* |

| | |
|---|---|
| | *គេអាចស្រដៀងគ្នានឹងជនអន្តោប្រវេសន៍ខុសច្បាប់ក៏ដោយ។ ពួកគេមិនមែនជាឧក្រិដ្ឋជនទេ ប៉ុន្តែពួកគេជាបុគ្គលដែលមានសិទ្ធិទទួលបានការគោរព យុត្តិធម៌ និងសិទ្ធិសម្រេចចិត្តដោយខ្លួនឯង ដើម្បីគូសវាសអនាគតរបស់ពួកគេដោយគ្មានការរើសអើង។" (ទំព័រ ១)* |
| **ឥណ្ឌូនេស៊ី** | *ផែនការសកម្មភាពជាតិដើម្បីលុបបំបាត់ការជួញដូរមនុស្ស* (២០១៥ – ២០១៩) មិនបានរៀបរាប់អំពីគោលការណ៍មិនដាក់ទណ្ឌកម្មឡើយ។<br><br>*ផែនការសកម្មភាពជាតិសម្រាប់ការលុបបំបាត់ការជួញដូរមនុស្ស* (២០២០ – ២០២៤) មិនបានរៀបរាប់អំពីគោលការណ៍មិនដាក់ទណ្ឌកម្មឡើយ។ |
| **ឡាវ** | *គោលការណ៍ណែនាំសម្រាប់ការការពារ ជំនួយ និងការបញ្ជូនជនរងគ្រោះដោយការជួញដូរមនុស្ស* (ក្រសួងសន្តិសុខសាធារណៈ លេខាធិការដ្ឋានគណៈកម្មាធិការថ្នាក់ជាតិស្តីពីការជួញដូរមនុស្ស ២០២០) មិនបានរៀបរាប់អំពីគោលការណ៍មិនដាក់ទណ្ឌកម្មឡើយ។ |
| **ម៉ាឡេស៊ី** | *ផែនការសកម្មភាពជាតិស្តីពីការប្រឆាំងការជួញដូរមនុស្ស ២០២១-២០២៥* មិនបានរៀបរាប់អំពីគោលការណ៍មិនដាក់ទណ្ឌកម្មឡើយ។ |
| **មីយ៉ាន់ម៉ា** | *ផែនការសកម្មភាពជាតិប្រាំឆ្នាំលើកទីបួនរបស់មីយ៉ាន់ម៉ា ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស* (២០២២-២០២៦) មិនបានរៀបរាប់អំពីគោលការណ៍មិនដាក់ទណ្ឌកម្មឡើយ។<br><br>ទោះយ៉ាងណាក៏ដោយ ក្នុងការអនុវត្តន៍ផែនការសកម្មភាពឆ្នាំ ២០២៤ មានការអនុវត្តន៍កម្មវិធីកសាងការយល់ដឹងស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្ម។ ទន្ទឹមនឹងនេះ សកម្មភាពផ្សេងៗស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្ម នឹងត្រូវបានបញ្ចូលទៅក្នុងផែនការការងារឆ្នាំ ២០២៥ និង ២០២៦។ |
| **ហ្វីលីពីន** | *គោលការណ៍ណែនាំស្តីពីការការពារសិទ្ធិស្ត្រីដែលត្រូវបានជួញដូរ* (គណៈកម្មការស្ត្រីហ្វីលីពីន ក្រោមការសម្របសម្រួលជាមួយក្រុមប្រឹក្សាអន្តរទីភ្នាក់ងារប្រឆាំងការជួញដូរមនុស្ស (IACAT) ឆ្នាំ ២០១៣)<br><br>"ស្ត្រីដែលត្រូវបានជួញដូរ គួរត្រូវបានចាត់ទុកជាជនរងគ្រោះ មិនមែនជាអ្នកល្មើសទេ"(៥.៣.៨.១.១.)<br><br>*គោលការណ៍ណែនាំស្តីពីប្រព័ន្ធបញ្ជូនដែលពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស* ដែលត្រូវបានអនុម័ត ដោយក្រុមប្រឹក្សាអន្តរទីភ្នាក់ងារប្រឆាំងការជួញដូរមនុស្ស (IACAT) នៅថ្ងៃទី ២ ខែមីនា ឆ្នាំ ២០១៧ តាមរយៈសេចក្តីសម្រេចលេខ ០០៦ ឆ្នាំ ២០១៧ ចែងថា ជនដែលត្រូវបានជួញដូរ មានសិទ្ធិ៖ |

| | |
|---|---|
| | ‘មិនត្រូវបានដាក់ទោសព្រហ្មទណ្ឌ (ឬចោទប្រកាន់ ឬដាក់ទណ្ឌកម្ម) សម្រាប់ការចូលរួមរបស់ពួកគេក្នុងសកម្មភាពល្មើសច្បាប់ ក្នុងអំឡុងពេលដែលពួកគេត្រូវបានជួញដូរ។” |
| **សិង្ហបុរី** | *វិធីសាស្ត្រថ្នាក់ជាតិប្រឆាំងការជួញដូរមនុស្ស ២០១៦ – ២០២៦* (ក្រុមការងារអន្តរទីភ្នាក់ងារសិង្ហបុរីទទួលបន្ទុកការជួញដូរមនុស្ស)<br>ទាក់ទងនឹងជនរងគ្រោះដោយការជួញដូរ៖ ‘ពួកគេមិនគួរត្រូវបានកាត់ទោសសម្រាប់ការរំលោភច្បាប់ការងារ និង/ឬច្បាប់អន្តោប្រវេសន៍ ឬសម្រាប់សកម្មភាពណាមួយដែលពួកគេបានចូលរួម ដែលជាផលវិបាកដោយផ្ទាល់នៃការណ៍ដែលពួកគេត្រូវបានជួញដូរឡើយ។” |
| **ថៃ** | *ផែនការសកម្មភាពសម្រាប់ការទប់ស្កាត់ និងដោះស្រាយបញ្ហាជួញដូរមនុស្ស ដើម្បីគាំទ្រយុទ្ធសាស្ត្រសន្តិសុខជាតិ* (២០១៨ – ២០៣៧) របស់ក្រសួងសុខុមាលភាព និងអភិវឌ្ឍន៍សង្គម (MSDHS) មិនបានរៀបរាប់អំពីគោលការណ៍មិនដាក់ទណ្ឌកម្មឡើយ។ |
| **វៀតណាម** | *បទដ្ឋានអប្បបរមាក្នុងការផ្តល់សេវាដល់ជនរងគ្រោះដោយការជួញដូរមនុស្ស* (ក្រសួងការងារ និងសង្គមកិច្ច ឆ្នាំ ២០១១) និង *ផែនការសកម្មភាពជាតិប្រឆាំងការជួញដូរមនុស្សឆ្នាំ ២០១៦-២០២០* និងកម្មវិធីជាតិប្រឆាំងការជួញដូរមនុស្ស *ឆ្នាំ ២០២១-២០២៥ ជាមួយនឹងចក្ខុវិស័យឆ្ពោះទៅកឆ្នាំ ២០៣០* មិនបានរៀបរាប់អំពីគោលការណ៍មិនដាក់ទណ្ឌកម្មឡើយ។ |

## ឧបសម្ព័ន្ធ ៣ ៖ ឧទាហរណ៍នៃកិច្ចព្រមព្រៀងទ្វេភាគី និងកិច្ចព្រមព្រៀងអនុតំបន់ដែលពាក់ព័ន្ធនឹងការមិនដាក់ទោសទណ្ឌ

| កិច្ចព្រមព្រៀង | ភាគី | បទបញ្ញត្តិស្តីពីការមិនដាក់ទោសទណ្ឌ |
|---|---|---|
| អនុស្សរណៈនៃការយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់ទន្លេមេគង្គ (COMMIT) (២០០៤) | កម្ពុជា<br>ចិន<br>ឡាវ<br>មីយ៉ាន់ម៉ា<br>ថៃ<br>វៀតណាម | ៣. ក្នុងផ្នែកនៃការការពារ ការស្តារនីតិសម្បទា និងសមាហរណកម្ម៖<br>១៦. ធានាថា ជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះ ដោយការជួញដូរមនុស្សមិនត្រូវបានឃុំខ្លួនក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ ដោយអាជ្ញាធរអនុវត្តច្បាប់។ |
| កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល កម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីសម្រាប់ការលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងការជួយជនរងគ្រោះដោយការជួញដូរមនុស្ស (២០០៥) | កម្ពុជា<br>វៀតណាម | មាត្រា ២. ភាគីទាំងពីរទទួលស្គាល់ថាឧទាហរណ៍នៃគោលបំណងជួញដូរស្ត្រី និងកុមាររួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម ដូចខាងក្រោម៖<br>១០. ការប្រើប្រាស់ក្នុងសកម្មភាពបទល្មើស។<br>មាត្រា ៥. ជនដែលត្រូវបានជួញដូរត្រូវចាត់ទុកជាជនរងគ្រោះ និងមិនមែនជាអ្នករំលោភ ឬអ្នកល្មើសច្បាប់អន្តោប្រវេសន៍ទេ។ ដូច្នេះ ៖<br>១. ស្ត្រី និងកុមារដែលត្រូវបានជួញដូរ នឹងមិនត្រូវបានចោទប្រកាន់ និងកាត់ទោសសម្រាប់អន្តោប្រវេសន៍ខុសច្បាប់ ឬពេស្យាចារទេ<br>២. ស្ត្រី និងកុមារដែលត្រូវបានជួញដូរ នឹងមិនត្រូវបានឃុំខ្លួនក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ ក្នុងពេលរង់ចាំដំណើរការធ្វើមាតុភូមិនិវត្តន៍ ជាផ្លូវការទៅកាន់ប្រទេសរបស់ខ្លួនវិញទេ។ ពួកគេត្រូវតែស្ថិតក្រោមការថែទាំ ដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទាំងពីរ។ ត្រូវផ្តល់ជម្រកសុវត្ថិភាពដល់ជនរងគ្រោះ ស្របតាមបទបញ្ញត្តិច្បាប់របស់រដ្ឋនីមួយៗ។ |

| | | |
|---|---|---|
| កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី សម្រាប់ការលុបបំបាត់ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ និងការជួយជនរងគ្រោះដោយការជួញដូរមនុស្ស (២០០៨) | ថៃ<br>វៀតណាម | មាត្រា ៦. "ស្ត្រី និងកុមារដែលត្រូវបានជួញដូរត្រូវចាត់ទុកជាជនរងគ្រោះ មិនមែនជាអ្នករំលោភ ឬអ្នកល្មើសច្បាប់អន្តោប្រវេសន៍ទេ។ ដូច្នេះ ៖<br>១.ស្ត្រី និងកុមារដែលត្រូវបានជួញដូរ នឹងមិនត្រូវបានកាត់ទោស សម្រាប់ការចូលក្នុងប្រទេសដោយខុសច្បាប់<br>២. ស្ត្រី និងកុមារដែលត្រូវបានជួញដូរ នឹងមិនត្រូវបានឃុំខ្លួនក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ ក្នុងពេលរង់ចាំការធ្វើមាតុភូមិនិវត្តន៍ ប៉ុន្តែត្រូវស្ថិតក្រោមការថែទាំ ដោយក្រសួងសន្តិសុខសាធារណៈ (វៀតណាម) ឬក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខប្រជាជន (ថៃ) និងត្រូវផ្តល់ជម្រកសុវត្ថិភាព និងការការពារដល់ជនរងគ្រោះអនុលោមតាមគោលនយោបាយរបស់ប្រទេសនីមួយៗ"។ |
| អនុស្សរណៈនៃការយោគយល់រវាងព្រះរាជាណាចក្រថៃ និងរដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា ស្តីពីកិច្ចសហប្រតិបត្តិការ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (២០០៩) | មីយ៉ាន់ម៉ា<br>ថៃ | មាត្រា ៨.<br>ជនរងគ្រោះដោយការជួញដូរមនុស្ស ត្រូវចាត់ទុកជាជនរងគ្រោះនៃបទល្មើស មិនមែនជាអ្នករំលោភ ឬអ្នកល្មើសច្បាប់អន្តោប្រវេសន៍ទេ។ ដូច្នេះ ៖<br>(ក) ជនរងគ្រោះដោយការជួញដូរមនុស្ស មិនគួរត្រូវបានកាត់ទោស ដោយភាគីណាមួយសម្រាប់ការចូល ឬចេញពីប្រទេសដោយខុសច្បាប់ និងសម្រាប់បទល្មើសផ្សេងទៀតដែលកើតឡើង ដោយផ្ទាល់ពីសកម្មភាពជួញដូរមនុស្ស<br>(ខ) ជនរងគ្រោះដោយការជួញដូរមនុស្ស នឹងមិនត្រូវបានឃុំខ្លួនក្នុងមន្ទីរអនុវត្តន៍ច្បាប់ ឬមន្ទីរឃុំឃាំងអន្តោប្រវេសន៍ណាមួយ ក្នុងពេលរង់ចាំការធ្វើមាតុភូមិនិវត្តន៍ឡើយ ប៉ុន្តែត្រូវដាក់ក្រោមការថែទាំ ដោយនាយកដ្ឋានសុខុមាលភាពសង្គម (មីយ៉ាន់ម៉ា) នាយកដ្ឋានអភិវឌ្ឍន៍សង្គម និងសុខុមាលភាព (ថៃ) ឬជម្រកសុវត្ថិភាពបណ្តោះអាសន្ន។ ត្រូវផ្តល់ជម្រកសុវត្ថិភាព និងការការពារ |

| | | |
|---|---|---|
| | | ដល់ជនរងគ្រោះដោយការជួញដូរមនុស្ស អនុលោមតាមច្បាប់ និងគោលនយោបាយរបស់ភាគីនីមួយៗ។ |
| អនុស្សរណៈនៃការយោគយល់រវាងរដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការលើការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (២០០៩) | មីយ៉ាន់ម៉ា<br>ចិន | មាត្រា ៥៖ ភាគីទាំងពីរត្រូវចាត់វិធានការសមស្រប ដើម្បីការពារជនរងគ្រោះ ដោយការជួញដូរមនុស្ស ដែលត្រូវបានចាត់ទុកជាជនរងគ្រោះ នៃអាកប្បកិរិយាឧក្រិដ្ឋ ជាជាងជនល្មើស ឬអ្នកដែលសង្ស័យថាជាជនល្មើស។ ដូច្នេះ ៖<br>១. ភាគីណាមួយ នឹងមិនដាក់ទោសទណ្ឌជនរងគ្រោះសម្រាប់ការចូល ឬចេញដោយខុសច្បាប់ពីទឹកដីរបស់ខ្លួន ឬបទល្មើសផ្សេងទៀតដែលកើតឡើងដោយផ្ទាល់ដែលបណ្តាលមកពីសកម្មភាពជួញដូរមនុស្ស<br>២. អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះដោយការជួញដូរមនុស្ស នឹងមិនត្រូវបាននិរទេសដោយការធ្វើមាតុភូមិនិវត្តន៍ជាផ្លូវការឱ្យបានទាន់ពេលវេលាឡើយ។ |
| កិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការការពារជនរងគ្រោះដោយការជួញដូរមនុស្ស (២០១០) | ឡាវ<br>វៀតណាម | មាត្រា ៤(១)(ខ) "ភាគីទាំងពីរប្តេជ្ញាចាត់វិធានការសមស្រប ដើម្បីការពារជនរងគ្រោះ។ អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទាំងពីរ ត្រូវធានាសុវត្ថិភាពរបស់ជនរងគ្រោះដូចខាងក្រោម៖<br>ត្រូវបានប្រព្រឹត្តចំពោះដោយស្មើភាព និងទទួលបានការគាំទ្រផ្លូវច្បាប់ មិនត្រូវបានឃុំខ្លួន និង/ឬដាក់ទោសសម្រាប់ការធ្វើអន្តោប្រវេសន៍ខុសច្បាប់ ឬបទល្មើសរដ្ឋបាលដែលពាក់ព័ន្ធផ្សេងទៀតទេ។" |
| កិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការលើការទប់ស្កាត់ និងប្រយុទ្ធ | វៀតណាម<br>ចិន | មាត្រា ២៖<br>ភាគីទាំងពីរត្រូវចាត់វិធានការសមស្រប ដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួនរបស់ជនរងគ្រោះ។<br>ក. ភាគីទាំងពីរ នឹងមិនដាក់ទោសទណ្ឌលើទង្វើរបស់ជនរងគ្រោះដែលចូល (ចេញ) ដោយខុសច្បាប់ទៅក្នុង |

| | | |
|---|---|---|
| ប្រឆាំងការជួញដូរមនុស្ស (២០១០) | | ទឹកដីរបស់ខ្លួន ឬអំពើល្មើសច្បាប់ផ្សេងទៀត ដែលជាលទ្ធផលដោយផ្ទាល់នៃការណ៍ដែលពួកគេត្រូវបានជួញដូរ។ |
| អនុស្សរណៈនៃការយោគយល់ រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃស្ដីពីកិច្ចសហប្រតិបត្តិការទ្វេភាគីសម្រាប់ការលុបបំបាត់ការជួញដូរមនុស្ស និងការការពារជនរងគ្រោះដោយការជួញដូរមនុស្ស (២០១៤) | កម្ពុជា<br>ថៃ | ជំពូក ៤ មាត្រា ៦៖ ជនដែលត្រូវបានជួញដូរ ត្រូវចាត់ទុកជាជនរងគ្រោះ មិនមែនជាអ្នករំលោភ ឬអ្នកល្មើសច្បាប់អន្តោប្រវេសន៍ទេ។ ដូច្នេះ ៖<br>(ក) អ្នកដែលត្រូវបានជួញដូរ នឹងមិនត្រូវបានកាត់ទោសសម្រាប់ការចូលប្រទេស ដោយខុសច្បាប់<br>(ខ) អ្នកដែលត្រូវបានជួញដូរ នឹងមិនត្រូវបានឃុំខ្លួនក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ ក្នុងពេលរង់ចាំដំណើរការធ្វើមាតុភូមិនិវត្តន៍ជាផ្លូវការទៅកាន់ប្រទេសរបស់ខ្លួនវិញទេ ប៉ុន្តែត្រូវដាក់ក្រោមការថែទាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (កម្ពុជា) ឬនាយកដ្ឋានអភិវឌ្ឍន៍សង្គម និងសុខុមាលភាព (ថៃ) ហើយត្រូវផ្ដល់ជម្រកសុវត្ថិភាព និងការការពារដល់ជនរងគ្រោះ អនុលោមតាមគោលនយោបាយរបស់រដ្ឋនីមួយៗ។ |
| កិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្ដីពីកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (២០១៤) | ឡាវ<br>ចិន | មាត្រា ៤៖ ភាគីទាំងពីរត្រូវចាត់វិធានការសមស្រប ដើម្បីការពារជនរងគ្រោះដោយការជួញដូរមនុស្ស ក្នុងផ្នែកដូចខាងក្រោម ៖<br>១. ភាគីណាមួយ នឹងមិនដាក់ទោសទណ្ឌជនរងគ្រោះសម្រាប់ការចូលដោយខុសច្បាប់ទៅ ឬចេញពីទឹកដីរបស់ខ្លួន ឬបទល្មើសផ្សេងទៀតដែលកើតឡើងដោយផ្ទាល់ពីសកម្មភាពជួញដូរមនុស្ស។ |
| គោលការណ៍ណែនាំ COMMIT ស្ដីពីយន្តការកំណត់អត្តសញ្ញាណ និងបញ្ជូនជនរងគ្រោះ៖ គោលការណ៍ណែនាំរួមសម្រាប់មហាអនុតំបន់ទន្លេមេគង្គ (២០១៦) | កម្ពុជា<br>ចិន<br>ឡាវ<br>មីយ៉ាន់ម៉ា<br>ថៃ<br>វៀតណាម | "ទោះក្នុងកាលៈទេសៈណាក៏ដោយ អ្នកដែលត្រូវបានជួញដូរ មិនត្រូវបានកាត់ទោសសម្រាប់ការរំលោភច្បាប់អន្តោប្រវេសន៍ ឬសម្រាប់សកម្មភាពដែលពួកគេពាក់ព័ន្ធដែលជាលទ្ធផលដោយផ្ទាល់នៃស្ថានភាពរបស់ពួកគេជាជនដែលត្រូវបានជួញដូរ ឬត្រូវបានឃុំខ្លួនក្នុងមន្ទីរឃុំឃាំងឡើយ"។ |

## ឧបសម្ព័ន្ធ ៤ ៖ គោលការណ៍ណែនាំស្តីពីការអនុវត្តល្អបំផុតជាអន្តរជាតិ

គោលការណ៍ណែនាំខាងក្រោមត្រូវបានដកស្រង់ចេញពីប្រភពដើមផ្ទាល់។

### អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ[120]

៥៣. រដ្ឋគួរផ្តល់សច្ចាប័ន និងអនុវត្តរាល់លិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធដែលហាមប្រាមការជួញដូរមនុស្ស និងចែងពីសិទ្ធិមិនត្រូវបានគេដាក់ទោស រួមទាំងពិធីសារ ILO សម្រាប់អនុសញ្ញាស្តីពីការងារដោយបង្ខំ ឆ្នាំ ១៩៣០ (អនុសញ្ញាលេខ ២៩)។

៥៤. រដ្ឋគួរអនុវត្តរាល់វិធានការសមស្របផ្នែកច្បាប់ គោលនយោបាយ រដ្ឋបាល និងវិធានការផ្សេងទៀតដើម្បីធានាការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព នូវគោលការណ៍មិនដាក់ទណ្ឌកម្មជនរងគ្រោះដោយការជួញដូរមនុស្ស និងគួរៈ

(ក) បញ្ចូលបទបញ្ញត្តិជាក់លាក់មួយទៅក្នុងច្បាប់ជាតិ ដើម្បីផ្តល់ការមិនដាក់ទោសទណ្ឌជនរងគ្រោះដោយការជួញដូរមនុស្ស

(ខ) អនុម័តគោលការណ៍ណែនាំស្តីពីការកាត់ទោស ដើម្បីសម្រួលដល់ការអនុវត្តន៍គោលការណ៍មិនដាក់ទោសទណ្ឌដែលមានសង្គតិភាព និងជាប្រព័ន្ធ ក្នុងគ្រប់ករណីជួញដូរមនុស្សទាំងអស់

(គ) អនុម័តបញ្ជីបើកទូលាយ និងមិនរៀបរាប់អស់សេចក្តីនៃបទល្មើសដែលពាក់ព័ន្ធជាញឹកញាប់ទៅនឹងការជួញដូរមនុស្សដែលគួរត្រូវបានផ្សព្វផ្សាយ និងបញ្ចូលក្នុងការបណ្តុះបណ្តាល និងក្នុងគោលការណ៍ណែនាំដែលបានបោះពុម្ពផ្សាយសម្រាប់អាជ្ញាធរអនុវត្តន៍ច្បាប់ទាំងអស់ និងមនុស្សទាំងអស់ដែលទំនងជាមានទំនាក់ទំនងជាមួយជនដែលត្រូវបានជួញដូរ។

៥៥. គោលការណ៍មិនដាក់ទណ្ឌកម្ម គួរត្រូវបានអនុវត្តៈ

(ក) ដោយអាជ្ញាធរក្នុងស្រុកទាំងអស់ដែលពាក់ព័ន្ធ រួមទាំងនគរបាល មន្ត្រីអន្តោប្រវេសន៍ និងមន្ត្រីព្រំដែន អធិការការងារ និងទីភ្នាក់ងារអនុវត្តច្បាប់ ឬមន្ត្រីផ្សេងទៀត ហើយពួកគេគួរទទួលការបណ្តុះបណ្តាល និងមានគុណសម្បត្តិគ្រប់គ្រាន់ ក្នុងការកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស។

[120] អនុសាសន៍ទាំងនេះត្រូវបានដកស្រង់ពីរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ Siobhán Mullally ស្តីពី *ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម*, ឯកសារ អ.ស.ប A/HRC/៤៧/៣៤ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១។ អនុសាសន៍ទាំងនេះក៏ត្រូវបានបញ្ចូលទៅក្នុងគោលការណ៍ណែនាំនេះផងដែរ។

(ខ) ភ្លាមៗ នៅពេលដែលមានមូលដ្ឋានសមហេតុផលអាចឱ្យជឿបានថា មនុស្សម្នាក់ត្រូវបានជួញដូរ ឬភ្លាមៗ នៅពេលដែលជនដែលត្រូវបានជួញដូរ ឬតំណាងស្របច្បាប់របស់ពួកគេ លើកឡើងពីវិធានការការពារក្នុងករណីជួញដូរមនុស្ស ដើម្បីឱ្យជនដែលត្រូវបានជួញដូរទទួលបានការការពារប្រកបដោយប្រសិទ្ធភាព និងពេញលេញ។

៥៦. រដ្ឋមានកាតព្វកិច្ចធានាការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស ឱ្យបានលឿនរហ័ស និងប្រកបដោយប្រសិទ្ធភាព។ គួរផ្តល់ជំនួយផ្លូវច្បាប់ក្នុងដំណើរការកំណត់អត្តសញ្ញាណទាំងមូល ដើម្បីធានាការកំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបានឆាប់ ការបញ្ជូនទៅរកជំនួយ និងការការពារ និងការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មប្រកបដោយប្រសិទ្ធភាព។

៥៧. រដ្ឋត្រូវធានាថា គោលការណ៍មិនដាក់ទណ្ឌកម្ម ត្រូវបានអនុវត្តចំពោះ៖

(ក) គ្រប់ទម្រង់នៃការជួញដូរមនុស្ស រួមទាំងក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ កេងប្រវ័ញ្ចការងារ និងបង្ខំឱ្យប្រព្រឹត្តបទល្មើស ក៏ដូចជាអនុវត្តទាំងចំពោះករណីនៃការជួញដូរជាអន្តរជាតិ និងករណីនៃការជួញដូរក្នុងស្រុក។

(ខ) សកម្មភាពល្មើសច្បាប់ណាមួយដែលធ្វើឡើងដោយជនដែលត្រូវបានជួញដូរ ដែលជាផលវិបាកដោយផ្ទាល់នៃស្ថានភាពដែលពួកគេត្រូវបានជួញដូរ ដោយមិនគិតពីស្ថានទម្ងន់ ឬភាពធ្ងន់ធ្ងរនៃបទល្មើសដែលបានប្រព្រឹត្ត។

(គ) បទល្មើសព្រហ្មទណ្ឌ បទល្មើសរដ្ឋប្បវេណី បទល្មើសរដ្ឋបាល និងបទល្មើសអន្តោប្រវេសន៍ ក៏ដូចជាទម្រង់ផ្សេងទៀតនៃការដាក់ទោសទណ្ឌ ដូចជា ការដកហូតសញ្ជាតិតាមទំនើងចិត្ត ការបដិសេធជំនួយកុងស៊ុល ឬការធ្វើមាតុភូមិនិវត្តន៍ ការដកចេញពីស្ថានភាពជាជនភៀសខ្លួន ឬទម្រង់ផ្សេងទៀតនៃការការពារពីអន្តរជាតិ និងការបំបែកចេញពីគ្រួសារ។

(ឃ) ស្ថានភាពណាមួយនៃការដកហូតសេរីភាព រួមទាំងការឃុំខ្លួនក្រោមបទល្មើសអន្តោប្រវេសន៍ និងការឃុំខ្លួនរង់ចាំនីតិវិធីបណ្តេញចេញ ផ្ទេរ ឬបញ្ជូនត្រឡប់ទៅវិញ។

៥៨. ដោយទទួលស្គាល់ថាការជួញដូរមនុស្សគឺជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម មិនគួរផ្អែកលើការកំណត់អត្តសញ្ញាណជនរងគ្រោះជាផ្លូវការ ឬការកាត់ទោសអ្នកជួញដូរមនុស្សដែលរងការចោទប្រកាន់ឡើយ។ ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្ម មិនត្រូវផ្អែកលើកិច្ចសហប្រតិបត្តិការរបស់ជនរងគ្រោះក្នុងនីតិវិធីព្រហ្មទណ្ឌឡើយ។

៥៩. ដើម្បីធានាការអនុវត្តន៍តាមគោលការណ៍មិនដាក់ទណ្ឌកម្ម ត្រូវរំដោះជនរងគ្រោះដោយការជួញដូរមនុស្សទាំងអស់ដែលត្រូវបានសន្មត ឬកំណត់អត្តសញ្ញាណ ចេញពីការឃុំខ្លួន ឬស្ថានភាពដកហូតសេរីភាពឱ្យបានទាន់ពេលវេលា ហើយផ្តល់ជំនួយ និងការការពារដល់ពួកគេ។

៦០. គោលការណ៍មិនដាក់ទណ្ឌកម្ម ត្រូវតែអនុវត្តដោយគ្មានការរើសអើងចំពោះជនរងគ្រោះដោយការជួញដូរមនុស្សទាំងអស់ រួមទាំងជនរងគ្រោះដោយការជួញដូរមនុស្សដែលស្វែងរកសិទ្ធិជ្រកកោន ឬទម្រង់ផ្សេងៗនៃការការពារពីអន្តរជាតិ។

៦១. រដ្ឋត្រូវធានាការការពារស្មើភាពគ្នាក្រោមច្បាប់ និងសមភាពចំពោះមុខច្បាប់ ក្នុងគ្រប់វិធានការប្រឆាំងការជួញដូរមនុស្សទាំងអស់ រួមទាំងការធានាការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវគោលការណ៍មិនដាក់ទណ្ឌកម្មសម្រាប់ជនមានពិការភាពដែលត្រូវបានជួញដូរ។ រដ្ឋត្រូវតែចាត់វាល់វិធានការសមស្របទាំងអស់ ដើម្បីធានាការមិនរើសអើងដោយសារពិការភាព និងធានាការផ្ដល់ផាសុកសមរម្យ រួមទាំងការផ្ដល់ការសម្របសម្រួលផ្នែកនីតិវិធី និងការសម្របសម្រួលដែលសមស្របតាមអាយុ ដើម្បីសម្រួលដល់ការទទួលបានយុត្តិធម៌ប្រកបដោយប្រសិទ្ធភាព និងការចូលរួមរបស់ជនមានពិការភាពដែលត្រូវបានជួញដូរ នៅក្នុងនីតិវិធីផ្លូវច្បាប់ទាំងអស់ រួមទាំងនីតិវិធីកំណត់អត្តសញ្ញាណ និងនៅដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលដំបូងៗផ្សេងទៀត។

៦២. រដ្ឋត្រូវតែធានាថា ជនរងគ្រោះជាកុមារមិនត្រូវបានដាក់ទោសសម្រាប់អំពើល្មើសច្បាប់ដែលទាក់ទងនឹងការណ៍ដែលពួកគេត្រូវបានជួញដូរ។ ក្នុងករណីដែលមិនច្បាស់ពីអាយុរបស់ជនរងគ្រោះ និងមានហេតុផលអាចជឿបានថាជនរងគ្រោះគឺជាកុមារ ត្រូវសន្មតជនរងគ្រោះថាជាកុមារ និងត្រូវផ្ដល់វិធានការការពារពិសេសរង់ចាំការផ្ទៀងផ្ទាត់អាយុរបស់គាត់។ នៅពេលដែលមានការកំណត់ទំនាក់ទំនងរវាងបទល្មើសដែលបានប្រព្រឹត្ត និងស្ថានភាពរបស់កុមារក្នុងនាមជាជនរងគ្រោះដោយការជួញដូរមនុស្ស ដែលត្រូវបានសន្មត ឬកំណត់អត្តសញ្ញាណ ត្រូវទទួលយកទំនាក់ទំនងនោះថាចាំបាច់ និងមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបញ្ឈប់ដំណើរការនីតិវិធី ឬលុបចោលការផ្ដន្ទាទោសដែលបានចេញរួចហើយ ក៏ដូចជាដោះលែងកុមារចេញពីកន្លែងឃុំឃាំងភ្លាមៗ។ ចំពោះកុមារ ដោយសារតែគ្មានមធ្យោបាយចាំបាច់ ដើម្បីកំណត់ស្ថានភាពរបស់ពួកគេជាជនរងគ្រោះដោយការជួញដូរមនុស្ស មិនអាចអនុវត្តការធ្វើតេស្តលើការបង្ខាប់បញ្ជាបានឡើយ។

៦៣. កុមារដែលត្រូវបានឃុំខ្លួនដោយសារការពាក់ព័ន្ធជាមួយក្រុមប្រដាប់អាវុធ រួមទាំងក្រុមភេរវកម្មដែលត្រូវបានកំណត់ គួរត្រូវបានទទួលស្គាល់ថាជាជនរងគ្រោះនៃការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌។ គួរផ្ដោតអាទិភាពលើការស្ដារឡើងវិញ ការធ្វើសមាហរណកម្ម និងការរស់នៅជួបជុំគ្រួសារឡើងវិញ មិនមែនការដាក់ទោសទណ្ឌនោះទេ។ ដោយរំលឹកឡើងវិញនូវសេចក្ដីសម្រេចលេខ ២៣៨៨ (២០១៧) របស់ក្រុមប្រឹក្សាសន្តិសុខ រដ្ឋទាំងអស់គួរចៀសវាងអនុវត្តការឃុំខ្លួនខាងរដ្ឋបាលចំពោះកុមារដែលជាជនរងគ្រោះដោយការជួញដូរមនុស្ស រួមទាំងកុមារដែលពាក់ព័ន្ធ ឬសង្ស័យថាពាក់ព័ន្ធជាមួយក្រុមប្រដាប់អាវុធមិនមែនរដ្ឋទាំងអស់ រួមទាំងក្រុមដែលប្រព្រឹត្តអំពើភេរវកម្ម។ គួរអនុវត្តនីតិវិធីប្រតិបត្តិការស្តង់ដារ ដើម្បីធានាការប្រគល់ទាន់ពេលវេលានូវកុមារដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ទៅកាន់ភ្នាក់ងារការពារកុមារជាជនស៊ីវិល។

៦៤. ដើម្បីធានាការអនុលោមតាមគោលការណ៍មិនដាក់ទណ្ឌកម្មក្នុងការចេញសេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញារដ្ឋត្រូវធានាថា៖

(ក) ព្រះរាជអាជ្ញាស្ថិតក្រោមកាតព្វកិច្ចបញ្ឈប់នីតិវិធីប្រឆាំងនឹងជនដែលត្រូវបានជួញដូរ សម្រាប់បទល្មើសទាំងអស់ដែលបានប្រព្រឹត្ត ដែលជាលទ្ធផលដោយផ្ទាល់នៃស្ថានភាពរបស់ពួកគេក្នុងនាមជាជនរងគ្រោះដោយការជួញដូរមនុស្ស។ ប្រសិនបើអាជ្ញាធរផ្តន្ទាទោសមិនបានធ្វើដូច្នេះ តុលាការក្នុងស្រុកគួរតែមានសមត្ថកិច្ចបញ្ជាឱ្យបញ្ឈប់នីតិវិធី ដោយឈរលើមូលដ្ឋាននៃការរំលោភបំពានដំណើរការ ឬដោយផ្អែកលើមូលដ្ឋានដែលការកាត់ទោស នឹងរំលោភកាតព្វកិច្ចមិនដាក់ទោសទណ្ឌ។

(ខ) អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ និងព្រះរាជអាជ្ញាទទួលបានការបណ្តុះបណ្តាលពេញលេញ ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្ស និងបទល្មើសដែលទាក់ទងនឹងការជួញដូរមនុស្ស និងបញ្ជា ឬស្នើឱ្យបញ្ឈប់នីតិវិធីឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

៦៥. នៅពេលដែលអាជ្ញាធរក្នុងស្រុកខកខានមិនបានអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ហើយមានការផ្តន្ទាទោស ឬការកាត់ទោសប្រឆាំងនឹងជនដែលត្រូវបានជួញដូរ គោលការណ៍ "ពិនិត្យផ្ទៀងផ្ទាត់បញ្ជាក់ភាពត្រឹមត្រូវ" តម្រូវឱ្យរដ្ឋដោះស្រាយការខកខានបែបនេះ។ ការធានាការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មឱ្យពេញលេញ និងមានប្រសិទ្ធភាពតម្រូវឱ្យមានបទបញ្ញត្តិសម្រាប់ការលុបចោល ឬការបិទកំណត់ត្រាបទល្មើសទាំងអស់ដែលពាក់ព័ន្ធ និងការជួយសម្រាលទោសដែលបានដាក់ រួមទាំងការពិន័យ ឬទណ្ឌកម្មរដ្ឋបាលផ្សេងទៀត។ គួរមានការជួយសម្រាលបែបនេះនៅក្នុងវិធានការច្បាប់ និងវិធានការចាំបាច់ផ្សេងទៀត និងត្រូវបានគាំទ្រតាមរយៈការផ្តល់ជំនួយផ្នែកច្បាប់ ដើម្បីបញ្ចៀសការដាក់បន្ទុកមិនសមស្របលើជនដែលត្រូវបានជួញដូរ និងអាចឱ្យមានការស្តារឡើងវិញពេញលេញ។

៦៦. រដ្ឋគួរតែធានាថា ការផ្តន្ទាទោសជនដែលត្រូវបានជួញដូរដែលបណ្តាលមកពីការខកខានមិនអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្ម ឬបណ្តាលមកពីការសង្ស័យថា ជនដែលត្រូវបានជួញដូរ បានចូលរួមក្នុងបទល្មើសទាក់ទងនឹងការជួញដូរមនុស្ស នឹងមិនបណ្តាលឱ្យមានការបដិសេធលិខិតអនុញ្ញាតការស្នាក់នៅ ឬរយៈពេលស្តារនីតិសម្បទា និងពិចារណាឡើងវិញ (recovery and reflection period) ការបដិសេធសន្តិសុខសង្គម ឬអត្ថប្រយោជន៍ផ្សេងទៀត ការរឹតត្បិតលើការទទួលបានការងារ ឬការអប់រំ ឬការរឹតត្បិតលើការទទួលបានសំណងជំងឺចិត្តឡើយ។

៦៧. ក្នុងពេលរង់ចាំការអនុវត្តន៍បទបញ្ញត្តិច្បាប់ជាក់លាក់ស្តីពីការមិនដាក់ទោសទណ្ឌ រដ្ឋគួរអនុលោមតាមកាតព្វកិច្ចមិនដាក់ទោសទណ្ឌរបស់ខ្លួន ដោយបកស្រាយបទដ្ឋានច្បាប់ជាតិដែលមានស្រាប់ រួមទាំងលក្ខខណ្ឌនៃការបង្ខិតបង្ខំ ឬស្ថានភាពនៃភាពចាំបាច់ ជាប្រការចែងទូទៅនៃការលើកលែងការទទួលខុសត្រូវ។ រដ្ឋគួរតែធានាថា វិធានការការពារទាំងនោះត្រូវបានកែសម្រួលទៅតាមបរិបទនៃការជួញដូរមនុស្ស ដោយទទួលស្គាល់ទម្រង់លាក់កំបាំងជាច្រើននៃការបង្ខិតបង្ខំដែលជនរងគ្រោះដោយការជួញដូរមនុស្សធ្លាប់ជួបប្រទះ រួមទាំងការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ និងមធ្យោបាយទាំងអស់ ដែលមានចែងក្នុងនិយមន័យនៃការជួញដូរមនុស្ស។

### សេចក្ដីសម្រេចលេខ S/RES/២៣៨៨ (២០១៧) របស់ក្រុមប្រឹក្សាសន្តិសុខ

១៧. ជំរុញឱ្យរដ្ឋសមាជិកធ្វើការវាយតម្លៃយ៉ាងហ្មត់ចត់លើស្ថានភាពផ្ទាល់ខ្លួន របស់បុគ្គលដែលត្រូវបានដោះលែងពីការចាប់បង្ខាំងដោយក្រុមប្រដាប់អាវុធ និងក្រុមភេរវករ ដើម្បីអាចកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្សឱ្យបានឆាប់រហ័ស ការប្រព្រឹត្តចំពោះពួកគេក្នុងនាមជាជនរងគ្រោះនៃបទល្មើស និងដើម្បីពិចារណា (ស្របតាមច្បាប់ជាតិ) មិនកាត់ទោស ឬដាក់ទណ្ឌកម្មជនរងគ្រោះដោយការជួញដូរមនុស្សសម្រាប់សកម្មភាពល្មើសច្បាប់ដែលពួកគេបានប្រព្រឹត្តដោយសារផលវិបាកដោយផ្ទាល់នៃការណ៍ដែលពួកគេក្លាយជាកម្មវត្ថុនៃការជួញដូរមនុស្ស។

## គោលការណ៍ជាអនុសាសន៍ និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស

### *គោលការណ៍ទី ៧៖*

ជនរងគ្រោះដោយការជួញដូរមនុស្ស មិនត្រូវបានឃុំខ្លួន ចោទប្រកាន់ ឬកាត់ទោសសម្រាប់ភាពល្មើសច្បាប់នៃការចូល ឬស្នាក់នៅរបស់ពួកគេក្នុងប្រទេសឆ្លងកាត់ និងប្រទេសគោលដៅ ឬសម្រាប់ការចូលរួមរបស់ពួកគេក្នុងសកម្មភាពល្មើសច្បាប់ក្នុងកម្រិតដែលការចូលរួមបែបនេះ ជាប់ទាក់ទងដោយផ្ទាល់ទៅនឹង ស្ថានភាពរបស់ពួកគេក្នុងនាមជាជនរងគ្រោះដោយការជួញដូរមនុស្ស។

### *ការណែនាំទី ៤៖ ការធានាក្របខណ្ឌច្បាប់គ្រប់គ្រាន់*

កង្វះច្បាប់ជាក់លាក់ និង/ឬច្បាប់គ្រប់គ្រាន់ស្ដីពីការជួញដូរមនុស្សនៅថ្នាក់ជាតិ ត្រូវបានកំណត់ថាជាឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗដែលរារាំងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ កិច្ចការបន្ទាន់ចំពោះមុខគឺត្រូវធ្វើយ៉ាងណាឱ្យមានសង្គតិភាពក្នុងនិយមន័យច្បាប់ នីតិវិធី និងកិច្ចសហប្រតិបត្តិការនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដោយអនុលោមតាមបទដ្ឋាន និងលិខិតុបករណ៍អន្តរជាតិ។ ការរៀបចំក្របខណ្ឌច្បាប់សមស្របដែលបន្សុីគ្នានឹងលិខិតុបករណ៍ និងបទដ្ឋានអន្តរជាតិពាក់ព័ន្ធ នឹងដើរតួនាទីសំខាន់ផងដែរក្នុងការទប់ស្កាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចដែលពាក់ព័ន្ធនឹងសកម្មភាពបែបនេះ។

រដ្ឋគួរពិចារណា៖

៥. ធានាថា ច្បាប់ការពារជនដែលត្រូវបានជួញដូរពីការកាត់ទោស ការឃុំខ្លួន ឬការដាក់ទោសទណ្ឌសម្រាប់ភាពខុសច្បាប់នៃការចូល ឬការស្នាក់នៅរបស់ពួកគេ ឬសម្រាប់សកម្មភាពដែលពួកគេពាក់ព័ន្ធ ដោយសារផលវិបាកដោយផ្ទាល់នៃស្ថានភាពរបស់ពួកគេជាជនដែលត្រូវបានជួញដូរ។

## *ការណែនាំទី ៥៖ ការធានាការឆ្លើយតបគ្រប់គ្រាន់ក្នុងទម្រង់ជាការអនុវត្តច្បាប់*

ទោះបីជាមានភស្តុតាងបង្ហាញថា សកម្មភាពជួញដូរមនុស្សកំពុងមានការកើនឡើងនៅគ្រប់ទីកន្លែងក្នុងពិភពលោកក៏ដោយ ប៉ុន្តែមានអ្នកជួញដូរមនុស្សតិចតួចប៉ុណ្ណោះដែលត្រូវបានចាប់ខ្លួន។ ការអនុវត្តន៍ច្បាប់ដែលកាន់តែមានប្រសិទ្ធភាព នឹងជួយបន្ទុចបង្អាក់អ្នកជួញដូរមនុស្ស ហើយដូច្នេះ នឹងមានផលប៉ះពាល់ដោយផ្ទាល់លើតម្រូវការ។ ការឆ្លើយតបគ្រប់គ្រាន់ក្នុងទម្រង់ជាការអនុវត្តន៍ច្បាប់ចំពោះការជួញដូរមនុស្ស អាស្រ័យលើកិច្ចសហប្រតិបត្តិការរបស់អ្នកដែលត្រូវបានជួញដូរ និងសាក្សីផ្សេងទៀត។ ក្នុងករណីជាច្រើន បុគ្គលស្ទាក់ស្ទើរ ឬមិនអាចរាយការណ៍អំពីអ្នកជួញដូរមនុស្ស ឬធ្វើជាសាក្សី ព្រោះពួកគេខ្វះទំនុកចិត្តលើនគរបាល និងប្រព័ន្ធតុលាការ និង/ឬដោយសារតែគ្មានយន្តការការពារប្រកបដោយប្រសិទ្ធភាព។ បញ្ហាទាំងនេះកាន់តែមានភាពស្មុគស្មាញនៅពេលដែលមន្ត្រីអនុវត្តច្បាប់ ពាក់ព័ន្ធ ឬចូលរួមក្នុងការជួញដូរមនុស្ស។ ចាំបាច់ត្រូវចាត់វិធានការយ៉ាងហ្មត់ចត់ ដើម្បីធានាថាការចូលរួម ឬការពាក់ព័ន្ធបែបនេះ ត្រូវបានស៊ើបអង្កេត កាត់ទោស និងដាក់ទោស។ ត្រូវកសាងការយល់ដឹងរបស់មន្ត្រីអនុវត្តច្បាប់ឱ្យផ្តោតអាទិភាពចម្បងលើការធានាសុវត្ថិភាពរបស់ជនដែលត្រូវបានជួញដូរ។ នេះជាការទទួលខុសត្រូវរបស់អ្នកស៊ើបអង្កេត និងមិនអាចទុកជាមោឃៈបានឡើយ។

រដ្ឋ និងក្នុងករណីដែលអាចអនុវត្តបាន អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល គួរពិចារណា៖

៥. ធានាថា អ្នកជួញដូរមនុស្សគឺជា និងនៅតែជាចំណុចផ្តោតនៃយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស ហើយការខិតខំអនុវត្តច្បាប់មិនធ្វើឱ្យអ្នកដែលត្រូវបានជួញដូរ ធ្លាក់ក្នុងហានិភ័យនៃការដាក់ទោសទណ្ឌសម្រាប់បទល្មើសដែលបានប្រព្រឹត្តដោយសារផលវិបាកនៃស្ថានភាពរបស់ពួកគេ។

## *ការណែនាំទី ៨៖ វិធានការពិសេសសម្រាប់ការការពារ និងការគាំទ្រកុមារដែលជាជនរងគ្រោះដោយការជួញដូរមនុស្ស*

គ្រោះថ្នាក់រាងកាយ ផ្លូវចិត្ត និងចិត្តសង្គមដែលទទួលរងដោយកុមារដែលជាជនរងគ្រោះដោយការជួញដូរមនុស្ស និងភាពងាយរងគ្រោះរបស់ពួកគេចំពោះការកេងប្រវ័ញ្ច តម្រូវឱ្យមានការដោះស្រាយករណីរបស់ពួកគេដាច់ដោយឡែកពីករណីមនុស្សពេញវ័យដែលត្រូវបានជួញដូរ ទាំងលើផ្នែកច្បាប់ គោលនយោបាយ កម្មវិធី និងអន្តរាគមន៍។ ផលប្រយោជន៍ល្អបំផុតរបស់កុមារត្រូវតែជាការពិចារណាចម្បងក្នុងសកម្មភាពទាំងអស់ ដែលពាក់ព័ន្ធនឹងកុមារដែលជាជនរងគ្រោះដោយការជួញដូរមនុស្ស មិនថាធ្វើឡើងដោយស្ថាប័នសុខុមាលភាពសង្គមសាធារណៈ ឬឯកជន តុលាការ អាជ្ញាធររដ្ឋបាល ឬស្ថាប័ននីតិបញ្ញត្តិ។ កុមារដែលជាជនរងគ្រោះដោយការជួញដូរមនុស្ស គួរទទួលបានជំនួយ និងការការពារសមស្រប និងគួរមានការពិចារណាយ៉ាងពេញលេញលើសិទ្ធិពិសេស និងតម្រូវការរបស់ពួកគេ។

បន្ថែមពីលើវិធានការដែលមានរៀបរាប់ក្រោមគោលការណ៍ណែនាំ ៦ រដ្ឋ និងក្នុងករណីដែលអាចអនុវត្តបាន អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល គួរពិចារណា ៖

៣. ធានាថាកុមារដែលជាជនរងគ្រោះដោយការជួញដូរមនុស្ស មិនត្រូវបានដាក់ឱ្យស្ថិតក្រោមនីតិវិធី ឬទណ្ឌកម្មព្រហ្មទណ្ឌសម្រាប់បទល្មើសដែលទាក់ទងនឹងស្ថានភាពរបស់ពួកគេក្នុងនាមជាជនដែលត្រូវបានជួញដូរឡើយ។

**អនុសញ្ញាស្តីពីសកម្មភាពប្រឆាំងការជួញដូរមនុស្ស** (កម្រងសន្ធិសញ្ញាក្រុមប្រឹក្សាអឺរ៉ុបលេខ ១៩៧)

**មាត្រា ២៦**

យោងតាមគោលការណ៍មូលដ្ឋាននៃប្រព័ន្ធច្បាប់របស់ខ្លួន ភាគីនីមួយៗត្រូវផ្តល់លទ្ធភាពនៃការមិនដាក់ទោសទណ្ឌលើជនរងគ្រោះសម្រាប់ការចូលរួមរបស់ពួកគេក្នុងសកម្មភាពល្មើសច្បាប់ ក្នុងកម្រិតដែលពួកគេត្រូវបានបង្ខំឱ្យធ្វើដូច្នោះ។

**បទបញ្ញាលេខ (EU) ២០២៤/១៧១២ របស់សភាអឺរ៉ុប និងក្រុមប្រឹក្សា ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០២៤ ធ្វើវិសោធនកម្មបទបញ្ញាលេខ ២០១១/៣៦/EU ស្តីពីការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការការពារជនរងគ្រោះ ជំនួសមាត្រា ៨ នៃបទបញ្ញាលេខ ២០១១/៣៦/EU របស់សហភាពអឺរ៉ុបស្តីពីការជួញដូរមនុស្ស (បទបញ្ញារបស់ EU)**[121]

*ការមិនកាត់ទោស ឬការមិនអនុវត្តទោសចំពោះជនរងគ្រោះ*

ស្របតាមគោលការណ៍មូលដ្ឋាននៃប្រព័ន្ធច្បាប់របស់ខ្លួន រដ្ឋសមាជិកត្រូវ ចាត់វិធានការចាំបាច់ ដើម្បីធានាថាអាជ្ញាធរជាតិដែលមានសមត្ថកិច្ច មានសិទ្ធិមិនកាត់ទោស ឬដាក់ទោសលើជនរងគ្រោះដោយការជួញដូរមនុស្សសម្រាប់ការចូលរួមរបស់ពួកគេក្នុងសកម្មភាពបទល្មើស ឬសកម្មភាពល្មើសច្បាប់ផ្សេងទៀត ដែលពួកគេត្រូវបានបង្ខំឱ្យប្រព្រឹត្តដោយសារផលវិបាកដោយផ្ទាល់នៃការក្លាយជាកម្មវត្ថុនៃសកម្មភាពណាមួយ ដែលបានលើកឡើងក្នុងមាត្រា ២។

**ករណីរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប *V.C.L និង A.N. ទល់នឹងចក្រភពអង់គ្លេស*** (ពាក្យសុំលេខ ៧៧៥៨៧/១២ និង ៧៤៦០៣/១២) **សាលក្រម Strasbourg ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១**

*សេចក្តីសង្ខេបករណី៖* មន្ត្រីនគរបាលនៅចក្រភពអង់គ្លេសបានរកឃើញអនីតិជនវៀតណាមពីរនាក់កំពុងធ្វើការនៅក្នុងកសិដ្ឋានកញ្ឆា។ ពួកគេត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទល្មើសពាក់ព័ន្ធនឹងគ្រឿងញៀន និងបានសារភាពថាមានទោស តាមការណែនាំរបស់អ្នកតំណាងផ្លូវច្បាប់របស់ពួកគេ និងត្រូវបានផ្តន្ទាទោស។ អាជ្ញាធរមានសមត្ថកិច្ចម្នាក់បានទទួលស្គាល់ពួកគេជាជនរងគ្រោះដោយការជួញដូរមនុស្ស ប៉ុន្តែព្រះរាជអាជ្ញា ដោយពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួនក្នុងការកាត់ទោសពួកគេ

[121] *"ស្របតាមគោលការណ៍មូលដ្ឋាននៃប្រព័ន្ធច្បាប់របស់ខ្លួន រដ្ឋសមាជិកត្រូវ ចាត់វិធានការចាំបាច់ ដើម្បីធានាថាអាជ្ញាធរជាតិដែលមានសមត្ថកិច្ច មានសិទ្ធិមិនកាត់ទោស ឬដាក់ទោសលើជនរងគ្រោះដោយការជួញដូរមនុស្សសម្រាប់ការចូលរួមរបស់ពួកគេក្នុងសកម្មភាពបទល្មើស ដែលពួកគេត្រូវបានបង្ខំឱ្យប្រព្រឹត្តដោយសារផលវិបាកដោយផ្ទាល់នៃការក្លាយជាកម្មវត្ថុនៃសកម្មភាពណាមួយ ដែលបានលើកឡើងក្នុងមាត្រា ២ [ស្ថានភាពជាជនរងគ្រោះរបស់ពួកគេ]។"*

បានសន្និដ្ឋានថា ពួកគេមិនមែនជាជនរងគ្រោះឡើយ។ សាលាឧទ្ធរណ៍បានរកឃើញថា ការសម្រេចកាត់ទោសពួកគេមានសំអាងហេតុត្រឹមត្រូវ។

ករណីនេះបានទៅដល់តុលាការសិទ្ធិមនុស្សអឺរ៉ុប។ ដោយផ្អែកលើមាត្រា ៤ (ការហាមឃាត់ការងារដោយបង្ខំ) និងមាត្រា ៦(១) (សិទ្ធិទទួលបានការជំនុំជម្រះដ៏យុត្តិធម៌) នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប អ្នកដាក់ពាក្យប្តឹង បានប្តឹងថា អាជ្ញាធរមិនបានការពារពួកគេបន្ទាប់ពីពួកគេត្រូវបានជួញដូរឡើយ និងមិនបានស៊ើបអង្កេតករណីជួញដូរពួកគេឱ្យបានគ្រប់គ្រាន់ ហើយការជំនុំជម្រះរបស់ពួកគេ មិនយុត្តិធម៌។

**ពាក់ព័ន្ធនឹងមាត្រា ៤ (ការហាមឃាត់ការងារដោយបង្ខំ)៖** តុលាការសិទ្ធិមនុស្សអឺរ៉ុបបានរកឃើញថា ច្បាប់អន្តរជាតិមិនផ្តល់ការលើកលែងពីការកាត់ទោសទេ ប៉ុន្តែរដ្ឋទាំងឡាយមិនអាចផ្តន្ទាទោសបានឡើយ ក្នុងករណីដែលស្តែងឱ្យឃើញច្បាស់នូវការបង្ខំឱ្យប្រព្រឹត្តបទល្មើស។ ការសម្រេចកាត់ទោសក្នុងករណីនេះ គឺមិនស្របនឹងកាតព្វកិច្ចរបស់ខ្លួនក្នុងការចាត់វិធានការដើម្បីការពារអ្នកដាក់ពាក្យប្តឹងនៅពេលដែលមានការសង្ស័យគួរឱ្យជឿបានថា ពួកគេត្រូវបានជួញដូរ។ នៅពេលដែលការសង្ស័យនោះលេចឡើង គួរមានការវាយតម្លៃត្រឹមត្រូវដោយបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ការសម្រេចកាត់ទោសគួរតែធ្វើឡើងតាមការវាយតម្លៃបែបនេះប៉ុណ្ណោះ ជាពិសេសក្នុងករណីដែលបុគ្គលនោះជាអនីតិជន។ ព្រះរាជអាជ្ញានឹងត្រូវការសំអាងហេតុច្បាស់លាស់ដែលស្របតាមច្បាប់អន្តរជាតិ ដើម្បីមិនយល់ស្របតាមការវាយតម្លៃនោះ។ ការណ៍ដែលថា អ្នកដាក់ពាក្យប្តឹងត្រូវបានរកឃើញនៅក្នុងកសិដ្ឋានកញ្ឆា នៅពេលដែលពួកគេជាអនីតិជន គួរតែនាំឱ្យមានការសង្ស័យគួរឱ្យជឿបានថា ពួកគេគឺជាជនរងគ្រោះ ប៉ុន្តែជាជាងការបញ្ជូនទៅ អ្នកដាក់ពាក្យប្តឹង ត្រូវបានចោទប្រកាន់ទៅវិញ។ ការកាត់ទោសមិនបានផ្តល់សំអាងហេតុច្បាស់លាស់ដែលស្របតាមនិយមន័យនៃការជួញដូរមនុស្សឡើយ ចាប់ពីការឈានដល់សេចក្តីសម្រេចផ្សេងមួយ រហូតដល់សេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចនោះ។

**ទាក់ទងនឹងមាត្រា ៦(១) (សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌)៖** តុលាការអឺរ៉ុបត្រូវកំណត់ថាតើការខកខានរបស់ចក្រភពអង់គ្លេសក្នុងការទទួលស្គាល់អ្នកដាក់ពាក្យប្តឹងថា ជាអ្នកដែលអាចជាជនរងគ្រោះ គឺជាបញ្ហាចោទក្រោមអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុបឬទេ។ តុលាការបានរកឃើញថា អ្នកដាក់ពាក្យប្តឹងបានសារភាពកំហុសរបស់ពួកគេ ដោយមិនបានដឹងពេញលេញអំពីអង្គហេតុទាំងឡាយ។ កង្វះការវាយតម្លៃថាតើពួកគេជាជនរងគ្រោះ ឬអត់ បានរារាំងពួកគេមិនឱ្យទទួលបានភស្តុតាងដែលអាចជួយដល់ការការពារក្តីរបស់ពួកគេ។ សាលាឧទ្ធរណ៍មិនបានដោះស្រាយភាពអយុត្តិធម៌នេះទេ ព្រោះការពិចារណារបស់ខ្លួនត្រូវបានកំណត់ត្រឹមថាតើមានការរំលោភនីតិវិធីឬទេ និងការពឹងផ្អែកលើកត្តាដែលហាក់មិនពាក់ព័ន្ធនឹងខ្លឹមសារក្នុងនិយមន័យនៃការជួញដូរមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។ ដូច្នេះ ដំណើរការនីតិវិធីនេះគឺអយុត្តិធម៌ ហើយបានរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់អ្នកដាក់ពាក្យប្តឹង។ តុលាការបានបញ្ជាឱ្យចក្រភពអង់គ្លេសបង់ប្រាក់ឱ្យអ្នកដាក់ពាក្យប្តឹងក្នុងម្នាក់

ចំនួន ២៥.០០០ អឺរ៉ូសម្រាប់ការខូចខាតមិនមែនជាទ្រព្យសម្បត្តិ និង ២០.០០០ អឺរ៉ូក្នុងម្នាក់ សម្រាប់ថ្លៃចំណាយ និងការចំណាយនានា។[122]

*ខាងក្រោមនេះជាដកស្រង់ចេញពីសាលក្រមរបស់តុលាការ៖*

១៥៨. ច្បាស់ណាស់ថា គ្មានការហាមប្រាមទូទៅលើការកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្ស អាចត្រូវបានបកស្រាយចេញពីអនុសញ្ញាប្រឆាំងការជួញដូរមនុស្ស ឬលិខិតុបករណ៍អន្តរជាតិណាមួយផ្សេងទៀតឡើយ។ ពិតមែនហើយ បទបញ្ញត្តិ «មិនដាក់ទោសទណ្ឌ» នៅក្នុងមាត្រា ២៦ នៃអនុសញ្ញាប្រឆាំងការជួញដូរមនុស្ស មាត្រា ៨ នៃបទបញ្ជាប្រឆាំងការជួញដូរមនុស្ស និងមាត្រា ៤ ខ ២ នៃពិធីសារឆ្នាំ ២០១៤ នៃអនុសញ្ញាស្តីពីការងារដោយបង្ខំរបស់ ILO (សូមមើលរៀងៗគ្នា ក្នុងកថាខណ្ឌ ១០៣, ១០៦ និង ៩៨ ខាងលើ) សុទ្ធតែមានលក្ខណៈសម្បត្តិសំខាន់ពីរ៖ ជនរងគ្រោះដោយការជួញដូរមនុស្សត្រូវតែត្រូវបានបង្ខំឱ្យប្រព្រឹត្តសកម្មភាពបទល្មើស ហើយក្នុងករណីនោះ អាជ្ញាធរថ្នាក់ជាតិគួរតែមានសិទ្ធិ ប៉ុន្តែមិនមានកាតព្វកិច្ច ក្នុងការសម្រេចមិនកាត់ទោស។ ខណៈដែលលក្ខខណ្ឌ "បង្គាប់បញ្ជា" ហាក់មិនចាំបាច់ ដើម្បីនាំកុមារឱ្យធ្លាក់ក្រោមវិសាលភាពនៃមាត្រា ២៦ នៃអនុសញ្ញាប្រឆាំងការជួញដូរមនុស្ស ឬមាត្រា ៨ នៃបទបញ្ជាប្រឆាំងការជួញដូរមនុស្ស គ្មានចំណុចណាមួយនៅក្នុងលិខិតុបករណ៍ទាំងពីរ ដែលអាចត្រូវបានបកស្រាយថាមិនអនុញ្ញាតឱ្យមានការកាត់ទោសកុមារដែលជាជនរងគ្រោះដោយការជួញដូរមនុស្ស ក្នុងគ្រប់កាលៈទេសៈទាំងអស់ឡើយ។

១៥៩. ទោះយ៉ាងណាក៏ដោយ តុលាការពិចារណាថា ក្នុងកាលៈទេសៈមួយចំនួន ការកាត់ទោសជនរងគ្រោះ ឬអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្សមនុស្ស អាចផ្ទុយនឹងកាតព្វកិច្ចរបស់រដ្ឋក្នុងការចាត់វិធានការប្រតិបត្តិការដើម្បីការពារពួកគេ នៅពេលណាដែលពួកគេដឹង ឬគួរតែដឹងអំពីកាលៈទេសៈ ដែលនាំឱ្យមានការសង្ស័យគួរឱ្យជឿជាក់ថាបុគ្គលម្នាក់ត្រូវបានជួញដូរ។ ក្នុងទស្សនៈរបស់តុលាការ កាតព្វកិច្ចចាត់វិធានការប្រតិបត្តិការក្រោមមាត្រា ៤ នៃអនុសញ្ញានេះ មានគោលបំណងចម្បងពីរ ៖ ដើម្បីការពារជនរងគ្រោះដោយការជួញដូរមនុស្សពីគ្រោះថ្នាក់បន្ថែមទៀត និងដើម្បីជួយសម្រួលដល់ការស្តារនីតិសម្បទារបស់គាត់។ ច្បាស់ណាស់ថា ការកាត់ទោសជនរងគ្រោះដោយការជួញដូរមនុស្ស នឹងធ្វើឱ្យប៉ះពាល់ដល់ការស្តារឡើងវិញផ្នែកផ្លូវកាយ ផ្លូវចិត្ត និងសង្គមរបស់ពួកគេ ហើយអាចធ្វើឱ្យពួកគេងាយត្រូវបានជួញដូរម្តងទៀតនាពេលអនាគត។ ពួកគេមិនត្រឹមតែត្រូវឆ្លងកាត់ការលំបាកនៃការកាត់ទោសព្រហ្មទណ្ឌប៉ុណ្ណោះទេ ប៉ុន្តែការផ្តន្ទាទោសព្រហ្មទណ្ឌអាចបង្កឧបសគ្គដល់សមាហរណកម្មក្នុងសង្គមរបស់ពួកគេ នៅពេលក្រោយមកទៀត។ លើសពីនេះ

[122] សូមមើល *V.C.L និង A.N ទល់នឹងចក្រភពអង់គ្លេស* (ពាក្យសុំលេខ ៧៧៥៨៧/១២ និង ៧៤៦០៣/១២) សេចក្តីប្រកាសព័ត៌មាន សេចក្តីសង្ខេប ECHR ០៥៨ (២០២១) ១៦.០២.២០២១

ការជាប់ពន្ធនាគារអាចរារាំងការទទួលបានការគាំទ្រ និងសេវាដែលអាចមានផ្តល់ ក្រោមអនុសញ្ញាប្រឆាំងការជួញដូរមនុស្ស។

១៦០. ដើម្បីឱ្យការកាត់ទោសជនរងគ្រោះ ឬអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្សមនុស្ស បង្ហាញពីការគោរពសេរីភាពដែលត្រូវបានធានាដោយមាត្រា ៤ ការកំណត់អត្តសញ្ញាណរបស់គាត់ឱ្យបានឆាប់ គឺសំខាន់ណាស់។ មាត្រានោះចែងថា ភ្លាមៗនៅពេលអាជ្ញាធរដឹង ឬគួរតែដឹងអំពីកាលៈទេសៈ ដែលនាំឱ្យមានការសង្ស័យគួរឱ្យជឿជាក់ថាបុគ្គលម្នាក់ដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ អាចត្រូវបានជួញដូរ ឬកេងប្រវ័ញ្ច គាត់គួរតែត្រូវបានវាយតម្លៃយ៉ាងឆាប់រហ័សដោយបុគ្គលដែលទទួលបានការបណ្តុះបណ្តាល និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីដោះស្រាយជាមួយជនរងគ្រោះដោយការជួញដូរមនុស្ស។ ការវាយតម្លៃនោះគួរតែផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងពិធីសារ Palermo និងអនុសញ្ញាប្រឆាំងការជួញដូរមនុស្ស (ពោលគឺបុគ្គលនោះគឺជាកម្មវត្ថុនៃការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងសំចត ឬការទទួល តាមមធ្យោបាយនៃការគំរាមកំហែងប្រើកម្លាំង ឬទម្រង់ដទៃទៀតនៃការបង្ខិតបង្ខំ ក្នុងបំណងកេងប្រវ័ញ្ច) ដោយមានការយកចិត្តទុកដាក់ទៅអង្គហេតុដែលថា ការគំរាមកំហែងប្រើកម្លាំង និង/ឬការបង្ខិតបង្ខំ គឺមិនចាំបាច់នោះទេ ក្នុងករណីដែលបុគ្គលនោះគឺជាកុមារ។

១៦១. លើសពីនេះទៅទៀត ដោយសារស្ថានភាពរបស់បុគ្គលម្នាក់ជាជនរងគ្រោះដោយការជួញដូរមនុស្ស អាចប៉ះពាល់ដល់ថាតើមានភស្តុតាងគ្រប់គ្រាន់ដើម្បីកាត់ទោស ឬទេ និងថាតើវាបម្រើឱ្យផលប្រយោជន៍សាធារណៈក្នុងការធ្វើដូច្នេះ ឬទេ ការសម្រេចចិត្តណាមួយថាតើត្រូវកាត់ទោសអ្នកដែលអាចជាជនរងគ្រោះដោយការជួញដូរមនុស្សមនុស្ស ឬទេ គួរធ្វើឡើង (ក្នុងកម្រិតដែលអាចធ្វើទៅបាន) តែបន្ទាប់ពីការវាយតម្លៃករណីជួញដូរមនុស្ស ដោយបុគ្គលដែលមានគុណសម្បត្តិគ្រប់គ្រាន់។ នេះមានសារៈសំខាន់ណាស់ ក្នុងករណីដែលពាក់ព័ន្ធនឹងកុមារ។ តុលាការបានទទួលស្គាល់ថា ដោយសារកុមារងាយរងគ្រោះជាពិសេស វិធានការដែលត្រូវបានអនុវត្តដោយរដ្ឋ ដើម្បីការពារពួកគេពីអំពើហិង្សាដែលស្ថិតក្រោមវិសាលភាពនៃមាត្រា ៣ និង ៨ គួរតែមានប្រសិទ្ធភាព និងរួមបញ្ចូលទាំងជំហានសមហេតុផល ដើម្បីទប់ស្កាត់ការធ្វើបាប ដែលអាជ្ញាធរបានដឹង ឬគួរតែបានដឹង និងការរារាំងដោយប្រសិទ្ធភាពប្រឆាំងនឹងការរំលោភបំពានធ្ងន់ធ្ងរលើបូរណភាពផ្ទាល់ខ្លួន (សូមមើល ឧទាហរណ៍ Söderman ទល់នឹង ស៊ុយអែត [GC] លេខ 5786/08, § 81, ECHR 2013, M.P. និង អ្នកផ្សេងទៀត ទល់នឹង ប៊ុលហ្គារី លេខ 22457/08, § 108, ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ និង Z និងអ្នកផ្សេងទៀត ទល់នឹងចក្រភពអង់គ្លេស [GC] លេខ 29392/95, § 73, ECHR 2001-V)។ វិធានការបែបនេះត្រូវតែមានគោលបំណងធានាការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការពារផលប្រយោជន៍ល្អបំផុតរបស់កុមារ (សូមមើល Söderman, ដែលបានដកស្រង់ខាងលើ, § 81)។ ដោយសារការជួញដូរមនុស្សគំរាមកំហែងដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងសេរី

ភាពជាមូលដ្ឋានរបស់ជនរងគ្រោះ (សូមមើល Rantsev, ដែលបានដកស្រង់ខាងលើ, § 282) គួរអនុវត្តដូចគ្នាចំពោះវិធានការការពារប្រឆាំងនឹងសកម្មភាពដែលស្ថិតក្រោមវិសាលភាពនៃមាត្រា ៤ នៃអនុសញ្ញានេះ។

១៦២. នៅពេលដែលការវាយតម្លៃអំពីការជួញដូរមនុស្ស ត្រូវបានធ្វើឡើងដោយបុគ្គលដែលមានគុណសម្បត្តិគ្រប់គ្រាន់ ការសម្រេចកាត់ទោសនៅពេលបន្ទាប់មកទៀត ត្រូវតែពិចារណាពីការវាយតម្លៃនោះ។ ខណៈដែលព្រះរាជអាជ្ញាអាចមិនចងភ្ជាប់ដោយការរកឃើញ ក្នុងអំឡុងពេលនៃការវាយតម្លៃករណីការជួញដូរមនុស្សនោះ ព្រះរាជអាជ្ញានឹងត្រូវមានសំអាងហេតុច្បាស់លាស់ដែលស្របនឹងនិយមន័យនៃការជួញដូរមនុស្សដែលមានចែងនៅក្នុងពិធីសារ Palermo និងអនុសញ្ញាប្រឆាំងការជួញដូរមនុស្ស សម្រាប់ការមិនយល់ស្របនឹងការវាយតម្លៃនោះ។

## ឧបសម្ព័ន្ធ ៥ ៖ ឧទាហរណ៍នៃបទល្មើសដែលស្ថិតក្រោមវិសាលភាពនៃគោលការណ៍មិនដាក់ទណ្ឌកម្ម

ខាងក្រោមនេះ គឺជាឧទាហរណ៍នៃបទល្មើសដែលស្ថិតក្រោមវិសាលភាពនៃគោលការណ៍មិនដាក់ទណ្ឌកម្ម។ ការរៀបរាប់ខាងក្រោមគឺមិនទាន់អស់នោះទេ។ គោលការណ៍មិនដាក់ទណ្ឌកម្មអនុវត្តចំពោះបទល្មើសទាំងអស់ដែលជនរងគ្រោះដោយការជួញដូរមនុស្ស អាចប្រព្រឹត្តដោយសារផលវិបាកដោយផ្ទាល់នៃការណ៍ដែលពួកគេត្រូវបានជួញដូរ។

### បទល្មើសស្ថានភាព (រដ្ឋបាល និងព្រហ្មទណ្ឌ)

- អន្តោប្រវេសន៍ (បទល្មើសព្រហ្មទណ្ឌ រដ្ឋបាល ឬរដ្ឋប្បវេណី)
  - ការចូលដោយខុសច្បាប់
  - ស្ថានភាពការងារខុសច្បាប់
  - ស្ថានភាពទេសន្តរប្រវេសន៍ខុសច្បាប់
  - ការស្នាក់នៅដោយខុសច្បាប់
  - កង្វះឯកសារ
  - ការក្លែងបន្លំលិខិតអនុញ្ញាតការងារ
- ការប្រើប្រាស់ ឬការកាន់កាប់ឯកសារអត្តសញ្ញាណក្លែងក្លាយ ឬក្លែងបន្លំ
- ការក្លែងបន្លំ ឬការកាន់កាប់ឯកសារអត្តសញ្ញាណក្លែងបន្លំ
- ផ្សេងៗ

### បទល្មើសព្រហ្មទណ្ឌផ្សេងទៀត

- បទល្មើសទាក់ទងនឹងគ្រឿងស្រវឹង
- ការសុំទាន
- ការប្រព្រឹត្តដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ
- ការលួចហោប៉ៅ

- ការកាន់កាប់គ្រឿងញៀន
- ពេស្យាចារ/ការល្បួងផ្លូវភេទ
- សណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌សាធារណៈ/អសីលធម៌
- ការលក់ផលិតផលក្លែងក្លាយ
- ការលួចឥវ៉ាន់ក្នុងហាង
- ការប្រើប្រាស់គ្រឿងញៀន
- ភាពអនាថា
- ការវាយដំ ឬការប្រើអំពើហិង្សា (ឧ. ដើម្បីគេចចេញពីស្ថានភាពជួញដូរមនុស្ស)
- ការចូលគាស់ផ្ទះ
- ការក្លែងបន្លំកាតឥណទាន
- បទល្មើសដែលគាំទ្រដោយប្រព័ន្ធអ៊ីនធឺណិត
- បទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត
- ការកាន់កាប់គ្រឿងញៀន
- ការផលិត ឬដាំដុះគ្រឿងញៀន (ឧ. នៅក្នុងកសិដ្ឋានកញ្ឆា និងមន្ទីរពិសោធន៍ថ្នាំមេតំហ្វេតាមីន)
- ការជួញដូរ ឬរត់ពន្ធគ្រឿងញៀន
- ការលួចអត្តសញ្ញាណ
- ការសម្លាប់មនុស្សដោយអចេតនា ឬឃាតកម្ម
- ការលាងលុយកខ្វក់ តាមរយៈការប្រើប្រាស់រូបិយប័ណ្ណឌីជីថលខុសច្បាប់
- ការបរិច្ចាគសរីរាង្គដោយខុសច្បាប់ ការផ្តល់ ឬការទទួលអត្ថប្រយោជន៍ជាប្រាក់ ជាថ្នូរនឹងសរីរាង្គ
- ការចូលរួមក្នុងក្រុមប្រដាប់អាវុធ
- ការឆបោក (scamming)
- ការក្លែងបន្លំអត្ថប្រយោជន៍សន្តិសុខសង្គម ឬអត្ថប្រយោជន៍សង្គម
- អំពើភេរវកម្ម
- ការជួញដូរមនុស្ស (ជាញឹកញាប់ បណ្តាលមកពីជនរងគ្រោះក្លាយជាអ្នកជួញដូរមនុស្ស ឬពុំនោះទេ ពាក់ព័ន្ធក្នុងការជ្រើសរើស ឬការកេងប្រវ័ញ្ចជនរងគ្រោះផ្សេងទៀត)
- ផ្សេងៗ ៕

